United Nations
Educational, Scientific and
Cultural Organization




# វិជ្ជាជីវៈសារព័ត៌មាន «ដំណឹងក្លែងក្លាយ» និង ព័ត៌មានមិនពិត

សៀវភៅមេរៀនសម្រាប់ការអប់រំ និងការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈសារព័ត៌មាន

ឯកសារជាលំដាប់របស់អង្គការយូណេស្កូលើការអប់រំផ្នែកវិជ្ជាជីវៈសារព័ត៌មាន

បោះពុម្ពផ្សាយនៅឆ្នាំ២០២០ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិហៅកាត់ថាយូណេស្កូ (UNESCO) អាស័យដ្ឋាន អគារ ៧, place de Fontenoy, ៧៥៣៥២ ក្រុងប៉ារីស ០៧ SP ប្រទេសបារាំង និង វិទ្យាស្ថានសារព័ត៌មានហ្វូចូ (Fojo Media Institute), សកលវិទ្យាល័យ Linnaeus ។

© UNESCO ២០២០

ISBN 978-92-3-000090-5

សៀវភៅនេះអាចប្រើប្រាស់បានក្រោមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណ Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) (http://creativecommons.org/licenses/by-sa/3.0/igo/)។ តាមរយៈការប្រើប្រាស់ខ្លឹមសារនៃសៀវភៅនេះ អ្នកប្រើប្រាស់ទទួលយល់ព្រមគោរពតាមលក្ខខណ្ឌប្រើប្រាស់ទិន្នន័យចំហ (Open Access Repository) របស់អង្គការយូណេស្កូ (http://www.unesco.org/open-access/terms-use-ccbysa-en)។

សៀវភៅនេះមានចំណងជើងដើមថា៖ វិជ្ជាជីវៈសារព័ត៌មាន "ដំណឹងក្លែងក្លាយ" និងព័ត៌មានមិនពិត៖ សៀវភៅមេរៀនសម្រាប់ការអប់រំ និងការបណ្ដុះបណ្ដាលផ្នែកវិជ្ជាជីវៈសារព័ត៌មាន (Journalism, "Fake News" & Disinformation: Handbook for Journalism Education and Training)។ សៀវភៅនេះត្រូវបានបោះពុម្ពនៅឆ្នាំ២០១៨ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ ហៅកាត់ថា យូណេស្កូ (UNESCO) អាស័យដ្ឋាន អគារ ៧, place de Fontenoy, ៧៥៣៥២ ក្រុងប៉ារីស ០៧ SP ប្រទេសបារាំង។

ការរចនា និងការបង្ហាញនានានៅក្នុងសៀវភៅនេះ មិនឆ្លុះបញ្ចាំងការបញ្ចេញមតិយោបល់ ឬផ្នែកណាមួយរបស់អង្គការយូណេស្កូ ដែលពាក់ព័ន្ធនឹងលក្ខខណ្ឌច្បាប់នៃប្រទេស ដែនដី ទីក្រុង ឬតំបន់ អាជ្ញាធរដែនដី ឬពាក់ព័ន្ធនឹងការកំណត់ព្រំដែន ឬព្រំប្រទល់។

រាល់គំនិត និងមតិ ដែលសម្ដែងឡើងនៅក្នុងសៀវភៅនេះគឺជារបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងគំនិតរបស់អង្គការយូណេស្កូ ហើយក៏មិនមែនជាទំនួលខុសត្រូវរបស់អង្គការយូណេស្កូឡើយ។

**អ្នកកែសម្រួល៖** Cherilyn Ireton និង Julie Posetti
**អ្នកនិពន្ធដែលបានចូលរួមចំណែក៖** Julie Posetti, Cherilyn Ireton, Claire Wardle, Hossein Derakhshan, Alice Matthews, Magda Abu-Fadil, Tom Trewinnard, Fergus Bell, Alexios Mantzarlis
**អ្នកស្រាវជ្រាវបន្ថែម៖** Tom Law
**អ្នករចនាក្រាហ្វិក៖** Clinton
**អ្នករចនាគម្របសៀវភៅ៖** Clinton
**អ្នកគូរគំនូរ៖** យូណេស្កូ និង First Draft និង Poynter
**ការបកប្រែ៖** វិទ្យាស្ថានសារព័ត៌មានហ្វូចូ
**អ្នករចនាអត្ថបទ៖** យូណេស្កូ
**បោះពុម្ពដោយ៖** យូណេស្កូ

បោះពុម្ពផ្សាយនៅប្រទេសកម្ពុជា

សៀវភៅមេរៀនជាភាសាខ្មែរនេះ គឺជាការបកប្រែពីអត្ថបទដើមភាសាអង់គ្លេស សម្រាប់ការអប់រំ និងក្នុងគោលបំណងផ្សព្វផ្សាយ និងចែករំលែក។ យោងតាមការណែនាំរបស់ក្រសួងព័ត៌មាន សម្រាប់គោលបំណងនៃសៀវភៅនេះ ពាក្យ "News" ត្រូវបានបកប្រែថាជា "ដំណឹង" ហើយពាក្យ "Information" ត្រូវបានបកប្រែថាជា "ព័ត៌មាន"។ ក្នុងករណីមានភាពមិនច្បាស់លាស់ សៀវភៅជាភាសាអង់គ្លេសគឺជាឯកសារគោល។ យូណេស្កូ មិនទទួលខុសត្រូវចំពោះភាពមិនស្របគ្នា ឬភាពខុសគ្នាណាមួយនៅក្នុងការបកប្រែនេះទេ ដោយសារនេះជាទំនួលខុសត្រូវរបស់អ្នកបកប្រែ។

ការបកប្រែសៀវភៅនេះជាភាសាខ្មែរអាចធ្វើទៅបានក្រោមការជួយគាំទ្រថវិកាដ៏សប្បុរសពីប្រទេសស៊ុយអែត។

This translation is made possible by the generous financial support of Sweden.

Cherilyn Ireton
និង Julie Posetti

# វិជ្ជាជីវៈសារព័ត៌មាន «ដំណឹងក្លែងក្លាយ» និង ព័ត៌មានមិនពិត

សៀវភៅមេរៀនសម្រាប់ការអប់រំ និងការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈសារព័ត៌មាន

# បញ្ជីមាតិកា


បុព្វកថាដោយ **Guy Berger** ៩

សេចក្តីផ្តើម ដោយ **Cherilyn Ireton** និង **Julie Posetti** ២១

ការប្រើប្រាស់សៀវភៅនេះជាកម្មវិធីសិក្សាគំរូ ដោយ **Julie Posetti** ៤០

មេរៀនទី១៖ ហេតុអ្វីបានជា ការពិត ទំនុកចិត្ត និងវិជ្ជាជីវៈសារព័ត៌មាន មានសារសំខាន់? ៤៩

ដោយ Cherilyn Ireton

- សង្ខេបមេរៀន ៥០
- គ្រោងនៃមេរៀន ៥៣
- គោលបំណងនៃមេរៀន ៦៣
- លទ្ធផលសិក្សា ៦៣
- ទម្រង់នៃមេរៀន ៦៣
- លំហាត់ស្រាវជ្រាវបន្ថែម ៦៥
- អំណានបន្ថែម ៦៥

មេរៀនទី២៖ ការគិតអំពី «ព័ត៌មានច្របូកច្របល់» ៖ ទម្រង់នៃព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្ម ៦៧

ដោយ Claire Wardle និង Hossein Derakhshan

- សង្ខេបមេរៀន ៦៨
- គ្រោងនៃមេរៀន ៦៩
- គោលបំណងនៃមេរៀន ៧៩
- លទ្ធផលសិក្សា ៨០
- ទម្រង់នៃមេរៀន ៨១
- លំហាត់ស្រាវជ្រាវបន្ថែម ៨៣
- ឯកសារបន្ថែម ៨៣
- អំណានបន្ថែម ៨៣

មេរៀនទី៣៖ ការវិវត្តនៃខូសប៉ាហាកម្មដំណឹង៖ បច្ចេកវិទ្យាឌីជីថល ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការសាយភាយព័ត៌មានខុស និងព័ត៌មានមិនពិត ៨៥

ដោយ Julie Posetti

សង្ខេបមេរៀន ៨៦
គ្រោងនៃមេរៀន ៨៩
គោលបំណងនៃមេរៀន ១០២
លទ្ធផលសិក្សា ១០២
ទម្រង់នៃមេរៀន ១០៣
លំហាត់ស្រាវជ្រាវបន្ថែម ១០៥
អំណានបន្ថែម ១០៥

មេរៀនទី៤៖ ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងព័ត៌មានខុស តាមរយៈអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន (MIL) ១០៧

ដោយ Magda Abu-Fadil

សង្ខេបមេរៀន ១០៨
គ្រោងនៃមេរៀន ១១១
គោលបំណងនៃមេរៀន ១១៧
លទ្ធផលសិក្សា ១១៧
ទម្រង់នៃមេរៀន ១១៨
លំហាត់ស្រាវជ្រាវបន្ថែម ១២២
ឯកសារបន្ថែម ១២២
អំណានបន្ថែម ១២៣

មេរៀនទី៥៖ ការផ្ទៀងផ្ទាត់ការពិត ១០១ ១២៥

ដោយ Alexios Mantzarlis

សង្ខេបមេរៀន ១២៦
គ្រោងនៃមេរៀន ១២៦
គោលបំណងនៃមេរៀន ១៣៥
លទ្ធផលសិក្សា ១៣៦

ទម្រង់នៃមេរៀន ១៣៦
លំហាត់ស្រាវជ្រាវបន្ថែម ១៤៣
អំណានបន្ថែម ១៤៤

## មេរៀនទី៦៖ ការផ្ទៀងផ្ទាត់ប្រព័ន្ធផ្សព្វផ្សាយសង្គម៖ ការវាយតម្លៃប្រភព និងមាតិការូបភាព ១៤៧

ដោយ Tom Trewinnard និង Fergus Bell

គ្រោងនៃមេរៀន ១៤៩
គោលបំណងនៃមេរៀន ១៥៨
លទ្ធផលសិក្សា ១៥៨
ទម្រង់នៃមេរៀន ១៥៩
លំហាត់ស្រាវជ្រាវបន្ថែម ១៦១
ឯកសារបន្ថែម ១៦១
អំណានបន្ថែម ១៦២

## មេរៀនទី៧៖ ការប្រយុទ្ធប្រឆាំងការរំលោភបំពានតាមអ៊ីនធឺណិត៖ នៅពេលដែលអ្នកសារព័ត៌មាន និងប្រភពបានក្លាយជាគោលដៅនៃការរំលោភបំពាន ១៦៧

ដោយ Julie Posetti

សង្ខេបមេរៀន ១៦៨
គ្រោងនៃមេរៀន ១៧០
គោលបំណងនៃមេរៀន ១៨០
លទ្ធផលសិក្សា ១៨០
ទម្រង់នៃមេរៀន ១៨១
លំហាត់ស្រាវជ្រាវបន្ថែម ១៨៣
អំណានបន្ថែម ១៨៣

សទ្ទានុក្រម ១៨៥
អ្នកចូលរួមក្នុងការបង្កើតសៀវភៅមេរៀននេះ ១៨៨
កម្មសិទ្ធិបញ្ញាលើរូបថត ១៨៩

# បុព្វកថា

អង្គការយូណេស្កូធ្វើការងារដើម្បីពង្រឹងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន ហើយសៀវភៅនេះគឺជាឯកសារដែលផ្តល់ធនធានផ្នែកចំណេះដឹងដ៏ជឿនលឿន និង ទំនើបចុងក្រោយបង្អស់។

ការបោះពុម្ពផ្សាយនេះគឺជាផ្នែកមួយនៃ «គំនិតផ្តួចផ្តើមជាសកលសម្រាប់ឧត្តមភាពក្នុងវិស័យអប់រំវិជ្ជាជីវៈសារព័ត៌មាន» ដែលជាការផ្តោតលើកម្មវិធីអន្តរជាតិរបស់អង្គការយូណេស្កូសម្រាប់អភិវឌ្ឍន៍វិស័យសារគមនាគមន៍ (IPDC)។ គំនិតផ្តួចផ្តើមនេះ មានគោលបំណងផ្សារភ្ជាប់ការបង្រៀនជាមួយការអនុវត្ត និងការស្រាវជ្រាវផ្នែកវិជ្ជាជីវៈសារព័ត៌មានពីទស្សនៈជាសកល ដោយរួមបញ្ចូលការចែករំលែកគំរូល្អនៅថ្នាក់អន្តរជាតិ។

ដូច្នេះហើយ សៀវភៅមេរៀននេះធ្វើឡើងដើម្បីប្រើប្រាស់ជាកម្មវិធីសិក្សាគំរូលំដាប់អន្តរជាតិ និងបើកចំហសម្រាប់ការអនុវត្តតាម ឬការយកលំនាំតាមដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមជាសកលនៃការផ្សាយព័ត៌មានមិនពិតដែលកំពុងប្រឈមនឹងសង្គមជាទូទៅ ជាពិសេសក្នុងវិស័យសារព័ត៌មាន។

សៀវភៅនេះអាចជៀសវាងការសន្មតថា ពាក្យ «ដំណឹងក្លែងក្លាយ (Fake News)» មានន័យត្រង់ ឬសាមញ្ញងាយយល់[1]។ ការធ្វើបែបនេះគឺដោយសារតែពាក្យ «ដំណឹង (News)» មានន័យថា ព័ត៌មាន (Information) ដែលបានផ្ទៀងផ្ទាត់រួចសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ហើយព័ត៌មានណាដែលមិនស្របតាមបទដ្ឋាននេះ មិនគួរហៅថាជាដំណឹងទេ។ ដូច្នេះនៅក្នុងន័យនេះ «ដំណឹងក្លែងក្លាយ» គឺជាបណ្តុំពាក្យពីរម៉ាត់ដែលមានន័យផ្ទុយគ្នា ដែលធ្វើឱ្យខូចភាពអាចជឿជាក់បាននៃព័ត៌មាន ដែលត្រូវបំពេញតាមលក្ខខណ្ឌ ឬកម្រិតនៃការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងជាប្រយោជន៍សាធារណជន ឧទាហរណ៍ ដំណឹងពិត។

ដើម្បីយល់ឱ្យកាន់តែច្បាស់ករណីនានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ល្បិចភាសាខុស និងបង្កើតប្រភេទព័ត៌មាន សៀវភៅនេះចាត់ទុកសកម្មភាពក្លែងបន្លំទាំងនេះទៅតាមសភាពពិតរបស់វា ពោលគឺចាត់ទុកថាជាប្រភេទដំណឹងក្លែងក្លាយនៅក្នុងទម្រង់កាន់តែចម្រុះនៃព័ត៌មានមិនពិត ដោយរួមទាំងទម្រង់ព័ត៌មានកម្សាន្តតាមរូបភាពជាដើម។

1 Available at Tandoc E; Wei Lim, Z and Ling, R. (2018). “Defining ‘Fake News’: A typology of scholarly definitions” in Digital Journalism (Taylor and Francis) Volume 6, 2018 - Issue 2: ‘Trust, Credibility, Fake News’

នៅក្នុងសៀវភៅនេះ ពាក្យព័ត៌មានមិនពិត (Disinformation) សំដៅជាទូទៅលើការប៉ុនប៉ងដោយចេតនា (មានការរៀបចំទុក) ដើម្បីបំភាន្ត ឬបោកប្រាស់មនុស្សតាមរយៈការផ្ដល់ព័ត៌មានមិនស្មោះត្រង់។ ទង្វើបែបនេះច្រើនតែធ្វើឡើងជាមួយយុទ្ធសាស្ត្រទាក់ទងស្របគ្នាខ្លះ និងប្រសព្វគ្នាខ្លះ ព្រមជាមួយល្បិចកលមួយចំនួនទៀតដូចជាការលួចទិន្នន័យ ឬការធ្វើឱ្យបាត់បង់ប្រយោជន៍បុគ្គល។ ព័ត៌មានខុស (Misinformation ) ជាទូទៅសំដៅលើព័ត៌មានដែលនាំឱ្យយល់ខុស ដែលគេបង្កើតឡើង ឬចែកចាយដោយមិនមានចេតនាគ្រប់គ្រង ឬបំណងអាក្រក់។ រឿងទាំងពីរនេះសុទ្ធតែបង្កបញ្ហាដល់សង្គម ប៉ុន្តែព័ត៌មានមិនពិតមានគ្រោះថ្នាក់ជាពិសេស ដោយសារព័ត៌មានប្រភេទនេះមានការរៀបចំ មានធនធានល្អ មានបច្ចេកវិទ្យាស្វ័យប្រវត្តិដើម្បីជួយពង្រឹង។

អ្នកចែកចាយព័ត៌មានមិនពិតប្រើប្រាស់ក្រុមដែលងាយរងគ្រោះ ឬក្រុមដែលមាននិន្នាការប្រកាន់បក្សពួក ដែលគេសង្ឃឹមថានឹងក្លាយជាក្រុមអ្នកបំពងសំឡេងនិងចែកចាយបន្ត។ តាមរបៀបនេះ ពួកគេរកមធ្យោបាយប្រើប្រាស់យើងទាំងអស់គ្នាជាឧបករណ៍បញ្ជូនសាររបស់ពួកគេ តាមរយៈទំនោររបស់យើងដើម្បីចែករំលែកព័ត៌មានក្នុងហេតុផលផ្សេងៗ។ អ្វីដែលគ្រោះថ្នាក់បំផុតនោះគឺថា «ដំណឹងក្លែងក្លាយ» មិនតម្រូវឱ្យក្រុមគោលដៅបង់លុយកាក់អ្វីទាំងអស់ មានន័យថាបុគ្គលដែលគ្មានលទ្ធភាពទទួលបានដំណឹងប្រកបដោយគុណភាព ឬមិនបានទទួលដំណឹងដែលឯករាជ្យ គឺជាជនដែលងាយរងគ្រោះបំផុតពីព័ត៌មានមិនពិតផង និងព័ត៌មានខុសផង។

ការផ្សព្វផ្សាយព័ត៌មានមិនពិត និងព័ត៌មានខុសអាចប្រព្រឹត្តទៅបានមួយភាគធំតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីផ្ញើសាររបស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលនាំឱ្យមានការចោទជាសំណួរទាក់ទងនឹងកម្រិតនៃបទបញ្ជា និងបទបញ្ជាសម្រាប់វិតក្បិតខ្លួនឯង និងរបស់ក្រុមហ៊ុនដែលផ្ដល់សេវាទាំងនេះ។ ក្នុងនាមជាវេទិកាផ្សារភ្ជាប់ទំនាក់ទំនង ជាជាងស្ថាប័នផលិតមាតិកា ក្រុមហ៊ុនទាំងនេះមានច្បាប់ទម្លាប់តិចតួចណាស់នៅក្នុងពេលបច្ចុប្បន្ននេះ (លើកលែងតែនៅក្នុងវិស័យកម្មសិទ្ធិបញ្ញា)។ ទោះជាយ៉ាងណា នៅក្នុងបរិបទនៃកំណើនសម្ពាធកាន់តែខ្លាំងព្រមទាំងហានិភ័យចំពោះការបញ្ចេញមតិដោយសេរីដែលបង្កឡើងដោយបទបញ្ជាច្រើនហួសកម្រិត គេឃើញមានវិធានការកាន់តែច្រើន ក្នុងទម្រង់ជាច្បាប់ទម្លាប់

ផ្ទៃក្នុង បើទោះបីជាមានតាមផ្នែកខ្លះក៏ដោយ[2]។ នៅឆ្នាំ២០១៨ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ទទួលបន្ទុកសេរីភាពនៃការបញ្ចេញមតិ បានផ្តោតសំខាន់លើបញ្ហានេះនៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ដោយជំរុញឱ្យក្រុមហ៊ុនអ៊ីនធឺណិតរៀនសូត្រពីបទបញ្ញាផ្ទៃក្នុងនៃប្រព័ន្ធផ្សព្វផ្សាយដំណឹង និងធ្វើឱ្យកាន់តែស្របទៅតាមបទដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិចែកចាយ ស្វែងរក និងទទួលព័ត៌មាន[3]។ នៅក្នុងការវិវត្តយ៉ាងឆាប់រហ័សនៃវិធានការដែលអនុវត្តដោយរដ្ឋ និងក្រុមហ៊ុនឯកជន អ្នកសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយដំណឹងមានតួនាទីយ៉ាងសំខាន់មួយដែលមានការពន្យល់លម្អិតក្នុងសៀវភៅនេះ។

## ការយល់ដឹងអំពីភាពខុសគ្នា

ព័ត៌មានមិនពិត និងព័ត៌មានខុសមានលក្ខណៈខុសគ្នាពីសារព័ត៌មាន (ដែលមានគុណភាព) ដែលស្របតាមបទដ្ឋានវិជ្ជាជីវៈនិងក្រមសីលធម៌។ ទន្ទឹមនឹងនេះដែរ ព័ត៌មានទាំងពីរប្រភេទនោះក៏ខុសគ្នាពីករណីនៃសារព័ត៌មានដែលខ្សោយមិនគ្រប់លក្ខណៈទៅតាមក្រមសីលធម៌វិជ្ជាជីវៈ។ ជាក់ស្តែង សារព័ត៌មានដែលមានបញ្ហាមានដូចជា កំហុសជាបន្តបន្ទាប់ (និងមិនបានកែតម្រូវ) ដែលកើតចេញពីកម្សោយនៃការស្រាវជ្រាវ ឬការផ្ទៀងផ្ទាត់ព័ត៌មានមិនគ្រប់ជ្រុងជ្រោយ។ ព័ត៌មានប្រភេទនេះមានទាំងការបំប៉ោងដើម្បីបង្កើនការចាប់អារម្មណ៍ និងការជ្រើសរើសការពិតដែលផ្អៀងទៅតាមបក្សពួកនិយមជ្រុលដោយបំពានភាពត្រឹមត្រូវ។

ទោះបីជាយ៉ាងណាក៏ដោយ ការលើកឡើងបែបនេះមិនមែនជាការសន្និដ្ឋានចំពោះឧត្តមគតិនៃវិជ្ជាជីវៈសារព័ត៌មានថា មានកម្រិតខ្ពស់ផុតពីការពិពណ៌នា និងទស្សនៈ ហើយសារព័ត៌មានដែលនៅក្រោមបទដ្ឋានសុទ្ធតែលាយឡំដោយមនោគមវិជ្ជានោះទេ។ ជំនួសមកវិញ ការលើកឡើងខាងលើនេះគឺដើម្បីបង្ហាញថាសារព័ត៌មានទាំងអស់សុទ្ធតែមានការពិពណ៌នា ហើយបញ្ហារបស់សារព័ត៌មានខ្វះបទដ្ឋានមិនមែនស្ថិតនៅលើវត្តមានរបស់ការពិពណ៌នានោះទេ ប៉ុន្តែបញ្ហាស្ថិតនៅត្រង់វិជ្ជាជីវៈទន់ខ្សោយ។ នេះហើយជាហេតុផលដែលវិជ្ជាជីវៈសារព័ត៌មានទន់ខ្សោយនៅតែ

2 Manjoo, F. (2018). What Stays on Facebook and What Goes? The Social Network Cannot Answer. New York Times, 19 July, 2018. https://www.nytimes.com/2018/07/19/technology/facebook-misinformation.html [accessed on 20/07/2018]; https://www.rt.com/usa/432604-youtube-invests-reputable-news/ [accessed on 15/07/2018]; https://youtube.googleblog.com/ [accessed on 15/07/2018]; https://sputniknews.com/asia/201807111066253096-whatsapp-seeks-help-fake-news/ [accessed on 15/07/2018].

3 Report of the Special Rapporteur on the promotion and protection of the right to freedom of opinion and expression. UN Human Rights Council 6 April 2018. A/HRC/38/35. https://documents-dds-ny.un.org/doc/UNDOC/GEN/G18/096/72/PDF/G1809672.pdf?OpenElement [accessed on 20/07/2018].

មិនដូចគ្នានឹងព័ត៌មានមិនពិត និងព័ត៌មានខុស។

ទោះជាយ៉ាងណា ពេលខ្លះដោយសារគុណភាពអន់ខ្សោយរបស់វិជ្ជាជីវៈសារព័ត៌មាន បណ្តាលឱ្យព័ត៌មានមិនពិត និងព័ត៌មានខុសមានឱកាសជ្រៀតចូលក្នុងប្រព័ន្ធសារព័ត៌មាន។ បុព្វហេតុនិងដំណោះស្រាយបញ្ហាសារព័ត៌មានអន់ខ្សោយមានលក្ខណៈខុសពីករណីព័ត៌មានមិនពិត និងព័ត៌មានខុស។ ក្នុងពេលជាមួយគ្នានេះដែរ មានភ័ស្តុតាងបង្ហាញថា គេត្រូវការសារព័ត៌មានប្រកបដោយក្រមសីលធម៌និងរឹងមាំដើម្បីជាមធ្យោបាយជំនួស និងជាថ្នាំបន្សាបការបំពុល បរិស្ថានព័ត៌មាន និងផលប៉ះពាល់រាលដាលដែលនាំឱ្យខូចឈ្មោះដំណឹងជាទូទៅ។

បច្ចុប្បន្ន អ្នកសារព័ត៌មានមិនមែនត្រឹមតែជាអ្នកឈរមើលនិន្នាការកើនឡើងយ៉ាងគំហុកនៃព័ត៌មានមិនពិត និងព័ត៌មានខុសប៉ុណ្ណោះទេ គេក៏កំពុងដើរនៅលើផ្លូវជាមួយគ្នានឹងនិន្នាការនេះផងដែរ[4]។ ដំណើរនេះមានន័យថា៖

➢ វិជ្ជាជីវៈសារព័ត៌មានប្រឈមនឹងហានិភ័យនៃការលិចលង់ដោយសារព័ត៌មានមិនពិត និងព័ត៌មានខុស។

➢ អ្នកសារព័ត៌មានប្រឈមនឹងការប្រើប្រាស់ពីតួអង្គនានាដែលធ្វើហួសពីក្រមសីលធម៌នៃទំនាក់ទំនងសាធារណៈ ដោយព្យាយាមបំភ័ន្ត ឬសូកប៉ាន់អ្នកសារព័ត៌មានឱ្យផ្សព្វផ្សាយព័ត៌មានមិនពិត[5]។

➢ អ្នកសារព័ត៌មានជាអ្នកទំនាក់ទំនងដែលធ្វើការបម្រើការពិត ដោយរួមទាំង «ការពិតដែលពិបាកទទួលយក» ផង អាចនឹងឃើញខ្លួនឯងថាកំពុងក្លាយជាគោលដៅនៃការកុហក ពាក្យចចាមអារ៉ាម និងការបោកប្រាស់ ដែលបង្កើតឡើងដើម្បីបំភិតបំភ័យ និងបង្ខូចកេរ្តិ៍ឈ្មោះ និងវិជ្ជាជីវៈរបស់ពួកគេ ជាពិសេសនៅពេលដែលស្នាដៃរបស់គេ គំរាមបកអាក្រាតរឿងមិនល្អរបស់មនុស្សដែលស៊ីឈ្នួល ឬបង្កើតនូវព័ត៌មានមិនពិត[6]។

4 បើទោះបីជាមានការគំរាមកំហែងក៏ដោយ យោងតាមការសិក្សាមួយនៅក្នុងការិយាល័យដំណឹងនៅក្នុងប្រទេសមួយខ្លះប្រព័ន្ធ ថវិកា និងបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលក្នុងការខិតខំ ដើម្បីប្រយុទ្ធប្រឆាំងនឹងការផ្សព្វផ្សាយព័ត៌មានមិនពិត សូមមើល៖ Penplusbytes. 2018. Media Perspectives on Fake News in Ghana. http://penplusbytes.org/publications/4535/ [accessed 12/06/2018].

5 Butler, P. 2018. How journalists can avoid being manipulated by trolls seeking to spread disinformation. http://ijnet.org/en/blog/how-journalists-can-avoid-being-manipulated-trolls-seeking-spread-disinformation សូមពិនិត្យមើលមេរៀនទី៣នៃសៀវភៅនេះ។

6 សូមពិនិត្យមើលមេរៀនទី៧

ជាងនេះទៀត អ្នកសារព័ត៌មានត្រូវទទួលស្គាល់ថា ក្នុងពេលដែលព័ត៌មានមិនពិតលេចចេញតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏មានបុគ្គលមួយចំនួនដែលមានឥទ្ធិពល កំពុងតែប្រើប្រាស់ក្តីកង្វល់អំពី «ដំណឹងក្លែងក្លាយ» ជាឧបករណ៍រឹតត្បិតប្រព័ន្ធផ្សព្វផ្សាយដំណឹងពិតប្រាកដ។ ច្បាប់ថ្មីៗ និងច្បាប់តឹងរឹង កំពុងទម្លាក់កំហុសទៅលើស្ថាប័នដំណឹងហាក់បីដូចជា ស្ថាប័នទាំងនោះជាកន្លែងបង្កើតដំណឹងក្លែងក្លាយ ឬបញ្ចូលស្ថាប័នដំណឹងទាំងនោះឱ្យស្ថិតក្រោមបទប្បញ្ញត្តិថ្មីៗ ដែលរឹតត្បិតគ្រប់មធ្យោបាយទំនាក់ទំនង និងសកម្មភាពនានាដោយគ្មានការបែងចែកក្នុងប្រការណាមួយ។ ជារឿយៗ ច្បាប់ទម្លាប់ទាំងអស់នោះក៏មិនស្របស្របតាមគោលការណ៍អន្តរជាតិ ដែលតម្រូវថា ការរឹតត្បិតទៅលើការបញ្ចេញមតិត្រូវតែមានការបញ្ជាក់ថា ចាំបាច់សមស្រប និងមានគោលបំណងស្របច្បាប់។ ផលប៉ះពាល់ពីបទប្បញ្ញត្តិរឹតត្បិតទាំងនេះ បើទោះបីមិនមែនសុទ្ធតែមានចេតនាបែបនេះទាំងអស់ក្តី គឺធ្វើឱ្យប្រព័ន្ធផ្សព្វផ្សាយដំណឹងពិតស្ថិតក្រោមដៃរបស់ «ក្រសួងនៃការពិត» ដែលមានអំណាចបង្ក្រាប ឬរឹតបន្តឹងព័ត៌មានដើម្បីហេតុផលនយោបាយសុទ្ធសាធ។

នៅក្នុងបរិបទនៃព័ត៌មានមិនពិត និងព័ត៌មានខុសសព្វថ្ងៃនេះ ការខូចខាតធំបំផុតមិនត្រឹមតែជាច្បាប់ទម្លាប់មិនសមហេតុផល ទៅលើសារព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែសាធារណជនអាចនឹងលែងជឿជាក់លើព័ត៌មានទាំងអស់តែម្តង រួមទាំងសារព័ត៌មានវិជ្ជាជីវៈផងដែរ។ នៅក្នុងស្ថានភាពបែបនេះ សាធារណជនទំនងជានឹងចាត់ទុកអ្វីៗទាំងអស់ថាអាចជឿជាក់បាន ទាក់ទងនឹងព័ត៌មានដែលប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់គេគាំទ្រ និងព័ត៌មានដែលត្រូវចិត្តគេ ដោយមិនខ្វល់ថាខុសឬត្រូវ។ យើងអាចមើលឃើញស្រាប់ហើយនូវផលប៉ះពាល់អវិជ្ជមានពីបញ្ហានេះទៅលើជំនឿជាសាធារណៈ អំពីសុខភាព វិទ្យាសាស្ត្រ ការយល់ដឹងអន្តរវប្បធម៌ និងស្ថានភាពនៃជំនាញឯកទេស។

ផលប៉ះពាល់ជាសាធារណៈនេះក៏ជាការគួរឱ្យព្រួយបារម្ភជាពិសេសចំពោះការបោះឆ្នោត និងចំពោះគំនិតប្រជាធិបតេយ្យ និងសិទ្ធិមនុស្សផងដែរ។ ចេតនានៃព័ត៌មានមិនពិត ជាពិសេសក្នុងអំឡុងពេលបោះឆ្នោត គឺមិនមែនដើម្បីបញ្ចុះបញ្ចូលឱ្យសាធារណជនជឿជាក់ទៅលើមាតិកានៃព័ត៌មាននោះថាជាការពិតទេ ប៉ុន្តែគឺដើម្បីជះឥទ្ធិពលលើការកំណត់របៀបវារៈ (អំពីអ្វីដែលប្រជាជនគិតថាសំខាន់) និងធ្វើឱ្យព័ត៌មានល្អក់កករ ដើម្បីធ្វើឱ្យកត្តាពិចារណាចុះខ្សោយ

នៅក្នុងជម្រើសបោះឆ្នោតរបស់ប្រជាជន[7]។ ដូចគ្នានេះដែរ បញ្ហាចំណាកស្រុក បម្រែបម្រួលអាកាសធាតុ និងបញ្ហាដទៃទៀត អាចរងផលប៉ះពាល់ខ្លាំងពីភាពមិនច្បាស់លាស់ដែលបង្កើតឡើងដោយព័ត៌មានមិនពិត និងព័ត៌មានខុស។

គ្រោះថ្នាក់ទាំងនេះគឺជាមូលហេតុដែលវិជ្ជាជីវៈសារព័ត៌មាន និងការអប់រំផ្នែកវិជ្ជាជីវៈសារព័ត៌មាន ចាំបាច់ត្រូវតែប្រឈមមុខដោយផ្ទាល់ជាមួយនឹងការកើនឡើងនៃ «ដំណឹងក្លែងក្លាយ»។ ស្របពេលជាមួយគ្នានេះដែរ ការគំរាមកំហែងក៏បង្កើតឱកាសសម្រាប់ការប្តេជ្ញាចិត្តទ្វេដង ក្នុងការបង្ហាញគុណតម្លៃនៃប្រព័ន្ធផ្សព្វផ្សាយដំណឹងដែរ។ ការប្រឈមទាំងនេះក៏ផ្តល់ឱកាសក្នុងការគូសបញ្ជាក់ឱ្យឃើញភាពខុសគ្នានៅក្នុងការអនុវត្តវិជ្ជាជីវៈ នៃការផ្តល់ព័ត៌មានដែលបានផ្ទៀងផ្ទាត់ និងការផ្តល់មតិយោបល់ដើម្បីប្រយោជន៍សាធារណៈ[8]។

## អ្វីដែលវិជ្ជាជីវៈសារព័ត៌មានត្រូវធ្វើ

នៅក្នុងបរិបទនេះ ដល់ពេលវេលាដែលប្រព័ន្ធផ្សព្វផ្សាយដំណឹងត្រូវប្រកាន់ខ្ជាប់ឱ្យបានកាន់តែម៉ឺងម៉ាត់ថែមទៀតនូវបទដ្ឋានវិជ្ជាជីវៈ និងក្រមសីលធម៌ ដើម្បីជៀសវាងការផ្សាយព័ត៌មានដែលមិនបានពិនិត្យផ្ទៀងផ្ទាត់ និងត្រូវដកខ្លួនឱ្យឆ្ងាយចេញពីព័ត៌មានដែលអាចផ្តល់ប្រយោជន៍ដល់ក្រុមខ្លះ ប៉ុន្តែមិនមែនជាប្រយោជន៍សាធារណៈ។

ដូច្នេះ សៀវភៅនេះក៏ជាការក្រើនរំឭកដ៏ទាន់ពេលវេលាមួយថា ស្ថាប័នដំណឹងទាំងអស់ និងអ្នកសារព័ត៌មានមកពីនិន្នាការនយោបាយណាមួយក៏ដោយត្រូវជៀសវាងការផ្សាយព័ត៌មានមិនពិត និងព័ត៌មានខុស ដោយចៃដន្យក្តី ឬដោយមិនបានពិចារណាជិតដល់ក្តី។ សព្វថ្ងៃនេះ នៅក្នុងប្រព័ន្ធផ្សព្វផ្សាយដំណឹងភាគច្រើន ការលុបបំបាត់ចោលការពិនិត្យផ្ទៀងផ្ទាត់ការពិតនៅក្នុងស្ថាប័ន ត្រូវបានសន្មតដោយ« ក្រុម Fifth Estate» របស់អ្នកសរសេរប្លក (blogger) និងតួអង្គខាងក្រៅផ្សេងទៀតដែលប្រកូកប្រកាសឱ្យគេឯងដឹងអំពីកំហុសរបស់អ្នកសារព័ត៌មានបើទោះជាកំហុស ឬដំណឹងនោះត្រូវបានផ្សព្វផ្សាយចេញរួចហើយក្តី។

---

7 Lipson, D (2018) Indonesia's 'buzzers' paid to spread propaganda as political elite wage war ahead of election, ABC News: http://mobile.abc.net.au/news/2018-08-13/indonesian-buzzers-paid-to-spread-propaganda-ahead-of-election/9928870?pfmredir=sm [accessed 17/8/18]

8 See Nordic Council of Ministers. 2018. Fighting Fakes - the Nordic Way. Copenhagen: Nordic Council of Ministers. http://www.nordicom.gu.se/en/latest/news/fighting-fakes-nordic-way [accessed 12/06/2018].

បាតុភូតថ្មីនេះ អាចទទួលបានការស្វាគមន៍ពីប្រព័ន្ធផ្សព្វផ្សាយដំណឹងថា ជាការពង្រឹងការយកចិត្តទុកដាក់របស់សង្គមលើព័ត៌មានដែលបានផ្ទៀងផ្ទាត់។ អ្នកសារព័ត៌មាន គួរតែផ្សព្វផ្សាយការងាររបស់ក្រុមផ្ទៀងផ្ទាត់ការពិតឯករាជ្យទៅដល់មហាជនទូទៅ។ ប៉ុន្តែគេគួរតែដឹងថា ក្នុងករណីដែលតួអង្គខាងក្រៅបង្ហាញឱ្យគេឃើញចំណុចខ្វះខាតជាប្រព័ន្ធនៅក្នុងស្ថាប័នដំណឹងណាមួយ ការបង្ហាញនេះនឹងបង្កើតជាសញ្ញាសួរចំពោះកេរ្តិ៍ឈ្មោះរបស់ស្ថាប័ននោះក្នុងនាមជាប្រភពដំណឹងវិជ្ជាជីវៈ។ ប្រព័ន្ធផ្សព្វផ្សាយគួរតែប្រយ័ត្នប្រយែងដែរថា ការកែតម្រូវនៅក្រោយការចេញផ្សាយដែលធ្វើឡើងដោយតួអង្គខាងក្រៅ មិនអាចជំនួសឱ្យដំណើរការគ្រប់គ្រងគុណភាពដំណឹងនៅក្នុងស្ថាប័នផ្ទៃក្នុងបានទេ។ អ្នកសារព័ត៌មានត្រូវតែធ្វើឱ្យបានល្អ និង «ត្រឹមត្រូវ» តាំងពីដំបូងទីទៅ បើមិនដូច្នេះទេសង្គមនឹងបាត់បង់ប្រព័ន្ធផ្សព្វផ្សាយដែលអាចជឿជាក់បាន។

សរុបសេចក្តីមក ល្បែងនៃការកែតម្រូវកំហុសដោយអ្នកឃ្លាំមើលពីខាងក្រៅ មិនមែនជាល្បែងដែលសារព័ត៌មានជាអ្នកឈ្នះនោះទេ។ អ្នកសារព័ត៌មានមិនត្រូវទុកឱ្យស្ថាប័នផ្ទៀងផ្ទាត់ការពិត ធ្វើកិច្ចការសារព័ត៌មាននៅក្នុងការផ្ទៀងផ្ទាត់មន្ទិលសង្ស័យដែលប្រភពបានផ្តល់ឱ្យនោះទេ (ទោះបីជាមន្ទិលសង្ស័យនោះត្រូវបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ឬឆ្លងផុតពីវិជ្ជាជីវៈសារព័ត៌មាន និងលេចឡើងដោយផ្ទាល់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមក្តី)។ សមត្ថភាពរបស់អ្នកសារព័ត៌មានដែលធ្វើឱ្យលើសពីការសរសេរថា «អ្នកនេះនិយាយបែបនេះ អ្នកនោះនិយាយបែបនោះ» ហើយស៊ើបអង្កេតភាពត្រឹមត្រូវនៃការអះអាងរបស់ប្រភពព័ត៌មានត្រូវតែធ្វើឱ្យប្រសើរឡើង។

សារព័ត៌មាន ចាំបាច់ត្រូវរកឱ្យឃើញ និងបកអាក្រាតករណី រួមទាំងទម្រង់ថ្មីៗនៃព័ត៌មានខុស។ នេះជាបេសកកម្មដ៏សំខាន់សម្រាប់ស្ថាប័នសារព័ត៌មាន និងក៏ជាវិធីគ្រប់គ្រង និងទប់ស្កាត់ «ដំណឹងក្លែងក្លាយ»។ ជាការឆ្លើយតបបន្ទាន់ចំពោះបញ្ហាដ៏ក្តៅគគុកនិងដ៏អន្តរាយ បេសកកម្មនេះបំពេញបន្ថែម និងពង្រឹងដល់យុទ្ធសាស្ត្ររយៈពេលមធ្យម ដូចជាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានដែលបង្កើនសមត្ថភាពក្រុមគោលដៅឱ្យចេះបែងចែកដំណឹង ព័ត៌មានមិនពិត និងព័ត៌មានខុស។ ព័ត៌មានមិនពិត គឺជារឿងក្តៅ ហើយការផ្សព្វផ្សាយអំពីព័ត៌មានមិនពិតនេះឱ្យបានខ្លាំងក្លា នឹងជួយពង្រឹងសេវារបស់សារព័ត៌មានចំពោះសង្គមជាតិ។

ដូច្នេះ សៀវភៅនេះគឺជាការអំពាវនាវឱ្យធ្វើសកម្មភាព។ សៀវភៅនេះក៏ជាការលើកទឹកចិត្តដល់អ្នកសារព័ត៌មានឱ្យចូលរួមក្នុងកិច្ចសន្ទនាសង្គមអំពីរបៀបដែលមនុស្សភាគច្រើនសម្រេចចិត្តអំពីភាពអាចជឿជាក់បាននៃវិជ្ជាជីវៈសារព័ត៌មាន និងអំពីមូលហេតុដែលមនុស្សខ្លះចែករំលែកព័ត៌មានដែលគ្មានការផ្ទៀងផ្ទាត់។ ដូចគ្នានឹងស្ថាប័នដំណឹងដែរ គ្រឹះស្ថានអប់រំវិជ្ជាជីវៈសារព័ត៌មាន និងនិស្សិតនៃគ្រឹះស្ថានទាំងនេះ ក៏ដូចជាគ្រូបណ្តុះបណ្តាល និងសិស្សដែរ នេះជាឱកាសដ៏ធំមួយសម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋឱ្យបានខ្លាំងក្លាជាមួយក្រុមគោលដៅ។ ឧទាហរណ៍ ការប្រមូល «ប្រភពពីសាធារណជន (crowd-sourcing)» គឺជាកត្តាសំខាន់ប្រសិនបើប្រព័ន្ធផ្សព្វផ្សាយលាតត្រដាង និងរាយការណ៍អំពីការលាក់បាំងនៃព័ត៌មានមិនពិត ហើយផ្សព្វផ្សាយតាមកម្មវិធីផ្ញើសាររបស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ឬតាមអ៊ីម៉េល។

## តួនាទីរបស់អង្គការយូណេស្កូ

សៀវភៅនេះទទួលបានការគាំទ្រមូលនិធិពីកម្មវិធីអន្តរជាតិដើម្បីអភិវឌ្ឍន៍វិស័យសារគមនាគមន៍ (IPDC) របស់អង្គការយូណេស្កូ ដែលផ្តល់នូវទស្សនៈច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយអំពីទិដ្ឋភាពផ្សេងៗគ្នានៃរឿងរ៉ាវព័ត៌មានមិនពិត រួមជាមួយនឹងការបង្កើតជំនាញជាក់ស្តែងដើម្បីបំពេញបន្ថែមទៅលើចំណេះដឹង និងការយល់ដឹង[9]។ កិច្ចការនេះជាផ្នែកមួយនៃឯកសាររបស់អង្គការយូណេស្កូ ក្នុងការលើកទឹកចិត្តដល់អ្នកសារព័ត៌មានក្នុងការបំពេញការងារឱ្យបានល្អបំផុត និងធ្វើស្វ័យនិយ័តកម្ម ដើម្បីជំនួសអន្តរាគមន៍របស់រដ្ឋក្នុងការដោះស្រាយបញ្ហាសេរីភាពបញ្ចេញមតិ។

សៀវភៅនេះបោះពុម្ពក្រោយស្នាដៃពីរផ្សេងទៀតរបស់អង្គការយូណេស្កូ ដែលមានចំណងជើងថា«Teaching Journalism for Sustainable Development: New Syllabi»[10] (2015) និង «Model Curriculum for Journalism Education: A Compendium of New Syllabli» (2013)។ សៀវភៅទាំងពីរនេះក៏ជាឯកសារបោះពុម្ពផ្សាយបន្តភាគពីសៀវភៅល្បីល្បាញរបស់អង្គការយូណេស្កូដែលមានចំណងជើងថា «Model

9 កិច្ចប្រជុំលើកទី ៦១ នៃការិយាល័យ IPDC ក្នុងឆ្នាំ ២០១៧ បានសំរេចគាំទ្រគំនិតផ្តួចផ្តើមសកលសម្រាប់ឧត្តមភាពក្នុងការអប់រំវិជ្ជាជីវៈសារព័ត៌មានដោយធ្វើការបែងចែកពិសេសដើម្បីអភិវឌ្ឍមេរៀនលើប្រធានបទសំខាន់ៗថ្មីៗសម្រាប់វិជ្ជាជីវៈសារព័ត៌មាន។ ដំណើរការត្រូវបានរាយការណ៍ទៅកិច្ចប្រជុំលើកទី ៦២ នៃការិយាល័យ IPDC ក្នុងឆ្នាំ ២០១៨ ដែលបន្ទាប់មកបានត្រៀមទុកថវិកាបន្ថែមដើម្បីគាំទ្រកម្មវិធីសិក្សានេះ។

10 http://www.unesco.org/new/en/communication-and-information/resources/publications-and-communication-materials/publications/full-list/teaching-journalism-for-sustainable-development/ [accessed12/06/2018].

Curriculum on Journalism Education»[11] ដែលបោះពុម្ពផ្សាយនៅឆ្នាំ២០០៧ ជា ៩ ភាសា។

សៀវភៅផ្សេងៗទៀតដែលនៅមានគុណតម្លៃ និងនៅក្នុងក្រុមឯកសារបោះពុម្ពផ្សាយរបស់ អង្គការយូណេស្កូ ដែលទាក់ទងនឹងការអប់រំ និងការបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈសារព័ត៌មាន រួមមាន ៖

➢ Model Course on the Safety of Journalists (2017)[12]

➢ Terrorism and the Media: A Handbook for Journalists (2017)[13]

➢ Climate Change in Africa: A Guidebook for Journalists (2013)[14]

➢ Global Casebook of Investigative Journalism (2012)[15]

➢ Story-Based Inquiry: A Manual for Investigative Journalists (2009)[16]

➢ Conflict-Sensitive Reporting: State of the Art; A Course for Journalists and Journalism Educators (2009)[17]

ការបោះពុម្ពផ្សាយទាំងនេះមានគុណប្រយោជន៍ នៅក្នុងប្រទេសជាច្រើនជុំវិញពិភពលោក ដែលអ្នកអប់រំ និងអ្នកបណ្តុះបណ្តាលផ្នែកសារព័ត៌មាន ព្រមទាំងនិស្សិត និងអ្នកសារព័ត៌មានអាជីព បានកែលម្អការអនុវត្តរបស់ខ្លួនតាមបែបផ្សេងៗ។ នៅកន្លែងខ្លះ គេមានភាពបត់បែនដើម្បីសម្របសម្រួលកម្មវិធីច្រើនឆ្នាំឱ្យស្របទៅតាមចំណេះដឹង និងចរន្តថ្មីៗ។ នៅកន្លែងខ្លះទៀត គេដាក់បញ្ចូល

11 http://www.unesco.org/new/en/communication-and-information/resources/publications-and-communication-materials/publications/full-list/model-curricula-for-journalism-education/ [accessed12/06/2018].

12 https://en.unesco.org/news/unesco-releases-model-course-safety-journalists [accessed 12/06/2018].

13 https://en.unesco.org/news/terrorism-and-media-handbook-journalists [accessed 12/06/2018].

14 http://www.unesco.org/new/en/communication-and-information/resources/publications-and-communication-materials/publications/full-list/climate- change-in-africa-a-guidebook-for-journalists/ [accessed on 12/06/2018].

15 http://www.unesco.org/new/en/communication-and-information/resources/publications-and-communication-materials/publications/full-list/the-global-investigative-journalism-casebook/ [accessed 12/06/2018].

16 http://unesdoc.unesco.org/images/0019/001930/193078e.pdf [accessed 12/06/2018].

17 http://www.unesco.org/new/en/communication-and-information/resources/publications-and-communication-materials/publications/full-list/conflict-sensitive-reporting-state-of-the-art-a-course-for-journalists-and-journalism-educators/ [accessed on 12/06/2018].

ផ្នែកខ្លះដែលយកពីធនធានរបស់អង្គការយូណេស្កូ ទៅក្នុងវគ្គបណ្តុះបណ្តាលដែលមានស្រាប់។ គុណភាព និងភាពស៊ីចង្វាក់គ្នានៃសៀវភៅថ្មីនេះអាចរំពឹងថានឹងបង្កើតបានគុណតម្លៃដូចគ្នានឹងសៀវភៅមុនៗសម្រាប់អ្នកអាន។

ដោយសារយូណេស្កូជាអង្គការអន្តររដ្ឋាភិបាល អង្គការនេះមិនលម្អៀងទៅរកភាគីណាមួយ នៅក្នុងភូមិសាស្ត្រនយោបាយនៃការប្រជែងផ្នែកព័ត៌មានឡើយ។ ដូចដែលគេបានដឹងជាទូទៅហើយថាមានការអះអាងខុសៗគ្នា និងមានការអះអាងតបទៅវិញទៅមកអំពីព័ត៌មានមិនពិត។ ចំណេះដឹងបែបនេះគួរតែផ្តល់ការតម្រង់ទិសដោយការអានសៀវភៅនេះ ព្រមទាំងជំរុញទឹកចិត្តក្រុមគោលដៅឱ្យជួយប្រមូលភស្តុតាងបន្ថែមទៀតអំពីករណីផ្សេងៗ។

ទន្ទឹមនឹងនេះដែរ សៀវភៅមេរៀននេះមានបញ្ចូលសមត្ថភាពដូចខាងក្រោមដើម្បីបង្កើតមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការវាយតម្លៃ និងការអនុវត្តៈ

១. ចំណេះដឹងអំពីដំណឹងដែលផលិតដោយតួអង្គ ដែលមានតម្លាភាព និងអាចផ្ទៀងផ្ទាត់បានមានសារៈសំខាន់ណាស់សម្រាប់លទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍវិទ្យាសាស្ត្រសុខាភិបាល និងវឌ្ឍនភាពរបស់មនុស្ស។

២. ការទទួលស្គាល់ថាព័ត៌មានមិនពិត មិនមែនជាបញ្ហាតូចតាចនោះទេ ហើយការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត ជាបេសកកម្មសំខាន់បំផុតសម្រាប់ប្រព័ន្ធផ្សព្វផ្សាយដំណឹង។

៣. ការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់ជំនាញវិជ្ជាជីវៈសារព័ត៌មានថាសំខាន់ ប្រសិនបើវិជ្ជាជីវៈសារព័ត៌មានដែលមានសុក្រឹតភាព និងគ្រប់សមាសភាពត្រូវប្រកួតប្រជែងក្នុងនាមជាអ្នកផ្តល់ដំណឹង ដែលអាចជឿទុកចិត្តបានដើម្បីប្រឆាំងនឹងដំណឹងក្លែងក្លាយ។

សៀវភៅដទៃទៀតដែលត្រូវបានលើកឡើងនៅក្នុងសៀវភៅនេះ ហើយដែលមានសារៈសំខាន់ និងមានឥទ្ធិពលសម្រាប់អ្នកសារព័ត៌មាន និងស្ថាប័នសារព័ត៌មាន រួមមានៈ

១. ចំណេះដឹង និងជំនាញនៅក្នុងការរៀបចំបង្កើតប្រព័ន្ធការិយាល័យដំណឹង ដើម្បីធានាឱ្យមានការតាមដាន ការស៊ើបអង្កេត និងការរាយការណ៍អំពីព័ត៌មានមិនពិត។

២. ចំណេះដឹងអំពីគុណតម្លៃនៃភាពជាដៃគូរវាងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ សាលាវិជ្ជាជីវៈសារព័ត៌មាន សង្គមស៊ីវិល អ្នកផ្ទៀងផ្ទាត់ការពិត សហគមន៍ ក្រុមហ៊ុនអ៊ីនធឺណិត និងនិយ័តករ ក្នុងការប្រយុទ្ធប្រឆាំងនឹងការបំពុលព័ត៌មាន។

៣. ចំណេះដឹងអំពីភាពចាំបាច់ក្នុងការអប់រំសាធារណជនឱ្យយល់អំពីសារៈសំខាន់នៃការស្រឡាញ់ និងការពារវិជ្ជាជីវៈសារព័ត៌មានកុំឱ្យលិចលង់ក្នុងព័ត៌មានមិនពិត ឬក្លាយជាគោលដៅវាយប្រហាររបស់តួអង្គទុច្ចរិតដែលដឹកនាំយុទ្ធនាការផ្សព្វផ្សាយព័ត៌មានមិនពិត ប្រឆាំងនឹងអ្នកសារព័ត៌មាន។

ជាទូទៅ សៀវភៅនេះនឹងជួយឱ្យសង្គមកាន់តែយល់ដឹងច្រើនថែមទៀតអំពីការឆ្លើយតបរបស់សង្គមចំពោះបញ្ហាព័ត៌មានមិនពិត ក្នុងនោះរាប់បញ្ចូលទាំងការឆ្លើយតបពីរដ្ឋាភិបាល អង្គការអន្តរជាតិ ក្រុមអ្នកការពារសិទ្ធិមនុស្ស ក្រុមហ៊ុនអ៊ីនធឺណិត និងក្រុមអ្នកគាំទ្រអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន។ ជាពិសេស សៀវភៅនេះបង្ហាញអំពីកិច្ចការដែលអ្នកសារព័ត៌មាន អ្នកបង្រៀន និងអ្នកបណ្តុះបណ្តាលផ្នែកវិជ្ជាជីវៈសារព័ត៌មានអាចធ្វើបាន។

យើងសង្ឃឹមថា យ៉ាងហោចណាស់ សៀវភៅនេះអាចជួយពង្រឹងការចូលរួមចំណែកដ៏សំខាន់ដែលវិជ្ជាជីវៈសារព័ត៌មានអាចផ្តល់ដល់សង្គម និងចូលរួមវិភាគទានក្នុងបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងការសម្រេចបាន «សិទ្ធិទទួលព័ត៌មានជាសាធារណៈ និងសេរីភាពជាមូលដ្ឋាន»។ អង្គការយូណេស្កូសូមថ្លែងអំណរគុណដល់ក្រុមអ្នកកែសម្រួល និងក្រុមអ្នកនិពន្ធដែលបានធ្វើឱ្យការបោះពុម្ពផ្សាយសៀវភៅនេះលេចរូបរាងឡើង។ ដូច្នេះ យើងសូមប្រគល់សៀវភៅនេះជូនអ្នកអាន ហើយយើងសូមស្វាគមន៍មតិរិះគន់កែលម្អ។

Guy Berger

នាយកផ្នែកសេរីភាពនៃការបញ្ចេញមតិ និងអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយរបស់អង្គការយូណេស្កូ

លេខាធិការនៃកម្មវិធី IPDC

# បុព្វកថា

វិទ្យាស្ថានសារព័ត៌មានហ្វូច ជាផ្នែកមួយនៃសកលវិទ្យាល័យសាធារណៈ Linnaeus នៅប្រទេសស៊ុយអែត ហើយវិទ្យាស្ថាននេះធ្វើការងារដើម្បីពង្រឹងសេរីភាព ឯករាជ្យភាព និងវិជ្ជាជីវៈសារព័ត៌មាន។ វិទ្យាស្ថានយើងខ្ញុំបាន និងកំពុងធ្វើការនៅប្រទេសជាច្រើនជុំវិញពិភពលោក។ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ យើងផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាននៅប្រទេសកម្ពុជា ឡាវ ភូមា និងវៀតណាម។

យើងមានសេចក្តីសោមនស្សរីករាយ ដែលមានឱកាសសហការជាមួយអង្គការយូណេស្កូ ដើម្បីបកប្រែ និងបោះពុម្ពសៀវភៅនេះ។ ព័ត៌មានមិនពិតធ្វើឱ្យសឹករេចរិលឫសគល់របស់លទ្ធិប្រជាធិបតេយ្យ ហើយពលរដ្ឋគ្រប់រូបនៅជុំវិញពិភពលោកត្រូវការព័ត៌មាន ដែលអាចជឿទុកចិត្តបានថាពិត និងស្មោះត្រង់។ អ្នកសារព័ត៌មានអាជីពត្រូវតែដឹងថា ធ្វើយ៉ាងណាសរសេរដំណឹងដែលប្រជាពលរដ្ឋអាចជឿនិងទុកចិត្ត។សៀវភៅនេះមានសារៈសំខាន់ក្នុងប្រទេសនេះ ក៏ដូចជានៅប្រទេសស៊ុយអែតរបស់ខ្ញុំ។ ដើម្បីឱ្យអ្នកសារព័ត៌មានរាប់ពាន់នាក់នៅប្រទេសកម្ពុជាអាចប្រើប្រាស់សៀវភៅនេះបាន យើងត្រូវតែបកប្រែវាជាភាសាខ្មែរ។ ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងជួយពង្រឹងវិស័យសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។

Kersti Forsberg

នាយកវិទ្យាស្ថានសារព័ត៌មានហ្វូច

# សេចក្ដីផ្ដើម

Cherilyn Ireton និង Julie Posetti[1]

ដើម្បីធ្វើជាកម្មវិធីសិក្សាគំរូមួយ សៀវភៅនេះត្រូវបានរៀបចំឡើងសម្រាប់ផ្ដល់ក្របខ័ណ្ឌ និងមេរៀនឱ្យអ្នកអប់រំ និងអ្នកបណ្ដុះបណ្ដាលផ្នែកវិជ្ជាជីវៈសារព័ត៌មាន រួមទាំងនិស្សិតសារព័ត៌មានសម្រាប់ជួយដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹង «ដំណឹងក្លែងក្លាយ»[2]។ យើងក៏សង្ឃឹមដែរថា សៀវភៅនេះនឹងក្លាយជាមគ្គុទ្ទេសក៍ដ៏មានប្រយោជន៍សម្រាប់អ្នកសារព័ត៌មានអាជីពទាំងអស់។

សៀវភៅនេះ ប្រមូលផ្ដុំគំនិតយោបល់ពីក្រុមអ្នកអប់រំវិជ្ជាជីវៈសារព័ត៌មានអន្តរជាតិ អ្នកស្រាវជ្រាវ និងអ្នកត្រិះរិះផ្ដើមៗ ដែលកំពុងជួយធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រ និងការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន ដើម្បីដោះស្រាយបញ្ហាប្រឈមនៃព័ត៌មានមិនពិត និងព័ត៌មានខុស។ មេរៀនទាំងអស់ក្នុងសៀវភៅនេះផ្អែកទៅលើបរិបទ និងទ្រឹស្ដី ហើយវាកាន់តែមានសារៈប្រយោជន៍ទៀតនៅក្នុងការផ្ទៀងផ្ទាត់តាមប្រព័ន្ធអ៊ីនធឺណិត។ នៅពេលដែលប្រើប្រាស់រួមគ្នាជាវគ្គបណ្ដុះបណ្ដាល ឬប្រើប្រាស់ដោយឯករាជ្យ មេរៀនទាំងនេះអាចជួយរំឭកមេរៀនដែលមានស្រាប់ ឬបង្កើតជាមេរៀនថ្មីៗ។ នៅខាងចុងនៃសេចក្ដីផ្ដើមនេះនឹងមានការណែនាំអំពីរបៀបប្រើប្រាស់សៀវភៅនេះជាកម្មវិធីសិក្សាគំរូ។

មានការជជែកដេញដោលអំពីការប្រើប្រាស់ពាក្យ «ដំណឹងក្លែងក្លាយ» នៅក្នុងចំណងជើង និងក្នុងមេរៀន។ បច្ចុប្បន្ន «ដំណឹងក្លែងក្លាយ» មិនមែនគ្រាន់តែឈ្មោះនៃព័ត៌មានមិនពិត និងព័ត៌មាននាំទៅរកការយល់ខុស ដែលបន្លំខ្លួន និងផ្សព្វផ្សាយដូចជាដំណឹងពិតប៉ុណ្ណោះទេ ដំណឹងប្រភេទនេះបានក្លាយជាអាវុធដើម្បីធ្វើឱ្យសារព័ត៌មានបាត់បង់តម្លៃ និងទំនុកចិត្ត។ ដោយសារមូលហេតុនេះហើយ ទើបយើងប្រើប្រាស់ពាក្យព័ត៌មានខុស ព័ត៌មានមិនពិត និង «ព័ត៌មានច្របូកច្របល់» ដែលបានស្នើឡើងដោយ Wardle និង Derakhshan[3] ប៉ុន្តែមិនមែនជាការដាក់កម្រិតឱ្យប្រើជាទូទៅទេ[4 5]។

1 Alice Matthews នៃប្រព័ន្ធផ្សព្វផ្សាយអូស្ត្រាលី ABC និង Tom Law នៃបណ្ដាញក្រុមសីលធម៌សារព័ត៌មាន Ethical Journalism Network បានចូលរួមចំណែកក្នុងការស្រាវជ្រាវ គំនិត និងធនធាន ដែលបានឆ្លុះបញ្ចាំងនៅក្នុងសេចក្ដីផ្ដើមនេះ។

2 យោងតាមការណែនាំរបស់ក្រសួងព័ត៌មាន សម្រាប់គោលបំណងនៃសៀវភៅនេះ ពាក្យ "News" ត្រូវបានបកប្រែថាជា "ដំណឹង" ហើយពាក្យ "Information" ត្រូវបានបកប្រែថាជា "ព័ត៌មាន"។

3 សូមពិនិត្យមើលមេរៀនទី២

4 The argument against using the term 'fake news' has been made by many writers and journalists themselves, including Basson, A. (2016) If it's fake, it's not news. https://www.news24.com/Columnists/AdriaanBasson/lets-stop-talking-about-fake-news-20170706 [accessed 12/06/2018].

5 Wardle, C, et al. (2018). "Information Disorder: the essential glossary". Shorenstein Center, Harvard University. Available at: https://firstdraftnews.org/wp-content/uploads/2018/07/infoDisorder_glossary.pdf?x25702 [accessed 21/07/2018].

## សេចក្តីប្រកាសរួមស្តីពីសេរីភាពនៃការបញ្ចេញមតិ និង «ដំណឹងក្លែងក្លាយ» ព័ត៌មានមិនពិត និង ការឃោសនា

សៀវភៅនេះត្រូវបានបង្កើតឡើងដោយសារកំណើននៃការព្រួយបារម្ភនៅទូទាំងពិភពលោក អំពី «សង្គ្រាមនៃព័ត៌មានមិនពិត» ដែលវាយប្រហារទៅលើវិស័យសារព័ត៌មាន និងអ្នកសារព័ត៌មាន ។ នៅដើមឆ្នាំ២០១៧ ក្នុងពេលដែលអង្គការយូណេស្កូ ចាប់ផ្តើមអនុវត្តគម្រោងនេះ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសេរីភាពនៃការបញ្ចេញមតិ និងតំណាងអង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អឺរ៉ុប (OSCE) ទទួលបន្ទុកសេរីភាពសារព័ត៌មាន អ្នករាយការណ៍ពិសេសរបស់អង្គការសហរដ្ឋអាមេរិកទទួលបន្ទុកសេរីភាពបញ្ចេញមតិ និងអ្នករាយការណ៍ពិសេសរបស់គណៈកម្មការសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិកទទួលបន្ទុកសេរីភាពបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មានបានចេញសេចក្តីថ្លែងការណ៍រួមមួយ ដោយបានបង្ហាញនូវការភ្ញាក់ផ្អើលចំពោះការសាយភាពនៃព័ត៌មានមិនពិត និងការឃោសនា ព្រមទាំងការវាយប្រហារមកលើស្ថាប័នដំណឹងថាជា«ដំណឹងក្លែងក្លាយ»។ អ្នករាយការណ៍ពិសេស និងអ្នកតំណាងទាំងអស់នោះបានទទួលស្គាល់ជាពិសេសនូវផលប៉ះពាល់លើអ្នកសារព័ត៌មាន និងវិជ្ជាជីវៈសារព័ត៌មានថា៖

> *«(យើង)មានការភ្ញាក់ផ្អើលចំពោះករណីនានាដែលអាជ្ញាធរសាធារណៈលាបពណ៌(បង្ខូចកេរ្តិ៍ឈ្មោះ) បំភិតបំភ័យ និងគំរាមកំហែងប្រព័ន្ធផ្សព្វផ្សាយ ក្នុងនោះមានទាំងការថ្លែងថា ប្រព័ន្ធផ្សព្វផ្សាយជា «អ្នកប្រឆាំង» ឬជា «ការកុហក» និងមានបង្កប់ការឃោសនានយោបាយ ដែលនាំឱ្យកើនឡើងនូវហានិភ័យនៃការគំរាមកំហែង និងអំពើហិង្សាលើអ្នកសារព័ត៌មាន បំផ្លាញទំនុកចិត្តជាសាធារណៈ និងការជឿជាក់លើសារព័ត៌មានក្នុងនាមជាអ្នកឃ្លាំមើលរបស់សាធារណជន ហើយអាចនាំឱ្យសាធារណជនភ័ន្តច្រឡំតាមរយៈការធ្វើឱ្យស្រពេចស្រពិលនូវព្រំដែនរវាងព័ត៌មានមិនពិត និងអត្ថបទសារព័ត៌មានដែលការពិតត្រូវបានផ្ទៀងផ្ទាត់ដោយឯករាជ្យ ។»*[6]

6 UN/OSCE/OAS/ACHPR(2017). Joint Declaration on Freedom of Expression and “Fake News”, Disinformation, Propaganda: https://www.osce.org/fom/302796?download=true [accessed 29/03/2017]. See also: Kaye, D (2017) Statement to the UN General Assembly on October 24th, 2017: https://www.ohchr.org/en/NewsEvents/Pages/DisplayNews.aspx?NewsID=22300&LangID=E [accessed: 20/8/18].

## ព័ត៌មានមិនពិតជារឿងចាស់ ដែលជំរុញបន្ថែមដោយបច្ចេកវិទ្យាថ្មី

ការប្រមូលផ្តុំ និងគ្រប់គ្រងព័ត៌មានជាទិដ្ឋភាពមួយនៃប្រវត្តិសាស្ត្រដ៏យូរលង់តាំងពីមុនពេលដែលសារព័ត៌មានសម័យទំនើបនេះបានបង្កើតបទដ្ឋាន ដែលកំណត់ថាដំណឹងជាប្រភេទដែលផ្អែកលើវិធានសុចរិតភាពជាក់លាក់។ ការកត់ត្រាដំបូងៗមាននៅក្នុងសម័យកាលរ៉ូម[7] ជាពេលដែលលោក Antony ជួបជាមួយព្រះរាជនី Cleopatra ហើយសត្រូវនយោបាយរបស់គាត់ ឈ្មោះ Octavian បានបើកយុទ្ធនាការបង្ខូចកេរ្តិ៍ឈ្មោះប្រឆាំងនឹងរូបគាត់ ដោយប្រើពាក្យស្លោកខ្លី និងមុតស្រួចដែលសរសេរនៅលើកាក់ក្នុងទម្រង់ជាសារសម័យបុរាណ»[8]។ ជនបង្កហេតុបានក្លាយជាអធិរាជរ៉ូម៉ាំងទីមួយ ហើយ«ដំណឹងក្លែងក្លាយបានជួយឱ្យ Octavian ចូលប្រព័ន្ធសាធារណរដ្ឋបានទាំងស្រុង និងជារៀងរហូត»[9]។

ប៉ុន្តែសតវត្សរ៍ទី២១ត្រូវគេមើលឃើញថា មានការប្រើប្រាស់ព័ត៌មានជាអាវុធក្នុងទ្រង់ទ្រាយមួយដែលមិនធ្លាប់មាន។ បច្ចេកវិទ្យាថ្មីដ៏មានឥទ្ធិពលធ្វើឱ្យការប្រើប្រាស់ និងការប្រឌិតមាតិកាកាន់តែងាយស្រួល ហើយប្រព័ន្ធផ្សព្វផ្សាយសង្គមជួយបំពងសំឡេងព័ត៌មានមិនពិតដែលចូលរួមដោយរដ្ឋ អ្នកនយោបាយប្រជាភិថុតិ និងអង្គភាពសាជីវកម្មទុច្ចរិត ក្នុងពេលដែលសាធារណជនក៏ចូលរួមចែកចាយព័ត៌មានមិនពិតនោះដោយខ្វះការពិចារណា។ បច្ចេកវិទ្យាបានក្លាយជាសមរភូមិដ៏អំណោយផលសម្រាប់យុទ្ធនាការឃោសនា[10] «បញ្ឆេះបញ្ឆើ»[11] និង «ក្រុមបញ្ឆេះបញ្ឆើ»[12] «បណ្តាញបោកប្រាស់តាមអ៊ីនធឺណិត»[13] និង«ក្រុមអ្នកបំផ្លើសការពិត»[14]។ បន្ទាប់មកទៀតក៏មាន «ពួកបញ្ឆេះបញ្ឆើ»

---

7 See a timeline plotting selected manifestations of 'information disorder' - from Cleopatra's era to the present - in a guide published by the International Center for Journalists (ICFJ) Posetti, J & Matthews, A (2018): https://www.icfj.org/news/short-guide-history-fake-news-and- disinformation-new-icfj-learning-module [accessed23/07/2018].

8 Kaminska,I.(2017). A lesson in fake news from the info-wars of ancient Rome. Financial Times. https://www.ft.com/content/aaf2bb08-dca2- 11e6-86ac-f253db7791c6 [accessed28/03/2018].

9 ibid

10 See Oxford Internet Institute's Computational Propaganda Project: http://comprop.oii.ox.ac.uk/ [accessed20/07/2018].

11 សូមពិនិត្យមើលមេរៀនទី៧នៃសៀវភៅនេះសម្រាប់ករណីសិក្សាបង្ហាញអំពីការគំរាមគំហែង។

12 Rappler.com (2018) Fake News in the Philippines: Dissecting the Propaganda Machine. https://www.rappler.com/newsbreak/rich- media/199895-fake-news-documentary-philippines-propaganda-machine [accessed20/07/2018].

13 Gent,E. (2017) Sock puppet accounts unmasked by the way they write and post. https://www.newscientist.com/article/2127107-sock- puppet-accounts-unmasked-by-the-way-they-write-and-post/ [accessed19/07/2018].

14 LeRoux,J.(2017). Hidden hand drives social media smears.https://mg.co.za/article/2017-01-27-00-hidden-hand-drives-social-media-smears [accessed 19/07/2018].

ស្វែងរកប្រយោជន៍នៅពេលមានការបោះឆ្នោត[15]។

ទោះបីកាលៈទេសៈ និងបច្ចេកវិទ្យាមានភាពខុសគ្នាក្តី ប្រវត្តិសាស្រ្តអាចឱ្យយើងយល់ដឹងអំពីបុព្វហេតុ និងផលវិបាកនៃបាតុភាពសហសម័យនៃ «ព័ត៌មានច្របូកច្របល់» ដែលសៀវភៅនេះព្យាយាមបកស្រាយ។ ដើម្បីធានាដល់ការរាយការណ៍ភាពល្អៀងគ្នាអំពីវិបត្តិនេះ អ្នកសារព័ត៌មាន អ្នកបណ្តុះបណ្តាល និងអ្នកអប់រំផ្នែកសារព័ត៌មាន (រួមទាំងនិស្សិតសារព័ត៌មាន) គួរសិក្សាអំពីព័ត៌មានមិនពិត ការឃោសនា ការបោកបញ្ឆោត និងសំណេរចំអកថាជាទិដ្ឋភាពប្រវត្តិសាស្រ្តនៃប្រព័ន្ធសារគមនាគមន៍[16]។

ដូច្នេះ ការរៀបចំបង្កើតយុទ្ធសាស្រ្តសារព័ត៌មាន ដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិតគួរតែធ្វើឡើងដោយដឹងថា ការគ្រប់គ្រងព័ត៌មានមានអាយុកាលរាប់សតវត្សរ៍មកហើយ ចំណែកឯវិវត្តន៍នៃវិជ្ជាជីវៈសារព័ត៌មានទើបតែចាប់ផ្តើមថ្មីៗនេះប៉ុណ្ណោះ[17]។ ខណៈដែលវិជ្ជាជីវៈសារព័ត៌មានបានប្រែប្រួលខ្លួនបន្តិចម្តងៗដើម្បីបំពេញតួនាទីក្នុងសង្គមសហសម័យ ប្រព័ន្ធផ្សព្វផ្សាយដំណឹងភាគច្រើនអាចប្រតិបត្តិការដាច់ដោយឡែកពីពិភពនៃការប្រឌិតដំណឹង និងការវាយប្រហារដោយសម្ងាត់ ក្រោមការការពារពីសារព័ត៌មានដែលចង់បានបទដ្ឋានវិជ្ជាជីវៈនៃការផ្សាយការពិត វិធីសាស្រ្តផ្ទៀងផ្ទាត់ និងក្រមសីលធម៌នៃប្រយោជន៍សាធារណៈ។ សារព័ត៌មានបានឆ្លងកាត់ដំណាក់កាលនិងស្រទាប់ជាច្រើននៃការញែកខ្លួនចេញពីបញ្ហា។ សព្វថ្ងៃ ទោះបី «សារព័ត៌មាន»មានប្រភេទផ្សេងៗគ្នាច្រើនក្តី គេនៅតែអាចកំណត់ភាពចម្រុះនៃការពណ៌នាក្នុងសាច់រឿងដំណឹងពិតជាសមាជិកគ្រួសារនៃការអនុវត្តវិជ្ជាជីវៈសារគមនាគមន៍ដែលជំរុញដោយក្រមសីលធម៌ច្បាស់លាស់ ហើយក៏ចង់មានភាពឯករាជ្យពីប្រយោជន៍នយោបាយ និងប្រយោជន៍ពាណិជ្ជកម្មផងដែរ។ ប៉ុន្តែមុនពេលនៃវិវត្តន៍បទដ្ឋានបែបនេះមានវិធានតិចតួចប៉ុណ្ណោះអំពីសុចរិតភាពនៃព័ត៌មានដែលគេអនុវត្តក្នុងចំណោមប្រជាជន។

ការរីកដុះដាលនៃរោងបោះពុម្ពរបស់លោក Gutenberg ចាប់តាំងពីពាក់កណ្តាល

15 Silverman, Cet al (2018) American Conservatives Played a Role in the Macedonian Fake News Boom of 2016 Buzzfeed https://www.buzzfeednews.com/article/craigsilverman/american-conservatives-fake-news-macedonia-paris-wade-libert [accessed20/07/2018].

16 Posetti, J and Matthews, A(2018) A short guide to the history of 'fake news': A learning module for journalists and journalism educators ICFJ https://www.icfj.org/news/short-guide-history-fake-news-and-disinformation-new-icfj-learning-module [accessed23/07/2018].

17 សូមពិនិត្យមើលមេរៀនទី៣

សតវត្សរ៍ទី១៥ មក ជាធាតុមិនអាចខ្វះបានចំពោះការរីកចម្រើននៃសារព័ត៌មានវិជ្ជាជីវៈ ប៉ុន្តែបច្ចេកវិទ្យានេះក៏បានផ្តល់លទ្ធភាពដល់ការបំពងសំឡេងនៃព័ត៌មានឃោសនា និងបោកប្រាស់ ដែលពេលខ្លះបានទម្លាក់កំហុសមកលើស្ថាប័នផ្សព្វផ្សាយថាជាអ្នកធ្វើខុសថែមទៀតផង[18]។ ប្រព័ន្ធសារព័ត៌មានផ្សព្វផ្សាយ (ទូរទស្សន៍, វិទ្យុ) បានជួយជំរុញលទ្ធភាពឃោសនា ការផ្សាយបោកប្រាស់ និងការបំផ្លើស ទៅកាន់កម្រិតថ្មីមួយទៀត ដូចគ្នានឹងអ្វីដែលល្ខោនវិទ្យុរឿង War of the World បានបង្ហាញកាលពីឆ្នាំ១៩៣៨[19]។ ជារឿយៗ ការកើនឡើងនៃការផ្សព្វផ្សាយជាអន្តរជាតិក៏ជំរុញឱ្យមានការប្រើប្រាស់ដំណឹងលើសពីព្រំដែននៃដំណឹងវិជ្ជាជីវៈនិងឯករាជ្យដែរ បើទោះជារឿង «ប្រឌិត» សុទ្ធសាធ និងការបង្កើតកំហុសដោយត្រង់ជាទូទៅបានក្លាយជាករណីលើកលែង ជាជាងក្បួនច្បាប់នៅក្នុងការពិពណ៌នាសាច់រឿងរបស់មនុស្សផ្សេងៗគ្នាក៏ដោយ។

ជាមួយគ្នានេះដែរ យើងក៏អាចរៀនសូត្រពីប្រវត្តិដ៏យូរលង់នៃការដែលមនុស្សជឿលើប្រពៃណីបោកប្រាស់ «April Fool» ក្នុងនោះក៏មានអ្នកសារព័ត៌មានខ្លះដែរ[20]។ សូម្បីសព្វថ្ងៃនេះ ជារឿយៗព័ត៌មានមិនពិតបានដើរតួនាទីសំខាន់នៅក្នុងទម្រង់សារព័ត៌មាន[21] ក៏ត្រូវបានអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមយល់ច្រឡំថាជាដំណឹងដែលអាចជឿទុកចិត្តបាន[22] [23] ហើយយកទៅផ្សព្វផ្សាយបន្តដែរ។ ពេលរំឭកដល់រឿងរ៉ាវដែលមានក្នុងប្រវត្តិសាស្ត្រ ករណីខ្លះមានស្រទាប់ជាច្រើនដែលគេហទំព័រដំណឹងបែបចំអកដើរតួជាផ្នែកមួយនៃបណ្តាញដ៏ធំ ដែលបង្កើតឡើងដើម្បីរកប្រាក់ចំណេញពីការផ្សាយពាណិជ្ជកម្មនៅលើអ៊ីនធឺណិត តាមរយៈអ្នកប្រើប្រាស់ដែលឆាប់ជឿ ចុចមើល និងចែកចាយ។ បញ្ហានេះមិនមែនប៉ះពាល់

---

18 See for example, what is said to the first-large scale news hoax – 'The Great Moon Hoax' of 1835. Detailed here: Thornton, B. (2000). The Moon Hoax: Debates About Ethics in 1835 New York Newspapers, Journal of Mass Media Ethics 15(2), pp. 89-100. http://www.tandfonline. com/doi/abs/10.1207/S15327728JMME1502_3 [accessed 28/03/2018].

19 Schwartz, A.B. (2015). The Infamous "War of The Worlds" Radio Broadcast Was a Magnificent Fluke, The Smithsonian. http://www.smithsonianmag.com/history/infamous-war-worlds-radio-broadcast-was-magnificent-fluke-180955180/#h2FAexeJmuCHJfSt.99 [accessed 28/03/2018].

20 Laskowski, A. (2009). How a BU Prof April Fooled theCountry: When the joke was on the Associated Press, BU Today. https://www.bu.edu/today/2009/how-a-bu-prof-april-fooled-the-country/ [accessed 01/04/2018].

21 Baym, G (2006) The Daily Show: Discursive Integration and the Reinvention of Political Journalism in Political Communication Taylor and Francis Volume 22, 2005-Issue3 pp 259-276 https://www.tandfonline.com/doi/abs/10.1080/10584600591006492 [accessed 20/07/2018].

22 Woolf, N. (2016) As fake news takes over Facebook feeds, many are taking satire as fact, The Guardian. https://www.theguardian.com/media/2016/nov/17/facebook-fake-news-satire [accessed 01/04/2018].

23 Abad-Santos, A. (2012). The Onion Convinces Actual Chinese Communists that Kim Jong-Un is Actually the Sexiest Man Alive, The Atlantic. https://www.theatlantic.com/entertainment/archive/2012/11/onion-convinces-actual-chinese-communists-kim-jong-un-actually-sexiest-man- alive/321126/ [accessed 28/03/2018].

ត្រឹមតែមាតិការបស់ «អ្នកក្លែងបន្លំ» ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ប៉ះពាល់ដល់ទំនុកចិត្តលើវិជ្ជាជីវៈសារព័ត៌មានផងដែរ[24]។ ហេតុដូច្នេះហើយបានជាអ្នកសារព័ត៌មានគួរតែខិតខំប្រឹងប្រែង និងប្តេជ្ញាចិត្តធ្វើយ៉ាងណាឱ្យសេចក្តីរាយការណ៍របស់គេមានភាពត្រឹមត្រូវតាំងពីដំបូងទីទៅ។ ទន្ទឹមនឹងនេះ វាក៏ជាហេតុផលរឹងមាំផងដែរ ដើម្បីឱ្យសង្គមត្រូវផ្តល់អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន[25]ដល់អ្នកប្រើប្រាស់ ដើម្បីពួកគេអាចយល់ដឹងច្បាស់លាស់ និងមានការត្រិះរិះពិចារណាអំពីប្រភេទ និងសន្ទតិកម្មដែលវិវត្តជុំវិញប្រព័ន្ធផ្សព្វផ្សាយដំណឹង ការផ្សាយពាណិជ្ជកម្ម ការកម្សាន្ត និងប្រព័ន្ធផ្សព្វផ្សាយសង្គម។

ប្រវត្តិសាស្ត្រក៏បង្រៀនយើងដែរថា កម្លាំងនៅពីក្រោយព័ត៌មានមិនពិត គឺមិនរំពឹងអូសទាញអ្នកសារព័ត៌មាន ឬមហាជនឱ្យជឿទៅលើការអះអាងក្លែងបន្លំនោះទេ ប៉ុន្តែគេបង្កើតឱ្យមានមន្ទិលសង្ស័យទៅលើស្ថានភាពនៃព័ត៌មាន ដែលអាចផ្ទៀងផ្ទាត់បាន ដែលផលិតដោយអ្នកផលិតដំណឹងវិជ្ជាជីវៈ។ ភាពច្របូកច្របល់នេះមានន័យថា អ្នកប្រើប្រាស់ដំណឹងជាច្រើនមានអារម្មណ៍ថា ពួកគេកាន់តែមានសិទ្ធិជ្រើសរើស ឬបង្កើត «ការពិត» ដោយខ្លួនឯង ដែលពេលខ្លះទទួលបានការជួយជំរុញពីអ្នកនយោបាយដែលព្យាយាមការពារខ្លួនពីការរិះគន់ស្របច្បាប់។

យើងត្រឡប់មកមើលឆ្នាំ២០១៨ និងការសាយភាយនៃឧបករណ៍បច្ចេកវិទ្យាថ្មីៗដ៏មានឥទ្ធិពលវិញម្តង។ ឧបករណ៍ទាំងនេះ រួមជាមួយប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីផ្ញើសារ ដែលមិនសូវមានបទដ្ឋានគ្រប់គ្រងគុណភាពសម្រាប់កំណត់ថាអ្វីជាដំណឹង ហើយវាធ្វើឱ្យកាន់តែងាយស្រួលថែមទៀតសម្រាប់ការចម្លងតាមស្ថាប័នដំណឹងស្របច្បាប់ ដើម្បីធ្វើឱ្យអ្វីដែលបន្លំបោកប្រាស់មើលទៅដូចជារបស់ពិត។ ជាមួយគ្នានេះដែរ គេក៏អាចកែកុនសំឡេង និងវីដេអូតាមវិធីផ្សេងៗលើសពីក្បួនខ្នាតនៃការកែសម្រួលដំណឹងត្រឹមត្រូវតាមច្បាប់ ដើម្បីធ្វើឱ្យវាមើលទៅដូចជាបុគ្គលណាម្នាក់បាននិយាយ ឬបានធ្វើអ្វីមួយនៅកន្លែងណាមួយ រួចហើយផ្សព្វផ្សាយចេញទៅដូចជាការថតពិត[26] និងធ្វើឱ្យរឿងនោះរីកសាយភាយនៅក្នុងប្រព័ន្ធទំនាក់ទំនងសង្គម។

សព្វថ្ងៃ ប្រព័ន្ធផ្សព្វផ្សាយសង្គមមានការរុញច្រានពីរឿងរ៉ាវច្រើនប្រភេទ រាប់តាំង

---

24 សូមពិនិត្យមើលមេរៀនទី៣

25 សូមពិនិត្យមើលមេរៀនទី៤

26 Solon, O (2017) The future of fake news: Don’t believe everything you see, hear or read in The Guardian: https://www.theguardian.com/technology/2017/jul/26/fake-news-obama-video-trump-face2face-doctored-content [accessed 20/07/2018].

ពីរឿងផ្ទាល់ខ្លួនរហូតដល់រឿងនយោបាយ។ មានឧទាហរណ៍នៃរឿងរ៉ាវជាច្រើន ដែលបង្កើតឡើងជាចំហ ឬដោយលាក់កំបាំង ដោយរដ្ឋាភិបាល និង/ឬក្រុមហ៊ុនទំនាក់ទំនងសាធារណៈ ដែលចុះកិច្ចសន្យាជាមួយតួអង្គនយោបាយឬតួអង្គពាណិជ្ជកម្ម។ ជាលទ្ធផល អ្នកសរសេរប្លុក «អ្នកមានឥទ្ធិពល» នៅលើបណ្ដាញ Instagram និងតារា YouTube ជាច្រើនរាប់មិនអស់ ផ្សព្វផ្សាយពាណិជ្ជកម្មឱ្យផលិតផល និងអ្នកនយោបាយ ដោយមិនបានបង្ហាញថាគេបានទទួលប្រាក់កម្រៃដើម្បីធ្វើកិច្ចការទាំងនោះ។ អ្នកធ្វើអត្ថាធិប្បាយមួយចំនួន (ដែលជារឿយៗប្រើអត្តសញ្ញាណក្លែងក្លាយ) ក៏បានទទួលប្រាក់កម្រៃដើម្បីបញ្ជាក់ បង្ខូចកេរ្តិ៍ឈ្មោះ ឬបំភិតបំភ័យនៅលើវេទិកាអ៊ីនធឺណិតដែរ។ នៅក្នុងស្ថានភាពបែបនេះ សារព័ត៌មានបាត់បង់លំនឹង ហើយមិនត្រឹមតែក្លាយជាកម្មវត្ថុនៃការរិះគន់ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកម្មវត្ថុនៃការវាយប្រហារ និងផ្ដួលរំលំដែរ។

ឥឡូវនេះ គ្រោះថ្នាក់គឺជាការអភិវឌ្ឍយ៉ាងលឿនដូចការប្រណាំងសព្វាវុធ (arms race) នៃព័ត៌មានមិនពិតទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ តាមរយៈអង្គភាព«ដំណឹង» ដែលប្រកាន់បក្សនយោបាយ និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលបំពុលបរិស្ថានព័ត៌មានសម្រាប់គ្រប់ភាគី ក្នុងលក្ខណៈមួយដែលអាចវិលត្រឡប់មកលងអ្នកផ្ដើមគំនិតខ្លួនឯងវិញ[27]។ នៅទីណាដែលមានការបកអាក្រាតយុទ្ធនាការព័ត៌មានមិនពិត លទ្ធផលគឺការខូចខាតធ្ងន់ធ្ងរចំពោះអ្នកដែលពាក់ព័ន្ធ ទាំងទីភ្នាក់ងារអនុវត្ត ទាំងក្រុមអ្នកទទួលសារនយោបាយ (សូមមើល Bell-Pottinger[28] [29] [30] [31] និង Cambridge Analytica)[32] [33] នាពេលថ្មីៗនេះ។

27 Winseck, D (2008). Information Operations 'Blowback': Communication, Propaganda and Surveillance in the Global War on Terrorism.International Communication Gazette 70 (6), 419-441

28 The African Network of Centers for Investigative Journalism, (2017). The Guptas, Bell Pottinger and the fake news propaganda machine, Time Live. https://www.timeslive.co.za/news/south-africa/2017-09-04-the-guptas-bell-pottinger-and-the-fake-news-propaganda-machine/ [accessed29/03/2018].

29 Cameron, J. (2017) Dummy's guide: Bell Pottinger – Gupta London agency, creator of WMC, BizNews https://www.biznews.com/global- citizen/2017/08/07/dummys-guide-bell-pottinger-gupta-wmc [accessed 29/03/2018] and Segal, D. (2018) How Bell Pottinger, P.R. Firm for Despots and Rogues, Met Its End in South Africa. New York Times, 4 Feb 2018. https://www.nytimes.com/2018/02/04/business/bell-pottinger- guptas-zuma-south-africa.html [accessed 29/03/2018].

30 Haffajee, F. (2017). Ferial Haffajee: The Gupta fake news factory and me. Huff Post South Africa. [online] Availableat:https://www.huffingtonpost.co.za/2017/06/05/ferial-haffajee-the-gupta-fake-news-factory-and-me_a_22126282/ [accessed 06/04/2018].

31 សូមមើលមេរៀនទី៧

32 Lee, G. (2018). Q&A on Cambridge Analytica: The allegations so far, explained, FactCheck, Channel 4 News. https://www.channel4.com/news/factcheck/cambridge-analytica-the-allegations-so-far [accessed 29/03/2018].

33 Cassidy, J. (2018). Cambridge Analytica Whistle blower claims that cheating swung the Brexit vote, The New Yorker. https://www.newyorker.com/news/our-columnists/a-cambridge-analytica-whistleblower-claims-that-cheating-swung-the-brexit-vote [accessed29/03/18].

ផលវិបាកនៃបញ្ហាទាំងអស់នេះគឺថា ព័ត៌មានមិនពិតដែលរុញច្រានដោយប្រព័ន្ធឌីជីថលនៅក្នុងបរិបទនៃការប្រកាន់បក្សពួកនេះ អាចនឹងធ្វើឱ្យបាត់បង់តួនាទីរបស់សារព័ត៌មាន។ លើសពីនេះទៅទៀត វិជ្ជាជីវៈសារព័ត៌មានអាជីពដែលមានការផ្ទៀងផ្ទាត់ត្រឹមត្រូវ និងជាប្រយោជន៍សាធារណៈ អាចនឹងបាត់បង់តម្លៃ និងទំនុកចិត្តនៅពេលដែលគ្មានវិធានការបង្ការជាមុន ដើម្បីបញ្ចៀសការដែលត្រូវគេយកទៅប្រើប្រាស់មិនត្រឹមត្រូវ។ នៅពេលដែលសារព័ត៌មានក្លាយជាភ្នាក់ងារចម្លងព័ត៌មានមិនពិត វានឹងកាត់បន្ថយទំនុកចិត្តសាធារណៈ ហើយជំរុញឱ្យមានការសង្ស័យដែលថាគ្មានអ្វីដែលខុសគ្នាទេរវាងការពិពណ៌នានៅក្នុងសារព័ត៌មានវិជ្ជាជីវៈ និងការពិពណ៌នាព័ត៌មានមិនពិត។ ដោយមូលហេតុនេះហើយ ទើបយើងលើកយកប្រវត្តិសាស្ត្រជុំវិញការប្រើប្រាស់រឿងរ៉ាវប្រជែងគ្នា និងទម្រង់ផ្សេងៗនៃការប្រើប្រាស់ទាំងនោះមកធ្វើជាទឡ្ហីករណ៍សម្រាប់ការណែនាំ។ ការយល់ដឹងអំពីដំណើរវិវត្តន៍ច្រើនជ្រុងនៃ «ព័ត៌មានច្របូកច្របល់» ក្នុងសតវត្សរ៍ទី២១នេះអាចជួយឱ្យអ្នកយល់កាន់តែច្បាស់ថែមទៀតអំពីបុព្វហេតុ និងផលវិបាកនៃការគំរាមកំហែងជាសកល ដែលមិនធ្លាប់មានពីមុនមក ជាការគំរាមកំហែងមួយដែលមានតាំងពីការបៀតបៀនអ្នកសារព័ត៌មានពីសំណាក់ «ពួកអ្នកបញ្ជើចបញ្ជើ» ក្រោមការគ្រប់គ្រងពីរដ្ឋ រហូតដល់ការបន្លំក្នុងការបោះឆ្នោត ការធ្វើឱ្យខូចខាតដល់សុខភាពសាធារណៈ និងការមិនព្រមទទួលស្គាល់ហានិភ័យនៃបម្រែបម្រួលអាកាសធាតុ។

## សៀវភៅដែលជួយទប់ទល់នឹងវិបត្តិនៃព័ត៌មានមិនពិត

សៀវភៅនេះបែងចែកជាពីរផ្នែកខុសដាច់ពីគ្នា ក្នុងលក្ខណៈជាកម្មវិធីសិក្សា៖ មេរៀនបីដំបូងពន្យល់អំពីបញ្ហា និងបរិបទនៃបញ្ហា ចំណែកឯមេរៀនបួនបន្ទាប់ទៀតផ្តោតលើការឆ្លើយតបចំពោះ «ព័ត៌មានច្របូកច្របល់» និងផលវិបាកនៃបញ្ហានោះ។

មេរៀនទី១ *ហេតុអ្វីបានជា ការពិត ទំនុកចិត្ត និងវិជ្ជាជីវៈសារព័ត៌មាន មានសារៈសំខាន់?*[34] នឹងលើកទឹកចិត្តដល់ការគិតក្នុងន័យទូលំទូលាយ អំពីសារៈសំខាន់ និងផលវិបាកនៃព័ត៌មានមិនពិត និងព័ត៌មានខុស ព្រមទាំងរបៀបដែលបញ្ហាទាំងនេះបង្កើតឱ្យមានវិបត្តិទំនុកចិត្តទៅលើសារព័ត៌មាន។

មេរៀនទី២ *ការគិតអំពី «ព័ត៌មានច្របូកច្របល់» ៖ ទម្រង់នៃ «ព័ត៌មានខុស និងព័ត៌មានមិនពិត»*[35] ដោះស្រាយបញ្ហា និងផ្តល់ក្របខ័ណ្ឌសម្រាប់ការស្វែងយល់អំពីទំហំនៃបញ្ហា។

---

34 សូមពិនិត្យមើលមេរៀនទី១

35 សូមពិនិត្យមើលមេរៀនទី២

នៅសតវត្សរ៍ទី២១នេះ ទំនុកចិត្តដ៏ផុយស្រួយលើប្រព័ន្ធផ្សព្វផ្សាយបានធ្លាក់ចុះនៅក្នុងកន្លែងជាច្រើននៃពិភពលោក មុនពេលដែលកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមបានចូលប្រឡូកនៅលើឆាកដំណឹង ដោយផ្តល់នូវលំហ និងឧបករណ៍ចែករំលែកព័ត៌មានដល់មនុស្សគ្រប់រូប[36]។ ហេតុផលទាំងអស់នេះមានលក្ខណៈខុសៗគ្នា និងស្មុគស្មាញ។ ពិភពអ៊ីនធឺណិត២៤ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ដែលមានតម្រូវការដំណឹងមិនចេះស្កប់ ក្នុងពេលដែលការិយាល័យដំណឹងបានផ្លាស់ប្តូរវិជ្ជាជីវៈសារព័ត៌មាន ដូចដែលពន្យល់លម្អិតនៅក្នុងមេរៀនទី៣ *ការវិវត្តនៃឧស្សាហកម្មដំណឹង៖ បច្ចេកវិទ្យាឌីជីថល ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការសាយភាយព័ត៌មានខុស និងព័ត៌មានមិនពិត*[37]។ បច្ចុប្បន្ននេះ សហគ្រាស និងដំណឹងបោកប្រាស់ដែលសាយភាយនៅលើអ៊ីនធឺណិត បានបង្កើតជាវិបត្តិថ្មីមួយទៀតសម្រាប់វិជ្ជាជីវៈសារព័ត៌មាន បង្កឱ្យមានផលវិបាកចំពោះអ្នកសារព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ និងសង្គម[38]។

ដូច្នេះ តើអ្នកដែលលើកកម្ពស់សារព័ត៌មាន រួមទាំងអ្នកអប់រំ អ្នកអនុវត្ត និងអ្នកធ្វើគោលនយោបាយប្រព័ន្ធផ្សព្វផ្សាយ គួរឆ្លើយតបយ៉ាងដូចម្តេច? *ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងព័ត៌មានខុស តាមរយៈអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន*[39] គឺជាប្រធានបទនៃមេរៀនទី៤។

នៅទីបំផុត គឺវិន័យនៃការផ្ទៀងផ្ទាត់ការពិតនេះហើយ ដែលញែកសារព័ត៌មានវិជ្ជាជីវៈដាច់ចេញពីសារព័ត៌មានប្រភេទដទៃទៀត[40] ហើយប្រធានបទមួយនេះគឺជាការផ្តោតសំខាន់របស់មេរៀនទី៥ *ការផ្ទៀងផ្ទាត់៖ ការផ្ទៀងផ្ទាត់ការពិត ១០១* [41]។ មេរៀនទី៦ *ការផ្ទៀងផ្ទាត់ប្រព័ន្ធផ្សព្វផ្សាយសង្គម៖ វាយតម្លៃប្រភព និងមាតិការូបភាព*[42] មានសារៈប្រយោជន៍ណាស់ ដោយផ្តោតទៅលើភាពប្រឈមនៃ វិជ្ជាជីវៈសារព័ត៌មានដែលផ្អែកលើការផ្ទៀងផ្ទាត់ និងភស្តុតាង ដែលបានបង្កើតឡើងដោយបច្ចេកវិទ្យាឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយសង្គម។

នៅក្នុងដំណើរនៃការផ្តល់លទ្ធភាពឱ្យមនុស្សគ្រប់គ្នា អាចចូលរួមជាផ្នែកមួយនៃ

---

36 Edelman. (2017). 2017 Edelman Trust Barometer-Global Results. Available at https://www.edelman.com/global-results/[accessed 03/04/2018].

37 សូមមើលមេរៀនទី៣

38 Viner, K. (2017). A mission for journalism in a time of crisis. [online] The Guardian. Available at https://www.theguardian.com/news/2017/nov/16/a-mission-for-journalism-in-a-time-of-crisis [accessed03/04/2018].

39 សូមមើលមេរៀនទី៤

40 Kovach, B. & Rosenstiel, T. (2014). The elements of journalism: What news people should know and the public should expect. New York: Crown Publishers.

41 សូមមើលមេរៀនទី៥

42 សូមមើលមេរៀនទី៦

ការផលិតដំណឹង ប្រព័ន្ធផ្សព្វផ្សាយសង្គមបានធ្វើឱ្យបាត់បង់ឆ្មាំទ្វារអព្យាក្រឹត[43]។ វិជ្ជាជីវៈសារព័ត៌មានកំពុងទទួលរងផលវិបាក ប៉ុន្តែដូចគ្នានឹងការផ្លាស់ប្តូរដែលជំរុញដោយបច្ចេកវិទ្យានានាដែរ គេត្រូវការពេលវេលាដើម្បីវាយតម្លៃវាស់វែង និងធ្វើផែនការឆ្លើយតប។ ដំណើរយឺតយ៉ាវនឹងកើតឡើងដោយជៀសមិនផុត នៅមុនពេលការស្រាវជ្រាវ និងគំរូអនុវត្តល្អៗលេចរូបរាងឡើង។

ព័ត៌មានមិនពិតជាបញ្ហាសកលមួយ ដែលគ្របដណ្តប់លើសពីវិស័យនយោបាយ និងរាលដាលទៅលើគ្រប់ទិដ្ឋភាពនៃដំណឹងដោយរួមទាំងការប្រែប្រួលអាកាសធាតុ ការកម្សាន្ត។ល។ ប៉ុន្តែ គិតមកទល់បច្ចុប្បន្ន ករណីសិក្សាជាច្រើនដែលបានចងក្រងជាឯកសារ ការឆ្លើយតបបឋម និងការផ្គត់ផ្គង់ហិរញ្ញវត្ថុដំណាក់កាលដំបូងៗសម្រាប់ការស្រាវជ្រាវ និងឧបករណ៍នានា គឺមានប្រភពចេញពីសហរដ្ឋអាមេរិក ដែលជាសំបុករបស់ក្រុមហ៊ុនបច្ចេកវិទ្យាធំៗជាងគេនៅលើពិភពលោក ហើយការចោទប្រកាន់របស់ប្រធានាធិបតីសហរដ្ឋអាមេរិក លោក Donald Trump ដែលថាស្ថាប័នដំណឹង និងអ្នកសារព័ត៌មានជាអ្នកគាំទ្រ «ដំណឹងក្លែងក្លាយ» បានបំផុសឱ្យរង្គោះរង្គើសកម្មភាព និងការផ្តល់មូលនិធិ។

ទិដ្ឋភាពជាសកលកំពុងវិវត្តជារៀងរាល់ថ្ងៃ ជាពិសេសក្នុងការឆ្លើយតបពីសំណាក់រដ្ឋនីមួយៗ មានរដ្ឋជាច្រើនកំពុងពិចារណាការធ្វើច្បាប់ និងបទប្បញ្ញត្តិដើម្បីដោះស្រាយបញ្ហានេះ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនបច្ចេកវិទ្យាធំៗក៏បានបង្កើនកិច្ចប្រឹងប្រែងក្នុងការព្យាយាមកម្ចាត់ព័ត៌មានខុស និងព័ត៌មានមិនពិតចេញពីកម្មវិធីរបស់ពួកគេ។

ខណៈដែលសៀវភៅនេះស្ថិតនៅក្នុងដំណាក់កាលរៀបរៀងឡើង គណៈកម្មការអឺរ៉ុបបានចេញផ្សាយរបាយការណ៍មួយ[44] ដោយផ្អែកលើការស៊ើបអង្កេត[45] ចំពេលដែលមានក្តីបារម្ភថា ព័ត៌មានមិនពិត និងព័ត៌មានខុស បង្កើតផលប៉ះពាល់អវិជ្ជមានដល់សង្គមទាំងមូល[46]។ អ្នកនយោបាយ និងស្ថាប័នគោលនយោបាយសាធារណៈនៅក្នុងបណ្តាប្រទេសនីមួយៗ រាប់តាំងពីអូស្ត្រាលី រហូតដល់ហ្វីលីពីន កាណាដា

43 Colón, A. (2017). You are the new gatekeeper of the news. [online] The Conversation. Available at https://theconversation.com/you-are-the- new-gatekeeper-of-the-news-71862 [accessed 03/04/2018].

44 European Commission (2018). Final report of the High-Level Expert Group on Fake News and Online Disinformation. http://ec.europa.eu/newsroom/dae/document.cfm?doc_id=50271 [accessed 03/04/2018].

45 European Commission (2017). Next steps against fake news: Commission sets up High-Level Expert Group and launches public consultation. [online] Available at http://europa.eu/rapid/press-release_IP-17-4481_en.htm [accessed03/04/2018].

46 Ansip, A. (2017). Hate speech, populism and fake news on social media–towards an EU response. Available at https://ec.europa.eu/commission/commissioners/2014-2019/ansip/announcements/statement-vice-president-ansip-european-parliament-strasbourg-plenary- debate-hate-speech-populism_en[accessed03/04/2018].

បារាំង ចក្រភពអង់គ្លេស ប្រេស៊ីល ឥណ្ឌា និងឥណ្ឌូនេស៊ី បានពិចារណារកវិធីទប់ទល់នឹងបញ្ហានេះ[47]។ ប្រទេសអាល្លឺម៉ង់បានចាត់វិធានការមុនគេបង្អស់ ដោយអនុម័តច្បាប់ថ្មីមួយដែលដាក់ពិន័យយ៉ាងធ្ងន់ធ្ងរនៅក្នុងរយៈពេល ២៤ ម៉ោងបន្ទាប់ពីជូនដំណឹង[48] ចំពោះកម្មវិធីឌីជីថលណាដែលមិនព្រមលុបចោល «មាតិកាខុសច្បាប់» ក្នុងនោះរាប់បញ្ចូលទាំង «ដំណឹងក្លែងក្លាយ» និងពាក្យសម្តីញុះញង់ឱ្យមានការស្អប់ខ្ពើម។ រដ្ឋសភារបស់ប្រទេសម៉ាឡេស៊ី ក៏បានអនុម័តច្បាប់ប្រឆាំងដំណឹងក្លែងក្លាយ នៅខែមេសា ឆ្នាំ២០១៨ដែរ ប៉ុន្តែត្រូវលុបចោលវិញនៅខែសីហាឆ្នាំដដែល[49]។ បញ្ជីបច្ចុប្បន្នភាពនៃការឆ្លើយតបរបស់រដ្ឋនានា ត្រូវបានចងក្រងដោយវិទ្យាស្ថាន Poynter[50]។

ក្រុមអ្នកតស៊ូមតិដើម្បីសេរីភាពក្នុងការបញ្ចេញមតិ ភ័យខ្លាចថាច្បាប់នេះនឹងប៉ះពាល់ដល់ព័ត៌មាន និងការបញ្ចេញមតិតាមបែបប្រជាធិបតេយ្យ ដែលបច្ចេកវិទ្យាថ្មីៗបានផ្តល់លទ្ធភាពឱ្យ។ នៅក្នុងប្រទេសមួយចំនួន ច្បាប់អាចត្រូវគេប្រើប្រាស់ដើម្បីបំបិទមាត់សារព័ត៌មានដែលរិះគន់[51]។

ចំពោះអ្នកសារព័ត៌មានជាច្រើនដែលជឿជាក់ខ្លាំង ទៅលើសេរីភាពបញ្ចេញមតិ និងបានចាត់ទុកខ្លួនឯងជាតួអង្គគាំទ្រដ៏សំខាន់ នៅក្នុងសង្គមប្រជាធិបតេយ្យ[52] ការទប់ទល់នឹង «ព័ត៌មានច្របូកច្របល់» គឺជាដំណើរការដ៏ស្មុគស្មាញ។ រឿងនេះក៏ជាបញ្ហាបុគ្គលដែរ។ ការវាយប្រហារតាមអ៊ីនធឺណិតទៅលើអ្នកសារព័ត៌មាន ជាពិសេសស្ត្រី កើតមានញឹកញាប់ណាស់ ហើយនៅក្នុងករណីជាច្រើន ការវាយប្រហារទាំងនោះបង្កគ្រោះថ្នាក់ផ្លូវកាយ និងផ្លូវចិត្ត និងគំរាមកំហែងដល់វិជ្ជាជីវៈសារព័ត៌មាន ដូចមានការលើកឡើងលម្អិតនៅក្នុងមេរៀនទី៧ *ការប្រយុទ្ធប្រឆាំងនឹងការរំលោភ*

47 Malloy, D. (2017). How the world's governments are fighting fake news. [online] ozy.com. Available at http://www.ozy.com/politics-and- power/how-the-worlds-governments-are-fighting-fake-news/80671 [accessed03/04/2018].

48 Federal Ministry of Justice and Consumer Protection. (2017). Act to Improve Enforcement of the Law in Social Networks (Network Enforcement Act, netzdg). [online]. Available at: http://www.bmjv.de/DE/Themen/fokusthemen/netzdg/_documents/netzdg_englisch.html[accessed03/04/2018].

49 Malaysia scraps 'fake news' law used to stifle free speech. The Guardian. https://www.theguardian.com/world/2018/aug/17/malaysia-scraps- fake-news-law-used-to-stifle-free-speech [accessed18/08/2018].

50 Funke, D. (2018). A guide to anti-misinformation actions around the world (Poynter). Available at https://www.poynter.org/news/guide-anti- misinformation-actions-around-world [accessed13/07/2018].

51 Nossel, S. (2017). FAKING NEWS: Fraudulent News and the Fight for Truth. [ebook] PENAmericaAvailableathttps://pen.org/wp-content/uploads/2017/10/PEN-America_Faking-News-Report_10-17.pdf [accessed 03/04/2018].

52 McNair, B. (2009). Journalism and Democracy. In: K. Wahl-Jorgensen and T. Hanitzsch, ed., Handbook of Journalism Studies, 6th ed. [online] New York: Routledge

*បំពាននៅតាមអ៊ីនធឺណិត ៖ នៅពេលដែលអ្នកសារព័ត៌មាន និងប្រភពរបស់ពួកគេក្លាយជាគោលដៅនៃការរំលោភបំពាន*[53]។

ព័ត៌មានមិនពិត និងព័ត៌មានខុស ជះឥទ្ធិពលលើសពីការធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ និងសុវត្ថិភាពរបស់អ្នកសារព័ត៌មាន។ ព័ត៌មានទាំងនោះក៏បង្កើតឱ្យមានមន្ទិលសង្ស័យទៅលើគោលបំណង និងប្រសិទ្ធភាពរបស់អ្នកសារព័ត៌មានដែរ ហើយមិនតែប៉ុណ្ណោះក៏ធ្វើឱ្យខូចឈ្មោះដល់វិជ្ជាជីវៈសារព័ត៌មាន ដែលនាំឱ្យប៉ះពាល់អវិជ្ជមានទៅដល់ការជជែករឿងសង្គមថែមទៀតផង។ ការកែលម្អបទដ្ឋាន និងទំនាក់ទំនងសង្គម គឺជាប្រយោជន៍ដល់អ្នកសារព័ត៌មាននាពេលអនាគត និងសង្គមទាំងមូល។ សៀវភៅនេះនឹងជំរុញអ្នកស្រាវជ្រាវ និស្សិត និងអ្នកប្រកបវិជ្ជាជីវៈសារព័ត៌មានឱ្យគិតគូរពិចារណា និងពិភាក្សាអំពីរបៀបដែលសារព័ត៌មាន អាចបម្រើសង្គមបើកចំហ និងលទ្ធិប្រជាធិបតេយ្យឱ្យបានកាន់តែប្រសើរឡើង នៅក្នុងបរិបទថ្មីនេះ ពីព្រោះ ៖

> «*សារព័ត៌មាន និងលទ្ធិប្រជាធិបតេយ្យដែលដំណើរការទៅបាន គឺទាមទារឱ្យមានការរិះគន់ តម្លាភាព និងផលវិបាកសម្រាប់កំហុសផ្នែកសារព័ត៌មាន។ ដំណើរការនេះក៏តម្រូវឱ្យយើងមានសមត្ថភាពញែកសារព័ត៌មាន និងលទ្ធិប្រជាធិបតេយ្យឱ្យដាច់ពីគ្នាពីការកុហក និងការបោកប្រាស់។ បើមិនដូច្នេះទេ ដំណឹងពិតនឹងត្រូវគេលាបពណ៌ទៅជាព័ត៌មានមិនពិត ហើយជាព័ត៌មាន (បែបសំរាម) ដែលគេប្រឌិតឡើង ប្រែទៅជាការពិតទៅវិញ។*»
>
> Craig Silverman[54]

## កំណត់សម្គាល់អំពីក្រមសីលធម៌ និងស្វ័យនិយ័តកម្ម

បទដ្ឋានវិជ្ជាជីវៈសម្រាប់សារព័ត៌មានដែលមានក្រមសីលធម៌ និងគណនេយ្យភាព គឺជាការការពារដ៏សំខាន់ប្រឆាំងនឹងព័ត៌មានមិនពិត និងព័ត៌មានខុស។ ក្រឹត្យក្រម និងគុណតម្លៃដែលផ្តល់ការណែនាំដល់អ្នកដែលប្រកបវិជ្ជាជីវៈសារព័ត៌មាន បានវិវត្តជាហូរហែក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ ដោយផ្តល់ដល់វិជ្ជាជីវៈសារព័ត៌មាន

53 សូមមើលមេរៀនទី៧

54 Silverman, C. (2018). I Helped Popularize The Term “Fake News” And Now I Cringe Every Time I Hear It. Buzz Feed. Available at https://www.buzzfeed.com/craigsilverman/i-helped-popularize-the-term-fake-news-and-now-i-cringe [accessed 03/04/2018].

នូវបេសកកម្ម និងវិធីសាស្ត្រជាក់លាក់។ ជាលទ្ធផល បេសកកម្ម និងវិធីសាស្ត្រទាំងនេះការពារដល់ព័ត៌មានដែលផ្ទៀងផ្ទាត់ត្រឹមត្រូវ និងការពិពណ៌នាគ្រប់ជ្រុងជ្រោយ ដែលចែករំលែកដើម្បីប្រយោជន៍សាធារណៈ។ កត្តាទាំងអស់នេះហើយដែលគាំទ្រដល់ភាពអាចជឿជាក់បាននៃវិជ្ជាជីវៈសារព័ត៌មាន។ ដូច្នេះកត្តាទាំងនេះត្រូវបានច្របាច់បញ្ចូលគ្នាក្នុងសៀវភៅនេះ។

នៅក្នុងបរិបទនេះ ប្រសាសន៍របស់សាស្ត្រាចារ្យ Charlie Beckett មកពីសាលាសេដ្ឋកិច្ចទីក្រុងឡុងដ៍ សង្ខេបយ៉ាងល្អអំពីសក្ដានុពលនៃវិបត្តិ «ដំណឹងក្លែងក្លាយ» ចំពោះសារព័ត៌មាន យ៉ាងដូច្នេះ ៖

> *«...ដំណឹងក្លែងក្លាយ គឺជារឿងល្អបំផុតដែលបានកើតឡើងអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ វាផ្ដល់ឱកាសដល់សារព័ត៌មានអាជីព ដើម្បីបង្ហាញថា សារព័ត៌មានមានគុណតម្លៃដោយឈរលើជំនាញ ក្រមសីលធម៌ ការចូលរួម និងបទពិសោធន៍។ វាជាការដាស់តឿនឱ្យសារព័ត៌មានកាន់តែមានតម្លាភាព ភាពពាក់ព័ន្ធ និងត្រូវផ្ដល់គុណតម្លៃបន្ថែមដល់ជីវិតរស់នៅរបស់ប្រជាជន។ ដំណឹងក្លែងក្លាយនេះទៀតសោត អាចជំរុញឱ្យមានការអភិវឌ្ឍគំរូធុរកិច្ចថ្មី នៃការត្រួតពិនិត្យការពិត ការទម្លាយអាថ៌កំបាំង និងជាទូទៅការធ្វើសកម្មភាពរួមគ្នាដើម្បីផ្ដល់ដំណោះស្រាយចំពោះការក្លែងបន្លំ។»*[55]

ទោះបីខំប្រឹងប្រែងធ្វើខ្លួនជា «អ្នកប្រាប់ការពិត» ប៉ុណ្ណាក៏ដោយ ក៏អ្នកសារព័ត៌មានមិនអាចតែងតែធានា «ការពិត» បានជានិច្ចនោះឡើយ។ ទោះជាយ៉ាងនេះក្ដី ការខំប្រឹងប្រែងប្រមូលការពិតឱ្យបានត្រឹមត្រូវ និងការផលិតនូវមាតិកាដែលឆ្លុះបញ្ចាំងភាពត្រឹមត្រូវអំពីការពិត គឺជាគោលការណ៍ដ៏សំខាន់បំផុតនៃវិជ្ជាជីវៈសារព័ត៌មាន។ ប៉ុន្តែ តើវិជ្ជាជីវៈសារព័ត៌មានដែលមានក្រមសីលធម៌មានរូបរាងយ៉ាងដូចម្ដេច នៅក្នុងយុគសម័យឌីជីថលនេះ?

វិជ្ជាជីវៈសារព័ត៌មានប្រកបដោយក្រមសីលធម៌ ដែលឱ្យតម្លៃទៅលើការអនុវត្តប្រកបដោយតម្លាភាព និងគណនេយ្យភាព គឺជាគ្រឿងសព្វាវុធដ៏សំខាន់នៅក្នុងសមរភូមិការពារការពិតក្នុងយុគសម័យនៃ «ព័ត៌មានច្របូកច្របល់»នេះ។ អ្នកសារព័ត៌មានត្រូវតែជាសំឡេងដែលឯករាជ្យ។ ក្នុងន័យនេះ អ្នកសារព័ត៌មានមិនត្រូវធ្វើសកម្មភាព ទោះជាផ្លូវការក្ដី ឬមិនផ្លូវការក្ដី តំណាងឱ្យក្រុមផលប្រយោជន៍ពិសេសណាឡើយ។

55 Beckett, C. (2017). 'Fake news': The best thing that's happened to Journalism at Polis. http://blogs.lse.ac.uk/polis/2017/03/11/fake-news-the- best-thing-thats-happened-to-journalism/ [accessed 04/03/2018].

ចំណុចនេះក៏មានន័យដែរថា អ្នកសារព័ត៌មានត្រូវតែទទួលស្គាល់ និងប្រកាសជាសាធារណៈ អំពីអ្វីៗដែលអាចជាទំនាស់ផលប្រយោជន៍ ដើម្បីបង្ហាញតម្លាភាព។ ដូចដែលសាស្រ្តាចារ្យ Emily Bell មកពីមជ្ឈមណ្ឌលសារព័ត៌មានឌីជីថល នៃសកលវិទ្យាល័យកូឡុំប៊ី បានពន្យល់គុណតម្លៃស្នូលរបស់សារព័ត៌មានដែលមានវិជ្ជាជីវៈគឺ៖

*«ធានាថា ដំណឹងត្រូវមានភាពសុក្រឹត មានទំនួលខុសត្រូវប្រសិនបើដំណឹងនោះមិនសុក្រឹត មានតម្លាភាពអំពីប្រភពនៃរឿង និងព័ត៌មាន ត្រូវប្រឈមចំពោះមុខរដ្ឋាភិបាល ដាក់សម្ពាធក្រុមនានា ផលប្រយោជន៍ពាណិជ្ជកម្ម ប៉ូលិស ប្រសិនបើពួកគេបំភិតបំភ័យ គំរាមកំហែង ឬចាប់ពិរុទ្ធលើរូបអ្នក។ ការពារប្រភពរបស់អ្នកពីការចាប់ខ្លួន និងការបញ្ចេញអត្តសញ្ញាណ។ ដឹងថានៅពេលណាដែលអ្នកទទួលបានការការពារដ៏ខ្លាំងពីប្រយោជន៍សាធារណជនដើម្បីបំពានច្បាប់ និងហ៊ានត្រៀមខ្លួនចូលពន្ធនាគារ ដើម្បីការពាររឿង និងប្រភពព័ត៌មានរបស់អ្នក។ ដឹងខ្លួនថាពេលណាជាការខ្វះសីលធម៌ក្នុងការផ្សាយរឿងអ្វីមួយ។ ត្រូវថ្លឹងថ្លែងរវាងសិទ្ធិឯកជនរបស់បុគ្គល និងសិទ្ធិទូលំទូលាយនៃផលប្រយោជន៍សាធារណជន។»*[56]

នៅចំពោះមុខនយោបាយទុច្ចរិតវិបត្តិនៃ «ព័ត៌មានច្របូកច្របល់» ការបង្ហាញអំពីការស្អប់ខ្ពើមនៅលើអ៊ីនធឺណិត ការសាយភាយនៃ «មាតិកាឃោសនាទីផ្សារ» ការផ្សាយពាណិជ្ជកម្ម និងយុទ្ធនាការទំនាក់ទំនងសាធារណៈដែលបម្រើប្រយោជន៍ផ្ទាល់ខ្លួន ស្ថាប័នដំណឹង និងអ្នកសារព័ត៌មានគួរតែនៅប្រកាន់ខ្ជាប់ដដែល នូវការលើកកម្ពស់ និងការពារសារព័ត៌មានដែលមានក្រមសីលធម៌ ជាសសរកន្លោងសម្រាប់គំរូនៃការអនុវត្តវិជ្ជាជីវៈសារព័ត៌មានដែលមាននិរន្តរភាព បើទោះបីត្រូវប្រឈមនឹងវិបត្តិហិរញ្ញវត្ថុ និងវិបត្តិទំនុកចិត្តយ៉ាងណាក៏ដោយ។ ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យក៏ដូចគ្នាដែរ គួរតែមានតួនាទីមួយនៅក្នុងការការពារវិជ្ជាជីវៈសារព័ត៌មាន និងអ្នកសារព័ត៌មាន និងប្រភពរបស់ពួកគេ ដើម្បីបុព្វហេតុប្រយោជន៍សាធារណៈ។

ក្រមសីលធម៌[57] ដែលបង្កើតឡើងដើម្បីគាំទ្រការប្រមូល និងការផ្ទៀងផ្ទាត់ព័ត៌មាន

56 Bell, E. (2015). Hugh Cudlipp Lecture (Full text), The Guardian https://www.theguardian.com/media/2015/jan/28/emily-bells-2015-hugh- cudlipp-lecture-full-text [accessed 01/04/2018].

57 Australian Media, Entertainment and Arts Alliance’s ‘Journalist Code of Ethics’. Available at: https://www.meaa.org/meaa-media/code-of-ethics/ [accessed: 04/03/2018].

ដើម្បីជាប្រយោជន៍សាធារណៈ គឺជាចំណុចញែកសារព័ត៌មាន ជាពិសេសការរាយការណ៍ដំណឹង ឱ្យដាច់ចេញពីប្រភេទសារគមនាគមន៍ដទៃទៀត។ ក្រមសីលធម៌នេះកាន់តែមានសារៈសំខាន់ខ្លាំងថែមទៀត នៅក្នុងយុគសម័យឌីជីថល ពីព្រោះវាមិនត្រឹមជាយុគសម័យនៃសារគមនាគមន៍បែបប្រជាធិបតេយ្យប៉ុណ្ណោះនោះទេ ប៉ុន្តែវាក៏ជាយុគសម័យនៃការរីករាលដាលព័ត៌មានមិនពិត ព័ត៌មានខុស ការឃោសនាកុហកបោកប្រាស់ និងការរំលោភបំពានដែរ។ នៅក្នុងបរិបទនេះ សារព័ត៌មានដែលប្រកាន់ក្រមសីលធម៌កាន់តែមានសារៈសំខាន់ខ្លាំងថែមទៀត ក្នុងការផ្តល់ក្របខ័ណ្ឌសម្រាប់ការបង្កើតគំរូវិជ្ជាជីវៈសារព័ត៌មានគាំទ្រទំនុកចិត្ត និងគណនេយ្យភាព ដើម្បីជាប្រយោជន៍ដល់ការកសាងទំនាក់ទំនងដែលមានការចូលរួមប្រកបដោយអត្ថន័យជាមួយក្រុមគោលដៅ។

ទំនុកចិត្តលើសេចក្តីរាយការណ៍ដែលត្រឹមត្រូវ មានគណនេយ្យភាព និងឯករាជ្យ គឺជាកត្តាសំខាន់ចាំបាច់ដើម្បីទទួលបានការគាំទ្រពីក្រុមគោលដៅ និងផ្តល់លទ្ធភាពដល់មជ្ឈដ្ឋានមហាជន ដើម្បីជជែកពិភាក្សាគ្នាដោយឈរលើការពិតដូចគ្នា។ អ្នកប្រើប្រាស់ដែលទទួលបានដំណឹងគ្រប់ជ្រុងជ្រោយ ហើយចូលរួម និងចែករំលែកមាតិកាដែលអាចជឿជាក់បាន គឺជាថ្នាំបន្សាបដ៏សំខាន់សម្រាប់ព័ត៌មានមិនពិត និងព័ត៌មានខុស។

ដើម្បីបញ្ជ្រាប និងពង្រឹងការអនុវត្តគុណតម្លៃស្នូលទាំងនេះ នៅក្នុងបរិស្ថានប្រព័ន្ធផ្សព្វផ្សាយដែលកំពុងប្រែប្រួល ការិយាល័យដំណឹង និងស្ថាប័នផ្សព្វផ្សាយទទួលយក និងកែសម្រួលក្រមសីលធម៌ ព្រមទាំងបង្កើតយន្តការសម្រាប់សាធារណជនតាមដានការអនុវត្តរបស់ខ្លួន។ ក្រុមប្រឹក្សាសារព័ត៌មាន ការីនិពន្ធរបស់មិត្តអ្នកអានគោលការណ៍និពន្ធ និងអធិការកិច្ចផ្ទៃក្នុង គឺជាយន្តការខ្លះនៃរចនាសម្ព័ន្ធស្វ័យនិយ័តកម្ម។ រចនាសម្ព័ន្ធស្វ័យនិយ័តកម្មទាំងនេះ ជួយឱ្យគេអាចកំណត់ឃើញកំហុសនៅក្នុងបរិបទផ្ទៀងផ្ទាត់ប្រកបដោយវិជ្ជាជីវៈ អាចសម្របសម្រួលការទទួលស្គាល់កំហុសជាសាធារណៈ និងទាមទារឱ្យមានការកែតម្រូវ ព្រមទាំងអាចជួយពង្រឹងការអនុវត្តក្រឹត្យក្រមវិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងបទដ្ឋាននៃការផ្សព្វផ្សាយដើម្បីប្រយោជន៍សាធារណៈ។ ជារឿយៗ បើទោះបីអ្នករិះគន់ដែលចង់ឱ្យមាននិយ័តកម្មពីខាងក្រៅប្រព័ន្ធផ្សព្វផ្សាយដំណឹង ចំអកឱ្យថាជា «ខ្លាអត់ធ្មេញ» ក៏រចនាសម្ព័ន្ធទាំងនេះ បម្រើគោលបំណងសំខាន់មួយ នៅក្នុងបរិបទវិបត្តិព័ត៌មានមិនពិត ៖ រចនាសម្ព័ន្ធទាំងនេះជួយពង្រឹងគណនេយ្យភាព និងតម្លាភាពវិជ្ជាជីវៈ

និងអាចពង្រឹងទំនុកចិត្តរបស់សហគមន៍មកលើសារព័ត៌មាន។ រចនាសម្ព័ន្ធទាំងនេះ ក៏ជួយបង្ហាញឱ្យឃើញច្បាស់នូវលក្ខណៈខុសប្លែករបស់វិជ្ជាជីវៈសារព័ត៌មាន ដែលប្រកាន់យកនូវវិន័យក្នុងការផ្ទៀងផ្ទាត់ ដើម្បីធានាភាពត្រឹមត្រូវ និងភាពអាចជឿជាក់បាន ដោយញែកសារព័ត៌មានដាច់ចេញឆ្ងាយពីការផ្សាយព័ត៌មានមិនពិត ការឃោសនា ការផ្សាយពាណិជ្ជកម្ម និងទំនាក់ទំនងសាធារណៈ។

## ពី«អ្នកសារព័ត៌មាន» ទៅ «វិជ្ជាជីវៈសារព័ត៌មាន»

នៅពេលដែលក្រមសីលធម៌សារព័ត៌មានត្រូវបានគេបង្ខាំងចំពោះអាជីវកម្ម ឬជំនួញ (ទោះបីមិនមានការគោរពពេញលេញក៏ដោយ) នៃអាជីពមួយ ឬមុខរបរ/ វិជ្ជាជីវៈមួយ បានក្លាយជាប្រវត្តិសាស្ត្រ។ ហើយចំណុចនេះមានការទទួលស្គាល់យ៉ាងទូលំទូលាយ ក្នុងនោះរួមទាំងអង្គការសហប្រជាជាតិ ដូចជារបាយការណ៍ឆ្នាំ២០១៧ របស់អគ្គលេខាធិការ ស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន A/72/290[58] ដែលថ្លែងថា៖

*«ពាក្យ «អ្នកសារព័ត៌មាន» រាប់បញ្ចូលទាំងអ្នកសារព័ត៌មានជាច្រើន និងទាំងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។ និយមន័យពាក្យសារព័ត៌មានត្រូវបានកំណត់ក្នុងឯកសារ CCPR/C/GC/34 កថាខណ្ឌ៤៤ ដែលមានន័យថា «មុខងារមួយដែលចែករំលែកដោយតួអង្គច្រើន ក្នុងនោះរាប់ទាំងអ្នករាយការណ៍ដំណឹង និងអ្នកវិភាគវិជ្ជាជីវៈដែលធ្វើការពេញម៉ោង និងអ្នកសរសេរប្លុក (bloggers) និងអ្នកដទៃទៀតដែលចូលរួមនៅក្នុងទម្រង់ផ្សេងៗនៃការបោះពុម្ពផ្សាយដោយខ្លួនឯង ជាក្រដាសក្តី នៅលើអ៊ីនធឺណិតក្តី ឬនៅកន្លែងផ្សេងទៀតក្តី»[59]។*

នៅក្នុងស្មារតីដូចគ្នានេះដែរ មហាសន្និបាតរបស់អង្គការយូណេស្កូ បានសំដៅលើ «អ្នកសារព័ត៌មាន បុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ និងផលិតករប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលបង្កើតនូវមាតិកាសារព័ត៌មានក្នុងបរិមាណច្រើនគួរសម ទាំងនៅលើបណ្តាញអ៊ីនធឺណិត (online) និងនៅក្រៅបណ្តាញអ៊ីនធឺណិត (offline)» (សេចក្តីសម្រេចលេខ៣៩ ខែវិច្ឆិកា ឆ្នាំ២០១៧)[60]។ ផែនការសកម្មភាពអង្គការសហប្រជាជាតិ

58 Available at https://digitallibrary.un.org/record/1304392?ln=en [accessed on 16/06/2018].

59 See also UN documents A/HRC/20/17, paras. 3-5, A/HRC/20/22 and Corr.1, para. 26, A/HRC/24/23, para. 9, A/HRC/27/35, para. 9, A/69/268, para. 4, and A/HRC/16/44 and Corr.1, para. 47.

60 Records of the General Conference. 39th session. Paris, 30 October–14 November 2017. http://unesdoc.unesco.org/images/0026/002608/260889e.pdf[accessed 02/07/2018].

ស្តីពីសុវត្ថិភាពអ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព ដែលអនុម័តដោយគណៈកម្មាធិការនាយកប្រតិបត្តិរបស់អង្គការសហប្រជាជាតិ កាលពីឆ្នាំ២០១២ បានកត់សម្គាល់ថា៖ «ការការពារអ្នកសារព័ត៌មាន មិនគួរកំណត់សម្រាប់តែមនុស្សដែលគេទទួលស្គាល់ជាផ្លូវការថាជាអ្នកសារព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែត្រូវរួមបញ្ចូលអ្នកផ្សេងទៀត ដូចជាបុគ្គលិកផ្សព្វផ្សាយដំណឹងសហគមន៍ ព្រមទាំងអ្នកសារព័ត៌មានប្រជាពលរដ្ឋ និងអ្នកផ្សេងទៀតដែលអាចនឹងប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបែបថ្មី ជាមធ្យោបាយសម្រាប់ការផ្សព្វផ្សាយទៅដល់ក្រុមគោលដៅរបស់ខ្លួន»[61]។

ក្នុងន័យនេះ សារព័ត៌មានអាចត្រូវគេមើលឃើញថាជាសកម្មភាពមួយ ដែលណែនាំដោយបទដ្ឋានក្រមសីលធម៌នៃការផ្ទៀងផ្ទាត់ព័ត៌មាន និងចែករំលែកដើម្បីជាប្រយោជន៍សាធារណៈ។ អ្នកដែលអះអាងថាប្រកបវិជ្ជាជីវៈសារព័ត៌មានអាចពង្រីកនិយមន័យលើសពីអ្នកដែលជាអ្នកសារព័ត៌មានអាជីព នៅក្នុងន័យជាមុខរបរ ខណៈដែលមនុស្សធ្វើការជាអ្នកសារព័ត៌មានដើម្បីប្រាក់ខែ ឬអ្នកដែលត្រូវបានកំណត់ថាជាអ្នកសារព័ត៌មាន សំដៅលើអ្នកដែលអាចផលិតមាតិកាសារព័ត៌មានដែលត្រឹមត្រូវ យុត្តិធម៌ មានវិជ្ជាជីវៈ និងឯករាជ្យដើម្បីប្រយោជន៍សាធារណៈផង។ អ្វីដែលសំខាន់ មិនមែនស្ថិតនៅលើឋានៈផ្លូវការ ឬឋានៈដែលអះអាងនោះទេ ប៉ុន្តែស្ថិតនៅលើចរិតលក្ខណៈរបស់ខ្លួនក្នុងការផលិតមាតិកាសារព័ត៌មានឡើង។

ក្នុងពេលដែលសារព័ត៌មានឈរលើការប្រើប្រាស់សេរីភាពបញ្ចេញមតិ ដែលនោះជាសិទ្ធិរបស់បុគ្គលគ្រប់រូប វាក៏ជាលំហាត់ឯកទេសដោយប្រកាន់ខ្ជាប់នូវបទដ្ឋានជាក់លាក់ដែលធ្វើឱ្យសារព័ត៌មានលេចធ្លោ ខុសពីទម្រង់នៃការបញ្ចេញមតិផ្សេងទៀត (ឧ. កំណាព្យ ទំនាក់ទំនងសាធារណៈ ការផ្សាយពាណិជ្ជកម្ម ព័ត៌មានមិនពិត ។ល។)។ បទដ្ឋានទាំងនេះ មានចំណងយ៉ាងជិតស្និទ្ធជាមួយនឹងក្រមសីលធម៌នៃការអនុវត្តសារព័ត៌មានវិជ្ជាជីវៈ។

## តើតម្លាភាពគឺជាសត្យានុម័តថ្មីមែនទេ?

សត្យានុម័ត (Objectivity) អាចមានន័យច្រើនយ៉ាង។ នៅក្នុងន័យដែលផ្ទុយពីអត្តនោម័ត ពាក្យ «សត្យានុម័ត» ជាប្រធានបទមួយដែលចម្រូងចម្រាសនៅក្នុងសារព័ត៌មានវិជ្ជាជីវៈ។ គេអាចព្យាយាមប្រឹងប្រែងដើម្បីសត្យានុម័ត ប៉ុន្តែកម្រនឹង

61 UN Plan of Action on the Safety of Journalists and the Issue of Impunity. 1CI-12/CONF.202/6 https://en.unesco.org/sites/default/files/un-plan- on-safety-journalists_en.pdf [accessed 03/11/2017].

សម្រេចបានណាស់ ហើយសត្យានុម័តក៏មិនមែនសុទ្ធតែគួរឱ្យចង់បានគ្រប់ពេលនោះទេ នៅចំពោះមុខភាពឃោរឃៅ ឬអមនុស្សធម៌ (ឧទាហរណ៍ ការរាយការណ៍ដែលយុត្តិធម៌ និងឯករាជ្យនឹងមិនផ្តល់ទំនុកចិត្តលើការអះអាងរបស់ជនដែលត្រូវគេកាត់ទោសពីបទប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ឱ្យស្មើគ្នានឹងការជឿជាក់លើការអះអាងរបស់ជនដែលរស់រានពីឧក្រិដ្ឋកម្មសង្គ្រាមឡើយ។ ទោះជាយ៉ាងណា ជនដែលរស់រានពីអំពើឧក្រិដ្ឋកម្មសង្គ្រាម នៅក្នុងឧទាហរណ៍នេះ មិនគួររួចផុតពីការស៊ើបអង្កេតទៅលើសច្ចភាពនៃឧក្រិដ្ឋកម្មទាំងនេះឡើយ។ ប៉ុន្តែយុត្តិធម៌ ឯករាជ្យភាព ភាពត្រឹមត្រូវតាមបរិបទ តម្លាភាព ការការពារប្រភពសម្ងាត់ និងការចេះថ្លឹងថ្លែង[62]នៅក្នុងការធ្វើសេចក្តីរាយការណ៍ បង្កើតបានជាទំនុកចិត្ត និងភាពជឿជាក់។

នៅឆ្នាំ២០០៩ អ្នកស្រាវជ្រាវមកពីសកលវិទ្យាល័យ Harvard លោកបណ្ឌិត David Weinberger បានប្រកាសថា «តម្លាភាពគឺជាសត្យានុម័តថ្មី»[63]។ នៅឆ្នាំដដែលនោះ អតីតនាយកផ្នែកដំណឹងពិភពលោករបស់ BBC លោក Richard Sambrook បានពន្យល់ថា គឺតម្លាភាពទេដែលផ្តល់នូវជំនឿទុកចិត្តនៅក្នុង «យុគសម័យប្រព័ន្ធផ្សព្វផ្សាយថ្មី» មិនមែនសត្យានុម័តឡើយ៖

> *«...ដំណឹងសព្វថ្ងៃនេះនៅតែត្រូវមានភាពត្រឹមត្រូវ និងយុត្តិធម៌ដដែល ប៉ុន្តែសំខាន់ដូចគ្នាដែរ គឺត្រូវឱ្យក្រុមគោលដៅ និងអ្នកទស្សនា មើលឃើញរបៀបផលិតដំណឹង តើព័ត៌មានបានមកពីណា និងតើវាមានដំណើរការយ៉ាងដូចម្តេច។ ដំណើរលេចជារូបរាងឡើងនៃដំណឹងគឺសំខាន់ដូចគ្នានឹងការផ្តល់ដំណឹងដែរ។»*[64]

## ចំណុចដែលខុសគ្នា

ធាតុផ្សំសំខាន់ៗនៃការអនុវត្តសារព័ត៌មានវិជ្ជាជីវៈ ដែលបានរៀបរាប់ខាងលើ មិនមែនមានន័យថា មានសារព័ត៌មានតែមួយទម្រង់ប៉ុណ្ណោះនោះទេ។ វត្ថុបំណងទាំងនេះអាចសម្រេចបាននៅក្នុងបែបផែន និងរឿងសារព័ត៌មានផ្សេងៗគ្នា ដោយ

62 សូមមើលគោលការណ៍សំខាន់នៅមេរៀនបន្ទាប់

63 Weinberger, D. (2009). Transparency is the new objectivity. http://www.hyperorg.com/blogger/2009/07/19/transparency-is-the-new- objectivity/ [accessed 28/03/2018].

64 Bunz, M. (2009). How Social Networking is Changing Journalism. https://www.theguardian.com/media/pda/2009/sep/18/oxford-social-media- convention-2009-journalism-blogs [accessed 28/03/2018].

បែបផែននីមួយៗបង្កប់នូវរបៀបពណ៌នារឿងខុសៗគ្នា ដែលផ្អែកលើគុណតម្លៃខុសៗគ្នា និងទស្សនៈផ្សេងៗគ្នានៃយុត្តិធម៌ ភាពស្របនឹងបរិបទពិតដែលពាក់ព័ន្ធ។ល។ ឧទាហរណ៍ អង្គភាពសារព័ត៌មានអាចនឹងមានការយល់ឃើញខុសៗគ្នាទៅលើដំណឹង ឬដំណឹងអ្វីមួយ (អង្គភាពខ្លះមិនទាំងរវល់ជាមួយនឹងរឿងនោះផង) ដោយមិនឃ្លាតឆ្ងាយពីគោលបំណង «ដំណឹងដើម្បីពាណិជ្ជកម្ម» ទៅចូលក្នុងដែននៃការផ្សាយព័ត៌មានមិនពិត និងព័ត៌មានខុស (សូមមើលជំពូកបន្ទាប់ អំពីការប្រើប្រាស់សៀវភៅនេះជាកម្មវិធីសិក្សាគំរូ និងមើលមេរៀនទី១ ទី២ និងទី៣)។ ប៉ុន្តែនៅពេលដែលមាតិកាឃ្លាតចាកពីគោលការណ៍វិជ្ជាជីវៈសារព័ត៌មាន និងជាពិសេស នៅពេលដែលមាតិកានោះនៅតែបង្ហាញខ្លួនជាដំណឹងដដែល គឺនៅពេលនោះយើងលែងដោះស្រាយរឿងសារព័ត៌មានទៀតហើយ ប៉ុន្តែដោះស្រាយទម្រង់មួយនៃការផ្សាយព័ត៌មានមិនពិតទៅវិញ។

ជំពូកអំពីសេចក្ដីផ្ដើមនេះ បានលើកយកមកបង្ហាញនូវបញ្ហាជាច្រើន ដែលមាននៅក្នុងកិច្ចពិភាក្សាអំពី «ដំណឹងក្លែងក្លាយ» ដោយផ្ដល់នូវបរិបទសម្រាប់ការបំភ្លឺ ការវិភាគ និងការរៀនសូត្រមេរៀនក្រោយៗបន្តបន្ទាប់ទៀត។

# ប្រើប្រាស់សៀវភៅនេះជាកម្មវិធីសិក្សាគំរូ

Julie Posetti

វគ្គសិក្សានេះប្រើគំរូគរុកោសល្យបែបរៀនសូត្រ តាមរយៈការស្វែងយល់ដោយខ្លួនឯង[1] មានន័យថា អ្នកប្រើប្រាស់សៀវភៅនេះ ត្រូវបានលើកទឹកចិត្តឱ្យយកបទពិសោធន៍របស់ខ្លួនមកចូលរួមនៅក្នុងដំណើរការនៃការរៀន ឬបង្រៀន។ មេរៀនទាំងអស់នេះមិនមែនជាបញ្ញត្តិនោះទេ ប៉ុន្តែអាចនិងគួរតែយកទៅកែសម្រួលដើម្បីឱ្យត្រូវទៅនឹងបរិបទជាតិ វប្បធម៌ ស្ថាប័ន និងបរិបទជាក់លាក់នៃការបង្រៀននិងការសិក្សា។ បើទោះជាមានការខិតខំប្រឹងប្រែង ដើម្បីធ្វើឱ្យមេរៀនទាំងនេះមានភាពទាក់ទាញជាសកលក៏នៅមានដែនកំណត់ជាច្រើននៅឡើយ។ អ្នកនិពន្ធលើកទឹកចិត្តដល់អ្នកអប់រំ អ្នកបណ្តុះបណ្តាល និងអ្នកចូលរួម ឱ្យដាក់បញ្ចូលករណីសិក្សា ឧទាហរណ៍ និងប្រភពនានាដែលបានផ្តល់នៅក្នុងសៀវភៅនេះ ជាមួយគ្នានឹងករណីសិក្សា និងឧទាហរណ៍ដែលឆ្លុះបញ្ចាំងនូវបទពិសោធន៍នៅក្នុងតំបន់របស់ខ្លួនផ្ទាល់ និងជាភាសារបស់ខ្លួនផ្ទាល់។

សូមចងចាំចំណុចខាងលើនេះ ហើយវិធីដើម្បីប្រើប្រាស់សៀវភៅនេះ មានរៀបរាប់ដូចខាងក្រោម៖

- ជាវគ្គ/មុខវិជ្ជាគ្រប់ជ្រុងជ្រោយ ដែលអនុវត្តសម្រាប់កម្រិតឧត្តមសិក្សា/ជំនាញផ្នែកសារព័ត៌មាន សារគមនាគមន៍ ប្រព័ន្ធផ្សព្វផ្សាយឌីជីថល ឬការសិក្សាប្រព័ន្ធផ្សព្វផ្សាយ។ គេអាចប្រើសៀវភៅនេះ សម្រាប់ជាមុខវិជ្ជាបន្ទាប់បន្សំ នៅក្នុងមុខវិជ្ជាសិក្សានយោបាយ និងសង្គមវិទ្យា ដែលទាក់ទងនឹងបញ្ហាប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍។

- ជាធនធានបន្ថែមទៅលើវគ្គសិក្សា/មុខវិជ្ជាដែលមានស្រាប់ (ឧ. ប្រវត្តិសាស្ត្រប្រព័ន្ធផ្សព្វផ្សាយ ក្រមសីលធម៌ប្រព័ន្ធផ្សព្វផ្សាយ ការរកប្រភពនិងការផ្ទៀងផ្ទាត់ ការរិះគន់ប្រព័ន្ធផ្សព្វផ្សាយ ការអនុវត្តប្រព័ន្ធផ្សព្វផ្សាយឌីជីថល សារព័ត៌មានសង្គម)។ ករណីសិក្សា ឯកសារបាឋកថា និងអំណានជាច្រើនអាចដាក់បញ្ចូលទៅក្នុងវគ្គសិក្សា/មុខវិជ្ជាដែលមានស្រាប់ ជាមធ្យោបាយនៃការធ្វើបច្ចុប្បន្នភាពមាតិកា ដើម្បីដោះស្រាយវិបត្តិនៃព័ត៌មានមិនពិតដែលកំពុងរាលដាលយ៉ាងលឿន។

1 Banda, F (Ed) 2015 Teaching Journalism for Sustainable Development: New Syllabi (UNESCO, Paris http://unesdoc.unesco.org/images/0023/002338/233878e.pdf) [accessed: 28/03/2018].

➢ ជាមុខវិជ្ជាដាច់តែឯង ឬជាវគ្គសិក្សាស៊ីជម្រៅសម្រាប់អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានដទៃទៀត ដោយអង្គភាពសារព័ត៌មាន ស្ថាប័ន ឬទីភ្នាក់ងារអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយ។

➢ ជាសៀវភៅបណ្ដុះបណ្ដាល៖ អ្នកបណ្ដុះបណ្ដាលសារព័ត៌មានអាចនឹងយកមេរៀនទាំងនេះ ទៅកែសម្រួលឱ្យត្រូវនឹងគោលបំណងរបស់ខ្លួន ដោយពឹងផ្អែកលើបញ្ជីនៃឯកសារ អំណាន និងករណីសិក្សានានាសម្រាប់ការដាក់បញ្ចូលបន្ថែម ឱ្យក្លាយជាកម្រងធនធានចំគោលដៅសម្រាប់ក្រុមអ្នកសារព័ត៌មាន។

➢ ជាប្រធានបទសម្រាប់ការសរសេរអត្ថបទឯករាជ្យ ជាភាគបន្តបន្ទាប់ទៀត ដែលរៀបចំដោយស្ថាប័នដែលធ្វើការក្នុងវិស័យនេះ អង្គភាពសារព័ត៌មាន ឬទីភ្នាក់ងារអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយ ជាផ្នែកនៃការអនុវត្តការចែករំលែកចំណេះដឹង។

➢ ជាធនធានអំណានសម្រាប់អ្នកសារព័ត៌មានអាជីព ដើម្បីពង្រីកនិងពង្រឹងបញ្ញាស្មារតី និងការអភិវឌ្ឍវិជ្ជាជីវៈ។ ជាក់ស្ដែង បច្ចេកទេសជាច្រើនដែលបានបង្ហាញនៅក្នុងសៀវភៅនេះ អាចយកទៅប្រើប្រាស់នៅក្នុងការរាយការណ៍ដំណឹង តាមរយៈ «ការសិក្សាដែលតម្រង់ទិសដោយខ្លួនឯង»។ ករណីសិក្សាខ្លះ ក៏អាចជាប្រធានបទសម្រាប់ការធ្វើសេចក្ដីរាយការណ៍កាន់តែទំនើបថែមទៀត ដោយក្នុងនោះគំនិតរឿងក្នុងស្រុកមួយចំនួន អាចយកទៅធ្វើការវិភាគ ដោយមានការបង្ហាញភ័ស្ដុតាងបរិបទស្មុគស្មាញបន្ថែមទៀត (ឧ. រឿងស្ដីពីការបោកប្រាស់មួយ ដែលបានធ្វើឱ្យអ្នកសារព័ត៌មានក្នុងស្រុកភ័ន្តច្រឡំ អាចយកទៅធ្វើសេចក្ដីរាយការណ៍នៅក្នុងបរិបទប្រវត្តិនៃព័ត៌មានបោកប្រាស់ជាលក្ខណៈអន្តរជាតិ រួមជាមួយនឹងការផ្ដោតសំខាន់លើការវិវត្តថ្មីៗ នៅក្នុងការផ្សព្វផ្សាយដ៏រាលដាលនៃព័ត៌មានមិនពិត និងព័ត៌មានខុស តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម)។

➢ ជាគ្រឹះនៃឯកសារអំណាន ធនធាន និងឧបករណ៍ ដែលបង្កើតឡើងដើម្បីរីកចម្រើន ក្នុងពេលដែលការស្រាវជ្រាវ និងការអនុវត្តនៅក្នុងវិស័យនេះកាន់តែរីកធំ។

## គោលការណ៍ស្នូល

ដោយមានការគាំទ្រដោយតម្លាភាពក្នុងដំណើរការ និងការអនុវត្តបទដ្ឋានក្រមសីលធម៌ច្បាស់លាស់ តួនាទីដែលលេចធ្លោនៃវិជ្ជាជីវៈសារព័ត៌មានបច្ចុប្បន្ន គឺស្ថិតនៅលើសមត្ថភាពរបស់ខ្លួន ក្នុងការរួមចំណែកបង្កើតភាពច្បាស់លាស់ និងកសាងទំនុកចិត្តនៅជុំវិញសាច់រឿងដែលត្រូវបានផ្ទៀងផ្ទាត់។ គោលការណ៍ទាំង៧ចំណុចខាងក្រោមនេះ ដែលផ្តោតលើក្រមសីលធម៌ជាមូលដ្ឋាន គួរតែផ្តល់ទិសដៅដល់ការអនុវត្តវគ្គសិក្សានេះ និងជាការណែនាំដល់ការធ្វើលំហាត់ ការពិភាក្សា និងការវាយតម្លៃ[2] ៖

- **ភាពត្រឹមត្រូវ៖** អ្នកសារព័ត៌មានមិនអាចធានា«ការពិត»បានជានិច្ចនិរន្តរ៍នោះទេ ប៉ុន្តែភាពត្រឹមត្រូវ និងការផ្តល់ការពិត នៅតែជាគោលការណ៍ដ៏សំខាន់នៃសារព័ត៌មាន។

- **ភាពឯករាជ្យ៖** អ្នកសារព័ត៌មានត្រូវតែជាសំឡេងឯករាជ្យ។ នេះមានន័យថា ទោះផ្លូវការក្តី ឬមិនផ្លូវការក្តី គេមិនធ្វើសកម្មភាពជំនួសមុខឱ្យក្រុមផលប្រយោជន៍ពិសេសណាមួយឡើយ និងមិនត្រូវប្រកាសឱ្យដឹងអំពីអ្វីមួយដែលអាចជាទំនាស់ផលប្រយោជន៍ទេ ដើម្បីតម្លាភាព។

- **យុត្តិធម៌៖** ការរាយការណ៍ដោយយុត្តិធម៌អំពីព័ត៌មាន ព្រឹត្តិការណ៍ ប្រភព និងរឿងរ៉ាវរបស់ប្រភពមានទាក់ទងនឹងការពិនិត្យជិតដល់ ការថ្លឹងថ្លែង និងការវាយតម្លៃព័ត៌មាន ដោយបើកចិត្តទូលាយ និងមានភាពវាងវៃ។ ការផ្តល់បរិបទ និងបង្ហាញនូវទស្សនៈចម្រុះជួយកសាងនូវទំនុកចិត្ត និងការជឿជាក់មកលើសេចក្តីរាយការណ៍។

- **រក្សាការសម្ងាត់៖** គោលការណ៍គ្រឹះមួយនៃសារព័ត៌មានស៊ើបអង្កេត គឺការការពារប្រភពសម្ងាត់ (មានករណីលើកលែងតិចតួចបំផុត)។ គោលការណ៍នេះសំខាន់ណាស់ សម្រាប់ការរក្សាទំនុកចិត្តរបស់ប្រភពព័ត៌មាន (ក្នុងនោះរាប់ទាំងអ្នកលួចបង្ហើបការសម្ងាត់ដែរ) ហើយ

2 សំគាល់៖ គោលការណ៍៥ ក្នុងចំនោមគោលការណ៍៧ ដែលបានលើកយកមកពិភាក្សានៅក្នុងបណ្តាញសារព័ត៌មានក្រមសីលធម៌ ‘Five Core Principles of Journalism’ http:// ethicaljournalismnetwork.org/who-we-are/5-principles-of-journalism [accessed 22/4/2018]. ទោះបីជាយ៉ាងណាក៏ដោយ យុត្តិធម៌ត្រូវបានគេពេញចិត្តជាងភាពលំអៀង ដោយសារតែភាពលំអៀងត្រូវលាយបញ្ចូលជាមួយសត្យានុម័ត ហើយវាត្រូវបានយល់ច្រឡំថា ប្រភពទាំងអស់ និងការពិតត្រូវថ្លឹងថ្លែងស្មើៗគ្នា។ នេះជាគំនិតដែលមានបញ្ហាសម្រាប់ហេតុផលដូចគ្នាដែរថា សត្យានុម័តគឺជាគំនិតប្រកួតប្រជែងក្នុងសារព័ត៌មាន។

ក្នុងករណីខ្លះ គោលការណ៍នេះធានាសុវត្ថិភាពរបស់ប្រភពព័ត៌មានទាំងនោះ[3]។

- **គុណតម្លៃមនុស្សជាតិ៖** ដំណឹងដែលអ្នកសារព័ត៌មានចុះផ្សាយ ឬផ្សព្វផ្សាយ អាចបង្កការឈឺចាប់ (ឧ. ភាពអាម៉ាស់ដែលអ្នកនយោបាយពុករលួយម្នាក់ទទួលរង នៅពេលដែលត្រូវបានបកអាក្រាតដោយសារព័ត៌មានស៊ើបអង្កេត) ប៉ុន្តែផលប៉ះពាល់នៃវិជ្ជាជីវៈសារព័ត៌មានទៅលើជីវិតរបស់អ្នកដទៃត្រូវតែពិចារណា។ ផលប្រយោជន៍សាធារណៈ គឺជាគោលការណ៍ជួយតម្រង់ទិសនៅក្នុងចំណុចនេះ[4]។ មនុស្សជាតិក៏មានន័យថា ជាការគិតគូរពិចារណាអំពីបញ្ហាដែលប្រឈមដោយក្រុមជនខ្វះលទ្ធភាពដែរ ប្រសិនបើមិនគិតច្រើនរហូតទៅដល់ការអនុវត្តសារព័ត៌មាន ដែលផ្តោតលើយុត្តិធម៌សង្គមទេនោះ។

- **គណនេយ្យភាព៖** គឺជាសញ្ញាដ៏ពិតប្រាកដនៃវិជ្ជាជីវៈ និងសារព័ត៌មានដែលមានក្រមសីលធម៌[5] ដោយការកែកំហុសបន្ទាន់ ឱ្យច្បាស់លាស់ និងស្មោះត្រង់។ គោលការណ៍នេះ ក៏ជាការស្តាប់ក្តីកង្វល់របស់ក្រុមគោលដៅ[6] និងការឆ្លើយតបចំពោះក្តីកង្វល់ទាំងនោះដែរ។ ការអនុវត្តបែបនេះ អាចបង្ហាញឱ្យគេឃើញ នៅក្នុងកំណត់ហេតុណែនាំរបស់អង្គភាពសារព័ត៌មាន និងស្ថាប័នស្វ័យនិយ័តកម្ម ដែលបង្ខំឱ្យសារព័ត៌មានត្រូវមានគណនេយ្យភាពផ្អែកលើក្រមសីលធម៌វិជ្ជាជីវៈដោយស្ម័គ្រចិត្ត។

- **តម្លាភាព៖** នៅក្នុងការអនុវត្តជាក់ស្តែង គឺគាំទ្រដល់គណនេយ្យភាព និងជួយនៅក្នុងការបង្កើតឱ្យមាន និងរក្សាបាននូវទំនុកចិត្តទៅលើវិជ្ជាជីវៈសារព័ត៌មាន[7]។

នៅក្នុងបរិបទនេះ រួមជាមួយភាពឯករាជ្យនៃវិជ្ជាជីវៈសារព័ត៌មាន បញ្ហាសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយ និងពហុភាពក៏សំខាន់ដូចគ្នាដែរ។ ពហុភាពនៃស្ថាប័ន

3 Posetti, J. (2017). Protecting Journalism Sources in the Digital Age (UNESCO) http://unesdoc.unesco.org/images/0024/002480/248054E.pdf [accessed 28/03/2018].

4 For a new ethical model applying empathy in the Digital Era see: Shelton, A. G., Pearson, M. & Sugath, S. (2017) Mindful Journalism and News Ethics in the Digital Era: A Buddhist Approach. Routledge, London. https://www.crcpress.com/Mindful-Journalism-and-News-Ethics-in- the-Digital-Era-A-Buddhist-Approach/Gunaratne-Pearson-Senarath/p/book/9781138306066 [accessed 01/04/2018].

5 Available at http://ethicaljournalismnetwork.org/what-we-do/accountable-journalism [accessed 22/4/2018].

6 Locker, K. & Kang, A. (2018). Focused listening can help address journalism's trust problem, at American Press Institute. https://ww w.americanpressinstitute.org/publications/focused-listening-trust/ [accessed 28/03/2018].

7 Aronson-Rath, R. (2017). Transparency is the antidote to fake news on NiemanLab, December 2017 http://www.niemanlab.org/2017/12/transparency-is-the-antidote-to-fake-news/ [accessed 15/06/2018].

ក៏ដូចជាភាពទីទៃពីគ្នានៃបុគ្គលិក ប្រភព និងឯកសារស្រាវជ្រាវ មានភាពចាំបាច់ណាស់ ប្រសិនបើវិជ្ជាជីវៈសារព័ត៌មានទាំងមូល ត្រូវរួមចំណែកក្នុងលទ្ធិប្រជាធិបតេយ្យ និងនិរន្តរភាពនៃសង្គមបើកចំហ។ ប្រព័ន្ធផ្សព្វផ្សាយបែបចូលរួម ដូចជាវិទ្យុសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គមក៏សំខាន់ដែរក្នុងការធានាថា សំឡេងរបស់ក្រុមជនដែលគ្មានតំណាង ឬក្រុមជនដែលខ្វះលទ្ធភាព មិនត្រូវបានគេផាត់ចោលនៅក្នុងការផលិតដំណឹង។ ពហុភាពក៏មានន័យដែរថា ជាការទទួលស្គាល់សុពលភាពនៃប្រភេទពិណ៌នា ក្នុងការអនុវត្តសារព័ត៌មានដែលមានក្រមសីលធម៌ទន្ទឹមគ្នានឹងការកំណត់មុខសញ្ញាព័ត៌មានមិនពិត ការឃោសនា និងប្រភេទមាតិកាផ្សេងទៀតដែលស្ថិតនៅក្រៅបទដ្ឋានវិជ្ជាជីវៈ។ (សូមមើលមេរៀនទី១ ទី២ និងទី៣)។

## សំណួរសម្រាប់ការពិចារណា

ការពិភាក្សាណាមួយអំពីការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន ដែលមានក្រមសីលធម៌នៅក្នុងពិភពលោកមួយដែល ព័ត៌មានមិនពិត ព័ត៌មានខុស និងការឃោសនាកំពុងរីករាលដាល អាចចាប់ផ្តើមដោយការពិចារណាសំណួរដូចខាងក្រោម៖

- តើវិជ្ជាជីវៈសារព័ត៌មានជាអ្វីពិតប្រាកដ នៅក្នុងយុគសម័យឌីជីថលនេះ? (នេះជាសំណួរមួយដែលរុញច្រានកិច្ចសន្ទនាពីសំណួរ «តើអ្នកសារព័ត៌មានជាអ្នកណា?» ទៅដល់ការយល់ដឹងកាន់តែច្បាស់ថែមទៀត អំពីវិជ្ជាជីវៈសារព័ត៌មានសហសម័យ)។
- តើអ្វីខ្លះដែលញែកសារព័ត៌មានដាច់ចេញពីការបង្កើត និងការបោះពុម្ពផ្សាយមាតិកាទ្រង់ទ្រាយធំផ្សេងទៀត (ដូចជាការផ្សាយពាណិជ្ជកម្ម ការឃោសនាទីផ្សារ ទំនាក់ទំនងសាធារណៈ ព័ត៌មានមិនពិត និងព័ត៌មានខុស) ទាំងនៅលើ និងនៅក្រៅបណ្តាញអ៊ីនធឺណិត?
- តើអ្នកអនុវត្តវិជ្ជាជីវៈសារព័ត៌មាន គួរបម្រើផលប្រយោជន៍ឱ្យអ្នកណា?
- តើអ្នកអនុវត្តវិជ្ជាជីវៈសារព័ត៌មាន គួរតែមានគណនេយ្យភាពចំពោះមាតិកាដែលខ្លួនផលិត/ផ្សព្វផ្សាយដែរឬទេ? ប្រសិនបើគួរ តើហេតុអ្វី និងតើអ្នកណាជាអ្នកបង្ខំឱ្យធ្វើ? ប្រសិនបើមិនគួរ តើហេតុអ្វី?
- តើកាតព្វកិច្ចសីលធម៌អ្វីខ្លះ ដែលអ្នកអនុវត្តវិជ្ជាជីវៈសារព័ត៌មានត្រូវមាន

ចំពោះប្រភព តួអង្គនៅក្នុងអត្ថបទដំណឹង និងក្រុមគោលដៅ?

➢ បច្ចុប្បន្ននេះ តើបញ្ហាចម្រូងចម្រាសសីលធម៌អ្វីខ្លះដែលអ្នកអនុវត្តវិជ្ជាជីវៈសារព័ត៌មានចាំបាច់ត្រូវពិចារណា នៅក្នុងបរិបទនៃ«ព័ត៌មានច្របូកច្របល់»?

## លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃ

គោលបំណងចម្បងបំផុតនៃសៀវភៅនេះ គឺពង្រឹងសមត្ថភាពត្រិះរិះពិចារណា និងពង្រឹងការការពារ នៅក្នុងចំណោមសិស្សនិស្សិតសារព័ត៌មាន អ្នកសារព័ត៌មានអាជីព និងអ្នកដទៃទៀត ដែលប្រតិបត្តិ «សកម្មភាពសារព័ត៌មាន»។ បទដ្ឋានភាពត្រឹមត្រូវ និងការផ្ទៀងផ្ទាត់ការពិត រួមទាំងការប្រកាន់ខ្ជាប់នូវគុណតម្លៃក្រមសីលធម៌ស្នូល ការស្រាវជ្រាវស៊ីជម្រៅ និងការវិភាគដោយការត្រិះរិះពិចារណា គួរតែជាលក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់ការវាយតម្លៃ។

*លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃនៃលំហាត់ទ្រឹស្តី៖*

➢ ភាពត្រឹមត្រូវ និងការផ្ទៀងផ្ទាត់ (ឧ. តើប្រភពដែលបានលើកឡើងនៅក្នុងរឿងមានការពណ៌នាបានត្រឹមត្រូវដែរឬទេ? តើគេប្រើប្រាស់វិធីសាស្ត្រផ្ទៀងផ្ទាត់សមស្របដែរឬទេ?)

➢ ចំណុចខ្លាំងនៃការស្រាវជ្រាវ (ឧ. តើក្នុងកម្រិតណាដែលអ្នកចូលរួមខិតខំស្វែងរកទិន្នន័យ/ប្រភពពាក់ព័ន្ធរឹងមាំ ដើម្បីគាំទ្រការវែកញែកហេតុផល/ការរកឃើញរបស់គេ?)

➢ គុណភាពនៃការវែកញែកហេតុផល និងការវិភាគ (តើការវែកញែកហេតុផល និងការវិភាគ ត្រូវបានធ្វើឡើងក្នុងគំនិតដើម និងស្មុគស្មាញកម្រិតណា?)

➢ សំនួនសេចក្តី (អក្ខរាវិរុទ្ធ វេយ្យាករណ៍ វណ្ណយុត្តិ រចនាសម្ព័ន្ធ)

➢ តើសំណេរ/សេចក្តីរាយការណ៍មានប្រសិទ្ធភាពកម្រិតណាក្នុងការបង្ហាញលទ្ធផលនៃការសិក្សាមេរៀននីមួយៗ?)។

*លក្ខណៈវិនិច្ឆ័យវាយតម្លៃសម្រាប់កិច្ចការអនុវត្តជាក់ស្តែង/សារព័ត៌មាន៖*

- ➢ ភាពត្រឹមត្រូវ និងការផ្ទៀងផ្ទាត់ (ឧ. តើប្រភពដែលបានលើកឡើងនៅក្នុងរឿង បានទទួលការពណ៌នាបានត្រឹមត្រូវដែរឬទេ? តើគេប្រើប្រាស់វិធីសាស្ត្រផ្ទៀងផ្ទាត់សមស្របដែរឬទេ?)
- ➢ ចំណុចខ្លាំងនៃការស្រាវជ្រាវ (ឧ. តើក្នុងកម្រិតណាដែលអ្នកចូលរួមខិតខំស្វែងរកទិន្នន័យ/ប្រភពពាក់ព័ន្ធរឹងមាំ ដើម្បីគាំទ្រការវែកញែកហេតុផល/ការរកឃើញរបស់គេ?)
- ➢ ការវិភាគដោយត្រិះរិះពិចារណា (ឧ. តើអ្នកចូលរួមស៊ើបសួរហ្មត់ចត់កម្រិតណា ទៅលើបញ្ហាសំខាន់ៗសម្រាប់អ្នកអាន?)
- ➢ គំនិតដើម
- ➢ ភាពខ្លាំងនៃការពិពណ៌នា (ឧ. តើអ្វីជាផលប៉ះពាល់នៃរឿង/ការផលិតទៅលើក្រុមគោលដៅ?)
- ➢ គុណតម្លៃនៃការផលិត (ឧ. ភាពខ្លាំងនៃការកាត់តសំឡេង/រូបភាព និងធាតុផ្សេងៗនៃសារគមនាគមន៍ចម្រុះ)
- ➢ សំនួនសេចក្តី (អក្ខរាវិរុទ្ធ វេយ្យាករណ៍ វណ្ណយុត្តិ រចនាសម្ព័ន្ធ)
- ➢ ការប្រកាន់ខ្ជាប់នូវគុណតម្លៃក្រមសីលធម៌ស្នូល ដែលបានចែងនៅក្នុងក្រមសីលធម៌វិជ្ជាជីវៈ។

## វិធីសាស្ត្របង្រៀន

មេរៀនទាំងនេះ រៀបចំឡើងសម្រាប់ទាំងការបង្រៀនក្នុងថ្នាក់រៀនដោយផ្ទាល់ ឬការបង្រៀនតាមអ៊ីនធឺណិត។ នៅក្នុងការបង្រៀន អ្នកចូលរួមនឹងទទួលប្រយោជន៍ពីបរិយាកាសសិក្សាបែបសហការទាំងនៅលើអ៊ីនធឺណិត (ជាក់ស្តែងតាមរយៈកម្មវិធីរៀនតាមអ៊ីនធឺណិត ដូចជា Moodle ឬការប្រើប្រាស់កម្មវិធី Facebook Group) ឬទាំងការបង្រៀនដោយផ្ទាល់។

មេរៀនភាគច្រើនយកតាមលំនាំដូចគ្នា គឺចែកចេញជាពីរផ្នែក ដែលផ្នែកទីមួយបង្ហាញពីការសិក្សាផ្នែកទ្រឹស្តី (ឧ. ដោយប្រើប្រាស់សិក្ខាសាលា ការអាន ឬ

បទបង្ហាញផ្អែកលើបាឋកថា) ដែលបំពេញបន្ថែមដោយលំហាត់អនុវត្តន៍ (ឧ. ក្រុមការងារដែលចាត់ឱ្យធ្វើលំហាត់ផ្ទៀងផ្ទាត់)។ ជាធម្មតា មេរៀននីមួយៗមានផ្នែកទ្រឹស្តីពី៦០ទៅ៩០នាទី និងសិក្ខាសាលា ឬការបង្រៀនពីគ្រូដែលមានថិរវេលាពី៩០នាទីទៅ២ម៉ោង។ វគ្គទាំងនេះអាចពង្រីក បង្រួញ ឬចែកជាផ្នែកៗ និង/ឬច្រើនថ្ងៃផ្សេងៗគ្នា ដោយអាស្រ័យលើក្របខ័ណ្ឌនៃការបង្រៀន/ការរៀនរបស់ស្ថាប័នពាក់ព័ន្ធ។ មេរៀននីមួយៗត្រូវដាក់ឱ្យមានលំហាត់មួយ។

នៅកន្លែងណាដែលអាចធ្វើទៅបាន គ្រូឧទ្ទេសនាម និងគ្រូបណ្តុះបណ្តាលគួរអញ្ជើញអ្នកជំនាញ និងអ្នកដែលមានវិជ្ជាជីវៈ ចូលរួមនៅក្នុងការធ្វើបាឋកថាក្នុងថ្នាក់ ឬក្នុងវេទិកាដែលមានបើកឱ្យមានការសួរ និងឆ្លើយ និងធានាថា ករណីសិក្សា បញ្ហា និងការពិភាក្សានានា ត្រូវបញ្ចូលទៅក្នុងកម្មវិធីសិក្សា។

ជាងនេះទៅទៀត ក្រុមអ្នកតាក់តែងវគ្គសិក្សានេះ លើកទឹកចិត្តដល់គ្រូឧទ្ទេសនាម/គ្រូបណ្តុះបណ្តាល ឱ្យដាក់បញ្ចូលឯកសារ និងឧទាហរណ៍ដែលមានសារៈសំខាន់ផ្នែកភាសា និងវប្បធម៌ពាក់ព័ន្ធនឹងបរិបទក្នុងស្រុក/តំបន់ ទៅក្នុងមេរៀនផង។

### សម្ភារៈ និងធនធាន

គ្រូ និងសិស្សនឹងត្រូវប្រើប្រាស់អ៊ីនធឺណិត ហើយនឹងទទួលប្រយោជន៍ពីការចូលប្រើប្រាស់ប្រព័ន្ធទិន្នន័យសិក្សា (academic databases) និង/ឬកម្មវិធី Google Scholar។

គេហទំព័រដ៏សំខាន់មួយសម្រាប់ធនធានសិក្សាបន្ថែមទៀត ដែលទាក់ទងនឹងការអនុវត្តជាក់ស្តែងនៃលទ្ធផលសិក្សាទូទៅ គឺ First Draft News[8]។

សូមកត់សម្គាល់៖ មាតិកា និងធនធានដែលផ្តល់ជូន នៅក្នុងសៀវភៅមេរៀននេះ គួរតែជាគុណសម្បត្តិរបស់ក្រុមអ្នកនិពន្ធកម្មវិធីសិក្សា និងអ្នកនិពន្ធផ្សេងទៀតដែលបានចូលរួមចំណែក។

## វិធីសាស្ត្រគរុកោសល្យ

វគ្គសិក្សាគំរូឯកទេសនេះ ត្រូវបានរៀបចំឡើងបន្តបន្ទាប់ពីការបោះពុម្ពផ្សាយកម្មវិធីសិក្សាគំរូជាច្រើនសម្រាប់ការអប់រំសារព័ត៌មាន[9] ដោយអង្គការយូណេស្កូ ដែល

8 https://firstdraftnews.com/ [accessed 28/03/2018].

9 UNESCO's Model Curricula for Journalism Education (2007). http://unesdoc.unesco.org/images/0015/001512/151209E.pdf [accessed 28/03/2018]. See also: UNESCO's Model Curricula For Journalism Education: a compendium of new syllabi (2013). [accessed 28/03/2018: http://unesdoc.unesco.org/images/0022/002211/221199E.pdf; និងTeaching Journalism for Sustainable Development: new syllabi (2015).

ចាប់ផ្តើមតាំងពីឆ្នាំ២០០៧មក។ វិធីសាស្ត្រគរុកោសល្យក៏ផ្អែកលើសៀវភៅ Media and Information Literacy Curriculum for Teacher[10] និងសៀវភៅ Model Course on Safety of Journalists[11] របស់អង្គការយូណេស្កូ ហើយតាមរយៈវិធីសាស្ត្រគរុកោសល្យនេះ គ្រូបណ្តុះបណ្តាលគួរអនុវត្តនូវចំណុចដូចខាងក្រោមនេះ ៖

- ➢ វិធីសាស្ត្រស៊ើបអង្កេតបញ្ហា
- ➢ ការសិក្សាដោយរៀនដោះស្រាយបញ្ហា
- ➢ ការស៊ើបអង្កេតបែបវិទ្យាសាស្ត្រ
- ➢ ករណីសិក្សា
- ➢ ការសិក្សាជាលក្ខណៈសហប្រតិបត្តិការ
- ➢ ការវិភាគទៅលើអត្ថបទ
- ➢ ការវិភាគទៅលើបរិបទ
- ➢ ការបកប្រែ
- ➢ ការចម្លងតាម
- ➢ ការផលិត

បន្ថែមពីលើនេះ គ្រូបណ្តុះបណ្តាលដែលប្រើកម្មវិធីសិក្សានេះ ត្រូវបានលើកទឹកចិត្តឱ្យសិក្សា និងវិភាគទៅលើគោលគំនិតនៃ «ការសិក្សាផ្អែកលើគម្រោង»[12] ជាអភិក្រមមួយដែលអភិវឌ្ឍលទ្ធផលសិក្សាតាមរយៈការអនុវត្ត និងការសាកល្បងជំនាញនៅក្នុងពេលផលិតមាតិកាព័ត៌មានដោយផ្ទាល់។ អ្នកសិក្សាក៏គួរដឹងដែរអំពីសក្តានុពលក្នុងការផលិតមាតិកាលឿនរហ័ស ឆ្លាតវៃ និងមានភាពទាក់ទាញខ្លាំង ដើម្បីឆ្លើយតបទៅនឹងព័ត៌មានមិនពិត និងគួរទទួលបានឱកាសសម្រាប់ការអនុវត្តជាក់ស្តែងលើវិធីសាស្ត្រនេះ[13]។

10 Wilson, C., Grizzle, A., Tuazon, R., Akyempong, K. and Cheung, C. (2011). Media and Information Literacy Curriculum for Teachers. [ebook] Paris: UNESCO. http://unesdoc.unesco.org/images/0019/001929/192971e.pdf [accessed 28/03/2018].

11 UNESCO (2017) Model Course on Safety of Journalists: A guide for journalism teachers in the Arab States.: http://unesdoc.unesco.org/images/0024/002482/248297e.pdf [accessed 28/03/2018].

12 Posetti, J & McHugh, S (2017) Transforming legacy print journalism into a successful podcast format: An ethnographic study of The Age's Phoebe's Fall. Peer reviewed conference paper presented at the International Association of Media and Communications Researchers conference in Cartagena, Colombia 18/07/2017

13 An interesting example is this clip from hashtag our stories: https://www.facebook.com/hashtagoursa/videos/679504652440492/ [accessed 15/06/2018].

# ហេតុអ្វីបានជា ការពិត ទំនុកចិត្ត និងវិជ្ជាជីវៈសារព័ត៌មាន មានសារៈសំខាន់?

*Cherilyn Ireton*



# មេរៀនទី១

## សង្ខេបមេរៀន

នៅបណ្តាប្រទេសជាច្រើននៃពិភពលោក ទំនុកចិត្តលើប្រព័ន្ធផ្សព្វផ្សាយ និងវិជ្ជាជីវៈសារព័ត៌មានមានភាពផុយស្រួយ និងចុះខ្សោយតាំងពីមុនពេលមានប្រព័ន្ធផ្សព្វផ្សាយសង្គម[1]ទៅទៀត។ និន្នាការនេះមិនខុសគ្នាពីការធ្លាក់ចុះទំនុកចិត្តទៅលើស្ថាប័ននានា ដែលក្លាយជាទិដ្ឋភាពទូទៅនៅក្នុងសង្គមជាច្រើន។ ប៉ុន្តែទោះជាយ៉ាងណា ទំហំ និងវិសាលភាពនៃព័ត៌មានមិនពិត និងព័ត៌មានខុសដែលបន្លំខ្លួនជាដំណឹងហើយចែកចាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម បានបង្កការឆ្លងរាលដាលដែលគំរាមកំហែងបង្វិចកេរ្តិ៍ឈ្មោះវិជ្ជាជីវៈសារព័ត៌មាន កាន់តែធ្ងន់ធ្ងរថែមទៀត។ បញ្ហានេះបង្កផលវិបាកដល់អ្នកសារព័ត៌មាន ប្រពន្ធ័ផ្សព្វផ្សាយដំណឹង ពលរដ្ឋ និងសង្គមបើកចំហ[2]។

នៅលើកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលចែករំលែកព័ត៌មានលឿន និងដោយឥតគិតថ្លៃសម្រាប់មនុស្សគ្រប់រូប និងនៅលើអ៊ីនធឺណិត អ្នកណាក៏អាចជាអ្នកផ្សព្វផ្សាយបានដែរ។ ជាលទ្ធផល ពលរដ្ឋពិបាកកត់សម្គាល់ភាពខុសគ្នារវាងអ្វីដែលពិត និងអ្វីដែលក្លែងក្លាយ។ រឿងគ្មានហេតុផល និងការមិនទុកចិត្តគ្នាក៏រីករាលដាល។ ទស្សនៈជ្រុលនិយម ទ្រឹស្តីឃុបឃិត និងប្រជាភិថុតនិយម រីកសាយភាយ ហើយការពិត និងស្ថាប័នដែលកាលពីមុនមក ធ្លាប់ទទួលបានការទុកចិត្តបែរជាត្រូវគេសង្ស័យ។ នៅក្នុងពិភពបែបនេះ ការិយាល័យដំណឹងត្រូវប្រយុទ្ធដើម្បីទាមទារមកវិញ និងបំពេញតួនាទីប្រវត្តិសាស្ត្ររបស់ខ្លួនជាឆ្មាំទ្វារ (gatekeepers)[3] ផលិតនូវដំណឹងដែលអាចជួយបង្កើតការពិត។ ស្របពេលជាមួយគ្នានេះ ការផុសឡើងនៃទីផ្សារសម្រាប់ «សារគមនាគមន៍ជាយុទ្ធសាស្ត្រ» និង «ប្រតិបត្តិការព័ត៌មាន» ក្នុងនោះរាប់បញ្ចូលទាំងព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្មផង បានក្លាយជាកត្តាចម្បងមួយ នៅក្នុងប្រព័ន្ធអេកូឡូស៊ីព័ត៌មាន[4]។

---

1 Edelman. (2017). Edelman Trust Barometer - Global Results. [online]. Available at: https://www.edelman.com/global-results/ [accessed 03/04/2018].

2 Viner,K. (2017). A mission for journalism in a time of crisis. [online] the Guardian. Available at: https://www.theguardian.com/news/2017/nov/16/a-mission-for-journalism-in-a-time-of-crisis [accessed 03/04/2018].

3 Singer, J. (2013). User-generated visibility: Secondary gatekeeping in a shared media space. New Media & Society, [online] 16(1), pp. 55-73. Available at: https://pdfs.semanticscholar.org/0d59/6a002c26a74cd45e15fbc20e64173cf2f912.pdf [accessed 0/3/04/2018].

4 See for example the cases described in Gu, L; Kropotov, V and Yarochkin, F. (nd).The Fake News Machine How Propagandists Abuse the Internet and Manipulate the Public. https://documents.trendmicro.com/assets/white_papers/wp-fake-news-machine-how-propagandists-abuse-the-internet.pdf[accessed16/06/2018].AnotherstudyispublishedbytheData&Society, ResearchInstitute, NewYork(2017)MediaManipulationandDisinformationOnline,https://datasociety.net/output/media-manipulation-and-disinfo-online/[accessed15/06/2018].

*ខណៈដែលវិសាលភាព និងផលវិបាកនៃ «ព័ត៌មានប្រឌិតប្រឌិតប្រឌិត» បានចាប់ផ្តើមលេចរូបរាងឡើងនៅក្នុងសង្គម សូម្បីតែអ្នកបង្កើតប្រព័ន្ធផ្សព្វផ្សាយសង្គមក៏មានការបារម្ភដែរ។ អ្នកគ្រប់គ្រង «ផ្នែកផលិតផល និងការចូលរួមរបស់ពលរដ្ឋ» នៅក្រុមហ៊ុន Facebook លោក Samidh Chakrabarti បាននិយាយថា ៖ «ប្រសិនបើមានការពិតជាមូលដ្ឋានមួយ អំពីផលប៉ះពាល់របស់ប្រព័ន្ធផ្សព្វផ្សាយសង្គមទៅលើលទ្ធិប្រជាធិបតេយ្យ ការពិតនោះគឺថា ប្រព័ន្ធផ្សព្វផ្សាយសង្គម ជួយបន្ទរសំឡេងរបស់មនុស្សទាំងល្អ ទាំងអាក្រក់។ ចំណុចល្អបំផុតគឺ វាអនុញ្ញាតឱ្យយើងសម្តែងមតិ និងធ្វើសកម្មភាព។ ចំណុចអាក្រក់បំផុតគឺ វាអនុញ្ញាតឱ្យមនុស្សផ្សព្វផ្សាយព័ត៌មានមិនពិត និងធ្វើឱ្យខូចខាតដល់លទ្ធិប្រជាធិបតេយ្យ»[5]។*

ច្បាស់ណាស់ថា ដើម្បីដោះស្រាយបញ្ហានេះ គេចាំបាច់ត្រូវតែមានកិច្ចអន្តរាគមន៍ទាំងទ្រង់ទ្រាយធំ និងទ្រង់ទ្រាយតូច។ ទំនោរមួយគឺការព្យាយាមដោះស្រាយបញ្ហាតាមរយៈនិយ័តកម្ម ហើយបណ្តាប្រទេសជាច្រើន កំពុងជ្រើសរើសយកផ្លូវមួយនេះ[6] ប៉ុន្តែអ្នកតស៊ូមតិដើម្បីសេរីភាពបញ្ចេញមតិព្រមានថា វិធីនេះអាចប៉ះពាល់ដល់ភាពបើកចំហ និងការចូលរួម ដែលបច្ចេកវិទ្យាថ្មីៗបានផ្តល់លទ្ធភាពឱ្យមាន[7]។

ជាពិសេស ប្រសិនបើមេដឹកនាំមានចិត្តគំនិតផ្តាច់ការឡើងកាន់អំណាច ពួកគេនឹងស្វែងរកអាវុធដែលមានឥទ្ធិពល និងស្របច្បាប់ដែលមានស្រាប់ ដើម្បីកំណត់ថាអ្វី «ក្លែងក្លាយ» និងអ្វីដែលមិនក្លែងក្លាយ ទាក់ទងនឹងការផ្សាយដំណឹងណាមួយដែលរិះគន់ការគ្រប់គ្រងរបស់គេ។

ជម្រើសមួយផ្សេងទៀត គឺជាការស្នើឡើងដោយគំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិល និងក្រុមហ៊ុន ដែលផ្តោតសំខាន់លើការធ្វើឱ្យក្រុមគោលដៅ មានការយល់ដឹងច្រើនជាងមុន និងផ្តល់ឧបករណ៍ដើម្បីបកប្រែ និងវាយតម្លៃព័ត៌មានដែលបានទទួល។

---

5 Chakrabarti, S. (2018). Hard Questions: What Effect Does Social Media Have on Democracy? Facebook Newsroom. [online] Newsroom. fb.com. Available at: https://newsroom.fb.com/news/2018/01/effect-social-media-democracy/ [accessed 03/04/2018].

6 Funke, D. (2018) A guide to anti-misinformation actions around the world Poynter https://www.poynter.org/news/guide-anti-misinformation-actions-around-world [accessed 22/05/2018].

7 Nossel, S. (2017). Faking News: Fraudulent News and the Fight for Truth. [ebook] PEN America. Available at: https://pen.org/wp-content/uploads/2017/10/PEN-America_Faking-News-Report_10-17.pdf [accessed 03/04/2018].

ចាប់ពីអាហ្វ្រិកខាងត្បូង[8] រហូតដល់ប្រទេសម៉ិចស៊ិក[9] ឧទាហរណ៍មានច្រើនសន្ធឹកសន្ធាប់។ អង្គការត្រួតពិនិត្យការពិតកំពុងកកើតឡើងសាយភាយ (ដូចដែលមានពន្យល់នៅក្នុងសៀវភៅនេះ)។

នៅក្នុងបរិបទនេះ អ្នកសារព័ត៌មាន និងសិស្ស និស្សិតសារព័ត៌មានចាំបាច់ត្រូវដឹងអំពីគំនិតផ្ដួចផ្ដើមទាំងនេះ និងអំពីតួនាទីបំពេញបន្ថែម ដែលពួកគេអាចអនុវត្តបាន ដូច្នេះហើយទើបមានសៀវភៅនេះ។

ចំពោះអ្នកសារព័ត៌មាន ដែលចាត់ទុកខ្លួនឯងជាតួអង្គគាំទ្រដ៏សំខាន់ នៅក្នុងសង្គមបើកចំហ និងប្រជាធិបតេយ្យអស់ពេលយូរមកហើយនោះ ព័ត៌មានមិនពិត និងព័ត៌មានខុស បង្កជាបញ្ហាប្រឈមលើសពីកេរ្តិ៍ឈ្មោះរបស់ពួកគេទៅទៀត។ «ព័ត៌មានច្របូកច្របល់» បង្កភាពមន្ទិលសង្ស័យលើគោលបំណង និងប្រសិទ្ធភាពរបស់អ្នកសារព័ត៌មាន។ វាក៏បង្ហាញឱ្យឃើញនូវសារៈសំខាន់ជាមូលដ្ឋាននៃភាពចាំបាច់សម្រាប់ឯករាជ្យភាពនៃសារព័ត៌មាន និងបទដ្ឋានវិជ្ជាជីវៈខ្ពស់។ ការលើកឡើងបែបនេះមិនមែនសន្មតថា សារព័ត៌មានប្រាស់ចាកបានទាំងស្រុងពីការគ្រប់ដណ្ដប់នៃមនោគមន៍វិជ្ជា ឬភាពលម្អៀងដែលកើតចេញពីយេនឌ័រ ជាតិព័ន្ធ ក្រុម ភាសា វណ្ណៈ ។ល។ ឬសាវតានៃអ្នកដែលផលិតដំណឹងនោះទេ។ ហើយយើងក៏មិនព្រងើយចំពោះបញ្ហាជាប្រព័ន្ធនៃឥទ្ធិពលពីបរិបទស្ថាប័ននៃម្ចាស់កម្មសិទ្ធិ គំរូអាជីវកម្ម ផលប្រយោជន៍របស់អ្នកអាន «បណ្ដាញ»ដំណឹងរបស់ប្រភពការិយាធិបតេយ្យ និងទំនាក់ទំនងសាធារណៈ។ល។ នោះទេ។ ប៉ុន្តែការលើកឡើងបែបនេះ គឺដើម្បីគាំទ្រសារៈសំខាន់នៃក្រមសីលធម៌និពន្ធ ដែលជាចន្លុះបំភ្លឺផ្លូវសម្រាប់ការរាយការណ៍ និងការពិចារណាដោយខ្លួនឯង សម្រាប់អ្នកសារព័ត៌មាន អំពីទស្សនៈយល់ឃើញរបស់ខ្លួនចំពោះពិភពលោក និងបរិបទ។ ចំណុចនេះក៏ចង់បង្ហាញដែរថា វិជ្ជាជីវៈសារព័ត៌មានមិនមែនជា «ទស្សនៈដែលគ្មានប្រភព» នោះទេ ប៉ុន្តែវាជាការអនុវត្តមួយដែលត្រូវការជាចាំបាច់នូវតម្លាភាព ប្រសិនបើចង់ឱ្យសាធារណជនជឿទុកចិត្តថា សារព័ត៌មាន ពិតជាប្រកាន់ខ្ជាប់នូវបទដ្ឋាននៃការផ្ទៀងផ្ទាត់ការពិត និងដើម្បីប្រយោជន៍សាធារណៈមែន ទោះបី

8 #KnowNews គឺជាកម្មវិធីបន្ថែមសម្រាប់រុករក (a web browser extension) ដែលបង្កើតដោយអង្គការ South Africa's Media Monitoring Africa ដែលជួយក្រុមគោលដៅអាចកំណត់ថា តើគេហទំព័រដែលពួកគេកំពុងតែអាន ឬស្វែងរកព័ត៌មាននោះ ផ្ដល់នូវព័ត៌មានដែលអាចជឿជាក់បាន។ ព័ត៌មានបន្ថែមសូមមើល៖ https:// chrome.google.com/webstore/search/KnowNews [accessed 15/06/2018].

9 See the website https://verificado.mx/ representing a coalition of 60 media, civil society and university institutions focusing on verification of contested content during the 2018 Mexican election. [accessed 15/06/2018]; https://knightcenter.utexas.edu/blog/00-19906-media- collaboration-and-citizen-input-fueled-verificado-2018-fact-checking-mexican-ele [accessed 04/07.2018].

ប្រធានបទ និងទស្សនៈពាក់ព័ន្ធនឹងប្រធានបទទាំងនោះជាអ្វីក៏ដោយ[10]។

នៅក្នុងមេរៀននេះ គ្រូគួរតែលើកទឹកចិត្តសិស្សឱ្យត្រិះរិះពិចារណាល្អិតល្អន់អំពីវិធីដែលវិជ្ជាជីវៈសារព័ត៌មានអាចបម្រើដល់សង្គម និងលទ្ធិប្រជាធិបតេយ្យ របៀបដែល«ព័ត៌មានច្របូកច្របល់»កំពុងជះឥទ្ធិពលអវិជ្ជមាន ក៏ដូចជាហានិភ័យដែលបង្កផលប៉ះពាល់បន្ថែមទៀត ទៅលើលទ្ធិប្រជាធិបតេយ្យ និងសង្គមសេរី របៀបដែលវិជ្ជាជីវៈសារព័ត៌មានអាចធ្វើបានកាន់តែប្រសើរឡើង និងកសាងទំនុកចិត្តឡើងវិញថាវិធីសាស្ត្រ និងបទដ្ឋានរបស់សារព័ត៌មាន ពិតជាលេចធ្លោទាក់ទងនឹងការផលិត និងផ្សាយព័ត៌មានដែលមានការផ្ទៀងផ្ទាត់ ដើម្បីប្រយោជន៍សាធារណៈ។ នេះមិនមែនសំដៅទៅលើទំនុកចិត្តទាំងងងឹតងងុល ទៅលើអ្នកអនុវត្តវិជ្ជាជីវៈសារព័ត៌មាននោះទេ ប៉ុន្តែគឺសំដៅទៅលើការស្គាល់ចរិត និងភាពខុសប្លែករបស់វិជ្ជាជីវៈសារព័ត៌មាន និងបំណងដែលចង់ឱ្យស្របទៅតាមដំណើរការ និងបទដ្ឋាននៃការផ្ទៀងផ្ទាត់ព័ត៌មានដើម្បីប្រយោជន៍សាធារណៈ និងការវាយតម្លៃដំណើរការ និងបទដ្ឋានទាំងនេះ។ ការលើកឡើងទាំងអស់នេះ មានន័យថាជាការទទួលស្គាល់គុណតម្លៃនៃភាពមន្ទិលសង្ស័យ ដែលផ្ទុយពីការខ្វះហេតុផល និងលទ្ធភាពរបស់សមាជិកមហាជន ក្នុងការវែកញែកឱ្យដាច់ពីគ្នារវាងជនដែលក្លែងបន្លំ ជាអ្នកអនុវត្តអាជីពសារព័ត៌មាន និងជនដែលខិតខំប្រឹងប្រែងយ៉ាងពិតប្រាកដដើម្បីធ្វើការងារសារព័ត៌មាន (និងជនដែលបង្ហាញនូវតម្លាភាព គណនេយ្យភាព ស្វ័យនិយ័តកម្ម និងកេរ្តិ៍ឈ្មោះប្រកបដោយគុណភាព ដែលនៅជាប់ជាមួយការងារសារព័ត៌មាននេះ)។ ចំពោះអ្នកសារព័ត៌មាន និងនិស្សិតសារព័ត៌មានបញ្ហាទាំងអស់នេះ មានន័យថា ជាការយល់អំពីបរិស្ថានព័ត៌មានដែលកំពុងប្រែប្រួល និងវិធីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា។

## គ្រោងនៃមេរៀន

ដើម្បីយល់អំពីផលវិបាកនៃ «ព័ត៌មានច្របូកច្របល់» ចំពោះអ្នកសារព័ត៌មាន និងសង្គមដែលពួកគេបម្រើ កិច្ចការសំខាន់គឺសិស្សត្រូវពិចារណាអំពីការផ្លាស់ប្តូរស៊ីជម្រៅសម្រាប់សារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី នៅកម្រិតរចនាសម្ព័ន្ធ វប្បធម៌ និងបទដ្ឋាន ដែលបានដើរតាមក្រោយដំណើរជឿនលឿនដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល និងឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួនដែលមាន

10 See Rosen, J. (2010). The View from Nowhere: Questions and Answers. PressThink. http://pressthink.org/2010/11/the-view-from-nowhere- questions-and-answers/ [accessed15/06/2018].

ភ្ជាប់អ៊ីនធឺណិត។ អ្វីដែលសំខាន់បំផុត គឺទំនាក់ទំនងរវាងបញ្ហាទំនុកចិត្តមកលើសារព័ត៌មាន និងការចូលរួមជាមួយប្រព័ន្ធផ្សព្វផ្សាយសង្គម[11]។

ការទម្លាក់កំហុសទាំងអស់ទៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម មិនមែនជារឿងត្រឹមត្រូវទេ។ ទំនុកចិត្តមានទំនាក់ទំនងដោយផ្ទាល់ ទៅនឹងសមត្ថភាពសារព័ត៌មាន ហើយទន្ទឹមនឹងនេះ ក៏មានទំនាក់ទំនងទៅវិញទៅមកដែរ ជាមួយនឹងការធ្លាក់ទំនុកចិត្តលើរដ្ឋាភិបាល ធុរកិច្ច និងស្ថាប័ននានា នៅក្នុងបណ្ដាប្រទេសជាច្រើន នៅជុំវិញពិភពលោក[12]។

ការផ្លាស់ប្ដូររចនាសម្ព័ន្ធជុំវិញ វិធីសាស្ត្រនៃការប្រមូល និងចែកចាយដំណឹង និងការដួលរលំនៃគំរូអាជីវកម្មចម្បងរបស់ក្រុមហ៊ុនដំណឹង បានធ្វើឱ្យបាត់បង់សមត្ថភាពផ្នែកវិជ្ជាជីវៈសារព័ត៌មាន នៅក្នុងការិយាល័យដំណឹងរបស់វិស័យសារព័ត៌មាន ហើយនាំឱ្យប៉ះពាល់ដល់ភាពស៊ីជម្រៅ ភាពទូលំទូលាយ និងគុណភាពនៃការរាយការណ៍ដំណឹង[13]។ ការធ្លាក់ចុះនៃមូលនិធិសម្រាប់ការិយាល័យដំណឹងនៅក្នុងស្ថាប័នផ្សព្វផ្សាយសាធារណៈ និងការត្រួតត្រារបស់រដ្ឋាភិបាលទៅលើភាគច្រើននៃវិស័យនេះ ក៏បានធ្វើឱ្យការផ្ដល់ដំណឹងចុះខ្សោយដែរ។

ខណៈដែលការវិវត្តផ្នែកឌីជីថល បាននាំមកនូវវិធីសាស្ត្រថ្មីៗនៃការផ្សព្វផ្សាយ និងមានការចូលចិត្តពីសំណាក់ក្រុមគោលដៅ វាក៏នាំមកនូវការលំបាកកាន់តែច្រើនឡើងសម្រាប់អ្នកផលិតដំណឹងបែបប្រពៃណី ដែលកំពុងចុះខ្សោយស្រាប់។ ជាទូទៅ ស្ថាប័នសារព័ត៌មានឌីជីថល នៅមិនទាន់បានអភិវឌ្ឍកម្លាំងស្នូលផ្នែកសារព័ត៌មានវិជ្ជាជីវៈ ដើម្បីបញ្ឈប់ការធ្លាក់ចុះនៃសារព័ត៌មាននៅឡើយទេ[14]។

នៅក្នុងប្រព័ន្ធព័ត៌មានបែបប្រជាធិបតេយ្យ និងសម្បូរបែប ការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាននៃព័ត៌មានមិនពិត និងព័ត៌មានខុស គឺជារឿងលំបាក មិនមែនតែសម្រាប់តែអ្នកប្រកបវិជ្ជាជីវៈសារព័ត៌មានប៉ុណ្ណោះនោះទេ ប៉ុន្តែចំពោះសង្គមទាំងមូលដែរ[15]។

11 សូមមើលមេរៀនទី៣

12 Edelman. (2017) op cit

13 សូមមើលមេរៀនទី៣

14 Greenspon, E. (2017). The Shattered Mirror: News, Democracy and Trust in the Digital Age. [ebook] Ottowa: Public Policy Forum, Canada. Available at: https://shatteredmirror.ca/download-report/ [accessed03/04/2018].

15 Ansip, A. (2017). Hate speech, populism and fake news on social media–towards an EU response.https://ec.europa.eu/commission/commissioners/2014-2019/ansip/announcements/statement-vice-president-ansip-european-parliament-strasbourg-plenary-debate-hate- speech-populism [accessed03/04/2018]

ការអនុវត្ត និងវិធីសាស្ត្រសារព័ត៌មាន នៅមុនសម័យឌីជីថល រួមមានទាំងការគោរពបទដ្ឋានវិជ្ជាជីវៈ ព្រមទាំងការពិនិត្យ និងគ្រប់គ្រងនៅថ្នាក់កណ្តាលជាច្រើនស្រទាប់ ដើម្បីគ្រប់គ្រងភាពត្រឹមត្រូវ  គុណភាព និងភាពយុត្តិធម៌របស់ដំណឹង។ អ្នកនៅក្នុងការិយាល័យដំណឹង ផ្តល់ការគាំទ្រដល់អ្នករាយការណ៍ដំណឹងនៅកន្លែងកើតហេតុ ដោយការជួយផ្ទៀងផ្ទាត់មាតិកានៅមុនពេលចេញផ្សាយ។ គំរូ «ឆ្មាំទ្វារ» នេះបានបណ្តុះស្មារតីវិជ្ជាជីវៈសម្រាប់អ្នកសារព័ត៌មាន[16]។

តាមរយៈការរាយការណ៍អំពីកិច្ចការសាធារណៈ និងបញ្ហាសហគមន៍ ការស៊ើបអង្កេត ការធ្វើអត្ថាធិប្បាយ ព្រមទាំងការវិភាគ អ្នកសារព័ត៌មានមានឥទ្ធិពលធ្វើឱ្យអ្នកនយោបាយ និងមន្ត្រីរដ្ឋាភិបាល ទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន។ ពួកគេជួយប្រជាពលរដ្ឋក្នុងការសម្រេចចិត្ត អំពីរបៀបគ្រប់គ្រង និងចាត់ចែងការងាររបស់ស្រុកទេស។ បើនិយាយឱ្យអស់ទៅ ស្ថាប័នផ្សព្វផ្សាយដំណឹងខ្លះមិនបានប្រកាន់ខ្ជាប់ទៅតាមភាពឥតខ្ចោះ និងបទដ្ឋាននៃសារព័ត៌មាននេះទេ។ ប៉ុន្តែជាទូទៅ  កិច្ចការរបស់ពួកគេគឺផ្អែកលើដំណឹងពិត ដែលជ្រើសរើសនិងបង្ហាញជាការពិពណ៌នាគួរឱ្យចាប់ចិត្ត ប៉ុន្តែមិនមែនជាការពិតដែលប្រឌិតឡើងដើម្បីគោលបំណងនយោបាយ ពាណិជ្ជកម្ម ឬកម្សាន្ត នោះទេ។

ការផ្តល់អំណាចដល់តួអង្គដទៃទៀតដើម្បីឱ្យធ្វើជាសាក្សី កត់ត្រា ធ្វើអត្ថាធិប្បាយ និងផ្សព្វផ្សាយដំណឹងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម បានបង្ខំឱ្យមានការផ្លាស់ប្តូរមិនត្រឹមតែទៅលើគំរូមជ្ឈការប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងផ្លាស់ប្តូរក្នុងកិច្ចពិភាក្សាសាធារណៈទៀតផង[17]។ បច្ចុប្បន្នវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គមជាហេដ្ឋារចនាសម្ព័ន្ធដ៏សំខាន់សម្រាប់ការនិយាយស្តីជាសាធារណៈ និងការនិយាយស្តីអំពីនយោបាយ។ អ្នកខ្លះបានលើកឡើងថា ប្រការនេះបានធ្វើឱ្យប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ និងសង្គមសេរីធ្លាក់ទៅក្នុង «ឱនភាពប្រជាធិបតេយ្យ»[18]។

តាមរយៈការទទូចថាពួកគេមិនមែនជាអ្នកផ្សព្វផ្សាយដំណឹង ក្រុមហ៊ុនបច្ចេកវិទ្យា និងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម បានគេចវេះពីកាតព្វកិច្ចផ្លូវច្បាប់នានាដែល

16 Kovach, B. and Rosenstiel, T. (2010). Blur: How To Know What’s True In The Age of Information Overload. 1st ed.New York: Bloomsbury, pp.171-184.

17 Nossel, S. (2017). Faking News: Fraudulent News and the Fight for Truth.[ebook] PEN America. Available at: https://pen.org/wp-content/uploads/2017/10/PEN-America_Faking-News-Report_10-17.pdf [accessed 03/04/2018].

18 Howard, P. (2017) Ibid

ចាប់បង្ខំឱ្យអ្នកសារព័ត៌មាន និងអ្នកផ្សព្វផ្សាយត្រូវមានគណនេយ្យភាព[19]។ ទោះបីតួអង្គទាំងនេះ មិនជួលអ្នកសារព័ត៌មានដើម្បីផលិតដំណឹងក្តី ក៏ការរៀបចំនិងរក្សាទុកដំណឹង និងសមត្ថភាពកែសម្រួលរបស់ពួកគេ កំពុងធ្វើឱ្យខ្លួនពួកគេកាន់តែឃ្លាតចាកឆ្ងាយពីតួនាទី «ត្រឹមតែជាភ្នាក់ងារចម្លង» ឬអន្តរការីធម្មតា។

វេទិកាប្រពន្ធ័ផ្សព្វផ្សាយសង្គម និងកម្មវិធីក្បួនដោះស្រាយតាមកុំព្យូទ័រ (algorithms) ជាកត្តាជួយរុញច្រានព័ត៌មានមិនពិត និងព័ត៌មានខុស ឬ «របស់មិនបានការ» ដូចដែលវិទ្យាស្ថានវិទ្យាសាស្ត្រកុំព្យូទ័រ Oxford ដាក់ឈ្មោះឱ្យ។ តាមរយៈបណ្តាញគ្រួសារនិងមិត្តភក្តិរបស់អ្នកប្រើប្រាស់ កម្មវិធី និងប្រតិបត្តិការកុំព្យូទ័រទាំងនេះផ្តល់នូវរចនាសម្ព័ន្ធ និងភាពស្របច្បាប់ដល់ព័ត៌មានមិនពិត និងព័ត៌មានខុស[20]។

ដូច្នេះហើយ មាតិកាព័ត៌មានបំភ័ន្តដោយចេតនា ដែលចែកចាយនៅលើកម្មវិធីប្រពន្ធ័ផ្សព្វផ្សាយសង្គមទាំងនេះ កំពុងធ្វើឱ្យប៉ះពាល់ដល់ការយល់ដឹងអំពីការពិត[21] របស់ពលរដ្ឋ និងធ្វើឱ្យខូចដល់ទំនុកចិត្តការពិភាក្សាដែលផ្អែកលើដំណឹងគ្រប់ជ្រុងជ្រោយ ស្មារតីរួមនៃតថភាព ការព្រមព្រៀងគ្នាទៅវិញទៅមក និងការចូលរួម[22]។ របៀបផ្សេងទៀត ដែលប្រព័ន្ធផ្សព្វផ្សាយសង្គមធ្វើឱ្យខូចខាតលទ្ធិប្រជាធិបតេយ្យ រួមមាន៖

- ការបង្កើតកន្លែងរំពងសំឡេង ការបែកខ្ញែកគ្នា និងការប្រកាន់បក្សពួកជ្រុល
- ការបំលែងប្រជាប្រិយភាពទៅជាភាពស្របច្បាប់
- ការបណ្តោយឱ្យមេដឹកនាំប្រជាភិថុតិនិយម រដ្ឋាភិបាល និងក្រុមជ្រុលនិយមប្រើប្រាស់
- ការលើកទឹកចិត្តឱ្យមានការប្រមូលយកទិន្នន័យផ្ទាល់ខ្លួន និងកំណត់ការផ្ញើសារខ្នាតតូច/ការផ្សាយពាណិជ្ជកម្ម ដែលគេចផុតពីការស្ទាក់ចាប់[23]
- ការរំខានបរិយាកាសសាធារណៈ[24]។

---

19 Howard, P. (2017) Ibid. មើលមេរៀនទី៣

20 Pariser, E. (2011). The filter bubble: what the Internet is hiding from you. London, Viking/Penguin Press.

21 European Commission (2017). Next steps against fake news: Commission sets up High-Level Expert Group and launches public consultation. [online] Available at: http://europa.eu/rapid/press-release_IP-17-4481_en.htm [accessed 13/06/2018].

22 Deb, A., Donohue, S. & Glaisyer, T. (2017). Is Social Media A Threat To Democracy? [ebook] Omidyar Group. Available at: https://www.omidyargroup.com/wp-content/uploads/2017/10/Social-Media-and-Democracy-October-5-2017.pdf [accessed on 03/04/2018].

23 Cadwalladr, C. and Graham-Harrison, E. (2018). How Cambridge Analytica turned Facebook ‘likes’ into a lucrative political tool. The Guardian. [online] Available at: https://www.theguardian.com/technology/2018/mar/2017/facebook-cambridge-analytica-kogan-data- algorithm [accessed03/04/2018].

24 Deb, A., Donohue, S. & Glaisyer, T. (2017) Ibid

ការពិតមិនចាំបាច់ត្រូវតែដូច្នេះទាំងអស់ទេ។ ប្រព័ន្ធផ្សព្វផ្សាយសង្គមអាចជាកម្មវិធីដ៏សំខាន់មួយ ដើម្បីផ្តល់លទ្ធភាពឱ្យសង្គមចូលរួមជាមួយសារព័ត៌មាន និងដើម្បីលើកកម្ពស់ការពិភាក្សា គុណតម្លៃនៃភាពជាពលរដ្ឋ និងការចូលរួមបែបប្រជាធិបតេយ្យនៅក្នុងបរិយាកាសមួយដែលពង្រឹងសិទ្ធិមនុស្ស ភាពចម្រុះនៃវប្បធម៌ វិទ្យាសាស្ត្រ ចំណេះដឹង និងការសម្រេចចិត្តប្រកបដោយវិចារណញ្ញាណ។ ដើម្បីសម្រេចគោលបំណងនេះ សារព័ត៌មាន ទោះនៅលើវេទិកាណាមួយក៏ដោយ ក៏គួរតែធ្វើសេចក្តីរាយការណ៍ អំពីបញ្ហាស្មុគស្មាញជូនសាធារណជនទូទៅ ដោយធ្វើយ៉ាងណាមិនឱ្យបាត់បង់ភាពត្រឹមត្រូវបែបវិទ្យាសាស្ត្រ និងដោយមិនសម្រួលបរិបទឱ្យសាមញ្ញពេករហូតនាំឱ្យសាធារណជនភ័ន្តច្រឡំ។ ជាពិសេស នៅក្នុងវិស័យព្យាបាលវេជ្ជសាស្ត្រទំនើប (ឧ. ការបង្កើតជីវិតសត្វ ឬរុក្ខជាតិថ្មីមួយដោយប្រើប្រាស់កោសិការបស់សត្វ ឬរុក្ខជាតិមួយទៀត - cloning) និងភាពជឿនលឿនផ្នែកវិទ្យាសាស្ត្រថ្មីៗ (ឧ. បញ្ញាសិប្បនិម្មិត -AI) ភាពប្រឈមរបស់អ្នកសារព័ត៌មានគឺផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ជៀសវាងការបញ្ចូលភាពលន្លង់លន្លោច ប្រយ័ត្នប្រយែងក្នុងការរាយការណ៍អំពីផលប៉ះពាល់នាពេលអនាគត និងអាចគិតបានល្អិតល្អន់ និងថ្លឹងថ្លែងរវាងទស្សនៈ ឬការរកឃើញផ្សេងៗគ្នាពីសំណាក់អ្នកជំនាញ ដែលអាចជឿជាក់បាន។

បន្ទាប់មកទៀត មានវិធីជាច្រើនដែលសារព័ត៌មាន អាចឆ្លើយតបដោយផ្ទាល់ចំពោះព័ត៌មានមិនពិត និងព័ត៌មានខុស។ វិធីទាំងនេះរួមមាន វាយបកទៅនឹងការបន្លំ និងឈានទៅរកការស៊ើបអង្កេត និងបកអាក្រាតដោយត្រង់ៗទៅលើយុទ្ធនាការផ្សាយព័ត៌មានមិនពិត។ ប៉ុន្តែវិធីទាំងនេះត្រូវតែអមដោយកិច្ចប្រឹងប្រែងចម្បងៗ ដើម្បីធ្វើឱ្យសារព័ត៌មានល្អប្រសើរឡើងជាទូទៅ (សូមមើលនៅខាងក្រោម)។

ការឆ្លើយតបរបស់សង្គមចំពោះ «ព័ត៌មានច្របូកច្របល់» និងភាពប្រឈមនានាដែលបង្កឡើងដោយប្រព័ន្ធផ្សព្វផ្សាយសង្គម មានភាពខុសៗគ្នា និងកើតឡើងច្រើនកម្រិត។ ដំណោះស្រាយក៏កំពុងតែវិវត្តដែរ ហើយដំណោះស្រាយខ្លះវិវត្តយ៉ាងលឿនថែមទៀតផង។ ដំណោះស្រាយជាច្រើនមានប្រភពចេញពីសហរដ្ឋអាមេរិក ជាទីកន្លែងដែលក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម និងក្រុមហ៊ុន Google បោះទីតាំងការិយាល័យកណ្តាលរបស់ពួកគេ។ ការផ្តួចផ្តើមទាក់ទងនឹងបច្ចេកវិទ្យាដែលកំពុងវិវត្តមួយចំនួន ដើម្បីដោះស្រាយបញ្ហាព័ត៌មានមិនពិត

រួមមាន៖

- ការប្តេជ្ញាចិត្តចម្រាញ់លទ្ធផលស្វែងរក និងកម្មវិធីធ្វើបច្ចុប្បន្នភាពដំណឹង ដើម្បីរកនូវអ្វីដែលក្រុមហ៊ុន (មានភាពចម្រូងចម្រាស) ចាត់ទុកថាជាដំណឹងក្លែងក្លាយ [25] [26] [27]។
- កាត់ផ្តាច់ប្រភពចំណូលពីក្រុមហ៊ុនចែកចាយព័ត៌មានមិនពិត ពីការផ្សព្វផ្សាយពាណិជ្ជកម្មតាមរយៈតាមរយៈការបញ្ឆោតឱ្យចុចអាន[28]។
- ផ្តល់ដំណោះស្រាយដែលជំរុញដោយបច្ចេកវិទ្យា សម្រាប់ការផ្ទៀងផ្ទាត់មាតិកា និងរូបភាពឌីជីថល[29]។
- ផ្តល់មូលនិធិដល់ការផ្តួចផ្តើមគាំទ្រវិជ្ជាជីវៈសារព័ត៌មាន ដែលផ្តោតលើការធ្វើការរួមគ្នារវាងសារព័ត៌មានបច្ចេកវិទ្យា និងការស្រាវជ្រាវសិក្សា[30]។
- បង្កើត និងប្រើប្រាស់បទដ្ឋានបច្ចេកទេស ឬសញ្ញាទំនុកចិត្ត ដើម្បីជួយដល់អ្នកប្រើប្រាស់ (និងប្រតិបត្តិការកុំព្យូទ័រ) ក្នុងការសម្គាល់ដំណឹងដែលមានប្រភពចេញមកពីអ្នកផ្តល់ ដែលគេអាចជឿជាក់បាន[31]។

ខណៈដែលសៀវភៅនេះចាប់ផ្តើមបដិសន្ធិនៅដើមឆ្នាំ២០១៨ ការផ្តួចផ្តើមដ៏សំខាន់បំផុតមួយ នៅក្នុងចំណោមការផ្តួចផ្តើមបទដ្ឋានបច្ចេកទេសសម្រាប់ស្ថាប័នសារព័ត៌មាន គឺគម្រោង The Trust Project ជាគម្រោងរួមគ្នាមួយដែលសហការគ្នាជិតស្និទ្ធ រវាងក្រុមហ៊ុនក្បាលម៉ាស៊ីនស្វែងរកព័ត៌មានធំៗ វេទិកាប្រពន្ធ័ផ្សព្វផ្សាយសង្គម និងក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយជាង ៧០ មកពី

25 Ling, J. (2017). Eric Schmidt Says Google News Will 'Engineer' Russian Propaganda Out of the Feed. Motherboard Vice.com. [online] Available at: https://motherboard.vice.com/en_us/article/pa39vv/eric-schmidt-says-google-news-will-delist-rt-sputnik-russia-fake-news?utm_ campaign=buffer&utm_content=buffer41cba&utm_medium=social&utm_source=facebook.com+Motherboard [accessed on 03/04/2018]; https://www.rt.com/news/411081-google-russia-answer-rt/

26 Mosseri, A. (2018). Helping ensure news on Facebook is from trusted sources. Facebook. https://newsroom.fb.com/news/2018/01/trusted- sources/ [accessed on03/04/2018].

27 Stamos, A. (2018) Authenticity matters: Why IRA has no place on Facebook. Facebook. https://newsroom.fb.com/news/2018/04/authenticity- matters/ [accessed on 03/04/2018].

28 Love, J. & Cooke, C. (2017). Google, Facebook move to restrict ads on fake news sites. Reuters. [online] Available at: https://www.reuters. com/article/us-alphabet-advertising/google-facebook-move-to-restrict-ads-on-fake-news-sites-idUSKBN1392MM[accessed 15/06/2018].

29 សូមមើលមេរៀនទី៦ ឧទាហរណ៍នៅទីនេះ៖ http://www.truly.media/ [accessed15/06/2018].

30 សូមមើលមេរៀនទី៥

31 The Trust Project (2017). The Trust Project–News with Integrity. [online] Available at: https://thetrustproject.org/?nr=0[accessedon 03/04/2018].

ជុំវិញពិភពលោក។ បេសកកម្មរបស់គម្រោងនេះគឺ បង្កភាពងាយស្រួលដល់សាធារណជនក្នុងការសម្គាល់ភិនភាគដំណឹងដែល «ត្រឹមត្រូវ មានទំនួលខុសត្រូវ និងមានក្រមសីលធម៌» ដោយសម្គាល់ទៅលើសញ្ញាទំនុកចិត្ត។ គម្រោងនេះបានបង្កើតបទដ្ឋានបច្ចេកទេសបឋមចំនួន៨[32] ដែលអ្នកផ្តល់ដំណឹងគួរតែបំពេញតាម និងធ្វើឱ្យងាយស្រួលកំណត់សម្គាល់នៅក្នុងបរិស្ថានរចនាលើអ៊ីនធឺណិត ដើម្បីឱ្យអ្នកប្រើប្រាស់ទុកចិត្តក្រុមហ៊ុនដែលផ្តល់ដំណឹងនោះ។ សូចនាករទំនុកចិត្តរបស់គម្រោង The Trust Project[33]រួមមាន ៖

- **គំរូអនុវត្តន៍៖**

  > តើមានបទដ្ឋានអ្វីខ្លះ?
  > តើអ្នកណាផ្តល់ហិរញ្ញប្បទានដល់អង្គភាព ឬស្ថាប័នដំណឹងនោះ?
  > តើអ្វីជាបេសកកម្មរបស់ស្ថាប័នដំណឹង?
  > ការប្តេជ្ញាចិត្តប្រកាន់ខ្ជាប់នូវក្រមសីលធម៌ សំឡេងចម្រុះ ភាពត្រឹមត្រូវ ការកែតម្រូវ និងបទដ្ឋានដទៃទៀត។

- **ជំនាញឯកទេសរបស់អ្នកនិពន្ធ/អ្នករាយការណ៍ដំណឹង៖** តើនរណាជាអ្នកផលិតរឿងនេះ? ដំណឹងលម្អិតអំពីអ្នកសារព័ត៌មាននោះ ដោយគិតទាំងឯកទេសរបស់គេ និងរឿងផ្សេងទៀតដែលរូបគេធ្លាប់បានផលិតនិងចេញផ្សាយ។

- **ប្រភេទនៃស្នាដៃ៖** តើស្នាដៃនោះស្ថិតនៅក្នុងប្រភេទដំណឹងអ្វី? ដាក់ឈ្មោះសម្គាល់ជាយោបល់ បទវិភាគ និងមាតិកាផ្សាយពាណិជ្ជកម្ម (ឬអត្ថបទដែលគេជួលផ្សព្វផ្សាយ) ឱ្យដាច់ដោយឡែកពីអត្ថបទដំណឹង។

- **ការដកស្រង់ និងឯកសារយោង៖** សម្រាប់រឿងរ៉ាវស៊ើបអង្កេត ឬស៊ីជម្រៅ គេត្រូវប្រើប្រាស់ប្រភពដែលនៅពីក្រោយការពិត និងការអះអាង។

- **វិធីសាស្ត្រ៖** សម្រាប់រឿងរ៉ាវស៊ីជម្រៅ ក៏ត្រូវមានកន្លែងបញ្ជាក់អំពីមូលហេតុដែលអ្នករាយការណ៍ដំណឹងសម្រេចចិត្តស៊ើបអង្កេតរឿងនេះ និងអំពីរបៀបដែលគេធ្វើរឿងនេះដែរ (ការធ្វើបែបនេះគឺជួយឱ្យមានតម្លាភាព)។

---

32 The Trust Project (2017). Ibid

33 The Trust Project (2017). Ibid

- **ប្រភពក្នុងស្រុក?** អនុញ្ញាតឱ្យអ្នកដឹងនៅពេលណាអត្ថបទរឿង មានប្រភពដើម ឬឯកទេសនៅក្នុងស្រុក។ តើការរាយការណ៍នោះធ្វើឡើង នៅនឹងកន្លែងកើតហេតុ ជាមួយនឹងចំណេះដឹងស៊ីជម្រៅអំពីស្ថានភាពនៅក្នុងមូលដ្ឋាន ឬសហគមន៍ដែរឬទេ?
- **សំឡេងចម្រុះ៖** កិច្ចប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់ការិយាល័យដំណឹង ក្នុងការប្រមូលទស្សនាទានចម្រុះ។ (ក្រុមគោលដៅអាចដឹងនៅពេលដែលខ្វះខាតសំឡេងរបស់ក្រុមណាមួយ ជាតិព័ន្ធណាមួយ ឬជំនឿនយោបាយណាមួយ)។
- **មតិត្រឡប់ដែលអាចធ្វើសកម្មភាពបាន៖** កិច្ចប្រឹងប្រែងរបស់ការិយាល័យនិពន្ធដើម្បីឱ្យសាធារណជនចូលរួមជួយកំណត់អាទិភាព ការរាយការណ៍ដំណឹង ដោយចូលរួមចំណែកដល់ដំណើរការនៃការធ្វើសេចក្តីរាយការណ៍ដំណឹង និងធានានូវភាពត្រឹមត្រូវ និងផ្នែកផ្សេងៗទៀត។ ក្រុមគោលដៅ ចង់ចូលរួម និងផ្តល់មតិត្រឡប់ ដែលអាចនឹងធ្វើឱ្យសាច់រឿងប្រែប្រួល ឬរីកធំ។

ទំនុកចិត្តលើការងារសារព័ត៌មាន ក៏ជួយបង្កើនចំនួន ភាពចម្រុះ និងគុណភាពនៃប្រភពដែលអ្នកសារព័ត៌មានអាចរកបានដែរ ហើយវាក៏មានឥទ្ធិពលវិជ្ជមានលើក្រុមគោលដៅផង។

ការឆ្លើយតបរបស់រដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកអប់រំ មានដូចជាការផ្តោតសំខាន់កាន់តែច្រើនឡើង ទៅលើអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន នឹងលើកយកមកពិភាក្សាលម្អិតថែមទៀត នៅក្នុងមេរៀនក្រោយ[34]។

ចំណុចទាំងនេះក៏មានការលើកយកមកពិភាក្សាផងដែរនៅឆ្នាំ២០១៧ ដោយវេទិកាការីនិពន្ធពិភពលោក ដែលលោក Marcelo Rech ជាប្រធានបានស្នើឡើងថា ការីនិពន្ធនៅជុំវិញពិភពលោក គួរតែប្រកាន់ខ្ជាប់នូវគោលការណ៍៥ដូចខាងក្រោម[35] ៖

- នៅក្នុងពិភពលោកដែលមានព័ត៌មានច្រើនលើសលប់ ភាពអាចជឿជាក់បាន ភាពឯករាជ្យ ភាពត្រឹមត្រូវ ក្រមសីលធម៌វិជ្ជាជីវៈ តម្លាភាព និងពហុភាព គឺជាគុណតម្លៃ ដែលនឹងបញ្ជាក់អំពីទំនាក់ទំនងនៃទំនុកចិត្តជាមួយសាធារណជន។

34 មើលមេរៀនទី៤

35 Ireton, C. (2016). World Editors Forum asks editors to embrace 5 principles to build trust https://blog.wan-ifra.org/2016/06/14/world-editors- forum-asks-editors-to-embrace-5-principles-to-build-trust [accessed 15/06/2018].

- សារព័ត៌មានកម្រិតបន្ទាប់មានភាពខុសប្លែកពីមាតិកាផ្សេងទៀត នៅត្រង់ការស្ទួរដេញដោល និងការផ្ទៀងផ្ទាត់ដោយប្រុងប្រយ័ត្ន និងដោយយកចិត្តទុកដាក់ទៅលើរឿងរ៉ាវដែលចែកចាយ នៅលើប្រពន្ធ័ផ្សព្វផ្សាយសង្គម។ ចំណុចនេះទទួលស្គាល់ប្រព័ន្ធផ្សព្វផ្សាយសង្គមថា ជាប្រភពដំណឹងសម្រាប់ការត្រួតពិនិត្យការពិតបន្ថែម និងជាវេទិកាសម្រាប់លើកកម្ពស់មាតិកាវិជ្ជាជីវៈ។

- បេសកកម្មរបស់វិជ្ជាជីវៈសារព័ត៌មាននៅកម្រិតបន្ទាប់នេះ គឺដើម្បីបម្រើសង្គម តាមរយៈការផ្តល់ព័ត៌មានដែលផ្ទៀងផ្ទាត់ និងមានគុណភាពខ្ពស់ និងដើម្បីបង្កើតយីហោដំណឹង ឱ្យទៅជាវិញ្ញាប័នប័ត្របញ្ជាក់ទំនុកចិត្តទៅលើខ្លឹមសារដើម។

- លក្ខខណ្ឌតម្រូវនៃសារព័ត៌មានកម្រិតបន្ទាប់ គឺដំណឹងនោះត្រូវធ្វើឱ្យលើសពីការពិតជាមូលដ្ឋាន ហើយត្រូវផ្តល់លទ្ធភាព និងលើកទឹកចិត្តឱ្យមានការវិភាគការរាយការណ៍ពន្យល់ បរិបទ និងស៊ើបអង្កេត និងការសម្តែងមតិដែលមានគ្រប់ជ្រុងជ្រោយ ដោយងាកចេញពីការត្រឹមតែផ្តល់ដំណឹងទៅរកចំណេះដឹងដែលផ្តល់អំណាច។

- សារព័ត៌មានកម្រិតបន្ទាប់គួរតែជំរុញដោយទំនុកចិត្ត និងគោលការណ៍ដឹកនាំនៃទំនាក់ទំនងសង្គម ផលប្រយោជន៍ស្របច្បាប់ និងការពិត។

ចំពោះអ្នកសារព័ត៌មាន និងការិយាល័យដំណឹង ការយកចិត្តទុកដាក់បន្ថែមទៀតគួរផ្តោតទៅលើការលើកកម្ពស់គុណភាព តាមរយៈការធ្វើឱ្យប្រសើរឡើងនូវ ៖

- ការអនុវត្តសារព័ត៌មានដែលមានការទទួលខុសត្រូវ និងប្រកបដោយក្រមសីលធម៌ និងការធ្វើសេចក្តីរាយការណ៍ដែលផ្អែកលើភ័ស្តុតាង[36]។

- ការត្រួតពិនិត្យការពិត និងបកអាក្រាតព័ត៌មានមិនពិត និងព័ត៌មានខុស[37]។

- ការផ្ទៀងផ្ទាត់ទិន្នន័យ និងប្រភពរូបភាពឌីជីថល[38]។

---

36 Wales, J. (2017). What do we mean by evidence-based journalism? Wikitribune. https://medium.com/wikitribune/what-do-we-mean-by- evidence-based-journalism-3fd7113102d3 [accessed on 03/04/2018].

37 មើលមេរៀនទី៥

38 Bell, F. (2018). In an age of data-journalism, verification is all the more complex. For instance, in cases of massive data troves it is likely that not just inaccurate information exists, but also that it is entirely possible that deliberately planned disinformation maybe included within the records. See Module Six of this course

➢ ការទាក់ទងជាមួយនឹងសហគមន៍ ដែលអ្នកសារព័ត៌មានធ្វើការជាមួយ និងការធានាថា របៀបវារៈដំណឹងស្របទៅតាមតម្រូវការរបស់សង្គម[39]។

នៅត្រង់ចំណុចចុងក្រោយខាងលើនេះ ភ័ស្តុតាងនៃការដាច់ទំនាក់ទំនងគ្នារវាងប្រព័ន្ធផ្សព្វផ្សាយមហាជន និងសាធារណជន មានភាពលេចធ្លោនៅក្នុងអំឡុងពេលនៃការបោះឆ្នោតនៅចក្រភពអង់គ្លេស ពេលដែលអង់គ្លេសចង់បំបែកខ្លួនពីសហភាពអឺរ៉ុប (Brexit) និងក្នុងការបោះឆ្នោតឆ្នាំ២០១៦ នៅសហរដ្ឋអាមេរិក។ ចំណុចខ្លាំងនៃសារគមនាគមន៍ប្រព័ន្ធផ្សព្វផ្សាយសង្គម គឺការចូលរួមដោយផ្ទាល់។ គ្រូបណ្តុះបណ្តាលគួរពិនិត្យរកមើលរបៀបផ្សេងៗ ដែលប្រព័ន្ធផ្សព្វផ្សាយអាចបម្រើអ្នកប្រើប្រាស់កាន់តែប្រសើរឡើង និងកសាងទំនុកចិត្ត ដោយពង្រឹងទំនាក់ទំនងរវាងប្រពន្ធ័ផ្សព្វផ្សាយសង្គមជាមួយនឹងសហគមន៍កាន់តែទូលំទូលាយ។

ក្នុងសៀវភៅ *Six or Seven Things News Can Do for Democracy*[40] របស់លោក Schudson ផ្តល់នូវក្របខ័ណ្ឌល្អមួយសម្រាប់កិច្ចពិភាក្សា ៖

១. ព័ត៌មាន៖ ផ្តល់ព័ត៌មានដែលមានយុត្តិធម៌ និងពេញលេញ ដើម្បីឱ្យពលរដ្ឋអាចសម្រេចចិត្តរឿងនយោបាយបានត្រឹមត្រូវ។

២. ការស៊ើបអង្កេត៖ ស៊ើបអង្កេតប្រភពប្រមូលផ្តុំនៃអំណាច ជាពិសេសអំណាចរដ្ឋាភិបាល។

៣. ការវិភាគ៖ ផ្តល់ក្របខ័ណ្ឌនៃការបកស្រាយ ដែលមានភាពស៊ីចង្វាក់គ្នា ដើម្បីជួយឱ្យពលរដ្ឋ យល់អំពីពិភពលោកដ៏ស្មុគស្មាញ។

៤. ការយល់ពីសង្គម៖ ប្រាប់មនុស្សអំពីអ្នកដទៃនៅក្នុងសង្គម និងពិភពលោករបស់ពួកគេ ដើម្បីឱ្យពួកគេយល់អំពីទស្សនៈនិងជីវិតរបស់អ្នកដទៃ ជាពិសេសអ្នកដែលក្រីក្រ ឬលំបាកជាងខ្លួន។

៥. វេទិកាសាធារណៈ៖ ផ្តល់ជាវេទិកាសម្រាប់កិច្ចសន្ទនា ក្នុងចំណោមពលរដ្ឋតាមរយៈអភិក្រមពហុភាគី និងអន្តរវិស័យជុំវិញបញ្ហានានា និងដើរតួនាទីជាអ្នកពាំនាំទស្សនាទានរបស់ក្រុមផ្សេងៗនៅក្នុងសង្គម។

---

39 Batsell, J. (2015). Engaged journalism: connecting with digitally empowered news audiences. New York. Columbia University Press.

40 Schudson, M. (2008). Why Democracies Need an Unlovable Press. Polity. Chapter Two: Six or Seven Things News Can Do For Democracy. Available at: https://books.google.co.uk/books?id=hmYGMe9ecKUC&printsec=frontcover&dq=schduson+michael+6+or+seven+ways&hl=en&sa=X&ved=0ahUKEwju_ ZGI6ozZAhWELsAKHc0vBlUQ6AEIKTAA - v=onepage&q&f=false [accessed on 03/04/2018].

៦. ការប្រមូលផ្តុំ៖ ដើរតួនាទី (ពេលដែលមានតម្រូវការ) ជាអ្នកតស៊ូមតិដើម្បីកម្មវិធី និងទស្សនាទាននយោបាយ ព្រមទាំងប្រមូលផ្តុំប្រជាជនឱ្យធ្វើសកម្មភាពគាំទ្រដល់កម្មវិធីទាំងនេះ ដោយមិនប៉ះពាល់ដល់បទដ្ឋានផ្ទៀងផ្ទាត់ និងផលប្រយោជន៍សាធារណៈ។

## គោលបំណងនៃមេរៀន

- លើកទឹកចិត្តសិស្សឱ្យគិតត្រិះរិះពិចារណាអំពីសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសង្គម
- លើកទឹកចិត្តសិស្សឱ្យវាយតម្លៃស្ថានភាពរបស់ខ្លួន នៅក្នុងលក្ខខណ្ឌ «ព័ត៌មានច្របូកច្របល់»។
- ជួយដល់សិស្សក្នុងការគិតត្រិះរិះពិចារណាអំពីផលប៉ះពាល់នៃ «ព័ត៌មានច្របូកច្របល់» ទៅលើសង្គម។

## លទ្ធផលសិក្សា

នៅចុងបញ្ចប់នៃមេរៀននេះ សិស្សគួរតែ ៖

១. បានសម្រេចការយល់ដឹងស៊ីជម្រៅរបស់ខ្លួនអំពីរបៀប ដែលវិជ្ជាជីវៈសារព័ត៌មានអាចបម្រើដល់លទ្ធិប្រជាធិបតេយ្យ និងសង្គមសេរីកាន់តែប្រសើរជាងមុន នៅក្នុងបរិស្ថានដំណឹងដែលរីកកាន់តែធំ និងអំពីហានិភ័យនៃ «ព័ត៌មានច្របូកច្របល់» ចំពោះលទ្ធិប្រជាធិបតេយ្យ។

២. បានយល់អំពីកត្តានានា ដែលបង្កើតឱ្យមានទំនុកចិត្តលើសារព័ត៌មាន និងរបៀបថែរក្សា ឬស្តារឡើងវិញនូវទំនុកចិត្តបែបនេះ។

៣. អាចពន្យល់ដល់អ្នកដទៃអំពីមូលហេតុនៃសារៈសំខាន់របស់វិជ្ជាជីវៈសារព័ត៌មាន។

## ទម្រង់នៃមេរៀន

ដំណឹងនៅក្នុងគ្រោងនៃមេរៀននេះ អាចបង្កើតជាមូលដ្ឋានសម្រាប់ការផ្តល់បាឋកថារយៈពេល ៣០នាទី ប្តូររួមជាមួយនឹងការបង្រៀន ឬកិច្ចពិភាក្សាតុមូល ៣០នាទីទៀត ស្តីពីមូលហេតុដែលវិជ្ជាជីវៈសារព័ត៌មានមានសារៈសំខាន់ និង

របៀបដែលសារព័ត៌មានបម្រើជាប្រយោជន៍សាធារណៈ។ លំហាត់អនុវត្តន៍៩០នាទី ក្នុងទម្រង់ជាកិច្ចសន្ទនាដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ អាចរកមើលថាតើគេអាចធ្វើដូចម្តេចខ្លះដើម្បីបញ្ចុះបញ្ចូល អ្នកដែលមិនមានទំនុកចិត្តលើសារព័ត៌មាន ឱ្យយល់ថាមិនមែនគ្រប់ព័ត៌មានទាំងអស់សុទ្ធតែទុកចិត្តមិនបាននោះទេ និងរកមើលថាតើប្រព័ន្ធផ្សព្វផ្សាយដំណឹងអាចធ្វើអ្វីបានខ្លះ ដើម្បីបង្កើតភាពជឿជាក់ក្នុងបរិស្ថានប្រព័ន្ធផ្សព្វផ្សាយសង្គមមួយ ដែលព័ត៌មានទាំងអស់មើលទៅដូចគ្នា។

## ការផ្សារភ្ជាប់ផែនការទៅនឹងលទ្ធផលសិក្សា

### ក. ទ្រឹស្តី

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| បាឋកថា និងកិច្ចពិភាក្សាដោយមានសំណួរចម្លើយ អំពីការពិត និងទំនុកចិត្ត | ៣០នាទី | ១, ២ |
| កិច្ចពិភាក្សាតុមូល អំពីមូលហេតុនៃសារៈសំខាន់របស់សារព័ត៌មាន និងរបៀបដែលសារព័ត៌មានបម្រើសាធារណជន | ៣០ នាទី | ១, ២, ៣ |

### ខ. អនុវត្តន៍

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| លំហាត់អនុវត្តន៍ | ៩០ នាទី | ៣ |

## លំហាត់ស្រាវជ្រាវបន្ថែម

លំហាត់ស្រាវជ្រាវបន្ថែមមានបីផ្នែក និងទាមទារឱ្យសិស្សធ្វើជាក្រុមតូចៗឬជាគូ ៖

- ប្រាប់សិស្ស (ធ្វើការជាក្រុមតូចៗឬជាគូ) ឱ្យសម្ភាសអ្នកប្រើប្រាស់ដំណឹង និងសួរឱ្យគេកំណត់ប្រភពដែលគេទុកចិត្តបំផុត សម្រាប់ដំណឹងក្នុងស្រុក ឬដំណឹងជាតិ និងព័ត៌មានប្រជាពលរដ្ឋ។ តាមរយៈការប្រើគំរូ «Six or Seven Things News Can Do for Democracy» របស់លោក Schudson សិស្សគួរសិក្សាដំណឹងដែលចេញផ្សាយ ឬអត្ថបទតាមប្រធានបទនៅក្នុងសារព័ត៌មានណាមួយ ដើម្បីកំណត់ និងវិភាគថាតើសារព័ត៌មានទាំងនេះមានប្រសិទ្ធភាពប៉ុណ្ណា នៅក្នុងការបម្រើដល់សហគមន៍តាមរយៈវិជ្ជាជីវៈសារព័ត៌មាន។ បច្ចេកទេសវិភាគមាតិកាជាវិធីសាស្ត្រមួយដ៏មានប្រយោជន៍សម្រាប់កិច្ចការនេះ។ ផ្នែកទីពីរគឺ ត្រូវកំណត់រកមើលថាតើគេអាចរកឃើញសូចនាករទំនុកចិត្តបានចំនួនប៉ុន្មាន ក្នុងចំណោមសូចនាករទំនុកចិត្តទាំង៨ របស់គម្រោង The Trust Project។ ផ្នែកទីបី ការរកឃើញអាចបង្កើតជាមូលដ្ឋានសម្រាប់របាយការណ៍ដំណឹងមួយ ឬបទវិចារណកថាមួយ ជាសំណេរ ឬជាខ្សែវីដេអូខ្លី ឬជាសំឡេងខ្លី ដែលបង្ហាញហេតុផលថា វិជ្ជាជីវៈសារព័ត៌មានពិតជាមានសារៈសំខាន់។

## អំណានបន្ថែម


Deb, A., Donohue, S. & Glaisyer, T. (2017). Is Social Media A Threat To Democracy? [ebook] Omidyar Group. Available at: https://www.omidyargroup.com/wp-content/uploads/2017/10/Social-Media-and-Democracy-October-5-2017.pdf

Edelman. (2017). 2017 Edelman TRUST BAROMETER - Global Results. [online] Available at: https://www.edelman.com/global-results/

Howard, P. (2017) Is social media killing democracy? Oxford. Available at https://www.oii.ox.ac.uk/videos/is-social-media-killing-democracy-computational-propaganda- algorithms-automation-and-public-life/

Nossel, S. (2017). FAKING NEWS: Fraudulent News and the Fight for Truth. [ebook] PEN America. Available at: https://pen.org/wp-content/uploads/2017/10/PEN-America_Faking-News-Report_10-17.pdf

Schudson, M. (2008). Why Democracies Need an Unlovable Press. Polity. Chapter Two: Six or Seven Things News can do for Democracies, Available at https://books.google.co.uk/books?id=hmYGMe9ecKUC&printsec=frontcover&dq=schduson+michael+6+or+sev- en+ways&hl=en&sa=X&ved=0ahUKEwju_ZGI6ozZAhWELsAKHc0vBlUQ6AEIKTAA - v=onepage&q&f=false

Viner, K. (2017). A mission for journalism in a time of crisis. [online] the Guardian. Available at: https://www.theguardian.com/news/2017/nov/16/a-mission-for-journalism-in-a-time-of-crisis




# ការគិតអំពី «ព័ត៌មានច្របូកច្របល់»៖ ទម្រង់នៃព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្ម

*Claire Wardle និង Hossein Derakhshan*

# មេរៀនទី២

## សង្ខេបមេរៀន

*មានការប្រើប្រាស់ពាក្យ«ដំណឹងក្លែងក្លាយ» ជាញឹកញាប់ និងសូម្បីតែពាក្យ «ប្រព័ន្ធផ្សព្វផ្សាយក្លែងក្លាយ» ដើម្បីពណ៌នាសេចក្តីរាយការណ៍ ដែលអ្នកអះអាងមិនយល់ស្របជាមួយ។ កម្មវិធីផែនទី Google Trends បានបង្ហាញថា សាធារណជនបានចាប់ផ្តើមស្វែងរកពាក្យនេះ យ៉ាងគំហុកនៅអំឡុងឆមាសទីពីរនៃឆ្នាំ២០១៦[1]។ នៅក្នុងមេរៀននេះ សិស្សនឹងសិក្សាអំពីមូលហេតុដែលពាក្យនេះ ក) មិនគ្រប់គ្រាន់សម្រាប់ពន្យល់វិសាលភាពនៃការបំពុលព័ត៌មាន និង ខ) មូលហេតុពាក្យនេះក្លាយជាបញ្ហា ដែលយើងគួរតែជៀសវាងប្រើប្រាស់វា។*

ជាអកុសល ពាក្យនេះងាយឱ្យគេបង្វែរទៅជានយោបាយ និងប្រើប្រាស់ជាអាវុធប្រឆាំងនឹងវិស័យដំណឹង ជាមធ្យោបាយបង្ខូចសេចក្តីរាយការណ៍ណាដែលអ្នកកាន់អំណាចមិនចូលចិត្ត។ គេគួរប្រើពាក្យ ព័ត៌មានខុស និងព័ត៌មានមិនពិតជំនួសវិញ។ មេរៀននេះនឹងពិនិត្យមើលប្រភេទផ្សេងៗគ្នានៃព័ត៌មានមិនពិត និងព័ត៌មានខុស និងកន្លែងណាខ្លះ ដែលប្រភេទព័ត៌មានទាំងនេះឈរនៅលើក្របខ័ណ្ឌនៃ «ព័ត៌មានច្របូកច្របល់»។

មេរៀននេះក៏មានទាំងព័ត៌មានចម្អក និងព័ត៌មានបំភ្លើស ចំណងជើងបញ្ឆោតឱ្យចុចអាន និងការប្រើប្រាស់ពាក្យបរិយាយរូបភាព ឬស្ថិតិដែលបំភ័ន្ត ព្រមទាំងមាតិកាពិតដែលចែកចាយខុសពីបរិបទ មាតិកាក្លែងបន្លំ (នៅពេលដែលឈ្មោះអ្នកសារព័ត៌មាន ឬនិមិត្តសញ្ញារបស់អង្គភាពដំណឹងត្រូវបានប្រើប្រាស់ដោយមនុស្សដែលគ្មានទំនាក់ទំនងជាមួយពួកគេ) និងមាតិកាក្លែងបន្លំ និងប្រឌិត។ ហេតុផលទាំងអស់នេះហើយ ដែលនាំឱ្យវិបត្តិដំណឹងកាន់តែមានភាពស្មុគស្មាញលើសពីពាក្យ «ដំណឹងក្លែងក្លាយ»ទៅទៀត។

បើយើងចង់គិតអំពីដំណោះស្រាយចំពោះព័ត៌មានប្រភេទទាំងអស់នេះ ដែលបំពុលចរន្តប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យើង និងបញ្ឈប់កុំឱ្យហូរចូលទៅក្នុងផលិតផលរបស់សារព័ត៌មានប្រពៃណី យើងចាំបាច់ត្រូវចាប់ផ្តើមគិតអំពីបញ្ហានេះ ដោយយកចិត្តទុកដាក់កាន់តែច្រើនថែមទៀត។ យើងក៏ចាំបាច់ត្រូវគិតអំពីមនុស្សដែលបង្កើតមាតិកាប្រភេទនេះដែរ និងគិតដល់កត្តាដែលជំរុញឱ្យគេធ្វើ

1 Google Trend Map of the term Fake News https://trends.google.com/trends/explore?date=today%205-y&q=fake%20news [accessed 06/04/2018].

បែបនេះ។ តើមាតិកាប្រភេទអ្វីខ្លះដែលគេកំពុងផលិត និងតើក្រុមគោលដៅទទួលយកមាតិកាទាំងនោះ ដោយរបៀបណាខ្លះ? ហើយនៅពេលដែលក្រុមគោលដៅដដែលនោះសម្រេចចិត្តចែកចាយមាតិកាទាំងនោះបន្ត តើមានកត្តាអ្វីដែលជំរុញចិត្តពួកគេឱ្យធ្វើដូច្នេះ? បញ្ហានេះជាប់ពាក់ព័ន្ធនឹងទិដ្ឋភាពជាច្រើន ហើយការពិភាក្សាភាគច្រើន ពុំគ្របដណ្តប់សព្វគ្រប់លើភាពស្មុគស្មាញនេះឡើយ។ នៅចុងបញ្ចប់នៃមេរៀននេះ អ្នកសិក្សាគួរតែមានអារម្មណ៍ថា អាចប្រើប្រាស់វាក្យសព្ទ និងនិយមន័យដែលសមស្របសម្រាប់ពិភាក្សាលើបញ្ហានានា ដែលទាក់ទិននឹង «ព័ត៌មានច្របូកច្របល់»។

## គ្រោងនៃមេរៀន

ជាទូទៅ សៀវភៅនេះប្រើពាក្យ «ព័ត៌មានមិនពិត» និង «ព័ត៌មានខុស» ដើម្បីឆ្លុះបញ្ចាំងន័យផ្ទុយគ្នាទៅនឹងដំណឹង ដែលផ្ទៀងផ្ទាត់ត្រឹមត្រូវ និងជាប្រយោជន៍សាធារណៈ ដែលជាផលិតផលនៃសារព័ត៌មានពិតប្រាកដ។ នៅក្នុងមេរៀននេះ ការផ្តោតស្អិតនៅលើភាពលេចធ្លោនៃព័ត៌មានមិនពិត។

ភាគច្រើននៃការពិភាក្សាអំពី «ដំណឹងក្លែងក្លាយ» ជាការរួមបញ្ចូលគំនិតពីរ៖ ព័ត៌មានខុស និងព័ត៌មានមិនពិត។ ប៉ុន្តែដើម្បីងាយស្រួលយល់ ព័ត៌មានខុស គឺជាព័ត៌មានដែលមិនពិត ប៉ុន្តែអ្នកដែលផ្សព្វផ្សាយដំណឹងនោះ ជឿថាជាព័ត៌មានពិត។ ចំណែកព័ត៌មានមិនពិតវិញ គឺជាព័ត៌មានមិនពិត ហើយអ្នកដែលផ្សព្វផ្សាយដំណឹងនោះដឹងថាជាព័ត៌មានមិនពិត។ វាជាការកុហកដោយចេតនា និងតម្រង់ទិសទៅរកមនុស្ស ដែលកំពុងទទួលព័ត៌មានមិនពិតនេះពីតួអង្គទុច្ចរិត[2]។

ប្រភេទទីបីអាចប្រើពាក្យព័ត៌មានបង្កព្យសនកម្ម គឺជាព័ត៌មានដែលឈរលើភាពពិតជាក់ស្តែង ប៉ុន្តែត្រូវគេប្រើប្រាស់ដើម្បីបង្កផលអាក្រក់ទៅលើមនុស្ស អង្គការ ឬប្រទេសមួយ។ ឧទាហរណ៍ ដូចជា របាយការណ៍មួយដែលបញ្ចេញឱ្យដឹងអំពីទំនោរផ្លូវភេទរបស់មនុស្សម្នាក់ ដោយគ្មានហេតុផលថាជាប្រយោជន៍សាធារណៈ។ ការបែងចែកសារដែលពិត និងសារមិនពិតជារឿងសំខាន់ ប៉ុន្តែគេក៏ត្រូវស្គាល់សារដែលពិត (និងសារដែលពិតដោយផ្នែក) ប៉ុន្តែជាសារដែលបង្កើត ផលិត ឬចែកចាយដោយ «ភ្នាក់ងារ» ដែលមានចេតនាបង្កផលអាក្រក់ជាជាងបម្រើប្រយោជន៍សាធារណៈ។ ព័ត៌មានបង្កព្យសនកម្មបែបនេះ ដូចជាព័ត៌មានពិត

2 Further insight into definitions can be observed in the study by Karlova and Fisher (2012).

ដែលរំលោភឯកជនភាពរបស់មនុស្សម្នាក់ ដោយគ្មានហេតុផលដើម្បីប្រយោជន៍សាធារណៈ ដែលជារឿងផ្ទុយនឹងបទដ្ឋាន និងក្រមសីលធម៌សារព័ត៌មាន។

ទោះបីមានភាពខុសគ្នាដូចបានលើកឡើងខាងលើក្តី ក៏ផលវិបាកទៅលើបរិស្ថានព័ត៌មាន និងសង្គមអាចមានភាពស្រដៀងគ្នា (ឧទាហរណ៍ដូចជា ការបង្ខូចសុចរិតភាពនៃដំណើរការប្រជាធិបតេយ្យ ឬការកាត់បន្ថយអត្រាចាក់ថ្នាំបង្ការ)។ ជាងនេះទៅទៀត ករណីជាក់លាក់មួយចំនួន អាចមានរួមបញ្ចូលគ្នានូវប្រភេទព័ត៌មានទាំងបីតែម្តង ហើយមានភស្តុតាងបង្ហាញថា ឧទាហរណ៍ដោយឡែកៗនៃប្រភេទព័ត៌មានមួយ ជារឿយៗអមដោយប្រភេទព័ត៌មានផ្សេងទៀតដែរ (ពោលគឺនៅលើកម្មវិធីខុសៗគ្នា ឬតាមលំដាប់លំដោយ) ជាផ្នែកនៃយុទ្ធសាស្ត្រព័ត៌មានទូលំទូលាយរបស់តួអង្គណាមួយ។ ទោះយ៉ាងណា គេត្រូវចងចាំទុកនូវភាពខុសគ្នាទាំងនេះ ពីព្រោះបុព្វហេតុ បច្ចេកទេស និងដំណោះស្រាយក៏អាចខុសគ្នាដែរ។




*រូបទី១ ៖ «ព័ត៌មានច្របូកច្របល់»*

ការបោះឆ្នោតជ្រើសរើសប្រធានាធិបតីបារាំងឆ្នាំ២០១៧ បានផ្តល់ឧទាហរណ៍ដែលពន្យល់អំពីប្រភេទទាំងបីនៃ «ព័ត៌មានច្របូកច្របល់»។

### ១. ឧទាហរណ៍នៃព័ត៌មានមិនពិត

ល្បិចកលបោកប្រាស់មួយ ដែលគេប៉ុនប៉ងធ្វើទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោតនៅប្រទេសបារាំង គឺការបង្កើតកាសែតមួយដែលចម្លងតាមកាសែតភាសាបារាំងរបស់ប៊ែលហ្ស៊ិក Le Soir[3] ដែលមានការចុះផ្សាយអត្ថបទក្លែងក្លាយមួយដែលអះអាងថា បេក្ខជនប្រធានាធិបតី Emmanuel Macron ទទួលបានការគាំទ្រមូលនិធិពីប្រទេស អារ៉ាប៊ី សាអូឌីត។ ឧទាហរណ៍មួយផ្សេងទៀត គឺការចែកចាយឯកសារនៅលើអ៊ីនធឺណិត ដែលអះអាងដោយគ្មានការពិតថា បេក្ខជនប្រធានាធិបតីដដែលនោះ បានបើកគណនីធនាគារនៅប្រទេសបាហាម៉ា (Bahamas)[4] និងចុងក្រោយ ព័ត៌មានមិនពិតដែលចែកចាយតាមរយៈបណ្ដាញ Twitter ជាមួយការចូលរួមរបស់មនុស្សដទៃទៀត ដោយប្រើប្រាស់សញ្ញា# និងសារដូចៗគ្នាក្នុងពេលតែមួយ ផ្សាយពាក្យចចាមអារ៉ាមអំពីជីវិតឯកជនរបស់បេក្ខជនប្រធានាធិបតីដដែលនោះ។

### ២. ឧទាហរណ៍នៃព័ត៌មានខុស

ការវាយប្រហារភេរវកម្មទៅលើវិមាន Champs Elysees នៅទីក្រុងប៉ារីស នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ បានជំរុញឱ្យមានការផ្សាយព័ត៌មានខុស[5] ហើយដំណឹងស្ទើរតែទាំងអស់នោះជាដំណឹងទាន់ហេតុការណ៍។ អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម នាំគ្នាផ្សព្វផ្សាយពាក្យចចាមអារ៉ាមមួយចំនួន ដោយមិនដឹងខ្លួន ក្នុងនោះរាប់ទាំងព័ត៌មានមួយដែលថា ប៉ូលិសទីពីរបានស្លាប់។ មនុស្សម្នាដែលចែករំលែកមាតិកាប្រភេទនេះ មិនមែនធ្វើដូច្នេះដើម្បីបង្កផលអាក្រក់នោះទេ។ ផ្ទុយទៅវិញ ពួកគេមិនបានគិតវែងឆ្ងាយ ដោយគ្រាន់តែចង់ធ្វើខ្លួនឱ្យមានប្រយោជន៍តាមរយៈការចែករំលែកព័ត៌មាន ប៉ុន្តែមិនបានពិនិត្យពិច័យ និងផ្ទៀងផ្ទាត់ព័ត៌មានដែលខ្លួនបានចែករំលែក។

---

3 CrossCheck, 2017. Was Macron's campaign for French Presidency financed by Saudi Arabia?: Available at https://crosscheck.firstdraftnews.org/checked-french/macrons-campaign-french-presidency-financed-saudi-arabia/ [accessed 03/04/2018].

4 CrossCheck, 2017. Did Emmanuel Macron Open an Offshore Account? CrossCheck, Available at https://crosscheck.firstdraftnews.org/checked-french/emmanuel-macron-open-offshore-account/ [accessed 03/04/2018].

5 One example was the rumour that Muslims in the UK celebrated the attack. This was debunked by the CrossCheck project: Cross Check, (April 22, 2017) Did London Muslims 'celebrate' a terrorist attack on the Champs-Elysees? CrossCheck, Available at https://crosscheck.firstdraftnews.com/checked-french/london-muslims-celebrate-terrorist-attack-champs-elysees / [accessed 03/04/2018].

## ៣. ឧទាហរណ៍នៃព័ត៌មានបង្កព្យសនកម្ម

ឧទាហរណ៍ដ៏លេចធ្លោមួយនៃព័ត៌មានបង្កព្យសនកម្ម បានកើតឡើងនៅពេលដែលអ៊ីម៉ែលរបស់លោក Emmanuel Macron បានបែកធ្លាយមុនការបោះឆ្នោតនៅថ្ងៃទី៧ ខែឧសភា។ អ៊ីម៉ែលនោះត្រូវគេចាត់ទុកថាជាអ៊ីម៉ែលពិតប្រាកដ។ ប៉ុន្តែតាមរយៈការបញ្ចេញព័ត៌មានឯកជន ទៅក្នុងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ តែប៉ុន្មាននាទីនៅមុនការហាមប្រាមដោយច្បាប់បោះឆ្នោត ទៅលើការផ្សាយណាមួយនៅមុនការបោះឆ្នោត ការបែកធ្លាយនេះធ្វើឡើងដើម្បីបង្កផលអាក្រក់អតិបរមា ទៅលើយុទ្ធនាការឃោសនាបោះឆ្នោតរបស់លោក Macron។

ពាក្យ «ការឃោសនា» មិនមែនមានន័យដូចគ្នានឹងពាក្យព័ត៌មានមិនពិតនោះទេ ទោះជាយ៉ាងណា ព័ត៌មានមិនពិតអាចបម្រើដល់ផលប្រយោជន៍នៃការឃោសនា។ ប៉ុន្តែជាធម្មតា ការឃោសនាមានចរិតកេងចំណេញជាចំហ ជាងព័ត៌មានមិនពិត ដោយសារតែព័ត៌មានប្រភេទនេះ រីកសាយភាយក្នុងរបៀបទាក់ទាញអារម្មណ៍ជាជាងការផ្តល់សារជាព័ត៌មាន[6]។

នៅក្នុងមេរៀននេះ យើងផ្តោតទៅលើព័ត៌មានខុស និងជាពិសេសព័ត៌មានមិនពិត និងចែករំលែកឧទាហរណ៍មួយចំនួនអំពីប្រភេទផ្សេងៗទៀត។

ប្រភេទនៃព័ត៌មានមិនពិត ព័ត៌មានខុស និងព័ត៌មានបង្កព្យសនកម្ម ដែលបានពន្យល់ខាងលើនេះ មិនគួរច្រឡំជាមួយនឹងការពិពណ៌នាដំណឹងពិតនោះឡើយ។

ឧទាហរណ៍ អ្នកសារព័ត៌មានម្នាក់អាចសរសេរថា «ខណៈដែលមិនជាប់ពាក់ព័ន្ធនឹងលោក Bernie Madoff ការចោទប្រកាន់ឆបោកនៅក្នុងករណីថ្មីនេះ បានប៉ះពាល់យ៉ាងខ្លាំងដល់អ្នកវិនិយោគតូចៗ»។ អ្នកនិពន្ធម្នាក់ទៀត អាចសរសេរដោយស្របច្បាប់បែបនេះថា ៖ «ការចោទប្រកាន់ឆបោកនៅក្នុងករណីថ្មីនេះ បានប៉ះពាល់យ៉ាងខ្លាំងទៅលើអ្នកវិនិយោគតូចៗ ប៉ុន្តែករណីនេះមិនជាប់ពាក់ព័ន្ធនឹង Bernie Madoff ទេ»។ ឃ្លាទីពីរនេះមានអត្ថន័យកាត់បន្ថយ ខ្លឹមសារប្រៀបធៀបរបស់ករណីថ្មី។ បញ្ហានៃការផ្តោតសំខាន់ខុសគ្នានៅក្នុងឧទាហរណ៍ទាំងនេះ មិនមែនជាការផ្សាយបន្តនូវព័ត៌មានខុស ឬព័ត៌មានមិនពិតនោះទេ នៅក្នុងន័យដូចដែលបានរៀបរាប់ខាងក្រោមនេះ។ ឧទាហរណ៍ទាំងនេះ អាចជាវិធីស្របច្បាប់ពីរយ៉ាងនៃការបកស្រាយស្ថានការណ៍តែមួយ។

---

6 Neale, S. (1977). Propaganda. Screen 18-3, pp 9-40

ចំណុចសំខាន់ គឺថាការពណ៌នាមានទាំងនៅក្នុងដំណឹង ព្រមទាំងនៅក្នុងព័ត៌មានមិនពិត ព័ត៌មានខុស និងព័ត៌មានបង្កព្យសនកម្ម។ ដូច្នេះ ការពណ៌នាត្រូវគេបង្កប់នៅក្នុងការពិត ដែលត្រូវបានជ្រើសរើសជាមុំលេចធ្លោជាងគេនៅក្នុងដំណឹង (ឬការពិតខ្លះត្រូវគេបង្កើតឡើង ឬកាត់ចេញពីបរិបទនៅក្នុងសារគមនាគមន៍ដែលបំពុល)។ របាយការណ៍ដំណឹងអំពីឧក្រិដ្ឋកម្ម ដែលមិនមែនជាព័ត៌មានមិនពិត ឬព័ត៌មានខុស ឬព័ត៌មានបង្កព្យសនកម្ម ដែលអ្នកផ្សាយយល់ថា ចាំបាច់ត្រូវប្រាប់អំពីជាតិសាសន៍ ឬសញ្ជាតិរបស់ជនល្មើស និងជនរងគ្រោះ ដោយស្មានៗ។ បើទោះជាថា វាអាចជាការពិតដែលថា ជនជាប់ចោទគឺជាជនអន្តោប្រវេសន៍ និងជាបុរស រីឯជនរងគ្រោះគឺជាពលរដ្ឋម្ចាស់ស្រុក និងជាស្ត្រី ហើយមិនថាអ្វីដែលលើកឡើងគឺមុំសំខាន់ ឬមិនសំខាន់នៃរឿងក៏ដោយ នេះជាឥទ្ធិពលនៃការស៊ើបអង្កេតរបស់អ្នកសារព័ត៌មាន ហើយជាពិសេស វាជាផ្នែកមួយនៃមនោគមន៍វិជ្ជាទស្សនាទាន ការពណ៌នាអំពីហេតុ និងផល និងអំពីអ្វីដែលសំខាន់ ដែលអ្នកសារព័ត៌មានយកមកផ្សាយ ដោយដឹងខ្លួន ឬដោយមិនដឹងខ្លួន។ នេះជាហេតុផលមួយដែល «ការផ្ទៀងផ្ទាត់ការពិត» និង «ការវិភាគទម្រង់នៃការពិតដើម្បីរកឱ្យឃើញការពិត និងមិនពិត ដែលត្រូវបានផ្សព្វផ្សាយក្នុងគោលបំណងជាក់លាក់ណាមួយ» (narrative unpacking)។ ការពណ៌នានៅក្នុងសារព័ត៌មានដែលត្រឹមត្រូវអាចមានភាពខុសគ្នា និងមិនបាត់បង់អត្តិភាពរបស់វា នៅពេលធៀបជាមួយនឹងការពណ៌នាក្នុងទម្រង់ចំនួន ៧ ដទៃទៀត ដូចការពណ៌នាខាងក្រោមនេះ ៖

## ១. ដៀលត្មិះ ឬ ចំអកឡកឡឺយ

ការពិពណ៌នាបែបចំអកឡកឡឺយ ទៅក្នុងប្រភេទព័ត៌មានមិនពិត និងព័ត៌មានខុសប្រហែលជារឿងគួរឱ្យភ្ញាក់ផ្អើល។ ព័ត៌មានបែបចំអកនិងបែបបំភ្លើស អាចចាត់ទុកបានថាជាទម្រង់មួយនៃសិល្បៈ ប៉ុន្តែនៅក្នុងពិភពលោកមួយដែលមនុស្សម្នាទទួលព័ត៌មានកាន់តែច្រើនឡើងៗ តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម មានការភ័ន្តច្រឡំនៅពេលដែលគេមិនយល់ថា គេហទំព័រនោះជាការនិពន្ធបែបចំអករិះគន់។ ឧទាហរណ៍ សារព័ត៌មាន The Khabaristan Times ដែលជាផ្នែកអត្ថបទចំអកនៃគេហទំព័រដំណឹង Pakistan Today[7]។ កាលពីខែមករា ឆ្នាំ២០១៧ គេហទំព័រនេះត្រូវបានបិទនៅក្នុងប្រទេសប៉ាគីស្ថាន ហើយក្រោយមកបានបញ្ឈប់ការចេញផ្សាយ[8]។

---

7 Pakistan Today (2018). Anthropologists make contact with remote cut-off tribe still thanking Raheel Sharif. [online] p.Khabaristan Today. Available at: https://www.pakistantoday.com.pk/2017/01/11/anthropologists-make-contact-with-remote-cut-off-tribe-still-thanking-raheel- sharif/ [accessed 06/04/2018].

8 ក្នុងចំនោមធនធានសម្រាប់ការពិគ្រោះយោបល់ គឺមានមួយដែលត្រូវបានសរសេរដោយសហអ្នកនិពន្ធ Julie Posetti ជាមួយនឹង Alice Mathews សូមមើល៖ (TBA)

### ២. ការភ្ជាប់ទំនាក់ទំនងមិនពិត

នៅពេលដែលចំណងជើង រូបភាព ឬសេចក្ដីពណ៌នារូបភាព មិនស៊ីនឹងមាតិកា នេះគឺជាឧទាហរណ៍នៃការភ្ជាប់ទំនាក់ទំនងមិនពិត។ ឧទាហរណ៍សាមញ្ញបំផុតនៃមាតិកាប្រភេទនេះ គឺចំណងជើងដែលបញ្ឆោតឱ្យគេចុចអាន (clickbait)។ នៅចំពោះមុខការប្រកួតប្រជែងកាន់តែខ្លាំងឡើង ដើម្បីដណ្ដើមការចាប់អារម្មណ៍របស់ក្រុមគោលដៅ ការីនិពន្ធកាន់តែច្រើនឡើងត្រូវសរសេរចំណងជើង ដើម្បីទាក់ទាញការចុចអាន បើទោះជានៅពេលគេអានអត្ថបទទៅ អ្នកអានមានអារម្មណ៍ថា ខ្លួនត្រូវបានបោកបញ្ឆោត។ ឧទាហរណ៍ជាក់ស្ដែង មាននៅលើគេហទំព័រ The Political Insider[9]។ ករណីបែបនេះក៏អាចកើតឡើងដែរ នៅពេលដែលរូបភាព ឬចំណងជើងរូបភាពត្រូវបានគេប្រើប្រាស់ ជាពិសេសនៅលើទំព័រ Facebook ដើម្បីទាក់ទាញការចាប់អារម្មណ៍ ដែលតាមពិតមិនមានអ្វីទាក់ទងនឹងអត្ថបទទាល់តែសោះ។ ប៉ុន្តែ នៅពេលដែលអ្នកអានមើលតែចំណងជើងនៅលើគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ខ្លួន ដោយមិនចុចអានអត្ថបទទេនោះ (ជារឿយៗមនុស្សជាច្រើនធ្វើដូច្នេះឯង) រូបភាព និងចំណងជើងដែលបំភ័ន្តអាចនឹងនាំឱ្យមានការយល់ខុសបាន។

### ៣. មាតិកាបំភ័ន្ត

មាតិកាប្រភេទនេះ គឺនៅពេលដែលមានការប្រើប្រាស់ព័ត៌មានបំភ័ន្តដើម្បីឱ្យគេមើលឃើញបញ្ហា ឬបុគ្គលនៅក្នុងផ្លូវជាក់លាក់ណាមួយ ដោយមធ្យោបាយកាត់តរូបភាព ឬជ្រើសរើសយកសម្រង់សម្ដី ឬស្ថិតិតែផ្នែកណាមួយដែលគេចង់បាន។ សកម្មភាពនេះហៅថា ទ្រឹស្ដីនៃការមូលបង្គាច់ (framing theory)[10]។ ឧទាហរណ៍មួយចំនួនមាននៅលើគេហទំព័រ Rappler.com[11]។ រូបភាព និងវីដេអូ មានឥទ្ធិពលជាពិសេសសម្រាប់ការចែកចាយព័ត៌មានបំភ័ន្ត ពីព្រោះខួរក្បាលរបស់យើងមិនសូវត្រិះរិះប្រយ័ត្នប្រយែងខ្លាំងទេជាមួយរូបភាព[12]។ អត្ថបទជួលឱ្យផ្សាយ ឬការផ្សាយ

---

9 The Political Insider (2015). First time voter waited 92 years to meet Trump...what happened next is AMAZING! [online] Available at: https://thepoliticalinsider.com/first-time-voter-waited-92-years-to-meet-trump-what-happened-next-is-amazing/ [accessed 06/04/2018].

10 Entman, R., Matthes, J. and Pellicano, L. (2009). Nature, sources, and effects of news framing. In: K. Wahl-Jorgensen and T. Hanitzsch (Contributor), ed., Handbook of Journalism studies. [online] New York: Routledge, pp.196-211. Available at: https://centreforjournalism.co.uk/sites/default/files/richardpendry/Handbook%20of%20Journalism%20Studies.pdf[accessed 03/04/ 2018].

11 Punongbayan, J. (2017). Has change really come? Misleading graphs and how to spot them. Rappler.com. [online] Available at :https://www.rappler.com/thought-leaders/20177731-duterte-change-fake-news-graphs-spot [accessed 06/04/2018].

12 សូមពិនិត្យមើលអត្ថបទដោយ Hannah Guy នៅក្នុងផ្នែកអត្ថបទតម្រូវឱ្យអាចក្នុងមេរៀននេះ

ពាណិជ្ជកម្មដែលធ្វើត្រាប់តាមមាតិកាវិចារណកថា ក៏ស្ថិតនៅក្នុងប្រភេទនេះដែរ នៅពេលដែលគ្មានការដាក់សម្គាល់ច្បាស់លាស់ថា ជាអត្ថបទពាណិជ្ជកម្ម[13]។

## ៤. បរិបទខុស

មូលហេតុមួយដែលពាក្យ «ដំណឹងក្លែងក្លាយ» មិនសូវគ្របដណ្ដប់បានទូលំទូលាយ គឺដោយសារថា គេឃើញមាតិកាពិតត្រូវគេយកមកចែកចាយឡើងវិញជារឿយៗ ដោយខុសពីបរិបទដើម។ ឧទាហរណ៍ រូបភាពមួយពីប្រទេសវៀតណាមដែលថត នៅឆ្នាំ២០០៧ ហើយត្រូវគេចែកចាយជាថ្មីឡើងវិញ នៅក្នុងពេល៧ឆ្នាំក្រោយមក គឺត្រូវគេយកទៅចែកចាយដោយក្លែងបន្លំថាជារូបភាពពីប្រទេសនេប៉ាល់ ដែលថត នៅក្រោយគ្រោះរញ្ជួយដីនាឆ្នាំ២០១៥[14]។

## ៥. មាតិកាបន្លំអត្តសញ្ញាណ

ការប្រើឈ្មោះរបស់អ្នកសារព័ត៌មាន នៅក្នុងអត្ថបទដែលគេមិនបានសរសេរ ឬ ការប្រើរូបសញ្ញារបស់ស្ថាប័នក្នុងវីដេអូ ឬរូបភាពដែលស្ថាប័ននោះមិនបានបង្កើត ឡើងជាបញ្ហាពិតប្រាកដ។ ឧទាហរណ៍ នៅមុនការបោះឆ្នោតនៅប្រទេសកេនយ៉ា នៅឆ្នាំ២០១៧ ទូរទស្សន៍ BBC Africa បានរកឃើញថា មានគេបង្កើតវីដេអូមួយ ដោយកាត់តរូបសញ្ញារបស់អង្គភាព BBC ហើយវីដេអូនោះ ត្រូវគេចែកចាយ តាមកម្មវិធី WhatsApp[15]។ ដូច្នេះ គេត្រូវផលិតវីដេអូមួយ ចែករំលែកនៅលើ ប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយព្រមានសាធារណជន កុំឱ្យចាញ់បោកវីដេអូប្រឌិត នោះ។

## ៦. មាតិកាបោកបញ្ឆោត

មាតិកាបោកបញ្ឆោត គឺនៅពេលដែលមាតិកាពិតមួយ ត្រូវគេយកទៅក្លែងបន្លំ ដើម្បីបោកប្រាស់។ ឧទាហរណ៍មួយពីអាហ្វ្រិកខាងត្បូង បង្ហាញនូវរូបភាពក្លែងបន្លំ ជារូបការីនិពន្ធគោចរ Ferial Haffajee របស់បណ្ដាញផ្សព្វផ្សាយ HuffPost អង្គុយ លើភ្លៅរបស់អ្នកជំនួញម្នាក់ ឈ្មោះ Johan Rupert ដោយចង់ឱ្យមនុស្សទូទៅយល់

13 សូមមើលមេរៀនទី៣

14 Pham, N. (2018). Haunting ‘Nepal quake victims photo’ from Vietnam. BBC. [online] Available at :http://www.bbc.co.uk/news/world- asia-32579598 https://www.rappler.com/thought-leaders/20177731-duterte-change-fake-news-graphs-spot [accessed 06/04/2018].

15 BBC (2017).Kenya election: Fake CNN and BBC news reports circulate. [Online] Available at: http://www.bbc.co.uk/news/world- africa-40762796 [accessed 06/04/2018].

ថា ការនិពន្ធរូបនេះ មានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងអ្នកជំនួញរូបនេះ[16]។

## ៧. មាតិកាប្រឌិត

មាតិកាប្រភេទនេះអាចមានទម្រង់ជាអត្ថបទ ដូចជា«គេហទំព័រដំណឹង»ប្រឌិតទាំងស្រុង ដូចជា WTOE5 News ជាគេហទំព័រដែលអះអាងដោយខ្លួនឯងថា ផលិតដំណឹងបែបស្រមើស្រមៃ បានចុះផ្សាយអត្ថបទមួយដែលអះអាងថា សម្តេចសង្ឃកាតូលិក Pope បានគាំទ្របេក្ខជនប្រធានាធិបតី Donald Trump។ មាតិកាប្រឌិតក៏អាចជារូបភាព ឬវីដេអូដែរ ដូចជាករណីខ្លះដែលគេបង្កើតគំនូសបង្ហាញដែលប្រាប់មនុស្សទាំងមិនត្រឹមត្រូវថា គេអាចបោះឆ្នោតឱ្យលោកស្រី Hillary Clinton បានតាមរយៈការផ្ញើសារតាមទូរស័ព្ទដៃ[17]។ រូបគំនូរទាំងនេះត្រូវគេប្រើប្រាស់សំដៅលើសហគមន៍ភាគតិច លើប្រព័ន្ធផ្សព្វផ្សាយសង្គម នៅមុនពេលការបោះឆ្នោតប្រធានាធិបតីក្នុងសហរដ្ឋអាមេរិក។

សាធារណជនទូទៅ ជាពិសេសអ្នកសារព័ត៌មាន ចាំបាច់ចែកឱ្យដាច់ដោយឡែកពីគ្នានូវ «ធាតុផ្សំ» នៃ «ព័ត៌មានច្របូកច្របល់» ៖ ភ្នាក់ងារ សារ និងអ្នកបកស្រាយ។ នៅក្នុងបរិបទនេះ មានសំណួរជាច្រើនដែលត្រូវសួរដេញដោលធាតុផ្សំនីមួយៗ។ ភ្នាក់ងារដែលបង្កើតសារប្រឌិតមួយ អាចនឹងផ្សេងគ្នាពីភ្នាក់ងារដែលផលិតសារនោះ ហើយក៏អាចផ្សេងគ្នាពី «ភ្នាក់ងារ» ដែលចែកចាយសារនោះដែរ។ ដូចគ្នានេះដែរ គេចាំបាច់ត្រូវតែមានការយល់ឱ្យបានហ្មត់ចត់ថា ភ្នាក់ងារទាំងនេះជាអ្នកណា និងមូលហេតុអ្វីដែលជំរុញឱ្យពួកគេធ្វើដូច្នោះ។ គេក៏ចាំបាច់ត្រូវយល់ប្រភេទខុសៗគ្នានៃសារ ដែលភ្នាក់ងារនោះចែកចាយដែរ ដើម្បីអាចចាប់ផ្តើមប៉ាន់ស្មានទៅលើវិសាលភាពនៃសារនីមួយៗ និងចាប់ផ្តើមដោះស្រាយបញ្ហា។ (គិតមកទល់បច្ចុប្បន្ន ការពិភាក្សាផ្តោតលើសលប់ទៅលើគេហទំព័រដំណឹងប្រឌិតក្នុងទម្រង់ជាអត្ថបទ ប៉ុន្តែ មាតិកាជារូបភាព ឬវីដេអូក៏មានភាពរាលដាលដូចគ្នា និងពិបាកកំណត់មុខសញ្ញា និងបកអាក្រាតថែមទៀតផង)។

ជាចុងក្រោយ គេចាំបាច់ត្រូវពិចារណាទៅលើ «ដំណាក់កាលបី» នៃ «ព័ត៌មានច្របូកច្របល់» ៖ ការបង្កើត ការផលិត និងការចែកចាយ (រូបទី២)។ ជាការសំខាន់

16 Haffajee, F. (2017). Ferial Haffajee: The Gupta fake news factory and me. HuffPost South Africa. [online] Available at: https://www.huffingtonpost.co.za/2017/06/05/ferial-haffajee-the-gupta-fake-news-factory-and-me_a_22126282/[accessed 06/04/2018].

17 Haltiwanger, J. (2016). Trump Trolls Tell Hillary Clinton Supporters They Can Vote Via Text. Elite Daily. Available at https://www.elitedaily. com/news/politics/trump-trolls-hillary-clinton-voting-text-message/1680338 [accessed on 23/03/2018].

ដែរដែលគេត្រូវពិចារណា ទៅលើដំណាក់កាលផ្សេងៗនៃឧទាហរណ៍ «ព័ត៌មានច្របូកច្របល់» ព្រមគ្នាជាមួយនឹងធាតុផ្សំរបស់វា ពីព្រោះភ្នាក់ងារដែលជាមេខ្លោងនៃមាតិកា ជារឿយៗគឺផ្សេងគ្នាពីអ្នកផលិត និងអ្នកផ្សព្វផ្សាយ។

| | | |
|---|---|---|
| ភ្នាក់ងារ | ប្រភេទតួអង្គ៖ | ផ្លូវការ / មិនផ្លូវការ |
| | កម្រិតនៃការចាត់តាំង៖ | គ្មាន / ធូររលុង / តឹងរ៉ឹង / បណ្ដាញ |
| | កត្តាជំរុញ៖ | ហិរញ្ញវត្ថុ/នយោបាយ/សង្គម/ចិត្តសាស្ត្រ |
| | កម្រិតស្វ័យប្រវត្តិកម្ម៖ | មនុស្ស / Cyborg / Bot |
| | ក្រុមគោលដៅ៖ | សមាជិក / ក្រុមសង្គម / សង្គមទាំងមូល |
| | ចេតនាបង្កផលអាក្រក់៖ | មាន / គ្មាន |
| | ចេតនាបំភ័ន្ត៖ | មាន / គ្មាន |
| សារ | ថេរវេលា៖ | រយៈពេលវែង/រយៈពេលខ្លី/ផ្អែកលើព្រឹត្តិការណ៍ |
| | ភាពត្រឹមត្រូវ៖ | បំភ័ន្ត / បន្លំ / ប្រឌិត |
| | ភាពស្របច្បាប់៖ | ស្របច្បាប់ / ខុសច្បាប់ |
| | ប្រភេទបន្លំអត្តសញ្ញាណ៖ | គ្មាន / ម៉ាកយីហោ / បុគ្គល |
| | គោលដៅនៃសារ៖ | បុគ្គល/ស្ថាប័ន/ក្រុមសង្គម/សង្គមទាំងមូល |
| អ្នកបកស្រាយ | មាតិកានៃសារ៖ | អនុត្តរភាព / ប្រឆាំង / បានចរចារ |
| | វិធានការដែលបានធ្វើ៖ | មិនអើពើ/ចែករំលែកគាំទ្រ/ចែករំលែកប្រឆាំង |

*រូបភាពទី២៖ ធាតុផ្សំទាំងបីនៃ «ព័ត៌មានច្របូកច្របល់»*

ជាឧទាហរណ៍ កត្តាជំរុញចិត្តរបស់មេខ្លោងដែល «បង្កើត» យុទ្ធនាការផ្សព្វផ្សាយព័ត៌មានមិនពិតដែលគាំទ្រដោយរដ្ឋ គឺខុសគ្នាឆ្ងាយពីពួកក្រុម «បញ្ជើចបញ្ជើ» ដែលទទួលប្រាក់កម្រៃតិចតួច សម្រាប់ការប្រែក្លាយប្រធានបទនៃយុទ្ធនាការទៅជាអត្ថបទ ចុះផ្សាយជាក់លាក់។ ហើយនៅពេលដែលសារមួយត្រូវបានចែកចាយ វាអាចត្រូវគេផលិតឡើងវិញ និងចែកចាយបន្តឥតឈប់ឈរ ដោយតួអង្គជាច្រើនជាមួយនឹងកត្តាជំរុញចិត្តផ្សេងៗគ្នា។ ឧទាហរណ៍ សារនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមមួយ អាចត្រូវបានសហគមន៍ជាច្រើនចែកចាយ បន្ទាប់មកប្រព័ន្ធសារព័ត៌មានបានយកវាទៅធ្វើជាដំណឹង (ដោយមិនបានពិនិត្យ

ពិច័យគ្រប់ជ្រុងជ្រោយ) និងផ្សព្វផ្សាយបន្តទៅដល់សហគមន៍ផ្សេងទៀត។ មានតែវិភាគហ្មត់ចត់ទៅលើ «ព័ត៌មានច្របូកច្របល់» តាមវិធីនេះប៉ុណ្ណោះ ទើបយើងអាចចាប់ផ្ដើមយល់ច្បាស់អំពីភាពស្រពេចស្រពិលទាំងនេះ[18]។

ឧទាហរណ៍អំពីគេហទំព័រមួយ ដែលចុះផ្សាយអត្ថបទអះអាងថា សម្ដេចសង្ឃ Pope បានប្រកាសគាំទ្របេក្ខភាពប្រធានាធិបតី Donald Trump ហើយមានការចែករំលែកយ៉ាងច្រើន គឺជាឧទាហរណ៍មួយដ៏ល្បីល្បាញបំផុត[19]។ នេះជាករណីសិក្សាដ៏មានប្រយោជន៍មួយ សម្រាប់ពិចារណាអំពីដំណាក់កាលផ្សេងៗគ្នានៃ «ព័ត៌មានច្របូកច្របល់» (រូបទី៣)។

18 កំណត់ចំណាំពីអ្នកកែសម្រួល៖ តារាងក្រាហ្វិកបន្ថែមដែលអាចត្រូវបានពិចារណា ត្រូវបានបង្កើតឡើងវិញដូចខាងក្រោម៖

| | តួអង្គ៖ រដ្ឋាភិបាល PSYOP គណបក្សនយោបាយ សហគ្រិន ក្រុមហ៊ុនទំនាក់ទំនងសាធារណៈ បុគ្គល ប្រព័ន្ធផ្សព្វផ្សាយ | បង្កលក្ខណៈដោយកម្មវិធីកុំព្យូទ័រ |
|---|---|---|
| បង្កើតមាតិកា - ឧ. អត្ថបទរឿង អត្ថាធិប្បាយ "likes" វីដេអូ រូបត្ថត | ជារឿយៗ លាក់អត្តសញ្ញាណ ឬប្រើអត្តសញ្ញាណលួចគេ ឬក្លែងក្លាយ | មានលក្ខណៈអន្តរកម្ម |
| ចែកចាយមាតិកា ដូចជាតាមរយៈការចែករំលែក និងការភ្ជាប់តំណ | ប្រើប្រាស់កម្មវិធីកុំព្យូទ័រដំណើរការស្វ័យប្រវត្តិ (bots) ជាជំនួយ | កម្មវិធីកុំព្យូទ័រដំណើរការស្វ័យប្រវត្តិ |
| "កែសម្រួល"មាតិកា ៖ លុប / កែ / សម្របសម្រួល / រក្សាទុក | ការលួចចូល និងល្បែង | កម្មវិធីក្បួនដោះស្រាយតាមកុំព្យូទ័រ (Algorithms) |

តារាង ៖ ក្របខ័ណ្ឌសម្រាប់ការបំពុល - របៀបដែលគេអាចធ្វើឱ្យខូចដល់សុចរិតភាពនៃព័ត៌មាន

ប្រភព: Berger, G. 2017. https://en.unesco.org/sites/default/files/fake_news_berger.pdf [accessed 22/04/2018]

19 WTOE 5News (2016). Pope Francis shocks world, endorses Donald Trump for President, releases statement. [online] Available at: https://web.archive.org/web/20161115024211/http://wtoe5news.com/us-election/pope-francis-shocks-world-endorses-donald-trump-for- president-releases-statement/ [accessed 06/04/2018].

**ការបង្កើត**

អត្ថបទប្រឌិតឡើងដោយមនុស្សមិនស្គាល់អត្តសញ្ញាណ

**ការផលិត**

អត្ថបទចុះផ្សាយនៅលើគេហទំព័រ WTOE5 News ជាផ្នែកមួយនៃគេហទំព័រព័ត៌មានប្រឌិតចំនួន ៤៣ ដែលបានចុះផ្សាយជាង៧៥០អត្ថបទ

**ការចែកចាយ**

អត្ថបទចែករំលែកលើ Facebookដោយមនុស្សម្នាក់ដែលធ្វើការឱ្យបណ្ដាញនៃគេហទំព័រព័ត៌មានប្រឌិតនេះ។

**ការផលិតឡើងវិញ**

អត្ថបទត្រូវបានចែករំលែកដោយមនុស្ស ដែលមានទំនាក់ទំនងនឹងបណ្ដាញនៃគេហទំព័រព័ត៌មានប្រឌិតនេះក្នុងការបន្ទរផលប៉ះពាល់នេះបន្ថែម ដើម្បីធ្វើអោយកាន់តែចំណេញច្រើន។

អត្ថបទចែករំលែកនៅលើ Facebook ដោយអ្នកគាំទ្ររបស់លោកត្រាំ។

អត្ថបទចែករំលែកដោយកម្លាំងដែលមានផលប្រយោជន៍ពីជ័យជំនះរបស់លោកត្រាំ ( ឧ. វាបានក្លាយជាមាតិកាដែលបន្ទរបន្ថែមដោយក្រុមត្រូល ឬកម្មវិធីកុំព្យូទ័រដំណើរការស្វ័យប្រវត្តិ) ។

អត្ថបទត្រូវបានចែករំលែកដោយអ្នកគាំទ្ររបស់លោកស្រីHillary Clinton ជាភ័ស្តុតាងបង្ហាញថាអ្នកគាំទ្ររបស់លោកត្រាំត្រូវគេបោកប្រាស់បាន។

*រូបភាពទី៣៖ ដំណាក់កាលនៃ «ព័ត៌មានច្របូកច្របល់»*

## គោលបំណងនៃមេរៀន

- ដើម្បីក្លាយជាអ្នកប្រើប្រាស់ព័ត៌មានលើអ៊ីនធឺណិត ដែលកាន់តែយល់ដឹងដោយគិតអំពីវិសាលគមទូលំទូលាយនៃព័ត៌មានមិនពិត និងព័ត៌មានខុស។
- គិតត្រិះរិះពិចារណាហ្មត់ចត់អំពីជន (ជារឿយៗជនអនាមិក ឬជនបន្លំអត្តសញ្ញាណ) ដែលបង្កើតព័ត៌មានប្រភេទទាំងនេះ តើព័ត៌មានទាំងនេះមានទម្រង់បែបណាខ្លះ តើគេអាចយកទៅបកស្រាយដូចម្ដេចខ្លះ ហើយតើព័ត៌មាននោះរាលដាលយ៉ាងដូចម្ដេច។
- ស្វែងយល់អំពីភាពស្មុគស្មាញនៃ «ព័ត៌មានច្របូកច្របល់» ជាពិសេសភាពចាំបាច់ក្នុងការសម្គាល់ភាពខុសគ្នា រវាងអ្នកដែលបង្កើតព័ត៌មាន

ប្រភេទទាំងនេះ ទម្រង់ដែលពួកគេប្រើ និងវិធីដែលក្រុមគោលដៅអាចនឹងចែករំលែកសារទាំងនេះ។

- ដើម្បីអាចពិចារណាអំពីការលំបាកដែលយើងមាន ចំពោះការដោះស្រាយបញ្ហាទាក់ទិននឹងព័ត៌មានមិនពិត និងព័ត៌មានខុស។
- ដើម្បីបង្ហាញឱ្យឃើញបញ្ហាដែល «ព័ត៌មានច្របូកច្របល់» ប៉ះពាល់លើលទ្ធិប្រជាធិបតេយ្យ និងសង្គមសេរី ដែលជាកម្មវត្ថុនៃមេរៀនមុននេះ។

## លទ្ធផលសិក្សា

នៅចុងបញ្ចប់នៃវគ្គនេះ សិស្សនឹងអាច ៖

១. យល់ច្បាស់អំពីរបៀបដែលអ្នកនយោបាយ ប្រព័ន្ធផ្សព្វផ្សាយដំណឹង និងគ្រឹះស្ថានសិក្សា ពិភាក្សានិងប្រើប្រាស់។

២. យល់អំពីផលប៉ះពាល់របស់ «ព័ត៌មានច្របូកច្របល់» និងការយល់ខុស។

៣. យល់អំពីប្រភេទនៃព័ត៌មានមិនពិត និងព័ត៌មានខុស ព្រមទាំងអនុវត្តវាទៅលើឧទាហរណ៍ខុសៗគ្នា។

៤. ត្រិះរិះពិចារណាអំពីឧទាហរណ៍មួយនៃព័ត៌មានមិនពិត ដែលវែកញែកធាតុផ្សំផ្សេងៗ ពោលគឺអ្នកណាជាអ្នកផ្តួចផ្តើម និង/ឬបង្កើតព័ត៌មាននោះ តើវាមានលក្ខណៈយ៉ាងដូចម្តេច និងតើអ្នកអានអាចបកស្រាយយ៉ាងដូចម្តេចជាដើម។

៥. ពន្យល់អ្នកផ្សេងទៀតអំពីសារៈសំខាន់ក្នុងការដែលយើង ត្រូវគិតពិចារណាអំពីបញ្ហានេះឱ្យបានហ្មត់ចត់។

## ទម្រង់នៃមេរៀន

### ការបង្រៀនជាទ្រឹស្តី និងសិក្ខាសាលាដែលមានការអនុវត្ត

បទបង្ហាញសម្រាប់មេរៀននេះ[20] ត្រូវបានតាក់តែងឡើង ដើម្បីគាំទ្រសិក្ខាសាលាដែលមានរយៈពេលវែង។ ក៏ប៉ុន្តែ សម្រាប់គោលបំណងនៃកម្មវិធីសិក្សានេះ អត្ថបទខាងលើគួរតែត្រូវបានប្រើប្រាស់ ជាមូលដ្ឋានសម្រាប់បាឋកថាទ្រឹស្តី។ លំហាត់អនុវត្តន៍ដែលមាននៅក្នុងបទបង្ហាញទាំងនេះ ត្រូវបានដកស្រង់ចេញសម្រាប់មេរៀនរយៈពេល៩០នាទី។ គ្រូបង្រៀនគួរតែធ្វើការជាមួយបទបង្ហាញទាំងនេះ ដោយប្រើប្រាស់សំណួរពិភាក្សា និងលំហាត់។

លំហាត់ទី១ ៖ ចូរមើលរូបភាពទី៤ខាងក្រោម ដែលពន្យល់អំពី «ប្រភេទទាំង៧នៃព័ត៌មានមិនពិត និងព័ត៌មានខុស»។ តាមរយៈការចាប់ដៃគូ ឬជាក្រុមតូចៗ គ្រូបង្រៀនអាចនឹងសុំឱ្យសិស្សផ្តល់ឧទាហរណ៍ ដែលត្រូវនឹងប្រភេទមេរៀនទាំងនេះ។




*រូបភាពទី៤ ៖ ប្រភេទទាំង៧នៃ «ព័ត៌មានច្របូកច្របល់» - firstdraftnews.org*

20 បទបង្ហាញអាចទាញយកតាមនេះ៖ at: https://en.unesco.org/sites/default/files/fake_news_syllabus_-_model_course_1_-_slide_deck.pdf

លំហាត់ទី២ ៖ ចូរពិនិត្យគំនូសពន្យល់រង្វង់ត្រួតគ្នា (គំនូសពន្យល់ទី១) ដែលពន្យល់អំពីភាពខុសគ្នារវាងព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្ម។ តើអ្នកយល់ស្របដែរឬទេ? តើមានធាតុណាមួយដែលត្រូវបន្ថែម? តើមានអ្វីដែលអ្នកចង់ជំទាស់ដែរឬទេ?

## ផ្សារភ្ជាប់ផែនការទៅនឹងលទ្ធផលសិក្សា

### ក. ទ្រឹស្តី

| ប្លាថកថា | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| ការធ្វើបទបង្ហាញ និងពិភាក្សាក្នុងថ្នាក់រៀន៖ ការចែករំលែកចំណេះដឹងពីមុនអំពីករណីនៃព័ត៌មានមិនពិត និងព័ត៌មានខុស | ៩០ នាទី | ១ |

### ខ. អនុវត្តន៍

| ប្លាថកថា | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| លំហាត់ទី១៖ ចូរមើលគំនូសពន្យល់ទី៤ ដែលពន្យល់អំពីប្រភេទនៃព័ត៌មានមិនពិត និងព័ត៌មានខុស និងធ្វើការជាគូ ឬជាក្រុមតូចៗ រួចស្វែងរកឧទាហរណ៍ដែលត្រូវនឹងប្រភេទទាំងនេះ។ | ៤៥ នាទី | ២ |
| លំហាត់ទី២៖ ចូរពិនិត្យមើលគំនូសពន្យល់ទី១ ដែលពន្យល់អំពីភាពខុសគ្នារវាងព័ត៌មានខុស ព័ត៌មានមិនពិត និងព័ត៌មានបង្កព្យសនកម្ម។ តើអ្នកយល់ស្របដែរ ឬទេ? តើមានអ្វីខ្វះបាត់? តើមានអ្វីដែលអ្នកចង់ជំទាស់ដែរឬទេ? | ៤៥ នាទី | ៣ |

## លំហាត់ស្រាវជ្រាវបន្ថែម

បង្កើតគ្រោងអត្ថបទរឿងមួយ[21]សម្រាប់ផលិតវីដេអូពន្យល់មួយ ដែលក្រុមហ៊ុនប្រព័ន្ធផ្សព្វផ្សាយសង្គម អាចយកទៅផ្សាយនៅពីលើ Newsfeed ដើម្បីអប់រំអ្នកប្រើប្រាស់អំពីអ្វីដែលពួកគេគួរប្រុងប្រយ័ត្ន នៅពេលដែលពួកគេប្រើប្រាស់ព័ត៌មាននៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។ សិស្សអាចដាក់បញ្ចូលឧទាហរណ៍នៃករណីព័ត៌មានមិនពិត និងព័ត៌មានខុស ដែលពួកគេធ្លាប់បានជួបប្រទះនៅក្នុងពេលសិក្សាវគ្គនេះ ដើម្បីបង្ហាញឱ្យគេឃើញហានិភ័យនៃការចុច «Like» និង «Share» និងការចូលរួមយោបល់លើអ្វីមួយ ដែលក្រុមគោលដៅមិនប្រាកដខ្លួនឯងថាជាការពិតឬអត់ផងនោះ។ ឧបករណ៍សម្រាប់ធ្វើគ្រោងអត្ថបទរឿងអាចរកបាននៅទីនេះ ៖ http://www.storyboardthat.com/

## ឯកសារបន្ថែម

បទបង្ហាញ: *https://en.unesco.org/sites/default/files/fake_news_syllabus_-_model_course_1_-_slide_deck.pdf*

## អំណានបន្ថែម


Berger, G. 2017. Fake news and the future of professional and ethical journalism. Presentation at conference organized by the Joint Extremism/Digital Europe Working Group Conference of the European Parliament on 6 September 2017 https:// en.unesco.org/sites/default/files/fake_news_berger.pdf

Busby, M. I. Khan & E. Watling (2017) Types of Misinformation During the UK Election, First Draft News, Available at https://firstdraftnews.com/misinfo-types-uk-election/

Guy, H. (2017) Why we need to understand misinformation through visuals, First Draft News, Available at https://firstdraftnews.com/understanding-visual-misinfo/


21 ចំណាំ៖ គម្រោងនៃរឿងជាដំណើរផែនការច្នៃប្រឌិត ហើយត្រូវបានប្រើក្នុងការផ្សាយពាណិជ្ជកម្ម ខ្សែភាពយន្តឯកសារ និងសារព័ត៌មានដែលបង្ហាញពីរូបភាពជាស៊ុមមួយដែលតំណាងឱ្យមាតិកា រូបភាព លំហូរអត្ថបទ វីដេអូ ឬសំឡេង។

Karlova, N.A. and Fisher, K.E. (2012) “Plz RT”: A Social Diffusion Model of Misinformation and Disinformation for Understanding Human Information Behaviour. Proceedings of the ISIC2012 (Tokyo). Available at https://www.hastac.org/sites/default/files/documents/ karlova_12_isic_misdismodel.pdf

Silverman, C. (2017) This is How your Hyperpartisan Political News Get Made, BuzzFeed News, Available at https://www.buzzfeed.com/craigsilverman/ how-the-hyperpartisan-sausage-is-made?

Wardle, C. & H. Derakhshan (2017) Information Disorder: Towards an Interdisciplinary Framework for Research and Policy-Making. Council of Europe. Available at https://firstdraftnews.com/resource/coe-report/

Wardle, C. & H. Derakhshan (2017) One year on, we’re still not recognizing the complexity of information disorder online, First Draft News, Available at https://firstdraftnews.org/coe_infodisorder/

Zuckerman, E. (2017) Stop Saying Fake News, It’s Not Helping, My Heart’s in Accra, Available at http://www.ethanzuckerman.com/blog/2017/01/30/stop-saying-fake-news-its-not-helping/

# ការវិវត្តនៃឧស្សាហកម្មដំណឹង៖ បច្ចេកវិទ្យាឌីជីថល ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការសាយភាយព័ត៌មានខុស និងព័ត៌មានមិនពិត

*Julie Posetti*



# មេរៀនទី៣

## សង្ខេប

គេចាត់ទុកសម័យឌីជីថលជា «យុគសម័យមាសសម្រាប់វិស័យសារព័ត៌មាន»[1]។ ការពិតបច្ចេកវិទ្យាឌីជីថល បានផ្តល់លទ្ធភាពដល់ការទទួលបាន និងប្រើប្រាស់ឃ្លាំងទិន្នន័យដ៏ច្រើនសម្រាប់សារព័ត៌មានបែបស៊ើបអង្កេត[2] គំរូថ្មីនៃការធ្វើសេចក្តីរាយការណ៍ដំណឹងសហការឆ្លងព្រំដែន លទ្ធភាពទទួលបាននិងប្រើប្រាស់ឃ្លាំងចំណេះដឹង និងធនធានចម្រុះដ៏ច្រើនដោយងាយស្រួលបំផុត។ ទន្ទឹមនឹងនេះ យុគសម័យនេះ ក៏ប្រឈមនឹងការផ្លាស់ប្តូរផ្នែករចនាសម្ព័ន្ធដែលមិនធ្លាប់មាន និងកំពុងតែបន្តលើឧស្សាហកម្មដំណឹងដែរ។ សារព័ត៌មានកំពុងរងនូវ«ការវាយប្រហារ[3]» ដោយប្រឈមនឹង «ព្យុះសង្ឃរា» នៃសម្ពាធប្រសព្វគ្នាដែលពូនផ្តុំជា «ព័ត៌មានច្របូកច្របល់»[4]។ សម្ពាធទាំងនេះរួមមាន ៖

- ➢ ការកើនឡើងនៃយុទ្ធនាការឃោសនាតាមប្រព័ន្ធកុំព្យូទ័រ[5] និង «ការប្រើប្រាស់ភាពមិនទុកចិត្តជាអាវុធ»[6]។
- ➢ ការរំខាននៃការផ្សាយពាណិជ្ជកម្មបែបឌីជីថល ដែលបណ្តាលឱ្យគំរូអាជីវកម្មបែបប្រពៃណី សម្រាប់វិស័យផ្សព្វផ្សាយដំណឹងដួលរលំ និងអត្រាខ្ពស់នៃភាពគ្មានការងារធ្វើ។
- ➢ បរាជ័យនៃការផ្សាយពាណិជ្ជកម្មតាមបែបឌីជីថល ក្នុងការជួយគាំទ្រដល់វិជ្ជាជីវៈសារព័ត៌មាន ជំនួសឱ្យការផ្សាយពាណិជ្ជកម្មនៅលើការបោះពុម្ព (ឥឡូវនេះក្រុមហ៊ុន Google និង Facebook គឺជាអ្នកទទួលផលដ៏ធំបំផុត

---

1 Posetti, J. (2017). Protecting Journalism Sources in the Digital Age UNESCO, Paris. p 104 http://unesdoc.unesco.org/images/0024/002480/248054E.pdf [accessed 01/04/2018]. (Citing ICIJ Director, Gerard Ryle)

2 Obermayer, B. & Obermaier, F. (2016). The Panama Papers: Breaking the story of how the rich and powerful hide their money, One World, London

3 UNESCO (2018). World Trends in Freedom of Expression and Media Development 2017/2018. UNESCO, Paris. http://unesdoc.unesco.org/images/0025/002597/259756e.pdf [accessed 29/03/2018].

4 Wardle, C. & Derakhshan, H. (2017). Council of Europe, Op Cit. Note: the video recording of a panel discussion at the 2018 International Journalism Festival, convened by the chapter author, is a resource that instructors may wish to use for the operationalization of this module. https://www.journalismfestival.com/programme/2018/journalisms-perfect-storm-confronting-rising-global-threats-from-fke-news- to-censorship-surveillance-and-the-killing-of-journalists-with-impunity

5 Clarke, R. & Gyemisi, B. (2017). Digging up facts about fake news: The Computational Propaganda Project. OECD. http://www.oecd.org/governance/digging-up-facts-about-fake-news-the-computational-propaganda-project.htm [accessed 01/04/2018].

6 UNESCO (2017). States and journalists can take steps to counter 'fake news'. UNESCO, Paris. https://en.unesco.org/news/states-and- journalists-can-take-steps-counter-fake-news [accessed 29/03/2018].

ពីការលក់ការផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធឌីជីថល)[7]។

- ភាពលឿនលឿននៃបច្ចេកវិទ្យាឌីជីថលដែលធ្វើឱ្យប្រែប្រួលការស៊ីឈ្នួលផលិតមាតិកា ការផលិត ការបោះពុម្ពផ្សាយ និងការចែកចាយមាតិកា ដែលធ្វើឱ្យមានសម្ពាធកាន់តែកើនឡើងលើពេលកំណត់ និងបណ្តាលឱ្យមានកំណើននៃការបាត់បង់ការងារធ្វើ។

- ការបៀតបៀនតាមអ៊ីនធឺណិត ដែលផ្តោតលើអ្នកសារព័ត៌មាន (ជាពិសេសស្ត្រី) ប្រភព និងក្រុមគោលដៅរបស់ពួកគេ[8]។

- វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលផ្តោតលើក្រុមគោលដៅជាធំ ក្នុងការស្វែងរក និងការចែកចាយមាតិកា[9] និងធ្វើឱ្យពួកគេក្លាយជាសហប្រតិបត្តិករក្នុងការផលិតដំណឹង (ដែលផ្តល់ប្រយោជន៍ជាច្រើន ប៉ុន្តែក្នុងពេលជាមួយគ្នានោះ ក៏ធ្វើឱ្យរង្គោះរង្គើអំណាចប្រព័ន្ធផ្សព្វផ្សាយដំណឹងប្រពៃណី និងប៉ះពាល់ទៅលើបទដ្ឋានផ្ទៀងផ្ទាត់ការពិតដែរ)[10]។

- ការរំពឹងចង់បានដំណឹង «តាមតម្រូវការ» របស់ក្រុមគោលដៅ ការបញ្ជូនដំណឹងតាមប្រព័ន្ធទូរស័ព្ទចល័ត និងការចូលរួមភ្លាមៗនៅលើប្រព័ន្ធសង្គមកាន់តែបង្កើនសម្ពាធមួយកម្រិតទៀត លើអ្នកសារព័ត៌មានវិជ្ជាជីវៈ ដែលកំពុងប្រឈមមុខនឹងការខ្វះធនធាន ក្នុងវដ្តផលិតដំណឹងឥតឈប់ឈរ។

- អ្នកផ្សាយដំណឹងខំប្រឹងរក្សាក្រុមគោលដៅ ខណៈលែងសូវមានឧបសគ្គក្នុងការបោះពុម្ពផ្សាយ ដោយធ្វើឱ្យបុគ្គល ឬស្ថាប័នណាក៏អាចមានលទ្ធភាពផលិតមាតិកា គេចផុតពីប្រព័ន្ធត្រួតពិនិត្យគុណភាពជាប្រពៃណី និងប្រកួតប្រជែងដណ្តើមការចាប់អារម្មណ៍ ក្នុងនោះរាប់ទាំងអ្នកនយោបាយមានឥទ្ធិពល ដែលព្យាយាមបង្ខូចភាពអាចជឿជាក់បានរបស់សេចក្តីរាយការណ៍បែបរិះគន់[11]។

---

7 Kollewe, J. (2017). Google and Facebook bring in one-fifth of global ad revenue The Guardian, May 2nd 2017. https://www.theguardian.com/media/2017/may/02/google-and-facebook-bring-in-one-fifth-of-global-ad-revenue [accessed 29/03/2018].

8 សូមពិនិត្យមើលមេរៀនទី៧

9 Nielsen, R. K. & Schroeder, C. K. (2014). The Relative Importance of Social Media for Accessing, Finding and Engaging With News in Digital Journalism, 2(4) http://www.tandfonline.com/doi/abs/10.1080/21670811.2013.872420 [accessed 29/03/2018].

10 Posetti, J. & Silverman, C. (2014). When Good People Share Bad Things: The Basics of Social Media Verification in Posetti (Ed) Trends in Newsrooms 2014 (WAN-IFRA, Paris). http://www.wan-ifra.org/sites/default/files/field_media_image_file_attach/WAN-IFRA_Trends Newsrooms_2014.pdf [accessed 29/03/2018].

11 Cadwalladr, C. (2017). Trump, Assange, Bannon, Farage...bound together in an unholy alliance, The Guardian, October 28th 2017. https://www.theguardian.com/commentisfree/2017/oct/28/trump-assange-bannon-farage-bound-together-in-unholy-alliance [accessed 29/03/2018].

- ក្រុមហ៊ុនសារព័ត៌មានឌីជីថលថ្មីៗ ដែលមានឥទ្ធិពលតិចតួច និងរកប្រាក់ចំណូលមិនច្រើន គ្រាន់តែជាការបំពេញចន្លោះប្រហោង ដែលជាការបរាជ័យរបស់កាសែតតែប៉ុណ្ណោះ។
- ភាពសឹករេចរឹលនៃទំនុកចិត្តចំពោះវិជ្ជាជីវៈសារព័ត៌មាន និងអង្គភាពសារព័ត៌មាន កាន់តែធ្វើឱ្យក្រុមគោលដៅ សោយចិត្ត ដែលការណ៍នេះធ្វើឱ្យប្រាក់ចំណេញកាន់តែតិចទៅៗ និងជំរុញឱ្យការរាលដាលនៃ «ព័ត៌មានច្របូកច្របល់» កាន់តែខ្លាំងឡើង។

ជាលទ្ធផល ខ្សែបន្ទាត់រវាងការពិត ការកម្សាន្ត ការផ្សាយពាណិជ្ជកម្ម ការប្រឌិត និងរឿងប្រលោមលោកកាន់តែមានភាពស្រពេចស្រពិល។ នៅពេលដែលព័ត៌មានមិនពិតត្រូវបានផ្សព្វផ្សាយ តាមប្រព័ន្ធផ្សព្វផ្សាយដំណឹងសង្គម ដែលពឹងផ្អែកលើការចែករំលែកក្នុងចំណោមមិត្តភក្តិ ធ្វើឱ្យមាតិកានោះកាន់តែរាលដាលខ្លាំង ដែលគេមិនអាចទាញត្រលប់មកវិញ ទោះបីអ្នកសារព័ត៌មាន និងអ្នកផ្ទៀងផ្ទាត់ការពិតដទៃទៀត បកអាក្រាតព័ត៌មានមិនពិតនោះដោយជោគជ័យក្តី។

មេរៀននេះ នឹងនាំសិស្សឱ្យយល់អំពីបរាជ័យនៃអាជីវកម្ម ប្រព័ន្ធផ្សព្វផ្សាយដំណឹងជាច្រើននៅក្នុងសម័យឌីជីថល បូករួមនឹងដំណើរផ្លាស់ប្តូរនៃបច្ចេកវិទ្យាឌីជីថល និងវត្តមាននៃប្រព័ន្ធផ្សព្វផ្សាយសង្គមផ្តល់ភាពស្របច្បាប់ និងសាយភាយនៃព័ត៌មានមិនពិត[12]។ វាក៏នឹងជួយសិស្សក្នុងការវិភាគដោយត្រិះរិះទៅលើការឆ្លើយតបរបស់ប្រព័ន្ធផ្សព្វផ្សាយដំណឹងចំពោះ «ព័ត៌មានច្របូកច្របល់»។ ជាងនេះទៀត វាផ្តល់ព័ត៌មានដល់សិស្សអំពីការអនុវត្តល្អៗនៅក្នុងវិស័យនេះ ដែលកំពុងផុសឡើង សម្រាប់ការគ្រប់គ្រងបញ្ហានេះ។

12 Posetti, J. & Silverman, C. (2014). Op cit

# គ្រោងនៃមេរៀន

## ការដោះស្រាយបញ្ហា

### រចនាសម្ព័ន្ធនៃបុព្វហេតុដែល «ព័ត៌មានច្របូកច្របល់» ប៉ះពាល់ឧស្សាហកម្មដំណឹង

### ១. ការដួលរលំអាជីវកម្មបែបប្រពៃណី

ការធ្លាក់ចុះយ៉ាងឆាប់រហ័សនៃចំណូល ពីការផ្សាយពាណិជ្ជកម្មបែបប្រពៃណី ដែលជាគំរូមូលនិធិដែលបានទ្រទ្រង់អាជីវកម្មសារព័ត៌មាន អស់រយៈពេលជិតពីរសតវត្សរ៍កន្លងមកនេះ និងបរាជ័យនៃការផ្សាយពាណិជ្ជកម្មបែបឌីជីថលក្នុងការបង្កើតប្រាក់ចំណេញគ្រប់គ្រាន់ បានរុញច្រានទៅដល់សម័យមួយនៃការធ្វើពិសោធជាបន្ទាន់ និងកាន់តែច្រើនឡើងៗ ដើម្បីរកវិធីធ្វើឱ្យអាជីវកម្មសារព័ត៌មានមាននិរន្តរភាព។ ប៉ុន្តែ ការដួលរលំនៃឧស្សាហកម្មដំណឹងកាន់តែបន្ថែមល្បឿន រួមនឹងការធ្លាក់ចុះយ៉ាងគំហុកនៃចំនួនកាសែត ការកែទម្រង់យ៉ាងគំហុក និងការបញ្ចប់ការងារបុគ្គលិកក្នុងចំនួនច្រើន ដែលឥឡូវនេះក្លាយទៅជាបទពិសោធធម្មតាទៅហើយ ក្នុងការិយាល័យដំណឹងសម័យឌីជីថល។ ឥរិយាបថអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដែលកំពុងប្រែប្រួល និងការសាយភាយនៃប្រព័ន្ធផ្សព្វផ្សាយសង្គម រួមនឹងវត្តមាននៃទូរស័ព្ទទំនើបដែលថោកថ្លៃ និងអាចប្រើកម្មវិធីបានច្រើន ក៏ជាហេតុបណ្តាលឱ្យធ្លាក់ចុះចំនួនអ្នកប្រើប្រាស់ផលិតផលដំណឹងបែបប្រពៃណី ដោយងាកទៅរករបៀបចែករំលែកព័ត៌មានពីមិត្តភក្តិ ដែលនាំឱ្យប្រាក់ចំណូលកាន់តែធ្លាក់ចុះថែមទៀត។

ផលប៉ះពាល់ដែលពាក់ព័ន្ធទៅនឹង «ព័ត៌មានច្របូកច្របល់» រួមមាន៖

- ការកាត់បន្ថយធនធាននៅក្នុងការិយាល័យដំណឹង (បុគ្គលិក និងថវិកា) ដែលបណ្តាលឱ្យធ្លាក់ចុះការពិនិត្យពិច័យទៅលើប្រភព និងព័ត៌មាន និងការថយចុះនៃការធ្វើសេចក្តីរាយការណ៍«ដល់ទីកន្លែង»
- កំណើនសម្ពាធកាលកំណត់សម្រាប់ការផលិតដំណឹង រួមទាំងដំណើរការត្រួតពិនិត្យគុណភាពដែលថយចុះ និងការបាត់បង់ការងារ ខណៈដែលតម្រូវការផលិតមាតិកា នៅតែបន្តមានដើម្បីផ្សាយនៅលើគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយសង្គម

- ពេលវេលា និងធនធានកាន់តែតិចសម្រាប់ «ការត្រួតពិនិត្យ និងតុល្យភាព» (ក្នុងនោះរាប់បញ្ចូលទាំងការផ្ទៀងផ្ទាត់ការពិត និងការកែសម្រួលអត្ថបទ )
- ការពឹងផ្អែកជ្រុលលើ "អត្ថបទផ្សាយពាណិជ្ជកម្មដើម (Native advertising)"[13] ដែលផ្ទៀងផ្ទាត់មិនសូវល្អ ប៉ុន្តែទទួលបានកម្រៃច្រើន និងចំណងជើងបញ្ឆោត ដែលនាំទៅរកការបាត់បង់ទំនុកចិត្ត កាន់តែច្រើនថែមទៀតពីក្រុមគោលដៅ

## ២. វិវត្តន៍ផ្នែកបច្ចេកវិទ្យាឌីជីថលនៃការិយាល័យដំណឹង និងការសរសេររឿង

ទសវត្សរ៍ឆ្នាំ ២០០០ បានធ្វើឱ្យរញ្ជួយដល់ពិភពប្រព័ន្ធផ្សព្វផ្សាយមួយភាគធំ[14] ដែលនាំឱ្យរំខានដល់គំរូ និងដំណើរការនៃការបង្កើត ការចែកចាយ និងការប្រើប្រាស់ដំណឹង ពេលដែលសម័យឌីជីថលចូលមកដល់។ វាបានផ្តល់ឱកាស និងភាពប្រឈមដែលមិនធ្លាប់មានក្នុងពេលតែមួយ។ ឥឡូវនេះ ការវិវត្តផ្នែកបច្ចេកវិទ្យាឌីជីថលរបស់ឧស្សាហកម្មដំណឹង និងអាជីពសារព័ត៌មានត្រូវគេយល់ថាជាដំណើរការជានិរន្តរ៍មួយ ដែលជំរុញព្រមពេលជាមួយគ្នា ដោយការប្រែប្រួលឥរិយាបថក្រុមគោលដៅ (ឧ. ការចែកចាយមាតិកាពីមិត្តម្នាក់ទៅមិត្តម្នាក់ទៀតទៅតាមតម្រូវការ) និងបច្ចេកវិទ្យា (ដូចជាការមកដល់នៃកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម បរិស្ថាននិម្មិត បញ្ញាសិប្បនិម្មិត និងកំណើនលទ្ធភាពនៃការប្រើទូរស័ព្ទទំនើប)[15]។ ដូច្នេះទើបមានតម្រូវការចាំបាច់ជាបន្តបន្ទាប់ សម្រាប់ការកសាងសមត្ថភាពផ្នែកឌីជីថល។

ផលប៉ះពាល់ដែលពាក់ព័ន្ធនឹង «ព័ត៌មានច្របូកច្របល់» រួមមាន ៖

- ការរួមបញ្ចូលគ្នានៃប្រព័ន្ធផ្សព្វផ្សាយច្រើនទម្រង់ (Media convergence)៖ បច្ចុប្បន្នអ្នកសារព័ត៌មានជាច្រើន ត្រូវបានចាត់តាំងឱ្យផលិតមាតិកាសម្រាប់កម្មវិធីជាច្រើនក្នុងពេលដំណាលគ្នា (ពីកម្មវិធីទូរស័ព្ទដៃរហូតដល់ការបោះពុម្ពជាកាសែត) ដែលនាំឱ្យពួកគេមានពេលវេលាកាន់តែតិច

---

13 ‘Native Advertising’ គឺជាពាក្យក្នុងឧស្សាហកម្មសារព័ត៌មានដើម្បីសំដៅទៅលើមាតិកាដែលត្រូវបានគេផ្តល់ប្រាក់ ដើម្បីឱ្យធ្វើត្រាប់តាមការរាយការណ៍។ វាត្រូវបានចាត់ទុកថាជាការអនុវត្តប្រកបដោយក្រមសីលធម៌ ដែលមានមាតិកា "បង់ប្រាក់ (paid)" ប៉ុន្តែដោយសារខ្លាចខ្វះអ្នកអានបានធ្វើឱ្យមិនមានតម្លាភាពក្នុងករណីខ្លះ។

14 Nielsen, R. K. (2012). The Ten Years That Shook the Media World: Big Questions and Big Trends in International Media Developments (Reuters Institute for the Study of Journalism, Oxford). https://reutersinstitute.politics.ox.ac.uk/sites/default/files/2017-09/Nielsen%20-%20 Ten%20Years%20that%20 Shook%20the%20Media_0.pdf [accessed 29/03/2018].

15 For detailed global analysis of digital media trends, see the Reuters Institute for the Study of Journalism’s (RISJ) Digital News Report. The 2018 edition is available at: http://www.digitalnewsreport.org/survey/2018/overview-key-findings-2018/

សម្រាប់ការធ្វើសេចក្តីរាយការណ៍បែបសកម្ម ដែលខុសគ្នាដាច់ពីការធ្វើដំណឹងបែបប្រតិកម្ម ដូចជាការសរសេរឡើងវិញ លើមាតិកាទំនាក់ទំនងសាធារណៈ ដោយគ្មានការត្រួតពិនិត្យពិច័យបានត្រឹមត្រូវ។

- អ្នករាយការណ៍ដំណឹងតម្រូវឱ្យពិនិត្យ កែសម្រួល និងចេញផ្សាយមាតិការបស់ខ្លួនឯងដោយផ្ទាល់ ដោយគ្មានការត្រួតពិនិត្យឡើងវិញត្រឹមត្រូវ[16]។
- កាលកំណត់សម្រាប់ការផលិតមាតិកា ដែលផ្សាយបែបបច្ចេកវិទ្យាគឺ «ពេលនេះ» ដែលនាំឱ្យមានហានិភ័យខ្ពស់ទៅលើកំហុស។
- ការចុះផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមមុនគេ គឺជារឿងធម្មតា ដោយអ្នករាយការណ៍ដំណឹងបង្ហោះអត្ថបទរឿងរបស់ខ្លួន ទៅក្នុងគណនីប្រព័ន្ធសង្គមឯកជនរបស់ខ្លួន និង/ឬគណនីរបស់ក្រុមហ៊ុនដើម្បីបំពេញតម្រូវការក្រុមគោលដៅ ដែលចង់បានដំណឹងទាន់ហេតុការណ៍។ ការអនុវត្តនានារួមមាន «ការផ្សាយផ្ទាល់លើប្រព័ន្ធផ្សព្វផ្សាយសង្គម Twitter» វីដេអូ «ផ្សាយផ្ទាល់លើបណ្តាញ Facebook» និងសកម្មភាពសារព័ត៌មានដទៃទៀត ដែលមិនចាំបាច់ឆ្លងកាត់ការត្រួតពិនិត្យផ្នែកនិពន្ធ (ដែលស្រដៀងគ្នាទៅនឹងការផ្សាយផ្ទាល់ដែរ) នាំឱ្យគេគិតថា «ផ្សាយមុន ពិនិត្យក្រោយ»។
- ការពឹងផ្អែកលើការវិភាគទិន្នន័យ ដែលផ្តោតសំខាន់តែទៅលើចំនួនអ្នកមើលជាជាង «ពេលវេលាផ្តោតយកចិត្តទុកដាក់» និង «ពេលវេលាដែលចំណាយ» (ជារង្វាស់ដែលមានប្រយោជន៍ជាងសម្រាប់សារព័ត៌មាន ដែលសរសេរជាអត្ថបទវែងៗ និងមានគុណភាព) ត្រូវគេប្រើប្រាស់ដើម្បីកំណត់ការទារតម្លៃថ្លៃសម្រាប់ការផ្សាយពាណិជ្ជកម្មបែបឌីជីថល ដែលកាន់តែកម្រ និងមានតម្លៃទាប។
- ការអនុវត្តមធ្យោបាយបញ្ឆោតដោយប្រើចំណងជើងបំភ័ន្ត (Clickbait) ដើម្បីទាក់ទាញក្រុមគោលដៅ ឱ្យចុចលើតំណភ្ជាប់នៃអត្ថបទ ដែលមានការពិពណ៌នាមិនពិត ត្រូវគេធ្វើឡើងដើម្បីជំរុញកំណើនអ្នកចូលអាន ឬអ្នកមើល ប៉ុន្តែវាជាប់ពាក់ព័ន្ធនឹងការបាត់បង់ទំនុកចិត្តលើសារព័ត៌មានវិជ្ជាជីវៈ។
- ការចង់បានឱ្យគេអានច្រើន និងចែករំលែកយ៉ាងផុសផុល ដោយមិនគិត

16 See Australian Community Media (ACM) case study: Robin, M. (2014). Who needs subs? Fairfax turns to reporter-only model Crikey. https:// www.crikey.com.au/2014/10/16/who-needs-subs-fairfax-turns-to-reporter-only-model/ [accessed 29/03/2018]. (Note: this method is now entrenched across Fairfax Media’s regional, rural and community publications)

អំពីគុណភាព និងភាពត្រឹមត្រូវ។ នេះជាបញ្ហាមួយដែលនឹងធ្វើឱ្យកាន់តែអាក្រក់ថែមទៀត កើតឡើងដោយសារ «ការរៀនរបស់ម៉ាស៊ីន»។

➢ ការកើនឡើងនៃក្រុមផ្ទៀងផ្ទាត់ការពិតនៅក្នុងការិយាល័យដំណឹង និងជាធាតុចេញនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយ

**៣. ការរាលដាល ឬការសាយភាយ (Virality) ៖ របៀបដែលព័ត៌មានមិនពិតរាលដាលយ៉ាងឆាប់រហ័សនៅក្នុងប្រព័ន្ធអេកូឡូស៊ីដំណឹងថ្មី**

*ក) ការកើនឡើងនៃចំនួនក្រុមគោលដៅ*

សម័យបច្ចេកវិទ្យាបានលុបបំបាត់ឧបសគ្គនានា ដែលរាំងស្ទះដល់ការផ្សព្វផ្សាយ[17] និងបង្ហាញសញ្ញានៃ «ការផ្ទេរឧបករណ៍ផលិតទៅឱ្យអ្នកដែលពីមុនគេស្គាល់ថា ជាក្រុមគោលដៅ[18]» ដែលបានក្លាយជាសហផលិតករនៃខ្លឹមសារ ក្នុងនោះរាប់បញ្ចូលទាំងដំណឹងដែលជាមុខងារ និងការអនុវត្តមួយឈ្មោះថា «ការបង្កើតខ្លឹមសារដោយអ្នកប្រើប្រាស់»[19]។ ដំបូងឡើយ គេបង្កើតក្រុមគោលដៅតាមរយៈអ៊ីម៉េល និងកន្លែងជជែកលេង (chat room) នៅមុនពេលដែលប្រព័ន្ធផ្សព្វផ្សាយសង្គម ជួយបង្កើនលទ្ធភាពយ៉ាងខ្លាំងក្លាដល់អ្នកអាន។

*ខ) ការចាប់បដិសន្ធិនៃប្រព័ន្ធផ្សព្វផ្សាយសង្គម*

នៅក្នុងប្រទេសជាច្រើន គិតត្រឹមចុងទសវត្សរ៍ ២០០០ Twitter និង Facebook បានចូលរួមជាមួយ YouTube ក្លាយជាតួអង្គដ៏សំខាន់នៃប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយជះឥទ្ធិពលលើការអនុវត្ត និងអត្តសញ្ញាណវិជ្ជាជីវៈរបស់អ្នកសារព័ត៌មាន (ជាពិសេសទាក់ទងនឹងការផ្ទៀងផ្ទាត់ ការចូលរួមរបស់ក្រុមគោលដៅ និងការប៉ះទង្គិចគ្នារវាងដែនបុគ្គល និងដែនសាធារណៈដែលកើតឡើងនៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម[20]) និងការចែកចាយមាតិកា។ ខណៈដែលបុគ្គលនានា បានបង្កើតបណ្តាញដែលឈរលើទំនុកចិត្ត ការចែកចាយមាតិកាពីមិត្តម្នាក់ទៅមិត្តម្នាក់ (ជាពិសេសនៅលើFacebook) បានចាប់ផ្តើមប្រកួតប្រជែងជាមួយវិធីផ្សព្វផ្សាយ

---

17 Gillmor, D. (2004). We, the Media: Grassroots Journalism By the People, For the People (O'Reilly). http://www.authorama.com/we-the- media-8.html [accessed 29/03/2018].

18 Rosen, J. (2006). The People Formerly Known as the Audience, PressThink blog (June 27th, 2006). http://archive.pressthink.org/2006/06/27/ppl_frmr.html [accessed 29/03/2018].

19 Bruns, A. (2008). Blogs, Wikipedia, Second Life, and Beyond: From Production to Produsage. Peter Lang, New York. See also: Bruns A (2006) Collaborative Online News Production. Peter Lang, New York.

20 Posetti, J. (2009). Transforming Journalism...140 Characters at a Time Rhodes Journalism Review 29, September 2009. http://www.rjr.ru.ac.za/rjrpdf/rjr_no29/Transforming_Journ.pdf [accessed at 29/03/2018].

មាតិកាជាប្រពៃណី។

អ្នកប្រើប្រាស់ជ្រើសរើសលំហូរមាតិកាដោយខ្លួនឯង ក្នុងនោះរាប់ទាំងមាតិកាពីអង្គភាពផ្តល់សេវាដំណឹង អ្នកសារព័ត៌មាន និងអ្នកផ្តល់ព័ត៌មានដែលអាចជឿជាក់បានដទៃទៀត ដោយគ្មានការសម្របសម្រួល។ ជាលទ្ធផលនៃការចែកចាយតាម «បណ្តាញទំនុកចិត្ត» (អ្នកប្រើប្រាស់ និងមិត្តភក្តិ) មាតិកាមិនត្រឹមត្រូវ មិនពិតទុច្ចរិត និងមាតិកាឃោសនាដែលក្លែងខ្លួនជាដំណឹង កាន់តែមានភាពទាក់ទាញខ្លាំងឡើងៗ។ អ្នកស្រាវជ្រាវបានរកឃើញថា ទាំងមាតិកាដែលធ្វើឱ្យរំជួលចិត្ត និងមាតិកាដែលចែករំលែកដោយមិត្តភក្តិ ឬដោយសមាជិកគ្រួសារទំនងជាត្រូវបានគេចែកចាយបន្តកាន់តែច្រើន នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម[21]។

ខណៈដែលអ្នកសារព័ត៌មាន និងស្ថាប័នដំណឹង បានបង្កប់ខ្លួនក្នុងកម្មវិធីប្រព័ន្ធសង្គមទាំងនេះ សម្រាប់គោលបំណងនៃការប្រមូលព័ត៌មាន ការចូលរួមរបស់ក្រុមគោលដៅ និងការចែកចាយមាតិកា (ពួកគេចាំបាច់ត្រូវតែស្ថិតនៅទីណាដែលក្រុមគោលដៅរបស់ខ្លួនមានសកម្មភាពខ្លាំង) «ទំនោរនៃការច្រោះព័ត៌មានដែលចង់បាន[22] ឬ «ទស្សនៈចង្អៀតចង្អល់[23]» មានការរីកដុះដាលខ្លាំង (ទោះបីវាមិនមែនបិទជិត ឬមិនមានប្រព័ន្ធការពារក៏ដោយ)។ កត្តាទាំងនេះបានកាត់បន្ថយលទ្ធភាពមើលឃើញទស្សនៈផ្សេងទៀត និងព័ត៌មានដែលបានផ្ទៀងផ្ទាត់ត្រឹមត្រូវរបស់អ្នកប្រើប្រាស់ជាច្រើន។ ការវិវត្តបែបនេះ បានពង្រីកហានិភ័យទាក់ទងនឹង «ព័ត៌មានច្របូកច្របល់»។

ផលប្រយោជន៍នៃសារព័ត៌មាន ដែលកសាងបណ្តាញជាមួយក្រុមគោលដៅ រួមមានលទ្ធភាពទទួលបានព័ត៌មានពីប្រភពចម្រុះ អនុវត្តការផ្ទៀងផ្ទាត់ដោយសហការគ្នា[24] (ដែលមានប្រយោជន៍ក្នុងការកែតម្រូវព័ត៌មានខុស បកអាក្រាតព័ត៌មានមិនពិត និងប្រកួកប្រកាសឱ្យគេដឹងតួអង្គទុច្ចរិត) និងបង្កើតក្រុមគោលដៅស្មោះត្រង់ (ដែលគាំទ្រដោយការចូលរួមផ្ទាល់រវាងតួអង្គសារព័ត៌មាន និងអ្នក

---

21 Bakir, V. & McStay, A. (2017) Fake News and the Economy of Emotions Digital Journalism (Taylor and Francis) July, 2017. http://www.tandfonline.com/doi/abs/10.1080/21670811.2017.1345645 [accessed 29/03/2018].

22 Note: Filter bubbles are the inflated space populated by like-minded people as a result of algorithms serving up individualised content to users c.f. Pariser, E. (2012). The Filter Bubble. Penguin and Random House, New York

23 ទស្សនៈចង្អៀតចង្អល់ (Echo chambers) សំដៅទៅលើផលប៉ះពាល់នៃការអះអាងដែលលម្អៀងទៅមនុស្សដែលមានចិត្តដូចគ្នានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ហើយមេរៀនទី៥នឹងពន្យល់បន្ថែមចំពោះការអះអាងដែលលម្អៀងនេះ។

24 Garciade Torres, E. (2017). The Social Reporter in Action: An Analysis of the Practice and Discourse of Andy Carvin in Journalism Practice, 11(2-3). http://www.tandfonline.com/doi/abs/10.1080/2017512786.2016.1245110 [accessed 29/03/2018].

ប្រើប្រាស់ដំណឹង)[25]។ សារព័ត៌មានបែបនេះ ក៏ផ្តល់លទ្ធភាពដល់ក្រុមគោលដៅក្នុងការ «ផ្តល់មតិយោបល់» ដើម្បីកែតម្រូវនៅកន្លែងណាដែលអ្នកសារព័ត៌មានមានកំហុស ឬដើម្បីរួមចំណែកសហការក្នុងការស្រាវជ្រាវ។ មជ្ឈដ្ឋានសាធារណជនដែលចងជាបណ្តាញក៏ជួយអ្នកសារព័ត៌មាន និងក្រុមគោលដៅ ឱ្យគេចផុតពីការរឹតត្បិត និងការចាប់ពិរុទ្ធតាមអំពើចិត្តដែរ ឧ. ស្រទាប់នៃ«ក្រុមអ្នកនាំពាក្យ (spin doctor)»ដែលអាចជាការរឹតត្បិតលើសិទ្ធិទទួលព័ត៌មាន និងសង្គមសេរី។

ការចូលរួមរបស់អ្នកសារព័ត៌មានជាមួយក្រុមគោលដៅ និងប្រភពព័ត៌មានតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមក៏អាចចាត់ទុកជាទិដ្ឋភាពថ្មីមួយ ដែលគួរឱ្យកត់សម្គាល់នៃការទទួលខុសត្រូវ ដែលជួយដល់ស្វ័យនិយ័តកម្មដោយខ្លួនឯងដែរ។ អន្តរកម្មទាំងនេះអាចឱ្យអ្នកសារព័ត៌មានឆ្លើយតបបានឆាប់រហ័ស និងជាសាធារណៈចំពោះការរិះគន់ដែលមានហេតុផលសមស្រប មកលើការងាររបស់ខ្លួនអាចកែកំហុស និងអាចបង្កើនតម្លាភាពនៃការអនុវត្តរបស់ពួកគេ[26]។

ចំណុចអវិជ្ជមានរួមមាន៖

- លទ្ធភាពកើនឡើងនៃការរាលដាលលឿននៃព័ត៌មានមិនពិត និងព័ត៌មានខុស តាមរយៈការចែកចាយដែលបន្តដោយ «បណ្តាញទំនុកចិត្ត (Trust network)»[27] និងប្រតិកម្មដោយអារម្មណ៍ (ឧ. បង្កដោយភាពលម្អៀង)។ (សូមមើលមេរៀនទី៥)
- លទ្ធភាពរបស់រដ្ឋាភិបាល និងទីភ្នាក់ងារផ្សេងទៀត ក្នុងការគេចវេះពីការចោទសួរដេញដោល និងការផ្ទៀងផ្ទាត់ ពីប្រព័ន្ធផ្សព្វផ្សាយដំណឹង ដោយ «សំដៅផ្ទាល់ទៅរកអ្នកអាន» តែម្តង ដើម្បីចៀសផុតពីការត្រួតពិនិត្យ។ មានភ័ស្តុតាងបង្ហាញពីការកើនឡើងនៃការកេងប្រវ័ញ្ច ឥទ្ធិពលរបស់ប្រព័ន្ធផ្សព្វផ្សាយសង្គមពីអ្នកទាំងឡាយ ដែលស្វះស្វែងជះឥទ្ធិពលលើលទ្ធផលនៃ

25 Posetti, J. (2010). Aussie #Spill Breaks Down Barriers Between Journalists, Audience PBS Media shift, May 24th, 2010. http://mediashift.org/2010/05/aussie-spill-breaks-down-wall-between-journalists-audience144/ [accessed 29/03/2018].

26 Posetti, J. (2013). The 'Twitterisation' of investigative journalism in S. Tanner & N. Richardson (Eds.), Journalism Research and Investigation in a Digital World (pp. 88-100): Oxford University Press. Available at http://ro.uow.edu.au/cgi/viewcontent.cgi?article=2765&context=lhapapers

27 'Trust networks' គឺជាបណ្តាញនៃប្រជាពលរដ្ឋដែលចែករំលែកព័ត៌មានតាមអ៊ីនធឺណិត តាមរយៈទំនាក់ទំនងដែលមានភាពជឿទុកចិត្ត (ឧទាហរណ៍ ក្រុមមិត្តភក្តិ និងក្រុមគ្រួសារ) នៅក្នុងលក្ខណៈជាការផ្ញើភ្លាមៗ ឬពីមិត្តមួយទៅមិត្តមួយ។ ការសិក្សាស្រាវជ្រាវបានបង្ហាញម្តងហើយម្តងទៀតថា អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ភាគច្រើនចែករំលែកព័ត៌មានដែលបានមកពីបណ្តាញដែលគេជឿទុកចិត្ត ដោយមិនគិតពីថាតើព័ត៌មាននោះពិត ឬបានផ្ទៀងផ្ទាត់ត្រឹមត្រូវដែរឬទេ។

ការបោះឆ្នោត និងគោលនយោបាយសាធារណៈ[28]

- ព័ត៌មានបែបរំជួលចិត្តទំនងជាត្រូវគេចែករំលែកបន្តច្រើន[29]
- មិនអាចទាញយកមកវិញ ឬកែតម្រូវព័ត៌មានមិនពិត នៅពេលដែលវាពាលដាលទៅហើយនោះ ហើយការបកអាក្រាត ឬការរាយការណ៍ដែលលាតត្រដាងពីភាពមិនពិតនៃដំណឹង ដែលផ្សាយទៅហើយនោះមិនអាចលុបផលប៉ះពាល់នៃអត្ថបទប្រឌិតមួយ រូបត្លុកដែលមានចេតនាអាក្រក់ វីដេអូឃោសនាដែលក្លែងខ្លួនជាដំណឹង ឬរបាយការណ៍ខុសមួយ ដែលបង្កឡើងដោយខ្វះការផ្ទៀងផ្ទាត់បានឡើយ
- តម្រូវការឱ្យផ្សាយបន្ទាន់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម អាចបណ្ដាលទៅជាការចែករំលែកព័ត៌មានមិនពិត ដោយធ្វេសប្រហែស ឬមាតិកាពីប្រភពបោកប្រាស់[30]
- កម្រិតទាបនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន និងជំនាញផ្ទៀងផ្ទាត់នៅក្នុងសង្គមទូទៅ។ ក្នុងន័យនេះ ករណីជាច្រើន អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមទូទៅ ពុំមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីកំណត់ថា តើមាតិកានោះពិត ឬមិនពិត នៅមុនពេលចែករំលែកវាឡើយ
- ហានិភ័យនៃវិធានការរបស់រដ្ឋដែលធ្វើឱ្យអន្តរាយដល់សេរីភាពបញ្ចេញមតិតាមរយៈការចាប់ពិរុទ្ធ និងការបិទដោយគ្មានហេតុផលត្រឹមត្រូវជាការឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ដូចដែលបានរៀបរាប់ខាងលើ
- ការអភិវឌ្ឍទំនោរនៃការឃើញតែរឿងដែលចង់ឃើញ ដែលលម្អៀងស្របចិត្ត និងកាត់បន្ថយការទទួលបានព័ត៌មាន ដែលមានគុណភាពនិងមានការផ្ទៀងផ្ទាត់
- ហានិភ័យនៃការអនុវត្តវិជ្ជាជីវៈសារព័ត៌មានខ្វះគុណភាព ដែលនឹងរឹតតែ

---

28 Freedom House (2017). Freedom of the Net 2017: Manipulating Social Media to Undermine Democracy Freedom House. https://freedomhouse.org/report/freedom-net/freedom-net-2017 [accessed29/03/2018]. See also Cadwalladr, C. (2018). I made Steve Bannon’s Psychological Warfare Tool: Meet the data war whistleblower, The Guardian/Observer https://www.theguardian.com/news/2018/mar/2017/data-war-whistleblower-christopher-wylie-faceook-nix-bannon-trump [accessed 31/03/2018].

29 Kalsnes, B. & Larsson, O. A. (2017). Understanding News Sharing Across Social Media: Detailing distribution on Facebook and Twitter in Journalism Studies (Taylor and Francis) March, 2017. http://www.tandfonline.com/doi/abs/10.1080/1461670X.2017.1297686?scroll=top&needAccess=true&journalCode=rjos20 [accessed 29/03/2018].

30 Posetti, J. (2009). Rules of Engagement For Journalists on Twitter PBS Media shift, June 19th 2009. http://mediashift.org/2009/06/rules-of- engagement-for-journalists-on-twitter170/ [accessed 29/03/2018].

ធ្វើឱ្យក្រុមគោលដៅបាត់បង់ជំនឿលើវិជ្ជាជីវៈនេះ និងផ្តល់ភាពស្របច្បាប់ដល់ការវាយប្រហារទៅលើប្រព័ន្ធផ្សព្វផ្សាយដំណឹង ពីអ្នកទាំងឡាយដែលចង់បំបិទមាត់អ្នករិះគន់

- ហានិភ័យនៃការយល់ច្រលំរបស់ក្រុមគោលដៅ អំពីអ្វីដែលជាដំណឹងត្រឹមត្រូវ ដែលខុសគ្នាពីព័ត៌មានមិនពិតដែលក្លែងខ្លួនជាដំណឹង[31]
- ការត្រៀមលក្ខណៈមិនបានគ្រប់គ្រាន់របស់ការិយាល័យនិពន្ធ ក្នុងការទប់ទល់នឹងព័ត៌មានមិនពិត និងភាពចាំបាច់សម្រាប់ក្រុមប្រព័ន្ធផ្សព្វផ្សាយសង្គមនៃការិយាល័យដំណឹង ដែលត្រូវអភិវឌ្ឍយុទ្ធសាស្ត្រឱ្យមានបច្ចុប្បន្នភាព ដើម្បីប្រយុទ្ធនឹងបញ្ហានេះឱ្យបានប្រសើរជាងមុន[32] ។

### *គ) ការរីកដុះដាលនៃកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម*

និពន្ធនាយិកាសារព័ត៌មាន The Guardian លោកស្រី Katherine Viner បានវាយតម្លៃថា «Facebook បានក្លាយជាក្រុមហ៊ុនផ្សព្វផ្សាយដែលមានជាងគេ និងមានឥទ្ធិពលជាងគេបំផុតនៅក្នុងប្រវត្តិសាស្ត្រ ដោយយកក្បួនដោះស្រាយបញ្ហាតាមប្រព័ន្ធកុំព្យូទ័រ (algorithms)មកជំនួសការីនិពន្ធ»[33]។ កម្មវិធីបប្រព័ន្ធផ្សព្វផ្សាយសង្គមត្រូវបានសរសើរថាជា «ឆ្នាំទ្វារ»ថ្មី[34] ប៉ុន្តែពួកគេនៅតែស្ទាក់ស្ទើរក្នុងការទទួលយកទំនួលខុសត្រូវសម្រាប់ការត្រួតពិនិត្យ ការផ្សាយបែបប្រពៃណី (ដែលក្នុងនោះរាប់ទាំងការផ្ទៀងផ្ទាត់ និងការជ្រើសរើស) ទោះបីជាបានសម្រេចចិត្តចាប់ពិរុទ្ធមាតិកាមួយចំនួន នៅក្នុងលក្ខណៈមួយ ដែលប៉ះពាល់ដល់សេរីភាពសារព័ត៌មានក្តី[35]។ ការប្រឹងប្រែងរបស់កម្មវិធីទាំងនេះ ក្នុងការដោះស្រាយបញ្ហាព័ត៌មានមិនពិតកំពុងវិវត្តយ៉ាងឆាប់រហ័ស ប៉ុន្តែការទប់ទល់ក្នុងការ ក) ឆ្លើយតបឱ្យបានគ្រប់គ្រាន់

31 Nielsen, R. K. & Graves, L. (2017). “News you don’t believe”: Audience Perspectives on Fake News Reuters Institute for the Study of Journalism Factsheet (RISJ, Oxford). https://reutersinstitute.politics.ox.ac.uk/sites/default/files/2017-10/Nielsen%26Graves_factsheet_1710v3_ FINAL_download.pdf [accessed 29/03/2018].

32 Elizabeth, J. (2017) After a Decade, It’s Time to Reinvent Social Media in Newsrooms, American Press Institute https://www.americanpressinstitute.org/publications/reports/strategy-studies/reinventing-social-media/single-page/ [accessed 29/03/2018].

33 Viner, K. (2017). A mission for journalism in a time of crisis The Guardian, November 17th, 2017. https://www.theguardian.com/news/2017/nov/16/a-mission-for-journalism-in-a-time-of-crisis [accessed 29/03/2018].

34 Bell, E. & Owen, T. (2017). The Platform Press: How Silicon Valley Reengineered Journalism Tow Center for Digital Journalism. https://www.cjr.org/tow_center_reports/platform-press-how-silicon-valley-reengineered-journalism.php [accessed 29/03/2018].

35 Hindustan Times (2016). Facebook Says Will Learn From Mistake Over Vietnam Photo. http://www.hindustantimes.com/world-news/facebook-says-will-learn-from-mistake-over-vietnam-photo/story-kwmb3iX6lKgmwalGZeKlyN.html [accessed 29/03/2018].

នៅកម្រិតពិភពលោក និង ខ) ទទួលយកទំនួលខុសត្រូវតាមបែបអ្នកបោះពុម្ពផ្សាយ ចំពោះផលប៉ះពាល់ផ្នែកសង្គម និងប្រជាធិបតេយ្យ ធ្វើឱ្យពួកគេប្រឈមនឹងការដែលត្រូវគេប្រើប្រាស់ជាអ្នកបង្កើត «ព័ត៌មានច្របូកច្របល់» និងការរំលោភបំពាននៅលើអ៊ីនធឺណិត[36]។

មុខងារក្បួនដោះស្រាយបញ្ហាតាមប្រព័ន្ធកុំព្យូទ័ររបស់ Facebook នៅក្នុងការផ្សព្វផ្សាយដំណឹង និងការផ្សាយព័ត៌មានមិនពិត ជាពិសេសនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ស្ថិតក្រោមការពិនិត្យពិច័យ ចាប់តាំងពីឆ្នាំ២០១៦[37]មក ជាពិសេសនៅក្នុងបរិបទនៃការឃោសនាតាមប្រព័ន្ធកុំព្យូទ័រ ដែលប៉ះពាល់ដល់កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលបើកឱ្យប្រើដោយចំហ[38]។ ប៉ុន្តែបន្ទាប់ពីការប្ដេជ្ញាចិត្ត និងការចាត់វិធានការដំបូងៗ ដោយសហការជាមួយអង្គភាពសារព័ត៌មាន និងគ្រឹះស្ថានសិក្សាសារព័ត៌មាន ដើម្បីដោះស្រាយវិបត្តិនេះ ក្នុងនោះរួមទាំងវិធានការដើម្បីឱ្យមាតិកាដែលអាចទុកចិត្តបានផុសចេញឡើង និងដាក់សញ្ញាសម្គាល់មាតិកាណាដែលមិនពិត និងបំភ័ន្ត Facebook បានដកថយវិញយ៉ាងគំហុកពីការបំពេញមុខងារនេះ កាលពីខែមករា ឆ្នាំ២០១៨[39]។ ការផ្លាស់ប្ដូរពីប្រព័ន្ធផ្សព្វផ្សាយសង្គមបើកចំហ ទៅរកប្រព័ន្ធមួយដែលបិទជិតសម្រាប់ការចូលរួមរបស់ក្រុមគោលដៅ ទំនងជានឹងកើតមានឡើង ដែលនឹងជះផលប៉ះពាល់ថ្មីមួយទៅលើការផ្សព្វផ្សាយដំណឹង និងនិរន្តរភាពរបស់សារព័ត៌មានដែលមានគុណភាព។ ទន្ទឹមនឹងនេះ ក៏មានហានិភ័យបន្ថែមទៀតនៃការបង្កើតទំនោរនៃការច្រោះដំណឹងដែលចង់បាន និងការរាលដាលនៃការផ្សាយព័ត៌មានមិនពិត[40]។ ហានិភ័យទាំងនេះ រួមបញ្ចូលទាំងបញ្ហាពាក់ព័ន្ធនឹងក្បួនដោះស្រាយបញ្ហាតាមប្រព័ន្ធកុំព្យូទ័ររបស់ម៉ាស៊ីនស្វែងរកព័ត៌មាន ដូចជា Google ដែលក្រុមហ៊ុនបានសារភាពនៅដើមឆ្នាំ២០១៨ ថាមានទំនោរពង្រឹងភាពលម្អៀង។ នៅពេលដែល

36 Posetti, J. (2017). Fighting Back Against Prolific Online Harassment, The Conversation, June 29th 2017. https://theconversation.com/fighting- back-against-prolific-online-harassment-in-the-philippines-80271 [accessed 29/03/2018].

37 Finkel, Casey & Mazur (2018). Op cit

38 Grimme, C., Preuss, M., Adam, L., & Trautmann, H. (2017). Social Bots: Human-Like by Means of Human Control?. Big Data 5(4) http://comprop.oii.ox.ac.uk/publishing/academic-articles/social-bots-human-like-by-means-of-human-control/ [accessed 29/03/2018].

39 Wang, S., Schmidt, C. & Hazard, O. L. (2018). Publishers claim they're taking Facebook's newsfeed changes in their stride-is the bloodletting still to come? NiemanLab. http://www.niemanlab.org/2018/01/publishers-claim-theyre-taking-facebooks-news-feed-changes-in- stride-is-the-bloodletting-still-to-come/ [accessed 29/03/2018].

40 Alaphillippe, A. (2018). Facebook's Newsfeed Changes Are Probably Going to be Great for Fake News, The Next Web. https://thenextweb.com/contributors/2018/01/2018/facebooks-news-feed-changes-probably-going-great-fake-news/ [accessed 29/03/2018].

កំពុងនិពន្ធសៀវភៅនេះ Google បានគូសបញ្ជាក់ថា ខ្លួនកំពុងធ្វើការលើបញ្ហា៖ «ទស្សនៈជាច្រើនដែលផ្តល់ដោយអ្នកបោះពុម្ពផ្សាយ ហើយយើងចង់ឱ្យអ្នកប្រើប្រាស់បានឃើញ និងទទួលទស្សនៈទាំងនោះពីប្រភពជាច្រើន»[41]។

**ផលវិបាកនៃ «ព័ត៌មានច្របូកច្របល់» ចំពោះវិជ្ជាជីវៈសារព័ត៌មាន និងឧស្សាហកម្មដំណឹង៖**

- ការបន្តរេចរឹលនៃទំនុកចិត្តលើយីហោដំណឹង វិជ្ជាជីវៈសារព័ត៌មាន និងអ្នកសារព័ត៌មាន ដែលចែករំលែកព័ត៌មានមិនត្រឹមត្រូវ ព័ត៌មានប្រឌិត ឬព័ត៌មានបំភ័ន្ត
- ការដាក់បញ្ចូលសេចក្តីរាយការណ៍ ដែលមានគុណភាពជាមួយព័ត៌មានមិនពិត និងមាតិកាផ្សាយពាណិជ្ជកម្ម (បង់ប្រាក់) ដែលដាក់ស្លាកសម្គាល់មិនបានត្រឹមត្រូវ ដែលក្លែងបន្លំជាដំណឹង នាំឱ្យកើនឡើងភាពមិនទុកចិត្តរបស់សាធារណជន
- សម្ពាធបន្ថែមលើគំរូអាជីវកម្មសារព័ត៌មាន៖ ក្រុមគោលដៅអាចនឹងលែងងាកទៅរកប្រព័ន្ធផ្សព្វផ្សាយដំណឹង ក្នុងពេលដែលមានវិបត្តិ និងគ្រោះមហន្តរាយ ដោយជឿថា ពួកគេនឹងទទួលបានដំណឹងអាចជឿទុកចិត្តបាន និងមានការផ្ទៀងផ្ទាត់ត្រឹមត្រូវ ដែលគេចែករំលែកជាប្រយោជន៍សាធារណៈ។ ទំនុកចិត្តបែបនេះបញ្ជាក់ភាពស្មោះត្រង់លើយីហោជាអ្វីដែលសំខាន់សម្រាប់ការកសាងគំរូអាជីវកម្មសារព័ត៌មានមួយ ដែលមាននិរន្តរភាព។
- ភាពខ្សោយនៃតួនាទីរបស់អ្នកសារព័ត៌មាន ក្នុងនាមជាភ្នាក់ងារប្រកបដោយទំនួលខុសត្រូវ (ឧ. តាមរយៈសារព័ត៌មានស៊ើបអង្កេត) ដែលប៉ះពាល់តិចតួចទៅលើសង្គមទូទៅ
- ការបង្ក្រាប (ក្រោមហេតុផលថា ជាការចាំបាច់លុបបំបាត់«ដំណឹងក្លែងក្លាយ») ដែលធ្វើឱ្យអន្តរាយដល់សិទ្ធិសេរីភាពសារព័ត៌មាន និងសេរីភាពបញ្ចេញមតិ ក្នុងនោះរាប់បញ្ចូលទាំងការបិទអ៊ីនធឺណិត ការបិទកម្មវិធី និងការចាប់ពិរុទ្ធ
- ការវាយប្រហារដោយទុច្ចរិតលើអ្នកសារព័ត៌មាន (ជាពិសេសអ្នកសារព័ត៌មានស្ត្រី) ពីអ្នកផ្សព្វផ្សាយព័ត៌មានមិនពិត ដោយប្រើវិធីបៀតបៀនតាមអ៊ីនធឺណិត

41 Hao, K. (2018). Google is finally admitting it has a filter bubble problem, Quartz. https://qz.com/1194566/google-is-finally-admitting-it-has-a- filter-bubble-problem/ [accessed 29/03/2018].

ដើម្បីបង្ខូចកេរ្តិ៍ឈ្មោះសេចក្ដីរាយការណ៍ដែលរិះគន់ រួមនឹងការប៉ុនប៉ងដោយចេតនាក្នុងការដាក់អន្ទាក់ឱ្យអ្នកសារព័ត៌មានជាប់នៅក្នុងការចែកចាយព័ត៌មានមិនពិត[42]

**ការអនុវត្តនៅក្នុងឧស្សាហកម្មដំណឹងដែលកំពុងកើតមាន៖ របៀបដែលអង្គភាពដំណឹង «ដំណឹងក្លែងក្លាយ» និងប្រឆាំងនឹង «ព័ត៌មានច្របូកច្របល់»**

បញ្ហា និងហានិភ័យដែលបានរៀបរាប់ខាងលើ ទាមទារការប្រយ័ត្នប្រយែងប្រកបដោយវិជ្ជាជីវៈ ការប្ដេជ្ញាចិត្តប្រកាន់ខ្ជាប់ក្រមសីលធម៌ បទដ្ឋានខ្ពស់នៃការរាយការណ៍ និងផ្ទៀងផ្ទាត់ (ក្នុងនោះរាប់ទាំងវិធីសាស្ត្រផ្ទៀងផ្ទាត់សហប្រតិបត្តិការ) ទៅលើព័ត៌មាន និងប្រភព រួមទាំងការបកអាក្រាត និងការរាយការណ៍ពីបញ្ហានេះប្រកបដោយភាពច្នៃប្រឌិត។

ខាងក្រោមនេះជាឧទាហរណ៍នៃកិច្ចប្រឹងប្រែងមួយចំនួន ដែលអនុវត្តដោយអង្គភាពដំណឹង និងអ្នកសារព័ត៌មានជាបុគ្គលដើម្បីរាយការណ៍ដំណឹង បញ្ចូលក្រុមគោលដៅក្នុងការអប់រំផ្នែកដំណឹង និងប្រឆាំងនឹងការផ្សាយព័ត៌មានមិនពិត៖

- ការប្រើប្រាស់ Instagram Stories របស់សារព័ត៌មាន The Guardian ដើម្បីប្រឆាំងនឹងការផ្សាយព័ត៌មានមិនពិត រួមទាំងការផ្សាយជាវីដេអូខ្លីៗ ដែលសំដៅទាក់ទាញការចូលរួមរបស់ក្រុមគោលដៅវ័យក្មេង https://www.instagram.com/p/BRd25kQBb5N/ (សូមមើល: The Guardian's 'Fake News' interactive quizhttps://www.theguardian.com/theguardian/2016/dec/28/can-you-spot-the-real-fake-news-story-quiz)
- ការប្រើប្រាស់សារព័ត៌មានស៊ើបអង្កេត និងការវិភាគទិន្នន័យធំៗរបស់ស្ថាប័នដំណឹង Rappler ដើម្បីលាតត្រដាងបណ្ដាញឃោសនា «ប្រើអត្តសញ្ញាណក្លែងបន្លំ» ដែលប៉ះពាល់លើលទ្ធិប្រជាធិបតេយ្យនៅប្រទេសហ្វីលីពីន។ https://www.rappler.com/nation/148007-propaganda-war-weaponizing-internet
- ការប្រើប្រាស់របៀបរាយការណ៍ បែបពន្យល់ខ្លាំងរបស់សារព័ត៌មាន The New York Times លើបញ្ហានេះតាមរយៈវិធីសាស្ត្របង្ហាញករណីសិក្សា៖ https://www.nytimes.com/2016/11/20/business/media/how-fake-news-spreads.html

---

42 សូមមើលមេរៀនទី៧

➢ ការប្តេជ្ញាចិត្តរបស់ Columbia Journalism Review ក្នុងការធ្វើបទវិភាគឆ្លុះបញ្ចាំងលើបញ្ហានេះ៖ https://www.cjr.org/analysis/how_fake_news_sites_frequently_trick_big-time_journalists.php

➢ សៀវភៅណែនាំសម្រាប់អ្នករាយការណ៍ដំណឹងស្តីពី ការតតាំងនឹងគំនិតប្រកែកនិយម ជុំវិញបញ្ហាការប្រែប្រួលអាកាសធាតុ
Guardian Australia ៖ https://www.theguardian.com/environment/planet-oz/2016/nov/08/tough-choices-for-the-media-when-climate-science-deniers-are-elected

➢ កិច្ចសហប្រតិបត្តិការលោតត្រដាងការពិតរបស់ជប៉ុន រវាងអ្នកសារព័ត៌មាននិងអ្នកសិក្សា ក្នុងអំឡុងពេលនៃការបោះឆ្នោតជាតិឆ្នាំ២០១៧ ដែលផ្អែកលើគោលការណ៍នៃគម្រោងឃ្លាំមើលការបោះឆ្នោត ដោយការផ្ទៀងផ្ទាត់ដែលទទួលបានជោគជ័យ នៅប្រទេសបារាំងឆ្នាំ២០១៧ដដែលនេះ៖ http://www.niemanlab.org/2017/10/a-snap-election-and-global-worries-over-fake-news-spur-fact-checking-collaborations-in-japan/

➢ នៅសហរដ្ឋអាមេរិក Electionland ជាឧទាហរណ៍ដ៏គួរឱ្យចាប់អារម្មណ៍នៃសហប្រតិបត្តិការមួយ ដែលរួមបញ្ចូលទាំងគ្រូ និងនិស្សិតសារព័ត៌មាន៖
https://projects.propublica.org/electionland/[43]

➢ របាយការណ៍ស៊ើបអង្កេតសកល លើករណីអាស្រូវរបស់ Cambridge Analytica (ដែលចូលរួមដោយ The Observer & The Guardian, Channel4 News និង The New York Times) និងវិធីបំប៉នចំណេះដឹង ដែល VoxMedia បានពន្យល់រឿងស្មុគស្មាញដល់អ្នកអាន៖ a. https://www.vox.com/policy-and-politics/2018/3/21/2017141428/cambridge-analytica-trump-russia-mueller b. https://www.vox.com/policy-and-politics/2018/3/23/2017151916/facebook-cambridge-analytica-trump-diagram

➢ ការប្រើអំណាចរបស់ក្រុមគោលដៅ ដើម្បីប្រឆាំងនឹងការផ្សាយព័ត៌មានមិនពិតតាមកម្មវិធី WhatsApp នៅឥណ្ឌារបស់សារព័ត៌មាន The Quint និងការជ្រើសរើសមាតិកាដែលផ្ទៀងផ្ទាត់រួចប្រកបដោយភាពច្នៃប្រឌិតនៅលើកម្មវិធី៖
https://www.thequint.com/neon/satire/whatsapp-indian-elections-and-

43 កំណត់សំគាល់របស់អ្នកនិពន្ធ៖ ការត្រួតពិនិត្យ និងការបោះឆ្នោតគឺជាផ្នែកមួយនៃបាតុភូតដែលកំពុងលេចចេញជាថ្មីនៃការផ្តួចផ្តើមជាបណ្តោះអាសន្នក្នុងទម្រង់ជាដៃគូដើម្បីប្រឆាំងនឹងការផ្សព្វផ្សាយព័ត៌មានមិនពិតក្នុងពេលបោះឆ្នោត។ ភាពជាដៃគូ "លេចចេញ" បែបនេះអាចជាបាតុភូតដ៏មានតម្លៃដែលទូទាត់សងសម្រាប់អវត្តមាន ឬភាពទន់ខ្សោយ នៃស្ថាប័នផ្ទៀងផ្ទាត់ការពិតដែលបានបង្កើតឡើង។

fake-propaganda-satire[44]

គ្រូបណ្តុះបណ្តាលត្រូវបានលើកទឹកចិត្ត ឱ្យបន្ថែមឧទាហរណ៍ផ្សេងទៀតចេញពីក្នុងតំបន់ដែលសិស្សរស់នៅ និងភាសារបស់សិស្ស។

តម្លៃដូចគ្នានេះដែរ គឺយុទ្ធសាស្រ្តរបស់សាស្រ្តាចារ្យ Charlie Beckett សម្រាប់ការលើកកម្ពស់ការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន ដែលមានក្រមសីលធម៌ក្នុងសម័យ «ដំណឹងក្លែងក្លាយ»។ លោកនិយាយថា អ្នកសារព័ត៌មានគួរតែ៖

- ភ្ជាប់ទំនាក់ទំនង - ដោយចូលប្រើនិងមានវត្តមាននៅលើគ្រប់កម្មវិធីទាំងអស់[45]
- ជ្រើសរើស - ដោយជួយអ្នកប្រើប្រាស់ស្វែងរកមាតិកាល្អៗ នៅគ្រប់ទីកន្លែងពាក់ព័ន្ធ
- មានភាពពាក់ព័ន្ធ- ដោយប្រើប្រាស់ភាសារបស់អ្នកប្រើប្រាស់ និង «ស្តាប់» ដោយភាពច្នៃប្រឌិត
- ធ្វើជាអ្នកឯកទេស - ដោយបន្ថែមគុណតម្លៃ គំនិត បទពិសោធន៍ និងបរិបទ
- ផ្តល់ការពិត - ដោយផ្ទៀងផ្ទាត់ការពិត តុល្យភាព ភាពត្រឹមត្រូវ
- ធ្វើបែបជាមនុស្ស - ដោយបង្ហាញការយល់ពីអារម្មណ៍អ្នកដទៃ ទទួលស្គាល់ភាពខុសគ្នា និងបង្ហាញចរិតស្ថាបនា
- តម្លាភាព - បង្ហាញប្រភព បង្ហាញការទទួលខុសត្រូវ និងអនុញ្ញាតឱ្យគេរិះគន់[46]។

## គោលបំណងនៃមេរៀន

- បង្កើតការយល់ដឹងនៅក្នុងចំណោមសិស្ស អំពីបុព្វហេតុផ្នែករចនាសម្ព័ន្ធនៃការចុះខ្សោយរបស់ឧស្សាហកម្មដំណឹង និងការរុញច្រានព័ត៌មានមិនពិត និងព័ត៌មានខុស

44 Note: For research examining the role of chat apps in disinformation distribution see: Bradshaw, S & Howard, P. (2018). Challenging Truth and Trust: A Global Inventory of Organized Social Media Manipulation. Working Paper 2018. 1. Oxford, UK: Project on Computational Propaganda: http://comprop.oii.ox.ac.uk/wp-content/uploads/sites/93/2018/07/ct2018.pdf [accessed: 20/8/18].

45 សម្គាល់៖ និពន្ធនាយកទទួលស្គាល់ថាវាមិនអាចទៅរួចទេសម្រាប់អ្នកសារព័ត៌មានទាំងអស់ដែលត្រូវឆ្លងកាត់គ្រប់វេទិកា (platforms)ទាំងអស់ដោយខ្លួនឯងទេ។ ទោះយ៉ាងណាវាអាចមានប្រយោជន៍សម្រាប់បន្ទប់ដំណឹង ដើម្បីចាត់តាំងអ្នកសារព័ត៌មានម្នាក់ៗអោយទៅចូលរួមវេទិកាដែលលេចធ្លោ និងមិនសូវមានឥទ្ធិពលខ្ពស់ ដូចប្រព័ន្ធផ្សព្វផ្សាយសង្គមសព្វថ្ងៃរួមមាន Twitter Facebook និង Instagram ។

46 Beckett, C. (2017). Op cit

- ឱ្យសិស្សចេះវិភាគការឆ្លើយតបឧស្សាហកម្មដំណឹង ចំពោះបាតុភាពនៃ «ព័ត៌មានច្របូកច្របល់»
- ស្វែងយល់ និងរិះគន់តួនាទីរបស់កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ក្នុងការអភិវឌ្ឍ និងវិបត្តិនៃការផ្សាយព័ត៌មានមិនពិត
- រៀនសូត្រពីការអនុវត្តល្អៗដែលកំពុងកើតមាន ក្នុងចំណោមអ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មាន ដែលឆ្លើយតបនឹងវិបត្តិនេះដោយប្រសិទ្ធភាព

## លទ្ធផលសិក្សា

ចុងបញ្ចប់នៃមេរៀននេះ សិស្សគួរតែអាច៖

១. វាយតម្លៃដោយការត្រិះរិះលើបុព្វហេតុផ្នែករចនាសម្ព័ន្ធ និងផលវិបាកធំនៃវិធានការឧស្សាហកម្មដំណឹងក្នុងការរាយការណ៍ និងចែកចាយព័ត៌មានខុស

២. យល់ និងរិះគន់តួនាទីបច្ចេកវិទ្យា និង «ឆ្មាំទ្វារថ្មី» (ឧ. កម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម) ដល់ការចែកចាយព័ត៌មានមិនពិត និងព័ត៌មានខុសយ៉ាងផុសផុល ដែលបន្លំខ្លួនធ្វើជាដំណឹងត្រឹមត្រូវ

៣. កំណត់ការអនុវត្តគំរូដែលលេចឡើងក្នុងឧស្សាហកម្មដំណឹង សម្រាប់ការចាប់ និងការប្រឆាំងនឹងព័ត៌មានមិនពិត

## ទម្រង់នៃមេរៀន

មេរៀននេះបង្កើតឡើងសម្រាប់បង្រៀនសិស្សដោយផ្ទាល់ ឬការបង្រៀនតាមអ៊ីនធឺណិត។ មេរៀននេះចែកចេញជាពីរផ្នែក៖ ទ្រឹស្តី និងអនុវត្តន៍។

### គ្រោងផែនការទៅនឹងលទ្ធផលសិក្សា

ក. ទ្រឹស្តី

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| ជាបទបង្ហាញអន្តរកម្ម និងមានវគ្គសំណួរ-ចម្លើយ បង្រៀនតាមបែបប្រពៃណី ឬកម្មវិធីសិក្ខាសាលាតាមអ៊ីនធឺណិតដោយសម្រួលដល់ការចូលរួមពីចម្ងាយ។<br><br>មាតិកានៃបទបង្ហាញអាចដកស្រង់ចេញពីទ្រឹស្តី និងឧទាហរណ៍ដែលផ្តល់ខាងលើ។ ប៉ុន្តែគ្រូឧទ្ទេសនាមត្រូវបានលើកទឹកចិត្តឱ្យដាក់បញ្ចូលករណីសិក្សាដែលពាក់ព័ន្ធផ្នែកវប្បធម៌/បរិបទក្នុងស្រុកក្នុងការបង្រៀនមេរៀននេះ។<br><br>លទ្ធផលសិក្សាគួរតែផ្តល់ជូនជាពិសេសតាមរយៈបទបង្ហាញក្នុងទម្រង់ជាកិច្ចពិភាក្សាក្រុមអ្នកឯកទេសដោយមាន អ្នកសារព័ត៌មាន ការីនិពន្ធ និងតំណាងកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមនានាឱ្យចូលរួមក្នុងកិច្ចពិភាក្សាដែលសម្របសម្រួលដោយគ្រូឧទ្ទេស ឬគ្រូបណ្តុះបណ្តាល ហើយសិស្សអាចចូលរួមផ្ទាល់ក្នុងវគ្គសំណួរ-ចម្លើយ។ | ៦០-៩០នាទី | ១, ២, ៣ |

## ខ. អនុវត្តន៍

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
| --- | --- | --- |
| សិក្ខាសាលា/ការបង្រៀនក្នុងថ្នាក់រៀនបែបប្រពៃណី ឬតាមកម្មវិធីរៀននៅលើអ៊ីនធឺណិតដូចជា Moodle, Facebook groups ឬសេវាដទៃទៀតដែលអាចឱ្យមានការចូលរួមពីចម្ងាយតាមអ៊ីនធឺណិត។ សិក្ខាសាលា/ការបង្រៀនអាចយកលំនាំតាមទម្រង់ដូចខាងក្រោម ៖<br>ក្រុមត្រូវបែងចែកជាក្រុមការងារ ដែលមួយក្រុមៗមានសិស្ស៣-៥នាក់។ ក្រុមនីមួយៗគួរតែ ៖<br>១.ផ្តល់ករណីសិក្សាមួយពាក់ព័ន្ធនឹងការធ្វើសេចក្តីរាយការណ៍ ឬការចែកចាយព័ត៌មានមិនពិត ព័ត៌មានខុសដោយចេតនា ឬអចេតនារបស់អង្គភាពដំណឹងមួយ<br><br>២. សហការគ្នាវាយតម្លៃទៅលើសម្ភារៈស្រាវជ្រាវប្រភពដើមនៃព័ត៌មាន និងបរិបទនៃការរាយការណ៍ខុស (ឧ. តើរឿងនេះជារឿងទាន់ហេតុការណ៍ឬទេ?)។ ចូរពិភាក្សាអំពីបុព្វហេតុនៃរឿងដែលអាចកើតមាន (ដោយយកចិត្តទុកដាក់លើកត្តារចនាសម្ព័ន្ធ ដូចជាការកាត់បន្ថយបុគ្គលិកក្នុងបន្ទប់ដំណឹង និងតួនាទីកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម)។ ចូរពិភាក្សាបទពិសោធន៍ផ្ទាល់ខ្លួននៃការបោកប្រាស់ដោយព័ត៌មានមិនពិត<br><br>៣. រួមគ្នាសរសេរសេចក្តីសង្ខេបចំនួន ២៥០ពាក្យ នៃការវិភាគបុព្វហេតុនៃការផ្សាយដោយកំណត់រឿងបីយ៉ាងដែលអ្នកសារព័ត៌មាន ឬស្ថាប័នដំណឹងអាចធ្វើខុសពីនេះ ដើម្បីទប់ស្កាត់ការផ្សាយព័ត៌មានមិនពិត។ កិច្ចការនេះអាចធ្វើដោយប្រើប្រាស់ Google Doc ឬកម្មវិធីកែសម្រួលស្រដៀងគ្នា ហើយដាក់ជូនគ្រូពិនិត្យ។ | ៩០-១២០នាទី | ៩០-១២០នាទី |

## កិច្ចការដែលគួរដាក់ឱ្យធ្វើ

របាយការណ៍ករណីសិក្សា (២០០០ពាក្យ)។ ចូរកំណត់រកករណីសិក្សាចំនួន៣ (ក្នុងនោះត្រូវមាន១ករណីចេញពីប្រទេស/តំបន់របស់អ្នក) ដែលពាក់ព័ន្ធនឹងការចែកចាយ ឬការស៊ើបអង្កេតរបស់អង្គភាពដំណឹងមួយ ទៅលើករណីផ្សាយព័ត៌មានមិនពិត។ ពិនិត្យលើឧទាហរណ៍នីមួយៗ (ដោយពិភាក្សាបុព្វហេតុ និងលទ្ធផលនៃការផ្សាយព័ត៌មានមិនពិត) និងទាញសន្និដ្ឋានមេរៀនដែលបានរៀនសូត្រពីករណីសិក្សានីមួយៗ (ចំណាំ៖ សិស្សគួរជ្រើសរើសឧទាហរណ៍ថ្មីៗ មិនមែនឧទាហរណ៍ដដែល ដែលបានផ្តល់សម្រាប់ការពិភាក្សា នៅក្នុងសិក្ខាសាលាទាក់ទងនឹងមេរៀននេះឡើយ)។

## អំណានបន្ថែម


Bakir, V. & McStay, A. (2017). Fake News and the Economy of Emotions in Digital Journalism (Taylor and Francis). http://www.tandfonline.com/doi/abs/10.1080/21670811. 2017.1345645 [accessed 29/03/2018].

Bell, E. & Owen, T. (2017). The Platform Press: How Silicon Valley Reengineered Journalism Tow Center for Digital Journalism, March 29th, 2017. https://www.cjr.org/tow_center_reports/platform-press-how-silicon-valley-reengineered-journalism.php [accessed 29/03/2018].

Ireton, C. (Ed) (2016). Trends in Newsrooms 2016 (WAN-IFRA, Paris). http://www.wan-ifra.org/sites/default/files/field_media_image_file_attach/WAN-IFRA_Trends_Newsrooms_2016.pdf [accessed 29/03/2018].

Kalsnes, B. & Larsson, O. A. (2017). Understanding News Sharing Across Social Media: Detailing distribution on Facebook and Twitter in Journalism Studies (Taylor and Francis).http://www.tandfonline.com/doi/abs/10.1080/1461670X.2017.1297686?scroll=top&needAccess=true&journalCode=rjos20 [accessed 29/03/2018].

Nielsen, R. K. (2012). The Ten Years That Shook the Media World: Big Questions and Big Trends in International Media Developments (Reuters Institute for the Study of Journalism, Oxford). https://reutersinstitute.politics.ox.ac.uk/sites/default/files/2017-09/Nielsen%20-%20Ten%20Years%20that%20Shook%20the%20Media_0.pdf [accessed 29/03/2018

McChesney, W. & Picard, V. (Eds) (2011). Will the Last Reporter Please Turn Out the Lights: The Collapse of Journalism and What Can Be Done to Fix it. The New Press, New York.

Mitchell, A., Holcomb, J. &Weisel, R. (2016). State of the News Media Pew Research Centre. http://assets.pewresearch.org/wp-content/uploads/sites/13/2016/06/30143308/state-of-the-news-media-report-2016-final.pdf [accessed 29/03/2018].

Posetti, J. (2009). Transforming Journalism...140 Characters at a Time Rhodes Journalism Review 29, http://www.rjr.ru.ac.za/rjrpdf/rjr_no29/Transforming_Journ.pdf [accessed 29/03/2018].

Posetti, J. (2013). The 'Twitterisation' of investigative journalism in S. Tanner & N. Richardson (Eds.), Journalism Research and Investigation in a Digital World (pp. 88-100): Oxford University Press, Melbourne. http://ro.uow.edu.au/cgi/viewcontent.cgi?article=2765&context=lhapapers [accessed 20/03/2018].

Posetti, J. & Silverman, C. (2014). When Good People Share Bad Things: The Basics of Social Media Verification in Posetti (Ed) Trends in Newsrooms 2014 (WAN-IFRA,Paris). http://www.wan-ifra.org/sites/default/files/field_media_image_file_attach/WAN- IFRA_Trends_Newsrooms_2014.pdf [accessed 29/03/2018].

Posetti, J. (Ed) (2015). Trends in Newsrooms 2015 (WAN-IFRA, Paris). http://www.wan-ifra.org/sites/default/files/field_media_image_file_attach/WAN-IFRA_Trends_Newsrooms_2015.pdf, (See also Trends in Newsrooms 2014) [accessed 29/03/2018].

RISJ (2018). Digital News Report 2018 (University of Oxford). http://media.digitalnewsreport.org/wp-content/uploads/2018/06/digital-news-report-2018. pdf?x89475 [accessed 29/06/2018].

Silverman, C. (2015). Lies, Damn Lies and Viral Content. Tow Center for Digital Journalism. http://towcenter.org/wp-content/uploads/2015/02/LiesDamnLies_Silverman_TowCenter.pdf [accessed 29/03/2018].

Society of Climate Change Reporters (2016). Climate Change: A Guide to Information and Disinformation http://www.sej.org/initiatives/climate-change/overview [accessed 29/03/2018].

UNESCO (2017). States and journalists can take steps to counter 'fake news'. https://en.unesco.org/news/states-and-journalists-can-take-steps-counter-fake-new [accessed 29/03/2018]. bs/10.1080/1461670X.2017.1297686?scroll=top&needAccess=true&journalCode=rjos20 [accessed 29/03/2018].



# ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងព័ត៌មានខុស តាមរយៈអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន (MIL)

*MagdaAbu-Fadil*

# មេរៀនទី៩

## សង្ខេប

មេរៀននេះណែនាំសិស្សឱ្យស្គាល់ និងយល់អំពីគោលគំនិតនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន[1] (MIL) ដើម្បីស្វែងយល់អំពីព័ត៌មានដែលជាមធ្យោបាយកំណត់មុខសញ្ញា «ព័ត៌មានច្របូកច្របល់» នៅក្នុងសារច្បាស់លាស់ និងសារបង្កប់។ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន គឺជាគោលគំនិតចម្បងដែលអង្គការយូណេស្កូប្រើ ដើម្បីបញ្ជាក់ពីភាពទាក់ទងគ្នាទៅវិញទៅមកនៃសមត្ថកិច្ចនានា ពាក់ព័ន្ធនឹងព័ត៌មានក្នុងន័យទូលំទូលាយ និងជាពិសេសប្រព័ន្ធផ្សព្វផ្សាយ។ គោលគំនិតទាំងនេះគ្របដណ្ដប់ទាំងការអប់រំសិទ្ធិមនុស្ស (ជាពិសេសសិទ្ធិសេរីភាពបញ្ចេញមតិ ដែលជាសិទ្ធិរបស់មនុស្សម្នាក់ៗក្នុងការស្វែងរក ទទួល និងផ្សព្វផ្សាយព័ត៌មាន និងមតិ) ការអប់រំអំពីដំណឹង (ក្នុងនោះរាប់ទាំងការអប់រំអំពីបទដ្ឋានសារព័ត៌មាន និងក្រមសីលធម៌) ការអប់រំការផ្សាយពាណិជ្ជកម្ម ការអប់រំផ្នែកកុំព្យូទ័រ ការយល់ដឹងអំពី «ការយកចិត្តទុកដាក់នៃសេដ្ឋកិច្ច» ការអប់រំអន្តរវប្បធម៌ ការអប់រំអំពីឯកជនភាព។ល។ ការអប់រំទាំងអស់នេះ រួមបញ្ចូលទាំងការយល់ដឹងអំពីរបៀប ដែលប្រព័ន្ធផ្សព្វផ្សាយទាក់ទងនឹងអត្តសញ្ញាណបុគ្គល និងការអភិវឌ្ឍសង្គម។ ការអប់រំនេះកំពុងតែក្លាយជាបំណិនជីវិតដ៏សំខាន់ដែលចាំបាច់ដើម្បីដឹងអំពីកត្តាផ្សេងៗ ដែលបង្កើតអត្តសញ្ញាណមនុស្សម្នាក់ៗ និងស្គាល់របៀបរស់នៅក្នុងពិភពជន់ជោរដោយដំណឹង ព្រមទាំងរបៀបចៀសផុតពីគ្រោះថ្នាក់ ដែលបង្កប់នៅក្នុងជំនន់ព័ត៌មាននោះ។ ការអប់រំនេះជួយឱ្យយើងយល់ដឹងអំពីការប្រើប្រាស់ ការផលិត ការរកឃើញ ការវាយតម្លៃ និងការចែករំលែកព័ត៌មាន និងការយល់របស់យើងចំពោះខ្លួនយើង និងចំពោះអ្នកដទៃនៅក្នុងសង្គមព័ត៌មាន។

ការអប់រំផ្នែកដំណឹងគឺជាលទ្ធភាពជាក់លាក់ដើម្បីយល់ដឹងភាសា និងប្រភេទដំណឹង និងដើម្បីស្គាល់របៀបដែលលក្ខណៈទាំងនេះ ត្រូវទាញយកផលប្រយោជន៍ដោយចេតនាទុច្ចរិត។ ប៉ុន្តែបើទោះជាការអប់រំទាំងនេះសំខាន់ក៏ដោយ បើមានតែការអប់រំ វាមិនទំនងថាអាចបង្កើតការទប់ទល់នឹងព័ត៌មានមិនពិត ដែលតែងកើតឡើងបានទេ។ បញ្ហានេះដោយសារតែមនុស្សចូលរួមក្នុងការប្រាស្រ័យទាក់ទងគ្នា មិនមែនប្រើតែខួរក្បាលមួយមុខនោះទេ ប៉ុន្តែក៏ប្រើទាំងបេះដូងដែរ។ ដូច្នេះ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ក៏ចាំបាច់ត្រូវបន្ថែមការយកចិត្តទុកដាក់

1 https://en.unesco.org/themes/media-and-information-literacy [Accessed 16/06/2018].

ទៅលើការលើកកម្ពស់ការយល់ដឹងក្នុងចំណោមបុគ្គលនានា អំពីរបៀបដែលពួកគេឆ្លើយតបចំពោះមាតិកានៅក្នុងព័ត៌មាន និងការឆាប់ផ្តល់ការជឿជាក់ ឬមិនជឿជាក់ទៅលើព័ត៌មាន។

មូលដ្ឋានគ្រឹះនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានគួរតែផ្តល់ឱ្យបុគ្គលនូវការយល់ដឹងស៊ីជម្រៅអំពីអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេថា តើពួកគេជាអ្នកណា តើពួកគេកំពុងក្លាយជាអ្នកណា និងតើប្រការនេះប៉ះពាល់ដល់ការចូលរួមរបស់ពួកគេជាមួយដំណឹង និងសារគមនាគមន៍ប្រភេទដទៃទៀត បានយ៉ាងដូចម្តេច។ មេរៀននេះមានគោលបំណងជួយសិស្សឱ្យស្គាល់ និងបែងចែកឱ្យដាច់ពីគ្នារវាងសារព័ត៌មាន និងព័ត៌មានដែលអះអាងថាជាសារព័ត៌មាន។ ការផ្តល់លទ្ធភាពបែបនេះ អាចជួយបុគ្គលម្នាក់ៗឱ្យក្លាយជាម្ចាស់អត្តសញ្ញាណផ្ទាល់ខ្លួន និងអាចស្គាល់ព្រមទាំងតទល់ នៅពេលដែលអ្នកកំពុងត្រូវបានបោកបញ្ឆោតពាក់ព័ន្ធនឹងព័ត៌មានមិនពិត ដែលក្លែងខ្លួនជាដំណឹងត្រឹមត្រូវ។

សិស្សនឹងរៀនអំពីរបៀបអភិវឌ្ឍ និងប្រើប្រាស់ក្របខ័ណ្ឌជំនាញត្រិះរិះពិចារណានៃ «ការវិនិច្ឆ័យឆ្លុះបញ្ចាំងដោយចេតនា»[2] ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ការវិភាគ ការបកស្រាយ ការវាយតម្លៃ ស្វ័យនិយ័តកម្ម ការសន្និដ្ឋាន និងការពន្យល់។

សិស្សនឹងត្រូវឆ្លងកាត់ជំហាននានានៃការវិភាគដំណឹង នៅលើកាសែត/ប្រព័ន្ធផ្សព្វផ្សាយ (វិទ្យុ និងទូរទស្សន៍) អ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយបំបែករចនាសម្ព័ន្ធនៃសារនានា ទៅជាផ្នែកធាតុផ្សំផ្សេងៗរបស់វា ព្រមទាំងសិក្សាអំពីប្រភព និងភាពអាចជឿជាក់បានរបស់ប្រភព (ឬកង្វះភាពអាចជឿជាក់បានរបស់ប្រភពជាដើម)។

ពួកគេនឹងដឹងថា ដំណឹងពិតមិនមែនជាវិទ្យាសាស្ត្រទេ ប៉ុន្តែវាត្រូវមានការពណ៌នាដែលទោះបីមានភាពចម្រូងចម្រាស់ក្តី ជាទូទៅវាប្រកាន់ខ្ជាប់ទៅតាមវិធីសាស្ត្រវិជ្ជាជីវៈ និងក្រមសីលធម៌ដែលជួយកាត់បន្ថយកំហុស និងចៀសវាងពីការប្រឌិត។ អ្នកសារព័ត៌មានគួរតែធ្វើសេចក្តីរាយការណ៍ និងផ្តល់សញ្ញាអំពីការកុហកនានាដែលសម្តែងដោយតួអង្គផ្សេងៗ។ ទន្ទឹមនឹងនេះ អ្នកសារព័ត៌មានមិនត្រូវទទួលយកការអះអាងថាជាការពិត ហើយមិនត្រូវបង្ហាញការអះអាងនេះ ដោយមិនផ្តល់គុណវុឌ្ឍិអមជាមួយ ដែលប្រាប់ក្រុមគោលដៅ ឱ្យដឹងអំពីស្ថានភាពជាក់ស្តែងឡើយ។

2 Facione, P. (2010, updated). Critical Thinking: What It Is and Why It Counts. [online] Insight Assessment. Available at: https://www.insightassessment.com/ [accessed 01/02/2018].

នៅក្នុងមេរៀននេះ សិស្សក៏នឹងរៀនថាតើវាងាយស្រួល និងឆាប់រហ័សយ៉ាងណា ក្នុងការកេងចំណេញ «របៀបសរសេរសារព័ត៌មាន (journalese)» ដើម្បីផលិតរឿងមួយដែលមើលទៅគួរឱ្យជឿជាក់បាន ចេញពីព័ត៌មានដែលមិនគ្រប់ជ្រុងជ្រោយ មានលក្ខណៈបំភ័ន្ត ឬដែលត្រូវគេប្រឌិតឡើង[3]។

សម្ភារៈបង្រៀនសម្រាប់មេរៀននេះ ផ្តោតទៅលើការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាននៅក្នុងការប្រឆាំងនឹងការផ្សាយព័ត៌មានមិនពិត និងព័ត៌មានខុស។ មេរៀននេះរាប់បញ្ចូលទាំងការប្រើប្រាស់ជំនាញត្រិះរិះពិចារណា ដើម្បីកំណត់មុខសញ្ញា «ដំណឹង» ដែលត្រូវបានគេប្រឌិតឡើង។ មេរៀននេះក៏បង្ហាញសារៈសំខាន់សម្រាប់សិស្ស ក្នុងការប្រើប្រាស់អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានផ្ទាល់ខ្លួននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃដែរ។ វាជួយដល់សិស្សឱ្យអាចមើលឃើញរបៀបដែលការអប់រំនេះ អាចពង្រឹងសិទ្ធិរបស់ខ្លួន និងសិទ្ធិអ្នកដទៃ ព្រមទាំងសារៈសំខាន់នៃការចៀសពីការជំរុញ និងផ្សព្វផ្សាយភាពមិនពិត[4]ដែរ។

ការបង្រៀនធ្វើឡើងនៅក្នុងទីតាំងមួយដែលបំពាក់កុំព្យូទ័រ និងភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតសម្រាប់ប្រើប្រាស់។ សិស្សអាចប្រើប្រាស់កម្មវិធីជជែកតាមអ៊ីនធឺណិតនៅក្នុងឧបករណ៍ចល័តរបស់ពួកគេបាន ក្នុងពេលនៃការធ្វើលំហាត់អនុវត្តន៍ក្នុងមេរៀន។ គេត្រូវការអ៊ីនធឺណិតជាចាំបាច់សម្រាប់ស្វែងរកប្រភពពីខាងក្រៅ និងអាចភ្ជាប់ប្រព័ន្ធអន្តរបណ្តាញនៅសាលារៀន (ក្នុងករណីដែលមេរៀននេះបង្រៀននៅកម្រិតឧត្តមសិក្សា) ដើម្បីចូលមើលឯកសារក្នុងបណ្ណាល័យ និងមណ្ឌលធនធានព័ត៌មានដទៃទៀត ដែលទុកសម្រាប់ការប្រើប្រាស់នៅក្នុងសាលារៀន។

3 For examples of “journalese” consider: Fluent in Journalese by Philip B. Corbett. March 17, 2015 https://afterdeadline.blogs.nytimes. com/2015/03/2017/fluent-in-journalese/ ; My ‘shameful secret’: I’ve learnt to love clichéd journalese by Rob Hutton. 05 Sep 2013. https://www. telegraph.co.uk/culture/10288967/My-shameful-secret-Ive-learnt-to-love-cliched-journalese.html [both accessed 22/04/2018].

4 The integration of MIL in journalism education is studied by for example Van der Linde, F. 2010.The necessity of a media literacy module within journalism or media studies curricula. Global Media Journal, African Edition. Vol4, no.2 http://globalmedia.journals.ac.za/pub/article/view/7

## គ្រោងនៃមេរៀន

ព័ត៌មានមិនពិតដែលក្លែងខ្លួនជាដំណឹងត្រឹមត្រូវ ហើយចេញពីការបោះឆ្នោតនៅអាមេរិក បារាំង កេនយ៉ា និងអាល្លឺម៉ង់ កាលពីឆ្នាំ២០១៦ និង២០១៧ គឺគ្រាន់តែជាបំណែកតូចមួយនៃការប្រឈមផ្នែកព័ត៌មាន ដែលកើតមានចំពោះសង្គមប៉ុណ្ណោះ ប៉ុន្តែវាប្រហែលមានផលវិបាកដ៏ធំធេង។ ទោះបីយ៉ាងណា សូមពិចារណាមើលថា ស្ថានីយទូរទស្សន៍ និងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម នៅជុំវិញពិភពលោក បានតាមដានក្នុងពេលព្រមគ្នានូវអព្ភូតហេតុដ៏អស្ចារ្យមួយ នៅក្នុងប្រទេសម៉ិចស៊ិក កាលពីឆ្នាំ២០១៧ ខណៈដែលអ្នកសង្គ្រោះបានព្យាយាមជួយសង្គ្រោះក្មេងស្រីសិស្សសាលាម្នាក់ ឈ្មោះ Frida Sofifa ដែលជាប់នៅក្នុងគំនរថ្មបាក់បែក បន្ទាប់ពីគ្រោះរញ្ជួយផែនដី ប៉ុន្តែការពិតទៅ នាងគ្មានរូបរាងពិតប្រាកដនោះទេ[5]។ នេះជារឿងមិនពិត ប៉ុន្តែប្រហែលមិនមែនជាករណីនៃការប្រឌិតរឿង ដោយចេតនានោះទេ។ ទោះជាយ៉ាងណា សារព័ត៌មានត្រូវតែចៀសវាងទាំងព័ត៌មានយល់ច្រឡំ និងដំណឹងក្លែងបន្លំ។ មិនមែនរឿងមិនពិតទាំងអស់នៅក្នុងដំណឹង សុទ្ធតែជា «ដំណឹងក្លែងក្លាយ» ក្នុងន័យជាព័ត៌មានមិនពិតនោះទេ ប៉ុន្តែរឿងទាំងពីរនេះបង្កបញ្ហាដូចគ្នាចំពោះលទ្ធភាពរបស់សង្គម ក្នុងការយល់ដឹងអំពីពិភពលោក។

ក្រុមគោលដៅចាំបាច់មិនត្រឹមតែ ត្រូវមានការយល់ដឹងអំពីប្រព័ន្ធផ្សព្វផ្សាយវាងវៃ និងព័ត៌មានជាទូទៅប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានការយល់ដឹងផ្នែកទស្សនវិជ្ជាមួយកម្រិតដែរ។ ឧទាហរណ៍ ពួកគេគួរតែយល់ថា ដំណឹងពិតប្រាកដមិនមែនបង្កើត «ការពិត» ពេញលេញនោះទេ (នេះគ្រាន់តែជាអ្វីមួយដែលប្រហាក់ប្រហែលប៉ុណ្ណោះ នៅក្នុងទំនាក់ទំនងមនុស្សជាមួយគ្នា និងជាមួយតថភាពនៅពេលយូរទៅ)។ សិស្ស និងនិស្សិតសារព័ត៌មានគួរតែយល់ថា ចំណុចសំខាន់គឺសារព័ត៌មានមិនត្រូវផ្សាយបន្ត ឬបន្ទរអ្វីដែលមិនពិតឡើយ។ ការប្រទះឃើញត្រីបាឡែន និងត្រីឆ្លាមនៅក្នុងអាងទឹក ឬនៅក្រោយផ្ទះរបស់ប្រជាជនក្រោយព្រឹត្តិការណ៍ព្យុះសង្ឃរា និងផលប៉ះពាល់មិនសូវទំនង ពីគ្រោះមហន្តរាយធម្មជាតិ ដែលបានចុះផ្សាយដោយបណ្តាញសារព័ត៌មាន គួរតែលើកជាសំណួរថា ៖ តើវាពិតទេ? ដំណឹងណាដែលមិនគោរពបទដ្ឋាននៃការផ្ទៀងផ្ទាត់ការពិត មិនត្រឹមតែជាលទ្ធភាពនៃការខ្ជីខ្ជាក្នុងការរាយការណ៍ និងកង្វះនីតិវិធីគ្រប់គ្រាន់សម្រាប់ដំណើរ

5 Campoy, A. (2017). A school girl trapped in Mexico's earthquake rubble won the world's hearts– except she did not exist. Quartz. Available at: https://qz.com/1084105/a-schoolgirl-trapped-in-mexicos-earthquake-rubble-won-the-worlds-hearts-except-she-didnt-exist/ [accessed 03/04/2018].

ការផ្សព្វផ្សាយប៉ុណ្ណោះទេ វាក៏អាចជាចេតនាបោកបញ្ឆោត និងបំភ័ន្តផងដែរ។ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានជាការចាំបាច់ដើម្បីបកស្រាយភាពខុសគ្នា និងវិធីប្រៀបធៀបករណីខាងលើជាមួយនឹងដំណឹង ដែលមានវិជ្ជាជីវៈ និងមានក្រមសីលធម៌។

ផ្លូវនៅវែងឆ្ងាយទៅមុខទៀត។ កម្រិតកើនឡើងនៃសម្ដីញុះញង់ឱ្យស្អប់ ការស្អប់ជនបរទេស និងការវាយប្រហារលើជនភៀសខ្លួន ឬប្រជាជនមកពីសាសនា និងជាតិព័ន្ធ«ផ្សេង» និងប្រជាជនដែលមានពណ៌សម្បុរខុសគ្នា ដែលផ្អែកលើទំនោរតាមគ្នាផ្សំពីស្ថិតិប្រឌិត រោហារសាស្ត្រប្រជាភិថុតិ និងរបាយការណ៍ដំណឹងបំភ័ន្តដែលមិនស្របតាមបទដ្ឋានវិជ្ជាជីវៈសារព័ត៌មាន សុទ្ធតែជាការបន្ថែមលើបរិស្ថានបំពុលព័ត៌មាន ដែលអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ចាំបាច់ត្រូវតែប្រឆាំងតបវិញ។ បញ្ហានេះនឹងកាន់តែស្មុគស្មាញថែមទៀត ខណៈដែលកម្មវិធីកុំព្យូទ័រដែលប្រើបញ្ញាសប្បនិម្មិត ត្រូវបានគេប្រើប្រាស់ ដើម្បីបង្កើតការធ្វើត្រាប់តាមមនុស្ស នៅក្នុងរបាយការណ៍ជាវីដេអូ និង/ឬជាខ្សែអាត់សំឡេងក្លែងបន្លំ ដែលពុំមានមូលដ្ឋានឈរលើការពិត[6]។

បញ្ហាលតម្រូវការសម្រាប់ណែនាំសិស្ស និស្សិត និងអ្នកអនុវត្តវិជ្ជាជីវៈសារព័ត៌មាន ឱ្យពិចារណាអំពីអ្វីដែលពួកគេស្ដាប់ឮ និងឃើញ រាប់តាំងពីកិច្ចសន្ទនាដ៏សាមញ្ញបំផុត រហូតដល់ដំណឹងដែលគេផ្សព្វផ្សាយទូលំទូលាយបំផុត នៅក្នុងប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយពហុបច្ចេកវិទ្យា។

បន្ថែមពីលើប្រភេទនៃព័ត៌មានមិនពិត និងព័ត៌មានខុសដែលបានកំណត់ដោយ Wardle និង Derakhshan (ឆ្នាំ២០១៧)[7] អង្គការ European Association for Viewers' Interests (EAVI) ដែលមានមូលដ្ឋាននៅទីក្រុងប្រ៊ុចសែល នៅក្នុងបរិបទនៃកម្មវិធីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយសម្រាប់ភាពជាពលរដ្ឋ បានផលិតក្រាហ្វិកដ៏មានប្រយោជន៍មួយមានចំណងជើងថា «Beyond Fake News: Ten Types of Misleading News» ដែលសង្ខេបអំពីអ្វីដែលអ្នកប្រើប្រាស់ដំណឹង កំពុងប្រឈមនាពេលបច្ចុប្បន្ន[8]។ ក្រាហ្វិកដំណឹងនេះគឺជាធនធានដ៏មានតម្លៃសម្រាប់សិស្ស និស្សិតសារព័ត៌មាន និងអ្នកអនុវត្តវិជ្ជាជីវៈសារព័ត៌មាន។

ឯកសារស្រាវជ្រាវរបស់លោកបណ្ឌិត Peter A. Facione ដែលធ្វើបច្ចុប្បន្នភាព

6 Edmund, C. (2017). This AI can create a video of Barack Obama saying anything. [online World Economic Forum. Available at: https://www.weforum.org/agenda/2017/07/obama-speech-simulation-washington-university?

7 សូមមើលមេរៀនទី២

8 EAVI. (2018). EAVI. eu. [online] Available at: https://eavi.eu/beyond-fake-news-10-types-misleading-info

និងមានចំណងជើងថា «Critical Thinking: What It Is and Why It Counts»[9] គឺជាមូលដ្ឋានគ្រឹះដ៏ល្អមួយសម្រាប់ឱ្យសិស្សយល់ដឹងអំពី «ការវែកញែកហេតុផល ការធ្វើសេចក្តីសម្រេចចិត្ត និងដំណើរការគិតគូរម្នាក់ឯង និងជាក្រុមប្រកបដោយប្រសិទ្ធភាព»។ ឯកសារស្រាវជ្រាវនេះ កាន់តែមានសារៈសំខាន់នៅក្នុងយុគសម័យ «ក្រោយសច្ចភាព» «ដំណឹងក្លែងក្លាយ» និង «ការពិតមួយបែបទៀត»។ នៅក្នុងអភិក្រមនេះ ការពិចារណារួមមាន៖

- ការចូលចិត្តឆ្ងល់ ឬសួរច្រើន អំពីបញ្ហាផ្សេងៗ
- ការខ្វល់ខ្វាយ ដើម្បីប្រែក្លាយ និងនៅតែយល់ដឹងច្រើន
- ភាពវាងវៃ និងរហ័សរហួន ក្នុងការស្វែងរកឱកាសដើម្បីគិតពិចារណា
- ការជឿជាក់លើដំណើរការសួរសំណួរ ដោយមានហេតុផល
- ភាពជឿជាក់លើខ្លួនឯង និងសមត្ថភាពខ្លួនឯងនៅក្នុងការផ្តល់ហេតុផល
- ចិត្តបើកទូលាយចំពោះទស្សនៈពិភពលោកដែលខុសៗគ្នា
- ភាពបត់បែននៅក្នុងការពិចារណាអំពីជម្រើស និងមតិ
- ការយល់អំពីមតិរបស់អ្នកដទៃ
- ចិត្តមានយុត្តិធម៌នៅក្នុងការវាយតម្លៃហេតុផល
- ការទទួលស្គាល់ និងការប្រឈមមុខយ៉ាងស្មោះត្រង់ចំពោះភាពលម្អៀងទៅរកខ្លួនឯង បុរេវិនិច្ឆ័យ ទំនោរតាមគ្នា ឬទំនោរអត្តនោម័ត។
- ការប្រុងប្រយ័ត្នក្នុងការផ្អាក ការធ្វើ ឬការកែប្រែសេចក្តីវិនិច្ឆ័យ
- ឆន្ទៈក្នុងការពិចារណាឡើងវិញ និងកែសម្រួលទស្សនៈ នៅពេលណាដែលការត្រិះរិះបង្ហាញថា ចាំបាច់ត្រូវមានការផ្លាស់ប្តូរ

យោងតាមការសិក្សានានា នៅក្នុងកន្លែងជាច្រើននៃពិភពលោក ការនិយមប្រើឧបករណ៍ចល័តរបស់យុវជន[10] មានន័យថាពួកគេទទួលដំណឹងភាគច្រើនបំផុតរបស់ខ្លួន តាមរយៈម៉ាស៊ីនទាំងនេះនៅលើកម្មវិធីជជែក ប្រព័ន្ធផ្សព្វផ្សាយសង្គម

9 Facione, P. (2010, updated). Ibid. Critical Thinkin

10 Children’s use of mobile phones. (2015). [ebook] Tokyo: Mobile Society Research Institute, NTTDotcomo. Available at: https://www.gsma.com/publicpolicy/wp- content/uploads/2012/03/GSMA_Childrens_use_of_mobile_phones_2014.pdf

និងជូនកាលតាមរយៈគេហទំព័រដំណឹងបែបប្រពៃណី និងគេហទំព័រសំណេរ[11 12 13]។ ភាគច្រើននៃកម្មវិធីទាំងនេះមានតិចតួច ឬគ្មានសោះនូវអ្វីដែលសម្គាល់ឱ្យដឹងថា អ្វីជាសារព័ត៌មានល្បីឈ្មោះ និងអ្វីជាសេចក្តីរាយការណ៍ខ្វះវិជ្ជាជីវៈ កុំថាឡើយ ដល់ទៅសម្គាល់ថា អ្វីជាព័ត៌មានមិនពិតនោះ។

បញ្ហាមួយផ្សេងទៀតគឺរបៀប ដែលកម្មវិធីទាំងនេះយល់អំពីដំណឹង។ ចំពោះ Facebook ដែលជាកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមដ៏ធំជាងគេបំផុត «...សារព័ត៌មានគឺជារឿងគួរឱ្យឈឺក្បាលតាំងពីថ្ងៃទីមួយមកម្ល៉េះ។ ឥឡូវនេះ ដោយកំពុងជាប់ផុងក្នុងបញ្ហាដោះស្រាយមិនបានអំពីដំណឹងក្លែងក្លាយ និងទំនាក់ទំនងសាធារណៈអាក្រក់ គេមើលឃើញច្បាស់ថា Facebook នឹងបោះចោលដំណឹងបន្តិចម្តងៗ»[14] នេះបើតាមការលើកឡើងរបស់ Frederic Filloux។ លទ្ធផលទៅជាយ៉ាងណា គេត្រូវរង់ចាំមើលបន្តទៀត។ ស្ថាប័នដំណឹងមួយចំនួននឹងមានអារម្មណ៍មិនល្អ បើ Facebook បិទដំណឹងមែន ដោយនិយាយថា ក្រុមគោលដៅរបស់ពួកគេនឹងទទួលបានតិច ពីព្រោះ Facebook ជាមធ្យោបាយចែកចាយសម្រាប់អ្នកប្រើប្រាស់ ដែលពឹងផ្អែកលើកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីតាមដានព្រឹត្តិការណ៍នានា[15]។ ប៉ុន្តែអ្នកគាំទ្រអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានខ្លះសង្ឃឹមថា ចំណាត់ការបែបនេះ អាចនឹងនាំឱ្យអ្នកប្រើប្រាស់ដំណឹងក្មេងៗ ពង្រីកជើងមេឃរបស់ខ្លួនដើម្បីដឹងរឿងរ៉ាវ ដែលកំពុងកើតឡើងនៅក្នុងពិភពលោក ជុំវិញខ្លួនរបស់ពួកគេ និងមិនពឹងផ្អែកទាំងស្រុងតែលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលមានការបំពុលដំណឹង និងការទទួលបានដំណឹងដោយមិនបាច់ប្រឹង តាមរយៈឧបករណ៍ដែលបើកចោល «ជានិច្ចកាល» របស់ពួកគេ។ ស្របពេលជាមួយគ្នានេះដែរ មានការលើកឡើងជាយោបល់ថា Facebook អាចនឹងប្រឡូកក្នុងការផលិតដំណឹងដោយខ្លួនឯងដោយប្រកួតប្រជែងជាមួយតួអង្គផ្សព្វផ្សាយដំណឹងដែលមានស្រាប់[16]។

តាមរយៈអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន សិស្សអាចរៀនទទួលស្គាល់

11 Digital News Report (2017). Reuters Institute for the Study of Journalism's (RISJ, Oxford) https://reutersinstitute.politics.ox.ac.uk/sites/default/files/Digital%20News%20Report%202017%20web_0.pdf

12 Shearer, E. & Gottfried, J. (2017). News Use Across Social Media Platforms. [ebook] Washington DC: Pew Research Centre. Available at: http://www.journalism.org/2017/09/07/news-use-across-social-media-platforms-2017/

13 Youth, Internet, and Technology in Lebanon: A Snapshot (2017) Social Media Exchange. Available at https://smex.org/youth-internet-and-technology-in-lebanon-a-snapshot/

14 Filloux, F. (2018). The Monday Note, 14 January, 2018. Available at: https://mondaynote.com/facebook-is-done-with-quality-journalism-deal-with-it-afc2475f1f84

15 សូមមើលមេរៀនទី២

16 Is Facebook's Campbell Brown a Force to Be Reckoned With? Or Is She Fake News? https://www.nytimes.com/2018/04/21/technology/facebook-campbell-brown-news.html

ថា សូម្បីដំណឹងពិតក៏ជានិច្ចកាល ត្រូវបានគេផលិតឡើង និងប្រើប្រាស់នៅក្នុងក្របខ័ណ្ឌពិពណ៌នាដ៏ទូលំទូលាយ ដែលផ្តល់អត្ថន័យឱ្យការពិត និងដែលជាប់ពាក់ព័ន្ធនឹងការសន្មត មនោគមន៍វិជ្ជា និងអត្តសញ្ញាណកាន់តែទូលំទូលាយ។ ដំណើរនេះ មានន័យថា ជាសមត្ថភាពស្គាល់ចំណុចខុសគ្នារវាងកិច្ចប្រឹងប្រែងចម្រុះរបស់សារព័ត៌មានដើម្បីផ្ចិតយក និងពណ៌នាការពិតដែលលេចធ្លោឱ្យបានត្រឹមត្រូវ និងជាឧទាហរណ៍នៃការបោកប្រាស់ ដែលកេងចំណេញពីទម្រង់ដំណឹង ខណៈដែលរំលោភលើបទដ្ឋានវិជ្ជាជីវៈនៃភាពអាចផ្ទៀងផ្ទាត់បាន។

អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានក៏អាចជាឧបករណ៍មួយដើម្បីប្រយុទ្ធប្រឆាំងនឹងទំនោរតាមគ្នា និងលើកកម្ពស់ការប្រាស្រ័យទាក់ទងចម្រុះវប្បធម៌ ដោយការប្រើប្រាស់ ពហុភាសានិយម ជាកត្តាសំខាន់ក្នុងការសម្រេចគោលដៅនោះ។ តួអង្គនានាបានចូលរួមចំណែកដល់កិច្ចប្រឹងប្រែងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ហើយធនធានល្អៗមាននៅលើគេហទំព័ររបស់អង្គការយូណេស្កូ[17]។ ប៉ុន្តែនៅមានអ្វីៗជាច្រើនទៀត ដែលចាំបាច់ត្រូវធ្វើឡើងតាមរយៈកម្មវិធីសិក្សា និងតាមការអនុវត្តជាក់ស្តែង ដើម្បីប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងព័ត៌មានខុស[18]។

ដើម្បីសម្រេចបានលទ្ធផលក្នុងមេរៀននេះ គេអាចប្រើប្រាស់វីដេអូគ្រប់ទីកន្លែងសម្រាប់ចូលរួមជាមួយសិស្ស តាមរយៈការប្រើប្រាស់វីដេអូខ្លីៗ និងមានចំណងជើង[19]ជាទម្រង់មួយនៃ«ការបង្រៀនបែបកម្សាន្ត» ដើម្បីបង្ហាញសារក្លែងក្លាយ ជំរុញឱ្យអ្នកសិក្សាស្វែងរកឧទាហរណ៍ ដោយខ្លួនឯងអំពីមាតិកាដែលបំភ័ន្ត និងបង្កើតទម្លាប់ពួកគេឱ្យចេះមានមន្ទិលសង្ស័យ ទៅលើគ្រប់ចំណុចនៃមាតិកា ក្នុងនោះរាប់បញ្ចូលទាំងមាតិកាដែលបង្ហាញជាដំណឹងផងដែរ។

គ្រូបង្រៀនក៏គួរតែជួយសិស្សឱ្យកែប្រែទម្លាប់ ឬទំនោររបស់ពួកគេ ដែលចូលចិត្តប្រើ «Google» ជាលក្ខណៈសើៗក្នុងការស្វែងរកដំណឹងភាគច្រើន ដោយងាកទៅ

17 Available at http://www.unesco.org/new/en/communication-and-information/media-development/media-literacy/mil-as-composite-concept/[accessed 22/04/2018].].

18 Abu-Fadil, M. (2007). Media Literacy: A Tool to Combat Stereotypes and Promote Intercultural Understanding. Available at: http://unesdoc.unesco.org/images/0016/001611/161157e.pdf [accessed 01/04/2018].

19 នេះគឺជាឧទាហរណ៍នៃវីដេអូដែលមានឥទ្ធិពលក្នុងការបង្ហាញអំពីតម្លៃនៃអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ដំណឹងនៅក្នុងបរិបទនៃការបាញ់ប្រហារនៅសហរដ្ឋអាមេរិកតាមប្រព័ន្ធផ្សព្វផ្សាយ Vice Media ថាអ្នកបោកបញ្ឆោតនិយាយថាជនរងគ្រោះក្នុងការបាញ់ប្រហារនោះជា "អ្នកបង្កឱ្យមានវិបត្តិ" មាននៅ៖ Vice Select on Facebookhttps://www.facebook.com/vicenews/videos/842904982564160/ [accessed 01/04/2018].

ផ្តួចផ្តើមការស្វែងរកនៅលើអ៊ីនធឺណិត ដែលមានលក្ខណៈស៊ីជម្រៅ ក្នុងនោះរាប់ទាំងការប្រើមុខងារស្វែងរកកម្រិតខ្ពស់ ការផ្ទៀងផ្ទាត់ប្រភពព័ត៌មានច្រើន និងការយល់អំពីគុណតម្លៃនៃបណ្ណាល័យ និងបណ្ណារក្សនៅក្នុងការកសាងចំណេះដឹងពាក់ព័ន្ធនឹងការរុករក និងវាយតម្លៃព័ត៌មាន[20]។ បណ្ណាល័យអ៊ីនធឺណិតបានបង្កលក្ខណៈកាន់តែងាយស្រួលថែមទៀត ក្នុងការចូលទៅស្វែងរក និងប្រើប្រាស់ឯកសារយោងរបស់បញ្ញវន្ត និងឯកសារយោងដទៃទៀត ដែលនិស្សិតសារព័ត៌មាន និងអ្នកសារព័ត៌មានអាជីពអាចប្រើប្រាស់ ដើម្បីសម្រួចចំណេះដឹងរបស់ខ្លួនអំពីដំណើរការ និងការអនុវត្តនានា សម្រាប់ការវាយតម្លៃ និងផ្ទៀងផ្ទាត់ព័ត៌មានដោយការពិចារណា។ ធនធានដទៃទៀត ក៏បំពេញបន្ថែមដល់ដំណើរការសិក្សា/ចំណេះដឹង ដើម្បីជួយសិស្សឱ្យចូលប្រឡូកក្នុងសមរភូមិ ប្រយុទ្ធប្រឆាំងនឹងដំណឹងបោកប្រាស់ ការពារខ្លួនប្រឆាំងនឹងផលប៉ះពាល់អវិជ្ជមានរបស់វា និងត្រៀមលក្ខណៈបកអាក្រាតដំណឹងបោកប្រាស់ជាផ្នែកមួយនៃការប្រកបវិជ្ជាជីវៈសារព័ត៌មាន[21]។

ការភ្ជាប់ទំនាក់ទំនងប្រជាពលរដ្ឋជាមួយនឹងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដែលទទួល និងចែករំលែកព័ត៌មានមិនពិត ឬព័ត៌មានខុស ក៏ជាវិធីសាស្ត្រមួយដ៏មានសក្តានុពលផងដែរ សម្រាប់អ្នកសារព័ត៌មាន និងនិស្សិតសារព័ត៌មាន ដើម្បីសិក្សាអំពីវិធីដែលមានប្រសិទ្ធភាពសម្រាប់ស្វែងរក តាមដាន និងបកអាក្រាតដំណឹងក្លែងក្លាយ ទាំងដើម្បីខ្លួនផង និងដើម្បីសហគមន៍ផង។ គ្រូត្រូវបានលើកទឹកចិត្តឱ្យពិចារណាដាក់លំហាត់ឱ្យសិស្ស ទាក់ទងនឹងបញ្ហានេះនៅក្នុងមេរៀន។

ពាក្យពេចន៍របស់ Rouba El Helou សាស្ត្រាចារ្យ និងជាអ្នកស្រាវជ្រាវប្រព័ន្ធផ្សព្វផ្សាយជាន់ខ្ពស់ នៃសកលវិទ្យាល័យ Notre Dame University ប្រទេសលីបង់ មានសារៈប្រយោជន៍ ដើម្បីពិចារណាអំពីសារៈសំខាន់នៃមេរៀននេះ ៖ «ការបំពាក់បំប៉នមនុស្សឱ្យមានជំនាញចាំបាច់ សម្រាប់បកស្រាយសារនានាគឺជាការតស៊ូឥតឈប់ឈរមួយ ដែលអ្នកអប់រំផ្នែកវិជ្ជាជីវៈសារព័ត៌មាន និងអ្នកសារព័ត៌មានត្រូវបានស្នើសុំឱ្យចូលរួមទាំងអស់គ្នា។ អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ជួយមនុស្សឱ្យរកឃើញតុល្យភាពរវាងទំនុកចិត្តទៅលើប្រភពដំណឹង និងមន្ទិលសង្ស័យ ដែលចាំបាច់ ដើម្បីចោទសួរពួកគេ»។

20 15 resources for teaching media literacy. ASCD. Available at http://inservice.ascd.org/15-resources-for-teaching-media-literacy/.[accessed 03/04/2018].

21 An example is Project Look Sharp, a media literacy initiative of Ithaca College, which has media literacy guides, curriculum kits and downloadable handouts. www.projectlooksharp.org. [accessed 23/03/2018].

## គោលបំណងនៃមេរៀន

មេរៀននេះមានគោលបំណងដើម្បី៖

- គូសបញ្ជាក់អំពីសារៈសំខាន់នៃការសិក្សា ឱ្យទទួលបានចំណេះដឹងដែលចាំបាច់[22] និងជំនាញដែលទាក់ទង[23] ដើម្បីយល់អំពីសារព័ត៌មាន (និងទម្រង់ក្លែងក្លាយដទៃទៀតនៃសារព័ត៌មាន) ហើយទន្ទឹមនឹងនេះ គឺរកឱ្យឃើញទាំងសារព័ត៌មានដែលខ្វះចន្លោះ និងដំណឹងបោកប្រាស់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយនានា។
- ផ្តល់ឱ្យសិស្សនូវជំនាញ ដើម្បីវិភាគអំពីការប្រើប្រាស់ព័ត៌មានរបស់ពួកគេ នៅទូទាំងវិសាលគមប្រព័ន្ធផ្សព្វផ្សាយ និងជំនាញដើម្បីមើលថា តើវាស្រួលក្នុងការផលិតព័ត៌មានមិនពិតបែបណា។
- បង្រៀនសិស្សឱ្យចេះអភិវឌ្ឍទម្លាប់សង្ស័យបែបវិជ្ជមាន ចំពោះរាល់ព័ត៌មានទាំងអស់ ដែលពួកគេប្រើប្រាស់ និងរបៀបថ្លឹងថ្លែងភាពត្រឹមត្រូវនៃសេចក្តីរាយការណ៍ អត្ថបទ រូបភាព វីដេអូ មាតិកាជាសំឡេង ក្រាហ្វិកដំណឹង និងស្ថិតិនៅក្នុងបរិបទសមស្រប។

## លទ្ធផលសិក្សា

នៅចុងបញ្ចប់នៃមេរៀននេះ សិស្សនឹងអាច៖

១. ស្គាល់ភាពខុសគ្នារវាងអ្វីដែលជាការពិត និងអ្វីដែលជាការប្រឌិត ព្រមទាំងភាពស្របច្បាប់នៃការពណ៌នា និងរឿងដែលមានភាពចម្រុះនៅក្នុងសារព័ត៌មានដែលត្រឹមត្រូវ។

២. យល់អំពីរបៀបជ្រើសរើសរឿង នរណាជាអ្នកផលិតមាតិកា វិធីសាស្ត្រអ្វីខ្លះដែលគេប្រើ ដើម្បីបង្កើតការពណ៌នាត្រឹមត្រូវអំពីតថភាព របៀបនៃការប្រើប្រាស់ភាសា គេសង្កត់ធ្ងន់លើអ្វីខ្លះ គេលុបចោលអ្វីខ្លះ អ្នកណានិយាយអ្វី តើអ្នកនោះសំខាន់និង/ឬអាចជឿជាក់បានកម្រិតណា តើគេមានរបៀបវារៈ

22 សម្រាប់ព័ត៌មានទាក់ទងនឹងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានសូមមើល៖ UNESCO’s Notions of MIL http://unesco.mil-for-teachers.unaoc.org/foreword/unifying-notions-of-media-and-information-literacy/ [accessed 22/4/2018].

23 In addition to critical thinking skills identified by Facione (2010), participants should be encouraged to be sceptical; question everything; assume nothing; fact-check sources.

អ្វីខ្លះ តើផលប៉ះពាល់អ្វីខ្លះដែលដំណឹងធ្លាប់មាន/មាន/នឹងមាន និងតើអ្នកដទៃមើលឃើញព្រមទាំងប្រើប្រាស់ដំណឹងដូចគ្នានេះដោយរបៀបណា។

៣. យល់ស៊ីជម្រៅទៅលើកម្រិតអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានរបស់ខ្លួន និងសារៈសំខាន់នៃការអប់រំនេះ ចំពោះមនុស្សក្នុងនាមជាបុគ្គល និងរបៀបដែលការអប់រំនេះ ទាក់ទងនឹងការចូលរួមរបស់បុគ្គលទាំងនោះជាមួយដំណឹង និងការប្រាស្រ័យទាក់ទង។

## ទម្រង់នៃមេរៀន

មេរៀននេះបែងចែកជាពីរវគ្គ ដោយមួយវគ្គៗមានរយៈពេល ៩០នាទី។ វគ្គទីមួយផ្តោតលើទ្រឹស្តី និងវគ្គទីពីរផ្តោតលើការអនុវត្ត។

វិធីសាស្ត្របង្រៀនផ្អែកលើកិច្ចពិភាក្សាថា តើការអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានមានអត្ថន័យយ៉ាងដូចម្តេច ហើយវាមានសារៈសំខាន់បែបណាក្នុងយុគសម័យព័ត៌មានមិនពិត និងការបំភ្លៃការពិតក្នុងទម្រង់ផ្សេងៗទៀត ដែលផ្សព្វផ្សាយរាលដាលយ៉ាងលឿន តាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណី និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ សម្ភារៈសម្រាប់ការបង្រៀនមេរៀននេះ អាចរកបាននៅលើអ៊ីនធឺណិត ហើយមានធនធានជាច្រើន ដែលមានប្រយោជន៍សម្រាប់ការស្រាវជ្រាវ និងលំហាត់អនុវត្តន៍។

គេហទំព័រសំខាន់ៗរួមមាន៖

- http://en.unesco.org/ and its Media Literacy site https://en.unesco.org/themes/media-literacy
- https://www.unaoc.org/
- http://www.unesco.org/new/en/communication-and-information/resources/ publications-and-communication-materials/publications/full-list/ media-and-information-literacy-curriculum-for-teachers/
- http://www.unesco.org/new/en/communication-and-information/media-development/media-literacy/five-laws-of-mil/
- https://eavi.eu/ beyond-fake-news-10-types-misleading-info/
- http://www.thenewsliteracyproject.org/, http://www.centerfornewsliteracy.org/

- http://propaganda.mediaeducationlab.com/
- http://drc.centerfornewsliteracy.org/
- https://centermil.org/resources/
- នៅមានជាច្រើនទៀត

សម្រាប់មេរៀននេះ គ្រូត្រូវបានលើកទឹកចិត្តឱ្យបន្ថែមធនធានពីបណ្ដាប្រទេស និងតំបន់នានារបស់ខ្លួនជាភាសាផ្សេងៗគ្នា។

ថ្នាក់រៀនគួរតែមានបំពាក់កុំព្យូទ័រ និងភ្ជាប់អ៊ីនធឺណិត ដើម្បីអាចឱ្យគ្រូ និងសិស្សនិស្សិតចូលមើលគេហទំព័ររបស់អង្គការនានា ដែលពាក់ព័ន្ធនៅក្នុងវិស័យអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន រួមនឹងករណីសិក្សាអំពីប្រព័ន្ធផ្សព្វផ្សាយ។

## ភ្ជាប់ផែនការទៅនឹងលទ្ធផលសិក្សា

ក. ទ្រឹស្ដី

គ្រូនឹងបង្ហាញសម្ភារៈ និងករណីសិក្សាអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន និងទំនាក់ទំនងរបស់ការអប់រំនេះទៅនឹងព័ត៌មានមិនពិត និងព័ត៌មានខុស ដែលក្លែងជាដំណឹង។

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| ចូរពន្យល់និងពិភាក្សាអំពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន និងឧបករណ៍នានា រួមទាំងក្របខ័ណ្ឌសម្រាប់ការត្រិះរិះពិចារណា | ៩៥នាទី | ១ + ៣ |
| ពិនិត្យឡើងវិញ និងពិភាក្សាអំពីឧទាហរណ៍ដែលបានជ្រើសរើស ដែលមានបរិបទពាក់ព័ន្ធនៅក្នុងទម្រង់ប្រព័ន្ធផ្សព្វផ្សាយនានា | ៩៥នាទី | ១ + ២ |

## ខ. អនុវត្តន៍

សកម្មភាពដែលទាក់ទងនឹងសម្ភារៈ និងឧបករណ៍សិក្សា៖

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| សកម្មភាពអនុវត្តន៍ | ៩០នាទី | ១ + ៣ |
| **សកម្មភាពទី១** ៖ ការស្គាល់វិជ្ជាជីវៈសារព័ត៌មាន<br><br>ចូររកមើលរឿងទំព័រមុខពីសារព័ត៌មានក្នុងស្រុក។ សិស្សម្នាក់ៗគួរតែស្រាវជ្រាវ និងពិនិត្យមើលរឿងតែមួយដូចគ្នាដែលគេផ្សាយនៅលើស្ថាប័នដំណឹងខុសៗគ្នាចំនួន៣។ ចូរដឹកនាំកិច្ចពិភាក្សា ដោយឱ្យសិស្សអនុវត្តបច្ចេកទេសត្រិះរិះ។ ពួកគេក៏គួរតែវិភាគទៅលើការពិពណ៌នាជាមូលដ្ឋាន រួមនឹងការរៀបចំ ជ្រើសរើស និងសរសេរដំណឹង។ ការវិភាគនេះគួរតែផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើវត្តមាននៃវិធីធ្វើដំណឹង (ធាតុផ្សំមានដូចជានរណាពាក់ព័ន្ធ មានរឿងអ្វី នៅកន្លែងណា នៅពេលណា កើតឡើងដូចម្តេច ហេតុអ្វី ការប្រើប្រាស់សម្រង់សម្តីផ្ទាល់ ការពឹងផ្អែកលើអ្នកជំនាញ និងប្រភពដែលអាចយកជាការបានរូបភាពគាំទ្រ វាក្យសព្ទដែលដូចគ្នាទៅនឹង «ភាសាសារព័ត៌មាន» អមជាមួយនឹងសញ្ញានៃ «ភាពមានតម្លៃជាដំណឹង» ដទៃទៀត។ | ៤៥ នាទី | |

| | | |
|---|---|---|
| **សកម្មភាពទី២៖** ការបង្ហាញព័ត៌មានមិនពិតថាជាដំណឹង<br><br>ចូរបង្ហាញសិស្សនូវឧទាហរណ៍មួយអំពីដំណឹងបោកប្រាស់ និងពិភាក្សាអំពីអ្វីដែល «លាក់ជិតបានល្អ» និងអ្វីដែល «លាតត្រដាងដោយអចេតនា»។ បន្ទាប់មកឱ្យសិស្សប្រើប្រាស់រឿងដែលពួកគេបានអាននៅក្នុងលំហាត់មុន ដោយបង្កើតវាទៅជារឿងក្លែងក្លាយមួយ ដែលកើតឡើងពេលអនាគតឆាប់ៗនេះ ហើយដែលមើលមួយភ្លែតមានរូបរាងដូចដំណឹងពិត។ (ឬជម្រើសមួយទៀតដោយឱ្យសិស្សជ្រើសរើសប្រធានបទផ្ទាល់ខ្លួនសម្រាប់ការបង្កើតព័ត៌មានមិនពិត)។<br><br>ពេលចប់ សិស្សបង្កើតក្រុមដើម្បីវាយតម្លៃកត្តាអ្វីខ្លះដែលធ្វើឱ្យរឿងនេះមើលទៅដូចរឿងពិត។ វាអាចពាក់ព័ន្ធនឹងការប្រើប្រាស់ការសាកល្បងវាយតម្លៃ ប៉ុន្តែគួរតែបញ្ចូលការកំណត់អត្តសញ្ញាណនៃសញ្ញាដំណឹងដែលត្រូវគេកេងចំណេញគ្រប់ចំណុច។ ចូរបែងចែកជាក្រុមឡើងវិញ ហើយឱ្យសិស្សចែករំលែកគំនិតរបស់ពួកគេ តាមរយៈបទបង្ហាញខ្លីៗដោយបង្ហាញទៅក្រុមធំទាំងមូល។ | ៤៥នាទី | ១ + ៣ |

## លំហាត់ស្រាវជ្រាវបន្ថែម

សិស្សម្នាក់ៗគួរតែស្រាវជ្រាវ នៅលើគណនីប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ខ្លួន ដើម្បីរកមើលដំណឹងទាក់ទងនឹងវិទ្យាសាស្ត្រ ឬវេជ្ជសាស្ត្រ (ឧ. របៀបតមអាហារប្លែកៗ ការផ្ទុះឡើងនៃជំងឺឆ្លង ផលប៉ះពាល់នៃការកើនឡើងកម្តៅផែនដីមកលើសហគមន៍របស់ខ្លួន ប្រសិទ្ធភាពរបស់រថយន្តប្រើអគ្គិសនីធៀបគ្នានឹងរថយន្តប្រើប្រេងឥន្ធនៈ)។ ពួកគេវាយតម្លៃការស្រាវជ្រាវរបស់ខ្លួន ការអះអាងលម្អៀងរបស់គេ (នៅទីណាដែលមាន) និងប្រតិកម្មផ្លូវអារម្មណ៍របស់ពួកគេចំពោះរឿងនោះ/ទស្សនៈរបស់ពួកគេចំពោះបញ្ហានោះ ដោយមើលឃើញរបៀបដែលចំណុចទាំងអស់នេះមានទំនាក់ទំនងគ្នាជាមួយនឹង បញ្ហាអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានដូចជា ការស្រាវជ្រាវ ការវាយតម្លៃ សន្តិសុខបច្ចេកវិទ្យា សិទ្ធិ និងអត្តសញ្ញាណ រួមនឹងគោលការណ៍ក្រមសីលធម៌ស្នូលរបស់ដំណឹង។

បន្ទាប់មក ពួកគេគួរផ្តល់ព័ត៌មាន ដែលបានទទួលពីការស្រាវជ្រាវរបស់ខ្លួនអំពី៖ តើអ្នកណាជាអ្នកផលិតរឿងនោះ តើអ្នករាយការណ៍ដំណឹង ឬមនុស្សនោះដឹងអំពីអ្វីដែលគេចុះផ្សាយយ៉ាងដូចម្តេច និងថាតើរូបគេនោះទទួលផលប្រយោជន៍ពីការផ្សព្វផ្សាយនោះដែរឬទេ ផ្ទៀងផ្ទាត់ទិន្នន័យ ស្ថិតិ ក្រាហ្វិក។ បើមានលទ្ធភាព សិស្សក៏អាចប្រើប្រាស់បណ្ណាល័យ/បណ្ណាល័យអ៊ីនធឺណិតរបស់សកលវិទ្យាល័យ ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យ។ ក្រោយមកអាចឱ្យពួកគេសរសេរលទ្ធផលនៃការរកឃើញរបស់ពួកគេ ជាអត្ថបទរិះគន់សារព័ត៌មានចំនួន១៥០០ពាក្យ ដោយវិភាគទៅលើភាពខ្លាំង ភាពខ្សោយ អ្វីដែលគេលុបចេញ និងចន្លោះប្រហោងនៃមាតិកាដែលបានកំណត់។

## ឯកសារបន្ថែម

អត្ថបទដែលមានបទបង្ហាញ រូបភាព និងវីដេអូ មាននៅក្នុងបញ្ជីខាងក្រោមនេះ។ គ្រូត្រូវបានលើកទឹកចិត្តឱ្យបង្កើតបទបង្ហាញផ្ទាល់ខ្លួន និងដាក់បញ្ចូលរូបថត និងវីដេអូដែលទាក់ទងនឹងប្រទេស និងបរិបទរបស់ប្រទេសរៀងៗខ្លួន។

## អំណានបន្ថែម


Abu-Fadil, M. & Grizzle, A. (2016). Opportunities for Media and Information Literacy in the Middle East and North Africa. Available at: https://milunesco.unaoc.org/wp-content/ uploads/MIL-Mena-2016-english.pdf [accessed 05/01/2018].

A lexicon for the digital age. (2017). The Unesco Courier, [online](July-September 2017). Available at: https://en.unesco.org/courier/2017-july-september/lexicon-digital- age [accessed 06/04/2018].

Facione, P. (2010). Critical Thinking: What It Is and Why It Counts. [online] Insight Assessment. Available at: https://www.insightassessment.com/ [accessed05/01/2018].

Gray, J., Bounegru, L. & Venturini, T. (2017). What does fake news tell us about life in the digital age? Not what you might expect.

NiemanLab. [online] Available at: http://www.niemanlab.org/2017/04/what-does-fake-news-tell-us-about-life-in-the-digital-age-not-what-you-might-expect/ [accessed 06/04/2018]

Stephens, B. (2017). The Dying Art of Disagreement. The New York Times. [online] Available at: https://www.nytimes.com/2017/09/24/opinion/dying-art-of-disagreement.html [accessed 06/04/2018]


### អំណានបន្ថែមទៀត


Lytvynenko, J. (2018). Here's How A Canadian Imam Got Caught Up In Fake News About Houston. BuzzFeed. [online] Available at: https://www.buzzfeed.com/janelytvynenko/ toronto-imam-caught-up-in-fake-news?bftw&utm_term=.ha3w9B5rr#.acEgmYE66 [accessed06/04/2018].

Mulrooney Eldred, S. (2017). In an era of fake news, students must act like journalists: schools rarely require news literacy, but it's more important than ever. Science News. [online] Available at: https://www.sciencenewsforstudents.org/article/era-fake-news- students-must-act-journalists [accessed 06/04/2018].

Rusbridger, A., Neilsen, R. and Skjeseth,H.(2017). We asked people from all over the world how journalists should cover powerful people who lie. Here is what they said. Reuters Institute for the Study of Journalism, Oxford University. https://reutersinstitute.politics.ox.ac.uk/risj-review/we-asked-people-all-over-world-how- journalists-should-cover-powerful-people-who-lie [accessed 12/06/2018]

Vesey-Byrne, J. (2017). Bikini designer exposes why you shouldn’t trust everything you see on Instagram. The Independent. [online] Available at: https://www.indy100.com/article/bikini-designer-instagram-before-after-karina-irby-7934006?amp[accessed 06/04/2018].

# ការផ្ទៀងផ្ទាត់ការពិត ១០១

*Alexios Mantzarlis*




# មេរៀនទី៥

## សង្ខេប

*ចាប់ពីអ្នកនយោបាយដល់អ្នកធ្វើទីផ្សារ ពីក្រុមតស៊ូមតិដល់យីហោផលិតផល គ្រប់គ្នាដែលចង់បញ្ចុះបញ្ចូលអ្នកដទៃតែងតែចង់បំភ្លៃ បំផ្លើស ឬបំភ័ន្តការពិត។ មេរៀននេះបង្រៀនសិស្សពីវិធីសាស្ត្រស៊ើបអង្កេត ការត្រួតពិនិត្យមើលការពិត និងវាយតម្លៃភ័ស្តុតាងប្រកបដោយការពិចារណា ស្របទៅតាមបទដ្ឋាននិងក្រឹត្យក្រមសីលធម៌។*

## គ្រោងនៃមេរៀន

### ប្រវត្តិ និងនិយមន័យនៃការផ្ទៀងផ្ទាត់ការពិត ត្រូវចាត់ទុកជាទម្រង់គណនេយ្យភាពនៃសារព័ត៌មាន

លោក Daniel Patrick Moynihan សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក ប្រចាំរដ្ឋញូវយ៉ក និងជាឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅឥណ្ឌា និងនៅអង្គការសហប្រជាជាតិ (ឆ្នាំ១៩២៧-ឆ្នាំ២០០៣) មានប្រសាសន៍ថា៖ «មនុស្សគ្រប់រូបមានសិទ្ធិបង្កើតទស្សនៈផ្ទាល់ខ្លួន តែមិនមែនបង្កើតការពិតផ្ទាល់ខ្លួននោះទេ»[1]។

ពាក្យ «ការផ្ទៀងផ្ទាត់ការពិត» អាចមានន័យពីរផ្សេងគ្នានៅក្នុងសារព័ត៌មាន។ ជាទូទៅ ការិយាល័យដំណឹងជួលអ្នកពិនិត្យមើលការពិតឱ្យអាន និងផ្ទៀងផ្ទាត់ការអះអាងដែលអ្នកយកដំណឹងបានសរសេរនៅក្នុងអត្ថបទរបស់ខ្លួន។ ការផ្ទៀងផ្ទាត់ការពិតប្រភេទនេះ វាយតម្លៃលើភាពរឹងមាំនៃសេចក្តីរាយការណ៍ ពិនិត្យមើលការពិត និងតួលេខ និងដើរតួនាទីជាអ្នកពិនិត្យមើលគុណភាពទូទៅសម្រាប់មាតិការបស់អង្គភាពដំណឹងមួយនៅមុនពេលបោះពុម្ពផ្សាយ។ ការចាប់បដិសន្ធិដំបូងនៃការអនុវត្តបែបនេះក្នុងវិជ្ជាជីវៈសារព័ត៌មានសម័យទំនើប យ៉ាងហោចណាស់នៅប្រទេសលោកខាងលិច គឺផ្តើមចេញពីទស្សនាវដ្តីប្រចាំសប្តាហ៍ធំៗនៅអាមេរិក ដូចជាទស្សនាវដ្តី TIME នៅក្នុងទសវត្សរ៍ឆ្នាំ១៩២០[2]។

1 Moynihan, D. & Weisman, S. (2010). Daniel Patrick Moynihan. New York: Public Affairs.

2 Scriber, B. (2016). Who decides what's true in politics? A history of the rise of political fact-checking. [online] Poynter. Available at: https://www.poynter.org/news/who-decides-whats-true-politics-history-rise-political-fact-checking [accessed 28/03/2018].

ការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចដែលស្ថាប័នដំណឹងភាគច្រើន នៅជុំវិញពិភពលោកបានជួបប្រទះ ចាប់តាំងពីចូលសតវត្សរ៍ទី២១មក[3] មានន័យថា ផ្នែកត្រួតពិនិត្យមើលការពិតបានកាត់បន្ថយបុគ្គលិក ច្របាច់បញ្ចូលគ្នាជាមួយក្រុមកែសម្រួលអត្ថបទ ឬលុបបំបាត់ចោលទាំងអស់តែម្តង។ សព្វថ្ងៃ មានតែទស្សនាវដ្តីប្រចាំសប្តាហ៍ដែលមានក្រុមគោលដៅច្រើនដូចជា The New Yorker នៅសហរដ្ឋអាមេរិក ឬ Der Spiegel នៅអាល្លឺម៉ង់ តែប៉ុណ្ណោះ ដែលនៅជួលអ្នកផ្ទៀងផ្ទាត់ការពិតផ្នែកនិពន្ធ[4]។

ប្រភេទនៃការផ្ទៀងផ្ទាត់ការពិត ដែលជាប្រធានបទផ្តោតសំខាន់នៃមេរៀននេះមិនមែនកើតឡើងមុនពេលផ្សព្វផ្សាយនោះទេ គឺកើតឡើងក្រោយពេលដែលការអះអាងមួយក្លាយជារឿងពាក់ព័ន្ធនឹងសាធារណជន។ ទម្រង់នៃការផ្ទៀងផ្ទាត់ការពិត «ក្រោយការចេញផ្សាយ» នេះមានគោលបំណងធ្វើឱ្យអ្នកនយោបាយ និងឥស្សរជនសាធារណៈដទៃទៀត ទទួលខុសត្រូវចំពោះសុចរិតភាពនៃសេចក្តីថ្លែងការណ៍របស់ខ្លួន។ អ្នកត្រួតពិនិត្យមើលការពិត ស្វែងរកប្រភពបឋម និងមានកេរ្តិ៍ឈ្មោះ ដែលអាចបញ្ជាក់ ឬបដិសេធការអះអាងនានាដែលគេបានប្រកាសជាសាធារណៈ។

ការផ្ទៀងផ្ទាត់ការពិត «នៅក្រោយការចេញផ្សាយ» ផ្តោតជាចម្បង (ប៉ុន្តែមិនមែនផ្តាច់មុខ) ទៅលើការផ្សាយពាណិជ្ជកម្មនយោបាយ សុន្ទរកថាឃោសនាបោះឆ្នោត និងកម្មវិធីនយោបាយរបស់គណបក្ស។ គម្រោងដំបូងៗដែលផ្តោតការងារលើការផ្ទៀងផ្ទាត់ការពិត ផ្នែកនយោបាយក្នុងទម្រង់នេះរួមមាន Factcheck.org ជាគម្រោងរបស់មជ្ឈមណ្ឌលគោលនយោបាយសាធារណៈ Annenberg នៅឯសកលវិទ្យាល័យ Pennsylvania ចាប់ផ្តើមកាលពីឆ្នាំ២០០៣ និង Channel 4 Fact Check ចាប់ផ្តើមនៅឆ្នាំ២០០៥។

ការផ្ទៀងផ្ទាត់ការពិតបានក្លាយជាបញ្ហាដ៏សំខាន់ និងបានរីករាលដាលជុំវិញពិភពលោកក្នុងទសវត្សរ៍ចុងក្រោយនេះ។

មានរឿងពីរដែលសំខាន់ដល់ការរីកលូតលាស់នៃសារព័ត៌មានប្រភេទនេះ។ រលកទីមួយចាប់ផ្តើមឡើងដោយពានរង្វាន់ Pulitzer ឆ្នាំ២០០៩ សម្រាប់សេចក្តីរាយការណ៍ដំណឹងជាតិ ដែលផ្តល់ទៅឱ្យ PolitiFact ជាគម្រោងផ្ទៀងផ្ទាត់ការពិត

3 សូមមើលមេរៀនទី៣

4 Bloyd-Peshkin, S. & Sivek, S. (2017). Magazines find there's little time to fact check online. [online] Columbia Journalism Review. Available at: https://www.cjr.org/b-roll/magazine-fact-checking-online.php [accessed 28/03/2018]

មួយ ដែលដំណើរការទើបតែបានជាងមួយឆ្នាំមុន ដោយសារព័ត៌មាន St Petersburg Times (បច្ចុប្បន្នមានឈ្មោះថា Tampa Bay Times) នៅរដ្ឋ Florida សហរដ្ឋអាមេរិក។ គំនិតច្នៃប្រឌិតរបស់ PolitiFact នេះ គឺវិភាគការអះអាងនានាដោយប្រើរង្វាស់ «Truth-O-Meter»ដោយបន្ថែមរចនាសម្ព័ន្ធមួយស្រទាប់ទៀត និងភាពច្បាស់លាស់ទៅលើការផ្ទៀងផ្ទាត់ការពិត។ (ចំពោះអ្នករិះគន់ ការដាក់ពិន្ទុនេះបង្កើតឱ្យមានអត្តនោម័តនៅក្នុងដំណើរការនេះ)។ វិធីសាស្ត្រដែលមានរចនាសម្ព័ន្ធត្រឹមត្រូវនេះ ប្រាប់ឱ្យក្រុមគោលដៅដឹងច្បាស់ នូវអ្វីដែលជាការផ្ទៀងផ្ទាត់ការពិតផ្នែកនយោបាយ និងបញ្ជាក់ច្បាស់អំពីតួនាទីរបស់ឧបករណ៍នេះថាជាឧបករណ៍សារព័ត៌មានមួយ ដែលបង្កើតឡើង ដើម្បីធ្វើឱ្យសាធារណជនទទួលខុសត្រូវពាក្យសម្ដីរបស់ខ្លួននៅក្នុងដំណើរការ ដោយបានលើកទឹកចិត្តឱ្យមានគម្រោងជាច្រើនទៀតនៅជុំវិញពិភពលោក[5]។

រលកទីពីរគឺគម្រោងផ្ទៀងផ្ទាត់ការពិត ដែលបានកើតឡើងបន្ទាប់ពីការកើនឡើងនៃ «ដំណឹងក្លែងក្លាយ» នៅទូទាំងសកលលោក។ បច្ចុប្បន្នពាក្យ «ដំណឹងក្លែងក្លាយ» នេះត្រូវគេសម្រេចជ្រើសរើសយកមកប្រើ និងប្រើប្រាស់ខុស រៀបរាប់អំពីរឿងបែបរំជួលចិត្តដែលប្រឌិតទាំងស្រុង ហើយរាលដាលទៅដល់ក្រុមគោលដៅដ៏ច្រើនលើសលប់ តាមរយៈការកេងប្រយោជន៍ពីដំណើរការដោះស្រាយបញ្ហា តាមប្រព័ន្ធកុំព្យូទ័ររបស់ប្រព័ន្ធផ្សព្វផ្សាយសង្គម។ ខណៈដែលវាបង្ហាញឱ្យឃើញកាន់តែច្បាស់នៅក្នុងអំឡុងឆ្នាំ២០១៦ ថាហេដ្ឋារចនាសម្ព័ន្ធព័ត៌មានតាមអ៊ីនធឺណិតមានចន្លោះប្រហោងដែលអាចឱ្យព័ត៌មានមិនពិត និងព័ត៌មានខុសជ្រាបចូលបាន មានក្រុមកាន់តែច្រើនឡើង ដែលបានសម្រេចចិត្តងាកមកចាប់អារម្មណ៍លើការផ្ទៀងផ្ទាត់ការពិត។

រលកលើកទីពីរនេះ បានផ្ដោតសំខាន់លើការផ្ទៀងផ្ទាត់ការពិតនៃការអះអាងជាសាធារណៈ ក្នុងការបកអាក្រាតដំណឹងបោកប្រាស់ទាំងនេះ។ ការលាតត្រដាងការពិតជាផ្នែកតូចមួយនៃការងារផ្ទៀងផ្ទាត់ការពិត និងទាមទារឱ្យមានជំនាញជាក់លាក់មួយ ដែលដូចគ្នានឹងការផ្ទៀងផ្ទាត់ការពិតដែរ (ពិសេសការពិនិត្យមើលមាតិកាដែលបង្កើតឡើងដោយអ្នកប្រើប្រាស់ ឬគេហៅថា UGC ចូរមើលដ្យាក្រាម Venn ខាងក្រោមនេះ)។ មេរៀននេះ នឹងផ្ដោតលើការផ្ទៀងផ្ទាត់

5 Mantzarlis, A. (2017). In its first decade, PolitiFact helped define political fact-checking far beyond Washington, D.C. [online] Poynter. Available at: https://www.poynter.org/news/its-first-decade-politifact-helped-define-political-fact-checking-far-beyond-washington-dc [accessed 28/03/2018].

ការពិតដូចដែលបានបញ្ជាក់នៅខាងក្រោម ហើយមេរៀនបន្ទាប់នឹងផ្តោតលើការពិនិត្យមើលមាតិកា និងប្រភពបែបបច្ចេកវិទ្យា[6]។




*រូបភាពទី៩ ៖ ភាពខុសគ្នារវាងការផ្ទៀងផ្ទាត់ការពិត និងការផ្ទៀងផ្ទាត់*

## ឧទាហរណ៍នៃអង្គការផ្ទៀងផ្ទាត់ការពិតនៅជុំវិញពិភពលោក

យោងតាម Duke Reporters’ Lab គិតត្រឹមខែធ្នូ ឆ្នាំ២០១៧[7] មានគម្រោងផ្ទៀងផ្ទាត់ការពិតចំនួន១៣៧ ដែលដំណើរការនៅក្នុង៥១ប្រទេស។

ខណៈដែលសហរដ្ឋអាមេរិកគឺជាទីផ្សារធំបំផុត សម្រាប់ការផ្ទៀងផ្ទាត់ការពិត ការងារមួយចំនួនដែលមានភាពច្នៃប្រឌិត និងគិតគូរបានហ្មត់ចត់បំផុត នៅក្នុងវិស័យនេះក៏កំពុងកើតមានដែរ នៅក្នុងបណ្តាប្រទេសនានានៅជុំវិញពិភពលោក។

6 សូមមើលមេរៀនទី៦

7 Stencel, M. (2017). Fact-checking booms as numbers grow by 20 percent. [online] Duke Reporters Lab. Availableat:https://reporterslab.org/big-year-fact-checking-not-new-u-s-fact-checkers/ [accessed 28/03/2018].

គ្រូឧទ្ទេសនាមគួរតែស្វែងយល់គម្រោងមួយចំនួន ដូចជា Africa Check (អាហ្វ្រិកខាងត្បូង សេណេហ្គាល់ នីហ្សេរីយ៉ា និងកេនយ៉ា) Chequeado (អាហ្សង់ទីន) Les Décodeurs (បារាំង) Faktisk (ន័រវេ៉) និង Full Fact (ចក្រភពអង់គ្លេស)។

សម្រាប់គ្រូឧទ្ទេសនាមដែលចង់ផ្តោតសំខាន់ទៅលើប្រទេស ឬតំបន់ជាក់លាក់ណាមួយ ធនធានខាងក្រោមនេះអាចនឹងមានប្រយោជន៍ ៖

- **ប្រេស៊ីល៖** អត្ថបទរបស់ Kate Steiker- Ginzberg សម្រាប់ Poynter, “Fact-checking booms in Brazil” មាននៅ៖ https://www.poynter.org/news/fact-checking-booms-brazil
- **អឺរ៉ុប៖** របាយការណ៍របស់ Lucas Graves និង Federica Cherubini សម្រាប់វិទ្យាស្ថាន Reutersនៅឯសាកលវិទ្យាល័យ Oxford “The Rise of Fact-Checking Sites in Europe” មាននៅ៖http://reutersinstitute.politics.ox.ac.uk/our-research/ rise-fact-checking-sites-europe#overlay-context=
- **ជប៉ុន៖** អត្ថបទដោយ Masato Kajimoto សម្រាប់ Poynter “A new fact-checking coalition is launching in Japan” មាននៅ៖ https://www.poynter.org/news/new-fact-checking-coalition-launching-japan
- **កូរ៉េខាងត្បូង៖** អត្ថបទដោយ Boyoung Lim សម្រាប់ Poynter “What’s behind South Korea’s fact-checking boom? Tense politics and the decline of investigative journalism” មាននៅ៖http://www.poynter.org/2017/whats-behind- south-koreas-fact-checking-boom-tense-politics-and-the-decline-of- investigative-journalism/463655/
- **អាមេរិកឡាទីន៖** អត្ថបទដោយ Ivan Echt សម្រាប់ Poynter “Lack of access to information is driving Latin America’s fact-checking boom” មាននៅ៖ https://www.poynter.org/news/lack-access-information-driving-latin-americas-fact-checking-boom
- **សហរដ្ឋអាមេរិក៖** សៀវភៅរបស់ Lucas Graves ហើយពិនិត្យឡើងវិញដោយ Brad Scriberនៅលើ Poynter “Deciding What’sTrue: The Rise of Political Fact- Checking in American Journalism” មាននៅ៖ https://www.poynter.org/news/ who-decides-whats-true-politics-history-rise-political-fact-checking

### វិធីសាស្រ្ត និងក្រមសីលធម៌នៃការផ្ទៀងផ្ទាត់ការពិត

ការផ្ទៀងផ្ទាត់ការពិតមិនមែនជាវិទ្យាសាស្រ្តរ៉ុកកែតទេ។ វាគឺជាការវិភាគដ៏ហ្មត់ចត់ដែលមានសំណួរជាមូលដ្ឋានមួយ៖ «តើយើងដឹងរឿងនោះយ៉ាងដូចម្តេច?»។ ទន្ទឹមនឹងនេះ ការផ្ទៀងផ្ទាត់ការពិត មិនមែនជាការផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធឡើយ។ ការផ្ទៀងផ្ទាត់បែបនេះពុំមានសៀវភៅណែនាំ ដែលផ្ទុកការពិតគ្រប់បែបយ៉ាងដូចវចនានុក្រមនោះទេ ហើយក៏គ្មានកម្មវិធីកុំព្យូទ័រសាមញ្ញណាមួយដែលពិនិត្យមើលឯកសារ និងដាក់សញ្ញាសម្គាល់គ្រប់ពេលនូវអ្វីមួយ ដែលត្រូវបានគេអះអាងខុសថាជាការពិតនោះដែរ។

ជាទូទៅ ការផ្ទៀងផ្ទាត់ការពិតមាន ៣ ដំណាក់កាល៖

១. **ការស្វែងរកការអះអាង** ដែលអាចផ្ទៀងផ្ទាត់ការពិតបាន តាមរយៈការស្រាវជ្រាវសំណុំឯកសារច្បាប់ ស្ថាប័នដំណឹង និងប្រព័ន្ធផ្សព្វផ្សាយសង្គម។ ដំណើរការនេះរួមបញ្ចូលការកំណត់ថា តើការអះអាងជាសាធារណៈធំៗណាមួយ (ក) ដែលអាចផ្ទៀងផ្ទាត់មើលការពិតបាន និង(ខ)គួរតែផ្ទៀងផ្ទាត់ការពិត។

២. **ការស្វែងរកការពិត** ដោយស្វែងរកភ័ស្តុតាងសំខាន់បំផុតដែលអាចរកបានពាក់ព័ន្ធនឹងការអះអាង ដែលជាកម្មវត្ថុនៃការផ្ទៀងផ្ទាត់។

៣. **ការកែតម្រូវឱ្យត្រឹមត្រូវ** ដោយវាយតម្លៃការអះអាងនោះ ប្រៀបធៀបនឹងភ័ស្តុតាងលើវង្វាស់នៃភាពពិត។

អង្គការផ្ទៀងផ្ទាត់ការពិត ដែលអាចទុកចិត្តបានពន្យល់ដំណើរការរបស់ខ្លួនក្នុងវិធីសាស្រ្ត ដែលផ្សព្វផ្សាយជាសាធារណៈ។ គ្រូឧទ្ទេសអាចនឹងចង់ណែនាំសិស្សឱ្យស្គាល់ស្ថាប័នផ្ទៀងផ្ទាត់ការពិតមួយ ឬច្រើនដូចខាងក្រោម៖

១. Africa Check’s “How We Work” page (accessible at https://africacheck.org/about-us/how-we-work/) as well as the infographic in the Materials section

២. Chequeado’s “Metodo” (accessible in Spanish at: http://chequeado.com/metodo/)

៣. Pagella Politica’s “Metodologia” and “Come funzioniamo” (accessible in Italian at https://pagellapolitica.it/progetto/index)

៤. PolitiFact’s “The Principles of PolitiFact” (accessible at http://www.politifact.com/truth-o-meter/article/2013/nov/01/principles-politifact-punditfact-and-truth-o-meter/)

បណ្ដាញផ្ទៀងផ្ទាត់ការពិតអន្តរជាតិ (IFCN)[8] ក៏បានបង្កើតក្រមនៃគោលការណ៍ដែលដឹកនាំអ្នកផ្ទៀងផ្ទាត់ការពិត ទៅលើការងារប្រចាំថ្ងៃរបស់ពួកគេផងដែរ។ អង្គការផ្ទៀងផ្ទាត់ការពិត ដាក់ពាក្យស្នើសុំធ្វើជាហត្ថលេខីបញ្ជាក់ក្រមនៃគោលការណ៍របស់ IFCN។ ការសុំធ្វើជាហត្ថលេខីនេះ ទាមទារការវាយតម្លៃពីខាងក្រៅ ទៅលើការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃបទដ្ឋានទាំងនេះ។ គ្រូអាចនឹងចង់សិក្សាឱ្យយល់ខ្លួនឯងអំពីក្រមនេះ និងស្វែងរកការវាយតម្លៃដែលបានធ្វើទៅលើអង្គការផ្ទៀងផ្ទាត់ការពិត មកពីប្រទេសរបស់ខ្លួន[9] និងពិភាក្សាថាតើសិស្សយល់ឃើញថា ការធ្វើដូច្នេះធ្វើឱ្យពួកគេទុកចិត្តអ្នកផ្ទៀងផ្ទាត់ការពិត ឬអត់។

គោលការណ៍រៀបចំឡើងដើម្បីជួយក្រុមគោលដៅ ឱ្យចេះបែងចែកភាពខុសគ្នារវាងការផ្ទៀងផ្ទាត់ការពិតដែលល្អ និងមិនល្អ។ ឧទាហរណ៍នៃដំណឹងមិនពិតដែលក្លែងខ្លួនជាការផ្ទៀងផ្ទាត់ការពិត គ្រូឧទ្ទេសនាមអាចនឹងចង់ចែករំលែកឧទាហរណ៍នៅក្នុងអត្ថបទទាំងពីរនេះ ៖

- អ្នកផ្ទៀងផ្ទាត់ការពិតក្លែងក្លាយ (fake fact-checker) ទាំងនេះកំពុងតែនិយាយកុហកអំពីអំពើប្រល័យពូជសាសន៍ និងការត្រួតពិនិត្យនៅប្រទេសទួរគី (Poynter) https://www.poynter.org/news/these-fake-fact-checkers-are-peddling-lies-about-genocide-and-censorship-turkey
- នៅក្នុងយុគសម័យក្រោយសេចក្ដីពិត - អ្នកផ្ទៀងផ្ទាត់ការពិតក្លែងក្លាយនៅស៊ុយអែតគឺជៀសមិនរួច (The Guardian) ៖ https://www.theguardian.com/media/2017/jan/19in-the-post-truth-era-swedens-far-right-fake-fact-checker-was-inevitable

## តើអ្វីខ្លះដែលរារាំងការពិត?

នៅមុនពេលសិក្សាស៊ីជម្រៅលើទិដ្ឋភាពជាក់ស្ដែងនៃការផ្ទៀងផ្ទាត់ការពិត សិស្សត្រូវតែដឹងដែនកំណត់នៃការផ្ទៀងផ្ទាត់ការពិត និងដែនកំណត់របស់ខ្លួន។

អ្នកអត្ថាធិប្បាយខ្លះបានប្រកាសថា យើងបានចូលមកដល់សម័យ «ក្រោយសច្ចភាព» ឬ «ក្រោយការពិត» (post-truth or post-fact) ហើយ។ ពាក្យទាំងនេះបានបង្ហាញ

8 The Author Alexios Mantzarlis International Fact Checking Network

9 Available at https://www.poynter.org/international-fact-checking-network-fact-checkers-code-principles. [accessed: 28/03/2018].

ខ្លួនក្នុងចំណងជើងសារព័ត៌មាន នៅទូទាំងពិភពលោកនៅឆ្នាំ២០១៦ និងត្រូវបានជ្រើសរើសជា «ពាក្យប្រចាំឆ្នាំ» ដោយទាំងវចនានុក្រម Oxford English និងទាំងសមាគមភាសាអាល្លឺម៉ង់។ ហេតុផលដែលផ្តល់ដោយអ្នកគាំទ្រពាក្យ «ក្រោយសច្ចភាព» គឺថា នយោបាយនិងប្រព័ន្ធផ្សព្វផ្សាយបានបែកបាក់ និងបែងចែកបក្សពួករហូតពលរដ្ឋនាំគ្នាប្រានចោលទាំងស្រុង នូវរាល់ការពិតណាដែលអ្នកនយោបាយ និងប្រព័ន្ធផ្សព្វផ្សាយមានការខ្វែងគំនិតគ្នា។

ការលើកឡើងដូច្នោះ គឺមិនស្របគ្នាទៅនឹងការស្រាវជ្រាវជាច្រើន ដែលបានរកឃើញថា នៅពេលកែតម្រូវឯកសារយោង ឬអំណះអំណាងដែលក្រុមគោលដៅគិតថា អាចជឿជាក់បាន មនុស្សម្នា (គិតជាមធ្យម) ទទួលបានព័ត៌មានកាន់តែប្រសើរឡើង។ គ្រូឧទ្ទេសនាមអាចនឹងត្រូវការអាន និងពិភាក្សាអំពីការសិក្សាខាងក្រោមនេះជាមួយសិស្ស៖

- Swire, B., Berinsky, A. J., Lewandowsky, S. & Ecker, U. K. H. (2017). Processing political misinformation: comprehending the Trump phenomenon (01 March 2017) http://rsos.royalsocietypublishing.org/content/4/3/160802 [accessed 28/03/2018].
- Nyhan, B. & Zeitzoff, T. (2018). Fighting the Past: Perceptions of Control, Historical Misperceptions, and Corrective Information in the Israel-Palestinian Conflict http://onlinelibrary.wiley.com/doi/10.1111/pops.12449/abstract. [accessed 28/03/2018].
- Wood, T. & Porter, E. (2016). The Elusive Backfire Effect: Mass Attitudes' Steadfast Factual Adherence (August 5, 2016). https://ssrn.com/abstract=2819073. [accessed 28/03/2018].

ជាមួយគ្នានេះដែរ វាមិនមែនជាភាពសាមញ្ញទេ ដោយគ្រាន់តែលើកឡើងថា ការពិតគឺជាលក្ខណៈសម្គាល់ដ៏ល្អឥតខ្ចោះនៃពិភពលោក និងថាមនុស្សគឺជាអង្គដែលមានហេតុផលទាំងស្រុង ដែលទទួលយកការពិតថ្មីដោយឥតខ្ចោះ ទោះបីជំនឿ និងចំណង់ចំណូលចិត្តពីមុនយ៉ាងដូចម្ដេចក៏ដោយ។ យើងម្នាក់ៗកើតមកជាមួយភាពលម្អៀងផ្នែកវិនិច្ឆ័យ និងភាពលម្អៀងផ្សេងទៀត ជាពិសេសឧបសគ្គផ្លូវចិត្តដែលអាចរាំងផ្លូវនៃការទទួលយកដំណឹងពិតថ្មី។ វាសំខាន់ណាស់ដែលគេត្រូវសង្កត់ធ្ងន់ថា នេះមិនមែនជាអ្វីដែលកើតមានឡើងចំពោះមនុស្សដទៃទេ ប៉ុន្តែវាកើតមានឡើងចំពោះយើងគ្រប់គ្នា។ គ្រូឧទ្ទេសនាម គួរតែពិភាក្សាភាពលម្អៀងនៅក្នុងថ្នាក់។

**ការអះអាងដែលលម្អៀង** (Confirmation bias) [ដកស្រង់ចេញពី Encyclopaedia Britannica —https://www.britannica.com/topic/confirmation-bias [accessed 28/03/2018]៖ និន្នាការនៃការចាត់ចែងព័ត៌មានដោយស្វែងរក ឬបកស្រាយព័ត៌មានដែលស្របនឹងជំនឿ ដែលមានស្រាប់របស់មនុស្សម្នាក់។ គោលការណ៍លម្អៀងនៃការធ្វើសេចក្ដីសម្រេចចិត្តបែបនេះ ភាគច្រើនគឺដោយអចេតនា ហើយនាំឱ្យគេមិនខ្វល់ពីព័ត៌មានណា ដែលមិនត្រូវនឹងជំនឿរបស់គេ។ ជំនឿដែលមានស្រាប់ រួមមានដូចជា ការរំពឹងទុករបស់មនុស្សម្នាក់ នៅក្នុងស្ថានភាពជាក់លាក់មួយ និងការទស្សន៍ទាយលទ្ធផលជាក់លាក់ណាមួយ។ មនុស្សទំនងជានឹងដំណើរការព័ត៌មាន ដើម្បីគាំទ្រជំនឿផ្ទាល់ខ្លួន នៅពេលដែលបញ្ហានោះមានសារៈសំខាន់ខ្លាំង ឬពាក់ព័ន្ធនឹងខ្លួនឯង។

**ហេតុផលដែលមានការជំរុញចិត្ត** [ដកស្រង់ចេញពី Discover Magazine—http://blogs.discovermagazine.com/intersection/2011/05/05/what-is-motivated-reasoning-how-does-it-work-dan-kahan-answers/#.WfHrl4ZrzBI [accessed 28/03/2018].

ការវិនិច្ឆ័យដោយជំរុញទឹកចិត្ត សំដៅលើនិន្នាការដោយមិនដឹងខ្លួន ដែលស្របនឹងដំណើរការព័ត៌មាន ទៅតាមសេចក្ដីសន្និដ្ឋានដែលស្របទៅនឹងលទ្ធផល ឬគោលដៅអ្វីមួយ។ ចូរពិចារណាឧទាហរណ៍ដ៏សាមញ្ញមួយនេះ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ចិត្តវិទូបានសុំឱ្យមនុស្សដែលខ្លួនធ្វើពិសោធន៍ ជាសិស្សមកពីមហាវិទ្យាល័យ **Ivy League** ចំនួនពីរឱ្យទស្សនាខ្សែភាពយន្តមួយបង្ហាញពី ការពិន័យដ៏ចម្រូងចម្រាសរបស់អាជ្ញាកណ្ដាល ក្នុងពេលប្រកួតបាល់ទាត់ រវាងក្រុមមកពីសាលារបស់ពួកគេទាំងពីរ។ សិស្សមកពីសាលានីមួយៗទំនងជាយល់ថា ការផ្ដុំកញ្ចៃពិន័យជាការត្រឹមត្រូវ នៅពេលដែលការពិន័យនោះ ចំណេញដល់ក្រុមសាលារបស់ខ្លួន ជាងពេលដែលវាផ្ដល់ការចំណេញទៅខាងគូប្រជែងរបស់ខ្លួន។ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា ចំណាប់អារម្មណ៍ផ្លូវចិត្តដែលសិស្សមាន នៅក្នុងការបញ្ជាក់ពីភាពស្មោះត្រង់ចំពោះស្ថាប័នរបស់ខ្លួន បានកំណត់អ្វីដែលពួកគេបានឃើញនៅក្នុងភាពយន្ត។

**ការប្រើប្រាស់ព័ត៌មានដែលមានស្រាប់** (Availability heuristic) [ដកស្រង់ចេញពី Oxford University Press A Dictionary of Psychology— http://www.oxfordreference.com/view/10.1093/acref/9780199534067.001.0001/acref-9780199534067-e-830 [accessed 28/03/2018]. ការគិតយល់ដោយខ្លួនឯង (A cognitive heuristic) តាមរយៈភាពញឹកញាប់ ឬចំនួនដងនៃព្រឹត្តិការណ៍ណាមួយត្រូវបានវិនិច្ឆ័យដោយចំនួនឧទាហរណ៍ដែលបានកើតឡើង ហើយដែលអាចងាយ

នឹកឃើញ។ កត្តានេះ អាចនាំឱ្យមនុស្សចាត់ទុកការអះអាងមិនត្រឹមត្រូវមួយ ថាជាការពិត ដោយសារពួកគេអាចចាំវាបានយ៉ាងងាយ។ នៅក្នុងពិសោធន៍មួយដែលធ្វើឡើងដោយ Lisa Fazio នៅសកលវិទ្យាល័យ Vanderbilt មនុស្សដែលត្រូវបានគេប្រាប់ឱ្យនិយាយដដែលៗថា «រ៉ូបរបស់ស្កុតឡេនជាសំពត់គិលរបស់ជនជាតិអេកុស្ស» ចំនួន៦ដង ជឿលើភាពមិនពិតនេះ ច្រើនជាងអ្នកដែលនិយាយឃ្លាខាងលើតែម្តង។ សារព័ត៌មានអាចប្រែក្លាយខ្លួនឯង ជាភ្នាក់ងារជួយឱ្យគេជឿទៅលើភាពមិនពិត តាមរយៈការផ្សាយភាពមិនពិតទាំងនោះ ដោយខ្វះការត្រិះរិះពិចារណា។ ឧទាហរណ៍ ការផ្សាយរបស់សារព័ត៌មានអំពីការសមគំនិត ជុំវិញទីកន្លែងកំណើតរបស់លោក បារ៉ាក់ អូបាម៉ា បានដើរតួនាទីផ្សព្វផ្សាយឱ្យគេជឿថា អតីតប្រធានាធិបតីអាមេរិករូបនេះ តាមពិតទៅ មិនមែនកើតនៅកោះហាវ៉ៃ សហរដ្ឋអាមេរិកទេ។

គេគួរកត់សម្គាល់ថា ការផ្ទៀងផ្ទាត់ការពិតនេះទៀតសោត ជាឧបករណ៍មួយដែលមិនមែនល្អឥតខ្ចោះនោះទេ។ អ្វីមួយអាចនឹងត្រឹមត្រូវមួយរយភាគរយ ក៏នៅតែភ្លេចបញ្ចូលបរិបទសំខាន់ៗដែរ[10]។ ជានិច្ចកាល ការពិតត្រូវបានផ្គុំឡើង រៀបលំដាប់លំដោយ និងរុះរើលំដាប់លំដោយប្រកបដោយអត្ថន័យ ក្នុងរចនាសម្ព័ន្ធនិទានទូលំទូលាយ ដែលអាចផ្តល់សារៈសំខាន់ផ្សេងៗគ្នាដល់ការពិតជាមូលដ្ឋានដូចគ្នា។ ជាងនេះទៅទៀត សច្ចភាព ឬសេចក្តីពិត លើសពីការប្រមូលការពិត។ ការផ្ទៀងផ្ទាត់ការពិតមិនមែនជាឧបករណ៍ ដែលប្រើប្រាស់ដើម្បីបិទការបកស្រាយផ្សេងទៀត ហើយក៏មិនមែនជាឧបករណ៍ដើម្បីធានាការពិតមួយឈុត ដែលអាចមានផលប៉ះពាល់លើការនិទាន និងភាពលម្អៀងរបស់បុគ្គលដើម្បីរឹតត្បិតការពិភាក្សាដោយមានហេតុផលនោះឡើយ។

## គោលបំណងនៃមេរៀន

- ដើម្បីលើកកម្ពស់ការស្គាល់អំពីការអនុវត្តល្អៗដែលកំពុងកើតមាន នៅជុំវិញពិភពលោកទាក់ទងនឹងកាផ្ទៀងផ្ទាត់ការពិត
- លើកកម្ពស់ការយល់ដឹងអំពីភាពលម្អៀងផ្នែកវិនិច្ឆ័យ ដែលអាចនឹងរាំងស្ទះដល់ការយល់ដឹងអំពីការពិត
- លើកកម្ពស់ជំនាញវិភាគបែបត្រិះរិះ

10 Available at Yanofsky, D. (2013). The chart Tim Cook doesn't want you to see. Available at https://qz.com/122921/the-chart-tim-cook-doesnt- want-you-to-see/. [accessed 28/03/2018].

## លទ្ធផលសិក្សា

១. ការយល់ដឹងការលេចឡើងនូវការផ្ទៀងផ្ទាត់ការពិត ជាទម្រង់ខុសប្លែកគេនៃសារព័ត៌មាន ព្រមទាំងក្រមសីលធម៌ និងវិធីសាស្ត្រនៃការអនុវត្តការផ្ទៀងផ្ទាត់ការពិត

២. ការយល់ដឹងសំណួរដែលត្រូវសួរ នៅពេលវាយតម្លៃគុណភាពរបស់ភស្តុតាង

៣. ការលើកកម្ពស់សមត្ថភាពញែកការអះអាង ដែលអាចផ្ទៀងផ្ទាត់ការពិតបាន ដាច់ចេញពីមតិ និងការបំផ្លើស

៤. ការយល់គោលគំនិតនៃភាពលម្អៀងផ្នែកការវិនិច្ឆ័យ ដែលអាចរាំងស្ទះផ្លូវនៃការយល់ដឹងការពិត

## ទម្រង់នៃមេរៀន

ផ្នែកទ្រឹស្តីនៃមេរៀននេះពិនិត្យទៅលើ៖

១. ប្រវត្តិ និងនិយមន័យ

២. វិធីសាស្ត្រ និងក្រមសីលធម៌

៣. តើអ្វីដែលរារាំងការពិត

ផ្នែកអនុវត្តន៍នៃមេរៀននេះចែកចេញជាពីរសកម្មភាព៖

១. ស្វែងរកការអះអាងដែលអាចផ្ទៀងផ្ទាត់ការពិតបាន
២. ស្វែងរកការពិត

លំហាត់ផ្តោតសំខាន់ទៅលើការកែតម្រូវឱ្យត្រឹមត្រូវ។

## ភ្ជាប់ផែនការទៅនឹងលទ្ធផលសិក្សា

ក. ទ្រឹស្តី

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| ១. ប្រវត្តិ និងនិយមន័យ | ២០នាទី | ១ |
| ២. វិធីសាស្ត្រ និងក្រមសីលធម៌ | ២០នាទី | ១ |
| ៣. តើអ្វីដែលរារាំងការពិត | ២០នាទី | ៤ |

ខ. អនុវត្តន៍

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| សកម្មភាពទី១៖ ការស្វែងរកការអះអាងដែលអាចផ្ទៀងផ្ទាត់ការពិត | ៣០នាទី | ៣ |
| សកម្មភាពទី២៖ ការស្វែងរកការពិត | ១ ម៉ោង | ២ |

## ១. ការស្វែងរកការអះអាងដែលអាចផ្ទៀងផ្ទាត់ការពិតបាន

ការផ្ទៀងផ្ទាត់ការពិតផ្តោតសំខាន់លើការអះអាង ដែលផ្ទុកការពិតយ៉ាងហោចណាស់មួយចំណុច ឬតួលេខមួយដែលសេចក្តីពិតនៃការពិតនោះ ឬតួលេខនោះអាចផ្ទៀងផ្ទាត់បានដោយសត្យានុម័ត។ ការផ្ទៀងផ្ទាត់ការពិតមិនមែនវាយតម្លៃសេចក្តីពិតនៃមតិ និងការទស្សន៍ទាយ ការបំផ្លើស ការនិយាយរិះគន់បែបកំប្លែង និងរឿងកំប្លែងនោះទេ។

**សកម្មភាពទី១៖** ចូរឱ្យសិស្សអានសេចក្តីដកស្រង់នៃសុន្ទរកថា ខាងក្រោមនេះដែលថ្លែងដោយឥស្សរជនសាធារណៈ៩រូប និងដាក់ពណ៌បៃតងឱ្យប្រយោគការពិតដែលអាចផ្ទៀងផ្ទាត់ការពិតបាន ដាក់ពណ៌ក្រហមឱ្យប្រយោគជាមតិ និងដាក់ពណ៌ទឹកក្រូចឱ្យប្រយោគដែលស្ថិតនៅកណ្តាលនៃការពិត និងមតិ។ បន្ទាប់ពីសិស្សបានប្រគល់កិច្ចការដែលគេបានគូសដាក់ពណ៌ឱ្យរួចហើយ ចូរពិនិត្យមើលទាំងអស់

គ្នា និងពិភាក្សាថាតើអ្វីដែលជាការអះអាង ដែលអាចផ្ទៀងផ្ទាត់ការពិតបាន ។



**ការណែនាំ**

ក្រហម – សេចក្តីដែលមិនអាចពិនិត្យមើលការពិតបាន

ទឹកក្រូច – សេចក្តីដែលនៅចន្លោះកណ្តាល

បៃតង –សេចក្តីដែលអាចផ្ទៀងផ្ទាត់ការពិតបាន

**Michelle Bachelet,** អតីតប្រធានាធិបតីប្រទេសឈីលី

ខណៈដែលយើងសម្រេចបានវឌ្ឍនភាពដ៏ច្រើនគួរសមក្នុងគោលដៅនោះ យើងក៏ដឹងដែរថា យើងត្រូវតែដោះស្រាយការគំរាមកំហែងមួយទៀតចំពោះប្រព័ន្ធអេកូឡូស៊ីសមុទ្រ នោះគឺប្លាស្ទិក។ ពីមួយឆ្នាំទៅមួយឆ្នាំ ប្លាស្ទិក៨លានតោនបានហូរចូលទៅក្នុងសមុទ្រដោយនៅទីនោះអស់រយៈពេលរាប់រយឆ្នាំ និងបង្កផលប៉ះពាល់យ៉ាងធំធេង។ ដើម្បីដោះស្រាយបញ្ហានេះ យើងចូលរួមក្នុងយុទ្ធនាការសម្អាតសមុទ្ររបស់កម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ។ ទន្ទឹមនឹងនេះដែរ នៅកម្រិតមូលដ្ឋាន យើងនឹងបង្ហាញសេចក្តីព្រាងច្បាប់មួយ ដើម្បីហាមការប្រើប្រាស់ថង់ប្លាស្ទិកនៅតាមទីក្រុងជាប់មាត់ឆ្នេរ ក្នុងរយៈពេល១២ខែខាងមុខ។ ច្បាប់នេះនឹងអនុញ្ញាតឱ្យប្រជាពលរដ្ឋរួមចំណែកក្នុងការការពារសមុទ្រដែរ។ ដូច្នេះ យើងនឹងក្លាយជាប្រទេសដំបូងគេបង្អស់ នៅក្នុងទ្វីបអាមេរិកដែលអនុវត្តច្បាប់បែបនេះ ហើយយើងសូមអំពាវនាវដល់បណ្តាប្រទេសផ្សេងទៀត ឱ្យទទួលយកទំនួលខុសត្រូវនេះដូចគ្នាដែរ។ ជាងនេះទៅទៀត មកដល់ពេលនេះគឺ៣០ឆ្នាំហើយ បន្ទាប់ពីការអនុម័តពិធីសារ ម៉ុងរ៉េអាល់ (Montreal Protocol) ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលការអនុម័តនេះបានធ្វើឱ្យស្រទាប់អូហ្សូន អាចស្តារខ្លួនឡើងវិញ។ ក្នុងឱកាសខួបលើកទី៣០នេះ ខ្ញុំសូមប្រកាសថា ប្រទេសខ្ញុំទើបតែបានដាក់ជូននូវសច្ចាប័នទៅលើវិសោធនកម្ម Kigali ឆ្នាំ២០១៦ នៃពិធីសារ ម៉ុងរ៉េអាល់នេះ ដែលមានគោលដៅទប់ស្កាត់ការកើនកម្តៅផែនដីឱ្យបាន០,៥អង្សា។ តាមរយៈសច្ចាប័ននេះ ប្រទេសChile ស្ថិតក្នុងចំណោមប្រទេសដំបូងៗគេ ដែលផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងថ្មីនេះ។ ប៉ុន្តែមិនមែនអស់ត្រឹមនេះទេ។ រួមនឹងការបង្កើតបណ្តាញឧទ្យាននៅ Patagonia យើងក៏បានបន្ថែមតំបន់បៃតងដែលសម្បូរទៅដោយជីវៈចម្រុះ ចំនួន ៤,៥លានហិកតា ដែលបច្ចុប្បន្នត្រូវបានការពារដោយរដ្ឋ សម្រាប់ការប្រើប្រាស់សាធារណៈ។

**Jacob Zuma, អតីតប្រធានាធិបតីប្រទេសអាហ្វ្រិកខាងត្បូង**

រចនាសម្ព័ន្ធបច្ចុប្បន្ននៃសេដ្ឋកិច្ចពិភពលោក បន្តធ្វើឱ្យមានគម្លាតកាន់តែធំឡើងៗ រវាងប៉ូលខាងជើង និងប៉ូលខាងត្បូងនៃពិភពលោក។ ខណៈដែលប្រជាជនប្រទេសមួយចំនួនតូចរីករាយនឹងទទួលផលប្រយោជន៍ពីសកលឧបនីយកម្ម ប្រជាជនភាគច្រើននៃសកលលោកនៅតែរស់នៅស្ថិតក្នុងភាពក្រីក្រ និងភាពអត់ឃ្លានដដែល ដោយគ្មានសង្ឃឹមនឹងអាចកែលម្អជីវភាពរស់នៅរបស់ពួកគេ បានល្អប្រសើរឡើយ។ សូម្បីនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ គម្លាតរវាងអ្នកមាននិងអ្នកក្រនៅតែមានទំហំធំ និងគួរឱ្យព្រួយបារម្ភខ្លាំង។ យើងត្រូវការចាំបាច់នូវឆន្ទៈនយោបាយពីមេដឹកនាំពិភពលោក ដើម្បីដោះស្រាយបញ្ហាប្រឈម និងឧបសគ្គនានាដែលបង្កឡើងដោយរចនាសម្ព័ន្ធសេដ្ឋកិច្ចពិភពលោកដែលមិនកែទម្រង់នេះ ប្រសិនបើយើងចង់សម្រេចគោលដៅ និងមហិច្ឆតានៃផែនការឆ្នាំ២០៣០។ ឧទាហរណ៍ ទ្វីបលោកសម្បូរដោយធនធានរ៉ែ ប៉ុន្តែ ប្រទេសក្រីក្រនៅតែមានចំនួនច្រើន។

**Sigmar Gabriel, អតីតរដ្ឋមន្ត្រីការបរទេសអាល្លឺម៉ង់**

យើងត្រូវផ្តល់ឱ្យអង្គការសហប្រជាជាតិនូវមធ្យោបាយ ដែលខ្លួនត្រូវការចាំបាច់ ដើម្បីបំពេញអាណត្តិរបស់ខ្លួន។ ប៉ុន្តែតួលេខបច្ចុប្បន្នប្រាប់យើងរឿងផ្សេងមួយទៀត ៖ កម្មវិធីស្បៀងអាហារពិភពលោក ទទួលមូលនិធិបានតិចជាង៥០% នៃមូលនិធិដែលខ្លួនត្រូវការចាំបាច់ ដើម្បីប្រយុទ្ធនឹងគ្រោះអត់ឃ្លានរបស់ពិភពលោកសព្វថ្ងៃ។ កម្មវិធីអភិវឌ្ឍន៍ពិភពលោកទទួលបាន១៥% នៃវិភាគទានរបស់ខ្លួនជាថវិកាស្ម័គ្រចិត្ត និងគ្មានចំណងនៅថ្ងៃនេះ ហើយនៅឆ្នាំ២០១១ អង្គការនេះទទួលថវិកាតែ៥០%ប៉ុណ្ណោះ។ អ្វីៗហាក់ដូចជាមិនល្អប្រសើរសោះ បើធៀបនឹងកម្មវិធីជំនួយផ្សេងទៀតរបស់អង្គការសហប្រជាជាតិ។ វាមិនអាចទេដែលឱ្យអ្នកទទួលខុសត្រូវនៅក្នុងអង្គការសហប្រជាជាតិ ចំណាយពេលលើការចែកចាយលិខិតសុំជំនួយស្វែងរកថវិកា ដែលត្រូវការចាំបាច់ច្រើនជាងពេលវេលារៀបចំ និងចាត់ចែងជំនួយឱ្យមានប្រសិទ្ធភាពនោះ។ យើងត្រូវផ្លាស់ប្តូររបៀបរបបនេះ។ យើងត្រូវផ្តល់ឱ្យអង្គការសហប្រជាជាតិនូវកម្រិតមូលនិធិគ្រប់គ្រាន់ និងសេរីភាពច្រើនជាងមុន។ អ្វីដែលយើងចង់បានមកវិញគឺប្រសិទ្ធភាព និងតម្លាភាពកាន់តែប្រសើរឡើងពាក់ព័ន្ធនឹងការប្រើប្រាស់មូលនិធិ។

ទោះក្នុងអត្រាណាមួយក៏ដោយ ប្រទេសអាល្លឺម៉ង់មានបំណងរក្សាការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ខ្លួន ឱ្យស្ថិតស្ថេរសម្រាប់អង្គការសហប្រជាជាតិ។

ក្នុងនាមជាអ្នកផ្តល់វិភាគទានធំបំផុតទី៤ និងរឿងដទៃទៀតជាឧទាហរណ៍មួយក្នុងនាមជាប្រទេសម្ចាស់ជំនួយធំបំផុតមួយ ក្នុងចំណោមម្ចាស់ជំនួយធំបំផុតនានាសម្រាប់ជំនួយមនុស្សធម៌នៅជុំវិញពិភពលោក យើងចង់បន្តផ្តល់វិភាគទានច្រើនក្រាស់ក្រែលជាបន្តទៀត ។

**Mark Zuckerberg, នាយកប្រតិបត្តិ Facebook**

Facebook ជាក្រុមហ៊ុនដែលល្អបំផុត និងប្រកបដោយសុទិដ្ឋិនិយម។ ចាប់តាំងពីពេលដែលយើងចាប់បដិសន្ធិរហូតមកដល់ពេលនេះ យើងផ្តោតសំខាន់លើគ្រប់រឿងល្អទាំងអស់ ដែលភ្ជាប់ទំនាក់ទំនងជាមួយប្រជាជន។ ខណៈដែលFacebook រីកកាន់តែធំ ប្រជាជននៅគ្រប់ទិសទីមានឧបករណ៍ថ្មីមួយ ដ៏មានឥទ្ធិពលសម្រាប់ការប្រាស្រ័យទាក់ទងគ្នាជាមួយមនុស្សជាទីស្រលាញ់ សម្តែងមតិ កសាងសហគមន៍ និងអាជីវកម្ម។ ទើបតែថ្មីៗនេះទេ ដែលយើងបានឃើញចលនា #metoo និង March for Our Lives ដែលត្រូវបានរៀបចំ និងចាត់តាំងនៅលើបណ្តាញFacebook ។ បន្ទាប់ពីព្យុះ Harvey ប្រជាជនរៃអង្គាសថវិកាបានជាង២០លានដុល្លារសម្រាប់ការជួយសង្គ្រោះ។ បច្ចុប្បន្ន អាជីវកម្មខ្នាតតូចជាង ៧០លាន ប្រើប្រាស់ Facebook ដើម្បីការលូតលាស់នៃអាជីវកម្មរបស់ខ្លួន និងការបង្កើតការងារ ។

## ២. ការស្វែងរកការពិត

សកម្មភាពទី២៖ ចូរបែងចែកសិស្សក្នុងថ្នាក់ជាក្រុម។ ចូរឱ្យក្រុមនីមួយៗ ជ្រើសរើសការអះអាង«ពណ៌បៃតង» មួយចេញពីការអះអាងពណ៌បៃតងនានា នៅខាងលើ ដើម្បីធ្វើការផ្ទៀងផ្ទាត់មើលការពិត (ឬឱ្យជ្រើសរើសចេញពីបញ្ជីដែលអ្នកបង្កើតដោយខ្លួនឯង) ។

ចូរឱ្យក្រុមនានាស្រាវជ្រាវរកភ័ស្តុតាងដែលគាំទ្រ ឬដែលបដិសេធការរកឃើញ។ នៅមុនឱ្យពួកគេធ្វើដូច្នេះ ចូរលើកទឹកចិត្តឱ្យពួកគេវាយតម្លៃប្រភពនានា ដែលពួកគេរកឃើញ ដោយយោងទៅតាមបារ៉ាម៉ែត្រខាងក្រោម៖

**ភាពនៅជិត៖** តើភ័ស្តុតាងនៅជិតគ្នានឹងបាតុភាពប៉ុណ្ណា? ឧ. ស្ថាប័នដំណឹងមួយដែលរាយការណ៍អំពីស្ថិតិនៃភាពគ្មានការងារធ្វើថ្មីបំផុត ដែលនៅជិតគ្នាតិចតួចនឹងទិន្នន័យ ដូច្នេះវាមិនសូវមានតម្លៃដូចទៅនឹងស្ថាប័នស្ថិតិជាតិ ដែលជាអ្នកវាស់វែងតួលេខការងារពិតប្រាកដនោះឡើយ។

**ឯកទេស៖** តើគុណសម្បត្តិអ្វីខ្លះ ដែលគួសបញ្ជាក់អំពីគុណភាពរបស់អ្នកផលិតភ័ស្តុតាង? ឧ. អ្នកនិពន្ធសៀវភៅមួយក្បាល មានសញ្ញាបត្រថ្នាក់បណ្ឌិតលើប្រធានបទនោះ ហើយនៅក្នុងវិស័យរបស់គាត់ គាត់ត្រូវគេប្រើឈ្មោះគាត់ជាអំណះអំណាងច្រើន។

**ភាពហ្មត់ចត់៖** តើភ័ស្តុតាងនោះប្រមូលបានមកយ៉ាងដូចម្តេច? ឧ. ទិន្នន័យអំពីអំពើហិង្សាលើស្ត្រីត្រូវប្រមូលតាមរយៈការស្ទង់មតិ[11]។ នេះអាចធ្វើឱ្យការសន្និដ្ឋានជាទូទៅគ្មានសុពលភាព និងពិបាកប្រៀបធៀបជាលក្ខណៈអន្តរជាតិ ដោយយោងហេតុផលទៅលើឆន្ទៈរបស់ស្ត្រីនៅក្នុងការឆ្លើយតប ហើយការយល់ឃើញអំពីការបៀតបៀនផ្លូវភេទអាចនឹងមានភាពខុសគ្នា ក្នុងនោះរាប់ទាំងខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតផងដែរ។ នេះមិនមែនដើម្បីកាត់បន្ថយភាពធ្ងន់ធ្ងរនៃអំពើហិង្សាលើស្ត្រីឡើយ ប៉ុន្តែគឺដើម្បីតស៊ូមតិឱ្យមានភាពហ្មត់ចត់គាំទ្រ ដើម្បីការអះអាងជាក់លាក់ដែលបានធ្វើឡើង។

**តម្លាភាព៖** តើអ្នកដឹងអ្វីខ្លះអំពីភ័ស្តុតាងនេះ? ឧ. ការសិក្សាបែបវិទ្យាសាស្ត្រមួយបានផ្សព្វផ្សាយទិន្នន័យទាំងអស់ ដែលខ្លួនប្រើជាមូលដ្ឋានសម្រាប់ការសន្និដ្ឋានរបស់ខ្លួននៅលើអ៊ីនធឺណិត ដើម្បីឱ្យអ្នកស្រាវជ្រាវដទៃទៀតពិនិត្យពិច័យ។

**ភាពអាចជឿជាក់បាន៖** តើមានប្រវត្តិពីមុនមកសម្រាប់វាយតម្លៃឬទេ? ឧ. អង្គការ Transparency International កំពុងផ្សព្វផ្សាយរបាយការណ៍អំពីការយល់ឃើញអំពីអំពើពុករលួយ (Corruption Perceptions Index) អស់រយៈពេលជាង២០ឆ្នាំហើយ។ នេះបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកជំនាញ ដើម្បីរកមើលដែនកំណត់នៃរបាយការណ៍នេះ[12]។

---

11 See indicator (48) of the UN Gender Statistics https://genderstats.un.org/#/downloads

12 Hough, D. (2016) Here's this year's (flawed) Corruption Perception Index. Those flaws are useful. The Washington Post. Available at: https://www.washingtonpost.com/news/monkey-cage/wp/2016/01/27/how-do-you-measure-corruption-transparency-international-does-its-best- and-thats-useful/?utm_term=.7ff90ea2890f [accessed 23/03/2018].

**ទំនាស់ផលប្រយោជន៍៖** តើផលប្រយោជន៍បុគ្គល ឬឯកជនរបស់ប្រភព មានជាប់ពាក់ព័ន្ធនឹងភ័ស្តុតាងដែរឬទេ? ឧ. ការសិក្សាអំពីផលប្រយោជន៍ផ្នែកសុខភាពពីការបរិភោគ pasta ត្រូវបានធ្វើឡើង និងគាំទ្រមូលនិធិដោយក្រុមហ៊ុនផលិត pasta ដ៏ធំមួយ[13]។

គ្រូឧទ្ទេសអាចនឹងត្រូវការបោះពុម្ពតារាងខាងក្រោមនេះ និងឱ្យសិស្សប្រើប្រាស់វាដើម្បីវាយតម្លៃប្រភពនីមួយៗ។

| | ខ្សោយ | មធ្យម | ខ្លាំង |
|---|---|---|---|
| ភាពនៅជិត | | | |
| ឯកទេស | | | |
| ភាពហ្មត់ចត់ | | | |
| តម្លាភាព | | | |
| ភាពអាចជឿជាក់បាន | | | |
| ទំនាស់ផលប្រយោជន៍ | | | |

## កិច្ចការដែលគួរដាក់ឱ្យធ្វើ

### ការកែតម្រូវឱ្យត្រឹមត្រូវ

ដោយប្រើប្រាស់ភ័ស្តុតាងដែលវាយតម្លៃនៅក្នុងមេរៀន សិស្សគួរតែសរសេររបាយការណ៍ផ្ទៀងផ្ទាត់ការពិតមួយ (ប្រហែល ១២០០ពាក្យ) ដោយទាញសេចក្តីសន្និដ្ឋានអំពីភាពពិតនៃសេចក្តីថ្លែងការណ៍ ដែលពួកគេបានជ្រើសរើស។

ពួកគេគួរបង្កើតមាត្រដ្ឋានពិន្ទុផ្ទាល់ខ្លួន ដើម្បីដាក់ពិន្ទុលើការអះអាងដែលត្រូវបានផ្ទៀងផ្ទាត់ការពិត។ ឧទាហរណ៍ PolitiFact ដាក់ចេញនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការដាក់ពិន្ទុដូចខាងក្រោម៖

13 This is a real example. More here: http://www.healthnewsreview.org/2016/07/study-really-find-pasta-opposite-fattening/. [accessed 23/03/2018].

**ពិត** - សេចក្តីថ្លែងត្រឹមត្រូវ និងគ្មានចំណុចសំខាន់ណាមួយ ដែលត្រូវបានបំភ្លេចចោលនោះទេ។

**ពិតភាគច្រើនបំផុត** - សេចក្តីថ្លែងមានភាពត្រឹមត្រូវ ប៉ុន្តែត្រូវការការបំភ្លឺ ឬព័ត៌មានបន្ថែម។

**ពិតពាក់កណ្តាល** - សេចក្តីថ្លែងមានភាពត្រឹមត្រូវពាក់កណ្តាល ប៉ុន្តែបាត់សេចក្តីលម្អិតសំខាន់ៗ ឬដាក់ព័ត៌មានខុសពីបរិបទ។

**ខុសភាគច្រើន** - សេចក្តីថ្លែងមានចំណុចខ្លះពិត ប៉ុន្តែមិនបញ្ចូលការពិតសំខាន់ៗ ដែលនឹងធ្វើឱ្យគេមានការយល់ឃើញផ្សេង។

**ខុស** - សេចក្តីថ្លែងមិនត្រឹមត្រូវ។

**កុហក** - សេចក្តីថ្លែងនោះមិនត្រឹមត្រូវទេ និងមានការអះអាងដ៏ហួសចិត្តមួយ។

មាត្រដ្ឋានសម្រាប់ដាក់ពិន្ទុ មិនចាំបាច់ត្រូវតែមានលក្ខណៈជាបន្ទាត់ដូចអ្វីដែល PolitiFact ប្រើនោះទេ ដែលមាត្រដ្ឋាននេះឱ្យពិន្ទុផ្អែកលើមាត្រដ្ឋានពិតរហូតដល់កុហក។ ឧទាហរណ៍ El Sabueso នៅម៉ិចស៊ិក[14]ដាក់បញ្ចូលការដាក់ពិន្ទុដូចជា «មិនអាចបញ្ជាក់ថាពិតបានទេ» សម្រាប់ការអះអាងណា ដែលភាពត្រឹមត្រូវពឹងផ្អែកលើវិធីសាស្ត្រដែលជ្រើសរើស។ ចូរលើកទឹកចិត្តឱ្យសិស្សមានភាពច្នៃប្រឌិត រួមនឹងការបង្កើតមាត្រដ្ឋានជាវិធីមួយ ដើម្បីវាស់លក្ខណៈសម្បត្តិនានា ដែលយើងអាចផ្តល់ទៅឱ្យសេចក្តីថ្លែងអំពីការពិតនីមួយៗ។

ដោយអាស្រ័យលើពេលវេលា និងធនធានដែលមាន គ្រូឧទ្ទេសក៏អាចនឹងប្រាប់ឱ្យសិស្សរៀបចំការផ្ទៀងផ្ទាត់ការពិតនៅក្នុងទម្រង់មួយ ដែលលើសពីអត្ថបទសុទ្ធ។ រូប meme វីដេអូខ្លីៗ GIFs, Snapchat ទាំងអស់នេះសុទ្ធតែជាឧបករណ៍ល្អសម្រាប់ការប្រយុទ្ធប្រឆាំងនឹងភាពក្លែងក្លាយ។ ពិតណាស់ ការសិក្សាមួយបានបង្ហាញថា ការផ្ទៀងផ្ទាត់ការពិតដូចគ្នាមានប្រសិទ្ធភាពជាង នៅពេលដែលបង្ហាញជាវីដេអូបែបកំប្លែង ជាជាងបង្ហាញជាអត្ថបទ[15]។

សម្រាប់ឧទាហរណ៍មួយចំនួនអំពីទម្រង់ច្នៃប្រឌិត គ្រូអាចនឹងត្រូវការមើលអត្ថបទ

14 AnimalPolitico (2015). Available at http://www.animalpolitico.com/blogueros-blog-invitado/2015/01/28/el-sabueso-un-proyecto-para-vigilar-el-discurso-publico/. [accessed 6/04/2018].

15 Young, D., Jamieson, K., Poulsen, S. and Goldring, A. (2017). Fact-Checking Effectiveness as a Function of Format and Tone: Evaluating FactCheck.org and FlackCheck.org. Journalism & Mass Communication Quarterly, 95(1), pp.49-75

ខាងក្រោមនេះដែលផ្សាយនៅលើ Poynter ៖

Mantzarlis, A. (2016). Fact-checkers experiment with Snapchat, GIFs and other stuff millennials. Available at https://www.poynter.org/news/fact-checkers-experiment-snapchat-gifs-and-other-stuff-millennials [accessed 28/03/2018].

Mantzarlis, A. (2016). How (and why) to turn a fact check into a GIF. [accessed 28/03/2018. Available at https://www.poynter.org/news/how-and-why-turn-fact-check-gif [accessed 28/03/2018].

## អំណានបន្ថែម

បន្ថែមពីលើឯកសារអំណានដែលរាយបញ្ជីខាងក្រោមនេះ Poynter បានបង្កើតផ្នែកផ្ទៀងផ្ទាត់ការពិតមួយ នៅលើគេហទំព័ររបស់ខ្លួន https://www.poynter.org/channels/fact-checking ដែលធ្វើបច្ចុប្បន្នភាពជាច្រើនដងក្នុងមួយសប្តាហ៍។ ទាំងនេះគឺជាធនធានថ្មីៗ និងមានប្រយោជន៍មួយចំនួន ដែលអាចទាញយកមកពីទីនោះ។

Poynter (2018). How to fact-check a politician's claim in 10 steps. Available at https://factcheckingday.com/articles/5/how-to-fact-check-a-politicians-claim-in-10-steps. [accessed 06/04/2018].

Van Ess, H. (2017). The ultimate guide to bust fake tweeters: A video toolkit in 10 steps Available at https://www.poynter.org/news/ultimate-guide-bust-fake-tweeters-video-toolkit-10-steps. [accessed 06/04/2018].

Mantzarlis, A. (2015). 5 things to keep in mind when fact-checking claim about science. Available at https://www.poynter.org/news/5-things-keep-mind-when-fact-checking- claims-about-science. [accessed 06/04/2018].

Mantzarlis, A. (2016). 5 tips for fact-checking claims about health. Available at https://www.poynter.org/news/5-tips-fact-checking-claims-about-health. [accessed 06/04/2018].

Mantzarlis, A. (2015). 5 tips for fact-checking datasets. Available at https://www.poynter. org/news/5-tips-fact-checking-datasets. [accessed 06/04/2018].

Mantzarlis, A. (2015). 5 studies about fact-checking you may have missed last month (Poynter). Available at https://www.poynter.org/news/5-studies-about-fact-checking- you-may-have-missed-last-month. [accessed 06/04/2018].

Mantzarlis, A. (2017). Repetition boosts lies—but it could help fact-checkers too Available at https://www.poynter.org/news/repetition-boosts-lies-could-help-fact- checkers-too. [accessed 06/04/2018].

Mantzarlis, A. (2017). French and American voters seem to respond to fact-checking in a similar way. Available at https://www.poynter.org/news/french-and-american-voters- seem-respond-similar-way-fact-checking. [accessed 06/04/2018].

Funke, D. (2017). Where there's a rumour, there's an audience. This study sheds light on why some take off.  Available at https://www.poynter.org/news/where-theres-rumor- theres-audience-study-sheds-light-why-some-take. [accessed 06/04/2018].

Funke, D. (2017). Want to be a better online sleuth? Learn to read webpages like a fact-checker. Available at https://www.poynter.org/news/want-be-better-online-sleuth- learn-read-webpages-fact-checker. [accessed 06/04/2018].

Funke, D. (2017). These two studies found that correctingmisperceptions works. But it's not magic. Available at https://www.poynter.org/news/these-two-studies-found- correcting-misperceptions-works-its-not-magic. [accessed 06/04/2018].

Mantzarlis, A. (2017). What does the "Death of Expertise" mean for fact-checkers? Available at https://www.poynter.org/news/what-does-death-expertise-mean-fact- checkers. [accessed 06/04/2018].

Mantzarlis, A. (2017). Journalism can't afford for corrections to be the next victim of the fake news frenzy. Available at https://www.poynter.org/news/journalism-cant-afford-corrections-be-next-victim-fake-news-frenzy. [accessed 06/04/2018].

Mantzarlis, A. (2016). Should journalists outsource fact-checking to academics? Available at https://www.poynter.org/news/should-journalists-outsource-fact-checking- academics. [accessed 06/04/2018].

## សៀវភៅ

Ball, J. (2017). Post-Truth: How Bullshit Conquered the World. London: Bite backPublishing.

Gladstone, B. (2017). The Trouble with Reality: a Rumination on Moral Panic in Our Time.

New York: Workman Pu.

Graves, L. (2016). Deciding What's True: the Rise of Political Fact-Checking Movement in American Journalism. New York: Columbia University Press.

## ធនធាននៅលើអ៊ីនធឺណិត

គម្រោងមេរៀនល្បែងបៀរសម្ដែងតួ សម្រាប់ទិវាផ្ទៀងផ្ទាត់ការពិតអន្តរជាតិ (រៀបចំឡើងសម្រាប់សិស្សអាយុ១៤-១៦ឆ្នាំ) មាននៅទីនេះ ៖ http://factcheckingday.com/lesson-plan.

គេហទំព័រនេះ ក៏មានផ្ទុកឯកសារផ្តល់គន្លឹះ តំណភ្ជាប់ទៅរកវគ្គបណ្តុះបណ្តាលតាមអ៊ីនធឺណិតសម្រាប់និស្សិត និងបញ្ជីអំណានស្តីពីការពិត និងការផ្ទៀងផ្ទាត់ការពិត។



# ការផ្ទៀងផ្ទាត់ប្រព័ន្ធផ្សព្វផ្សាយសង្គម៖ ការវាយតម្លៃប្រភព និងមាតិការូបភាព

*Tom Trewinnard និង Fergus Bell*

# មេរៀនទី៦

មេរៀននេះរៀបចំឡើង ដើម្បីជួយសិស្សក្នុងការកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់ប្រភពដើមនៃព័ត៌មានឌីជីថលនៅលើអ៊ីនធឺណិត។ មេរៀននេះនឹងណែនាំយុទ្ធសាស្ត្រផ្សេងៗ សម្រាប់កំណត់ភាពត្រឹមត្រូវនៃប្រភព រូបថត និងវីដេអូ ជាពិសេសមាតិកាបង្កើតឡើងដោយអ្នកប្រើប្រាស់ ដែលចែករំលែកនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម។

នៅចុងបញ្ចប់នៃមេរៀននេះ សិស្សនឹងយល់ដឹងអំពីប្រភេទខុសៗគ្នានៃមាតិកាក្លែងក្លាយ និងបំភ័ន្តដែលជារឿយៗត្រូវបានចែករំលែក នៅក្នុងអំឡុងពេលព្រឹត្តិការណ៍ជំណឹងទាន់ហេតុការណ៍ នៅលើកម្មវិធីនានា ដូចជា Facebook Twitter Instagram និង YouTube[1]។ ជារឿយៗ មាតិកាបែបនេះត្រូវបានអង្គភាពសារព័ត៌មានដែលអាចទុកចិត្តបាន ជ្រើសរើសយកទៅចុះផ្សាយ ដើម្បីបកអាក្រាតពីភាពមិនពិតរបស់វា។ ជាមួយគ្នានេះដែរ មាតិកានេះត្រូវបានចែកចាយបន្ត និងបន្ទរនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ពីសំណាក់អ្នកសារព័ត៌មាន ដែលពេលខ្លះត្រូវបានតួអង្គទុច្ចរិត ប្រើជាគោលដៅសម្រាប់ការបញ្ជ្រាបឥទ្ធិពល លើកិច្ចពិភាក្សាសាធារណៈ[2] និងបង្កើនភាពអាចជឿទុកចិត្តរបស់អ្នកសារព័ត៌មាន ជាប្រភពដែលទុកចិត្ត[3]។

សិស្សត្រូវបានស្នើឱ្យសាកល្បងសភាវគតិរបស់ខ្លួន ដោយប្រើប្រាស់ទិដ្ឋភាពនិងឧទាហរណ៍ជាក់ស្តែង នៅមុនពេលដាក់ឱ្យអនុវត្តបច្ចេកទេស និងយុទ្ធសាស្ត្របែបស៊ើបអង្កេតជាមូលដ្ឋាន សម្រាប់ការផ្ទៀងផ្ទាត់មាតិកា ក្នុងនោះរួមបញ្ចូលទាំង ៖

- ការកំណត់អត្តសញ្ញាណ និងឱ្យតម្លៃទៅប្រភពដើម ស្របទៅតាមគោលការណ៍ក្រមសីលធម៌ ដែលណែនាំការប្រើប្រាស់បែបសារព័ត៌មាននៃមាតិកា ដែលបង្កើតឡើងដោយអ្នកប្រើប្រាស់[4]
- ការកំណត់អត្តសញ្ញាណ និងលុបចោលគណនីក្លែងក្លាយ ឬគណនី

1 Alejandro, J. (2010). Journalism in The Age Of Social Media. Reuters Institute Fellowship. Available at: http://reutersinstitute.politics.ox.ac.uk/sites/default/files/research/files/Journalism%2520in%2520the%2520Age%2520of%2520Social%2520Media.pdf [accessed 22/04/2018].].

2 Paulussen, S. & Harder, R. (2014). Social Media References in Newspapers. Journalism Practice, 8(5), pp. 542-551.

3 មេរៀនទី៧នឹងពិភាក្សា និងដោះស្រាយបញ្ហានេះ

4 See Online News Association's UGC Ethics guide: https://ethics.journalists.org/topics/user-generated-content/ [accessed18/4/2018].

ដំណើរការស្វ័យប្រវត្តិ[5] [6]

- ➢ ការបញ្ជាក់ថា មានការប្រាប់ប្រភពដើមមាតិការូបភាព ឬវីដេអូបានត្រឹមត្រូវ
- ➢ ការផ្ទៀងផ្ទាត់ពេលវេលានៃការផលិត និងការបង្ហោះមាតិកា
- ➢ កំណត់ទីតាំងភូមិសាស្ត្ររបស់រូបភាពនិងវីដេអូ

ការមានលទ្ធភាពកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់មាតិកាដើម អនុញ្ញាតឱ្យអ្នកសារព័ត៌មានអាចសុំសិទ្ធិដើម្បីផ្សព្វផ្សាយមាតិកាបង្កើតឡើងដោយអ្នកប្រើប្រាស់ស្របទៅតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ និងក្រមសីលធម៌។

## គ្រោងនៃមេរៀន

អ្នកនិពន្ធ Bill Kovach និង Tom Rosenstiel នៅក្នុងសៀវភៅ The Elements of Journalism[7] បញ្ជាក់ថា៖ «នៅទីបំផុត វិន័យនៃការផ្ទៀងផ្ទាត់ការពិត គឺជាអ្វីដែលញែកសារព័ត៌មានចេញពីការកម្សាន្ត ការឃោសនា ការប្រឌិត ឬសិល្បៈ ...សារព័ត៌មានតែមួយមុខគឺផ្តោតសំខាន់ជាបឋម ទៅលើការរាយការណ៍អំពីអ្វី ដែលបានកើតឡើងឱ្យបានត្រឹមត្រូវ...»។ ក្នុងន័យនេះ មេរៀននេះពិនិត្យទៅលើ «វិន័យនៃការផ្ទៀងផ្ទាត់» នៅក្នុងពេលបច្ចុប្បន្ន។

ប្រព័ន្ធផ្សព្វផ្សាយសង្គម បានកែប្រែទម្លាប់អនុវត្តន៍វិជ្ជាជីវៈសារព័ត៌មាន។ ការចូលរួមរបស់ក្រុមគោលដៅភ្លាមៗ បានជំរុញឱ្យកើនឡើងនូវមាតិកាដែលមានប្រភពពីមហាជន ហើយសូម្បីតែការងាររាយការណ៍ ដូចជាការផ្ទៀងផ្ទាត់ក៏ឥឡូវនេះ អាចប្រគល់ទៅឱ្យក្រុមគោលដៅបានផងដែរ[8]។ ជាគោលការណ៍ បើទោះជាសារព័ត៌មាននៅតែជាវិន័យនៃការផ្ទៀងផ្ទាត់[9] ក៏វិធីផ្ទៀងផ្ទាត់ខ្លឹមសារនិងប្រភពទាមទារការធ្វើបច្ចុប្បន្នភាពជាប្រចាំដែរ ដើម្បីឆ្លុះបញ្ចាំងអំពីផលប៉ះពាល់នៃ

---

5 Woolley, S. C. & Howard, P. N. (2017). Computational Propaganda Worldwide: Executive Summary. Samuel Woolley and Philip N. Howard, Eds. Working Paper 2017.11. Oxford, UK: Project on Computational Propaganda.comprop.oii.ox.ac.uk. Available at http://comprop.oii.ox.ac.uk/wp-content/uploads/sites/89/2017/06/Casestudies-ExecutiveSummary.pdf [accessed 22/04/2018].].

6 Joseph, R. (2018). Guide. How to verify a Twitter account. Africa Check. Available at https://africacheck.org/factsheets/guide-verify-twitter- account/. [accessed. 6/04/2018].

7 Kovach, B., & Rosenstiel, T. (2014). The elements of journalism: What news people should know and the public should expect. New York: Crown Publishers.

8 Carvin, A. (2012). Distant witness: Social Media's Journalism Revolution. New York, NY: CUNY Journalism Press.

9 Kovach, B. & Rosenstiel, T. (2014). Op cit

បច្ចេកវិទ្យាឌីជីថលដែលវិវត្តយ៉ាងឆាប់រហ័ស តវិយាបថនៅលើអ៊ីនធឺណិត និងរបៀបរបបប្រមូលដំណឹង។ ឧទាហរណ៍ នៅក្នុងអំឡុងពេលបាតុកម្ម Arab Spring គោលគំនិតនៃ «ការផ្ទៀងផ្ទាត់ដោយបើកចំហ» ជាដំណើរការនៃការផ្ទៀងផ្ទាត់ភ្លាមៗជាលក្ខណៈសាធារណៈ និងសហប្រតិបត្តិការ បានចាប់ផ្តើមកើតមានឡើង។ ប៉ុន្តែដំណើរការនេះ នៅតែមានភាពចម្រូងចម្រាសនៅឡើយ ដោយសារតែហានិភ័យទាក់ទងនឹងព័ត៌មានមិនពិត ដែលរាលដាលលឿននៅក្នុងពេលនៃការព្យាយាមផ្ទៀងផ្ទាត់ព័ត៌មានមួយជំហានម្តងៗ នៅតាមវេទិកាសាធារណៈ (ឧ. អ្នករាយការណ៍ដំណឹងម្នាក់ ដែលចែករំលែកព័ត៌មានមិនបានផ្ទៀងផ្ទាត់ ក្នុងគោលបំណងទាក់ទាញសាធារណជន ចូលរួមក្នុងដំណើរការផ្ទៀងផ្ទាត់ព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយសង្គម)[10]។

សព្វថ្ងៃនេះ ការរៀបរាប់របស់សាក្សីដែលបានឃើញហេតុការណ៍ផ្ទាល់ភ្នែក និងមាតិកាជារូបភាព ឬវីដេអូស្ថិតនៅក្នុងចំណោមឧបករណ៍សំខាន់ និងទាក់ទាញបំផុតដែលអ្នកសារព័ត៌មាន ឬអ្នកផ្សព្វផ្សាយដំណឹងអាចយកមកប្រើដើម្បីប្រាប់រឿងមួយដ៏មានឥទ្ធិពល។ ក្នុងករណីដំណឹងទាន់ហេតុការណ៍ ល្បឿនជាកត្តាដ៏សំខាន់នៅក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន ដែលទទួលបានពីប្រព័ន្ធផ្សព្វផ្សាយសង្គម[11]។

អ្នកសារព័ត៌មានត្រូវតែអាចជម្នះ លើបរិមាណព័ត៌មានដ៏ច្រើនលើសលប់ ដើម្បីទៅឱ្យដល់ប្រភពព័ត៌មាន និងរូបភាពដែលសំខាន់។ កំណើនដ៏លឿននៃបរិមាណមាតិការូបភាព (រូបថត វីដេអូ និងរូបភាពក្នុងទម្រង់ GIF) ដែលបង្ហោះលើប្រព័ន្ធផ្សព្វផ្សាយសង្គម ត្រូវជំរុញដោយកត្តាសំខាន់ៗចំនួន៣៖

- ការសាយភាយនៃទូរស័ព្ទទំនើបដែលមានកាមេរ៉ា និងកម្មវិធីប្រើប្រាស់សម្បូរបែបនៅទូទាំងពិភពលោក[12]
- កំណើនលទ្ធភាពទទួលបានទិន្នន័យចល័ត (mobile data) ដែលថូរថ្លៃ (និងឥតគិតថ្លៃ នៅទីកន្លែងមួយចំនួន)។
- ការកើតឡើងយ៉ាងផុសផុលនៃប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីផ្ញើសារ

10 Posetti, J. & Silverman, S. (2014). When Good People Share Bad Things: The basics of social media verification at Media shift July24th, 2014. Available: http://mediashift.org/2014/07/goodwhen-good-people-share-bad-things-the-basics-of-social-media-verification/ [accessed 22/04/2018].].

11 Brandtzaeg, P., Lüders, M., Spangenberg, J., Rath-Wiggins, L. & Følstad, A. (2015). Emerging Journalistic Verification Practices Concerning Social Media. Journalism Practice, 10(3), pp. 323-342.

12 See Slide 5 of Mary Meeker's Internet Trends Report: https://www.slideshare.net/kleinerperkins/internet-trends-v1. [accessed 22/04/2018].].

ដែលអនុញ្ញាតឱ្យមនុស្សគ្រប់រូបអាចផ្សព្វផ្សាយខ្លឹមសារ និងបង្កើតក្រុមគោលដៅ។

ក្នុងករណីដំណឹងទាន់ហេតុការណ៍ជាច្រើន រឿងរ៉ាវ រូបភាព និងវីដេអូមុនគេដែលលេចចេញពីឧបទ្ទវហេតុនោះ ទោះជារឿងបាតុកម្មតវ៉ា គ្រោះថ្នាក់រថភ្លើងបុកគ្នា ព្យុះសង្ឃរា ឬការវាយប្រហារភេរវកម្មក្តី ទំនងជាត្រូវបានផ្សព្វផ្សាយដោយសាក្សីដែលឃើញហេតុការណ៍ផ្ទាល់ភ្នែក អ្នកចូលរួម ឬអ្នកឈរមើលដែលមានទូរស័ព្ទទំនើប។ បច្ចេកទេសនៃការផ្ទៀងផ្ទាត់មាតិកានេះមានខុសៗគ្នា អាស្រ័យទៅតាមធនធាន ទម្លាប់ និងបទដ្ឋានរបស់ការិយាល័យដំណឹង និងការអនុវត្តផ្ទាល់ខ្លួនរបស់អ្នកសារព័ត៌មាន។

មេរៀននេះ នឹងណែនាំសិស្សឱ្យស្គាល់វិធីសាស្រ្តអនុវត្តន៍ល្អៗមួយចំនួន ព្រមទាំងឧបករណ៍ និងធនធានលើអ៊ីនធឺណិតនានា ប៉ុន្តែទាក់ទងនឹងបច្ចេកវិទ្យា ឧបករណ៍វិវត្តលឿនណាស់[13]។

ទោះជាផ្ទៀងផ្ទាត់បែបណាក៏ដោយ ក៏ត្រូវគ្នានឹងគោលការណ៍ណែនាំទូទៅមួយចំនួន ដែលផ្តល់ជូនដោយ Kovach និង Rosenstiel (ឆ្នាំ២០១៤)[14] ដែរ ៖

- កែសម្រួលដោយមន្ទិលសង្ស័យ
- មានបញ្ជីពិនិត្យភាពត្រឹមត្រូវ
- មិនត្រូវសន្និដ្ឋានអ្វីទាំងអស់ មិនត្រូវចាញ់បោកសញ្ញាពាក់ព័ន្ធនឹង «សេចក្តីពិត»ឡើយ[15]
- ចូរប្រយ័ត្នប្រយែងចំពោះប្រភពអនាមិក

តាមរយៈការដឹងប្រភពដើមនៃព័ត៌មាន ឬរូបភាព និងការពិនិត្យមើលជាលក្ខណៈប្រព័ន្ធទៅលើប្រភព និងមាតិកាដែលគេបានចែករំលែក អ្នកគួរតែអាចផ្ទៀងផ្ទាត់ប្រភពនោះ ឱ្យតែការផ្ទៀងផ្ទាត់នោះ ផ្តល់លទ្ធផលដែលអ្នកត្រូវការ[16]។

ការផ្ទៀងផ្ទាត់ទាំងនេះ ដូចគ្នានឹងការងារដែលអ្នកសារព័ត៌មានធ្វើដែរ បើពួក

13 Schifferes, S., Newman, N., Thurman, N., Corney, D., Göker, A. & Martin, C. (2014). Identifying and Verifying News through Social Media. Digital Journalism, 2(3), pp. 406-418.

14 Kovach & Rosenstiel (2014). Op cit.

15 Zimmer, B (2010). "Truthiness", The New York Times. https://www.nytimes.com/2010/10/2017/magazine/2017FOB-onlanguage-t.html[accessed 15/04/2018].

16 Bell, F. (2015). Verification: Source vs Content [online] Medium. Available at: https://medium.com/1st-draft/verficiation-source-vs-content-b67d6eed3ad0 [accessed 22/04/2018].].

គេមានវត្តមានផ្ទាល់ នៅនឹងកន្លែងកើតហេតុដោយសម្ភាសសាក្សី ដែលបានឃើញផ្ទាល់។ អ្នកសារព័ត៌មានដែលអាចធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយប្រភពបាន នឹងសួរដេញដោលសួរជីកបួសជីកគល់សាក្សី ដោយបន្ថែមលើព័ត៌មានលម្អិតសំខាន់ៗ និងសន្និដ្ឋានអំពីភាពអាចជឿទុកចិត្តបាននៃដំណឹងទាំងនោះ ដោយផ្អែកលើការផ្ទៀងផ្ទាត់ការពិត។ សភាវគតិក៏អាចជាមគ្គុទេសក៍មួយផ្នែកដែរ រួមជាមួយនឹងការសង្កេតមើលតម្រុយនៃឥរិយាបថ។ ដំណើរការនៃការបញ្ជាក់ប្រភព តាមប្រព័ន្ធបច្ចេកវិទ្យាត្រូវអនុញ្ញាតឱ្យមានការធ្វើសេចក្តីសន្និដ្ឋាន បើទោះបីជាគេមិនអាចនិយាយទៅកាន់មនុស្សម្នាក់ផ្ទាល់ ឬក្នុងពេលភ្លាមៗនោះក្តី[17]។

ការិយាល័យដំណឹងធំៗជាច្រើនមានក្រុម និងបច្ចេកវិទ្យាថ្លៃៗ ឬភ្នាក់ងារផ្តល់សេវាស្វែងរកខ្លឹមសារនេះ ឱ្យបានរហ័សតាមដែលអាចធ្វើទៅបាន[18]។ ទន្ទឹមនឹងនេះ គេក៏ស្វះស្វែងសុំសិទ្ធិផ្សព្វផ្សាយ និងផ្ទៀងផ្ទាត់ខ្លឹមសារនៅមុនពេលចុះផ្សាយដែរ។ ការិយាល័យដំណឹងតូចៗភាគច្រើន និងអ្នកសារព័ត៌មានជាលក្ខណៈឯកជនជាច្រើន ពុំមានធនធានដូចគ្នាទេ[19] និងពឹងផ្អែកលើវិធីសាស្ត្រជាប្រព័ន្ធដែលវិវត្តផ្ទាល់ខ្លួន ដើម្បីកំណត់ភាពដែលអាចជឿជាក់បាន[20]។

ហេតុអ្វីបានជាការផ្ទៀងផ្ទាត់ប្រភព និងមាតិការូបភាព មានសារៈសំខាន់ខ្លាំង? ចម្លើយសាមញ្ញគឺដើម្បីសារព័ត៌មានល្អ។ នៅក្នុងពិភពឌីជីថលសព្វថ្ងៃនេះ តួអង្គដែលមានចេតនាទុច្ចរិត អាចបង្កើត និងចែករំលែកមាតិកាក្លែងបន្លំ ដែលមានភាពទាក់ទាញយ៉ាងងាយស្រួល ប៉ុន្តែពិបាកមើលដឹងណាស់ថាជាការក្លែងបន្លំ។ មានករណីជាច្រើនដែលអ្នកសារព័ត៌មានវិជ្ជាជីវៈ និងការិយាល័យដំណឹងបានបំផ្លិចបំផ្លាញកេរ្តិ៍ឈ្មោះរបស់ខ្លួនដោយសារតែការចែករំលែក ឬចុះផ្សាយបន្តនូវដំណឹងរូបភាព ឬវីដេអូបំភ័ន្តការពិត ដែលមានប្រភពចេញមកពីមនុស្សក្លែងក្លាយ។ ពេលខ្លះ ពួកគេក៏បានយល់ខុសចំពោះមាតិកាបែបកំប្លែងរិះគន់ ដោយចែករំលែក

17 Kovach & Rosenstiel (2014). Op cit.

18 Diakopoulos N., De Choudhury M. & Naaman M. (2012). Finding and assessing social media information sources in the context of journalism Conference on Human Factors in Computing Systems - Proceedings, pp. 2451-2460. Available at: http://www.nickdiakopoulos.com/wp-content/uploads/2011/07/SRSR-diakopoulos.pdf [accessed 22/04/2018].

19 Schifferes, S., Newman, N.,Thurman, N., Corney, D., Goker, A.S. & Martin, C. (2014). Identifying and verifying news through social media: Developing a user- centred tool for professional journalists. Digital Journalism, 2(3), pp. 406-418. Available at http://openaccess.city.ac.uk/3071/1/IDENTIFYING AND VERIFYING NEWS THROUGH SOCIAL MEDIA.pdf [accessed 22/04/2018].].

20 Brandtzaeg, P.B., Lüders, M., Spangenberg, J., Rath-Wiggins, L., & Følstad, A. (2016). Emerging journalistic verification practices concerning social media. Journalism Practice, 10(3), 323-342.

ឬចុះផ្សាយមាតិកាបែបនេះថាជាការពិត[21]ទៀតផង។

បញ្ហានេះរីកកាន់តែធំដោយសារតែបរិមាណនៃមាតិការូបភាព ដែលមាននៅលើអ៊ីនធឺណិត ហើយមាតិកាទាំងអស់នោះ សុទ្ធតែអាចត្រូវគេលុបបរិបទដើម និងយកវាមកប្រើឡើងវិញនៅក្នុងព្រឹត្តិការណ៍ដំណឹងនាពេលអនាគត ដូចដែលយើងឃើញកើតមានឡើងជារៀងរាល់ថ្ងៃ នៅជុំវិញពិភពលោក ដែលមានជនបោកប្រាស់ប្រើល្បិចបោកបញ្ឆោតអ្នកនយោបាយ និងអ្នកសារព័ត៌មានវិជ្ជាជីវៈ។

ទោះជាយ៉ាងណា មានវិធានការជាច្រើនដែលគេអាចអនុវត្ត ដើម្បីវាយតម្លៃភាពអាចជឿជាក់បានរបស់ប្រភពមួយ ដែលមានរឿងដែលត្រូវប្រាប់ ឬមាតិកាដែលត្រូវចែករំលែក។ គេគួរតែសួរសំណួរសំខាន់ៗដោយផ្ទាល់ខ្លះ ហើយសំណួរខ្លះទៀតគួរតែឆ្លើយតាមរយៈការប្រើប្រាស់ភស្តុតាង ដែលអាចរកបានពីការស៊ើបអង្កេត។ គេអាចប្រើប្រាស់ឧបករណ៍ផ្ទៀងផ្ទាត់ ដើម្បីកំណត់ប្រភពដែលបង្ហោះមាតិកានោះ ប៉ុន្តែគេក៏អាចផ្ទៀងផ្ទាត់ប្រភពមួយ ដោយប្រើមនុស្សតាមរយៈការវិភាគសារតានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ពួកគេ ដើម្បីពិនិត្យរកមើលតម្រុយដែលអាចបញ្ជាក់លទ្ធភាពថា គេស្ថិតនៅកន្លែងណាមួយ និងក្នុងពេលណា។ ការផ្ទៀងផ្ទាត់សារតានៃការប្រាស្រ័យទាក់ទងរបស់ពួកគេ ជាមួយនឹងអ្នកប្រើប្រាស់ដទៃទៀត និងការពិនិត្យមាតិកាដែលជាប់ទាក់ទង នៅក្នុងអ្វីដែលគេបង្ហោះលើប្រព័ន្ធផ្សព្វផ្សាយសង្គម ក៏ជួយដល់ដំណើរការផ្ទៀងផ្ទាត់ និងអាចជួយលុបបំបាត់ដំណឹង ដែលចែករំលែកដោយប្រព័ន្ធដំណើរការស្វ័យប្រវត្តិ។

ការផ្ទៀងផ្ទាត់កែសម្រួលដោយមន្ទិលមានភាពចាំបាច់ ប៉ុន្តែមនុស្សភាគច្រើនដែលនៅក្នុងព្រឹត្តិការណ៍ដំណឹង និងចែករំលែករឿងរបស់ខ្លួន មិនមែនមានបំណងដើម្បីបោកប្រាស់គេទេ។ ពួកគេគ្រាន់តែចែករំលែកបទពិសោធន៍របស់ខ្លួនតែប៉ុណ្ណោះ។ ប្រសិនបើព័ត៌មានខុសកើតឡើងរបៀបនេះ វាប្រហែលមិនមែនជាចេតនាអាក្រក់ទេ។ ជំនួសមកវិញ វាអាចទៅរួចដែរដែលថា បុគ្គលម្នាក់ចងចាំព្រឹត្តិការណ៍មិនបានត្រឹមត្រូវ ឬអាចនឹងជ្រើសរើសបញ្ចេញបញ្ចូលរឿងបន្ថែម។ ប្រការនេះក៏អាចកើតឡើងដែរ បើអ្នកមានឱកាសសម្ភាសមនុស្សផ្ទាល់ ដូចក្នុងករណីរាយការណ៍ ឬសេចក្តីថ្លែងការណ៍ចម្រូងចម្រាស ពីទីកន្លែងកើតហេតុឧក្រិដ្ឋកម្ម ឬឧប្បត្តិហេតុដែលនៅទីនោះ ការរៀបរាប់របស់សាក្សីដែលជួបប្រទះនឹងការប៉ះទង្គិចផ្លូវចិត្ត ឬជនរងគ្រោះអាចនឹងមានកម្រិតខុសគ្នាច្រើន។

21 Deutsche Welle (2018) Germany's Bild falls for hoax and unleashes fake news debate (22/02/2018) Available at http://www.dw.com/en/germanys-bild-falls-for-hoax-unleashes-debate-on-fake-news/a-42704014 [accessed 22/04/2018].].

ក្នុងពេលដែលគេអាចនឹងមិនមានលទ្ធភាពបញ្ជាក់ ដោយច្បាស់លាស់ពេញលេញ អំពីប្រភពដើមនៃមាតិកា ដែលអាចមើលឃើញក៏ពិតមែន ប៉ុន្តែមាន«សញ្ញាព្រមាន» ជាច្រើនដែលគេអាចរកឃើញ តាមរយៈដំណើរការផ្ទៀងផ្ទាត់សាមញ្ញមួយ ដែលសួរសំណួរដូចខាងក្រោម៖

- ➢ តើមាតិកានេះជាមាតិកាដើមមែនទេ? ឬត្រូវបានគេ «ផ្សេផ្សំ» យកចេញពីសេចក្តីរាយការណ៍មុន និងកែសម្រួលក្នុងលក្ខណៈមួយ ដែលនាំឱ្យមានការភ័ន្តច្រឡំឬទេ?
- ➢ តើមាតិកានេះត្រូវបានគេកែកុន ដោយបច្ចេកវិទ្យាឌីជីថលដែរឬទេ[22]?
- ➢ តើយើងអាចបញ្ជាក់អំពីពេលវេលា និងទីកន្លែងនៃការថតរូបភាព/វីដេអូ ដោយប្រើទិន្នន័យមេតា (metadata) បានដែរឬទេ?
- ➢ តើយើងអាចបញ្ជាក់ពីពេលវេលា និងទីកន្លែងនៃការថតរូបភាព/ វីដេអូ ដោយប្រើតម្រុយដែលអាចមើលឃើញ នៅក្នុងមាតិកានោះបានដែរឬទេ?

ដើម្បីស្វែងរកសញ្ញាព្រមានប្រកបដោយប្រសិទ្ធភាព យើងក៏ចាំបាច់ត្រូវយល់អំពីប្រភេទខុសៗគ្នានៃមាតិការូបភាពក្លែងក្លាយ ឬបំភ័ន្តដែលកើតមានជាទូទៅដែរ៖

- ➢ **ខុសពេលវេលា/ខុសទីកន្លែង៖** ប្រភេទទូទៅបំផុតមួយនៃមាតិការូបភាព ដែលធ្វើឱ្យភ័ន្តច្រឡំ គឺមាតិការូបភាពចាស់ ដែលត្រូវគេចែករំលែកឡើងវិញ ជាមួយនឹងការអះអាងថ្មីអំពីអ្វី ដែលមាតិកានោះបង្ហាញឱ្យឃើញ។ ភាពរាលដាលលឿននៅក្នុងករណីបែបនេះ ច្រើនតែកើតចេញពីការចែករំលែកដោយចៃដន្យនូវមាតិកា ដែលងាយនឹងលាតត្រដាងការពិត ប៉ុន្តែងាយស្រួលក្នុងការលុបចោលវិញ[23]។
- ➢ **មាតិកាបោកបញ្ឆោត៖** ជាមាតិកាដែលត្រូវគេកែបន្លំ ដោយប្រើបច្ចេកវិទ្យាឌីជីថលតាមរយៈការប្រើកម្មវិធីកាត់ត ឬកែរូបថត/វីដេអូ។
- ➢ **មាតិកាដែលគេប្រឌិតឡើង៖** ជាមាតិកាដើមដែលគេបង្កើតឡើង ឬចែករំលែកក្នុង

22 សិស្សដែលបានរស់រានមានជីវិតពីការសំលាប់រង្គាលនៅឯសាលាផាកលែន រដ្ឋ Florida ប្រទេសអាមេរិក បានរៀបចំបាតុកម្មថ្នាក់ជាតិបានយ៉ាងជោគជ័យសម្រាប់គ្រប់គ្រងកាំភ្លើង ដោយផ្សាយជារូបភាពចែកចាយនៅលើបណ្តាញផ្សព្វផ្សាយសង្គមរបស់ក្រុមបក្សពួកនិយម។ https://www.buzzfeed.com/janelytvynenko/here-are-the-hoaxes- and-conspiracies-still-going-around?utm_term=.euy6NPayy#.jhe2YvV44. [Accessed 22/04/2018].].

23 វីដេអូនេះអះអាងថាជាភស្តុតាងនៃទឹកជំនន់នៅព្រលានយន្តហោះអន្តរជាតិប៉េនហ្គាឡូរក្នុងប្រទេសឥណ្ឌា តាមការពិតវាគឺជាវីដេអូទឹកជំនន់នៅព្រលានយន្តហោះម៉ិចស៊ិកទេ។ https://www.thequint.com/news/webqoof/fake-video-claiming-bengaluru-airport-was-flooded-is-from-mexico [accessed 22/04/2018].].

ចេតនាដើម្បីបំភ័ន្ត[24]

នៅក្នុងមេរៀននេះ សិស្សនឹងត្រូវណែនាំឱ្យស្គាល់ឧបករណ៍ និងបច្ចេកទេសជាមូលដ្ឋានជាច្រើន ដើម្បីរៀន និងអនុវត្តកិច្ចការផ្ទៀងផ្ទាត់ប្រភព និងមាតិកា (បទបង្ហាញរួមមានទាំងកំណត់សម្គាល់របស់គ្រូ និងការផ្តល់ជូនឯកសារអំណានបន្ថែម)ដូចជា[25]៖

**ការវិភាគគណនី** Facebook៖ តាមរយៈការប្រើប្រាស់ ឧបករណ៍លើអ៊ីនធឺណិតពីគេហទំព័រ Intel Techniques[26]អ្នកអាចស្វែងយល់បន្ថែមអំពីប្រភពមួយ ដោយការវិភាគគណនី Facebook របស់ពួកគេ។

**ការវិភាគគណនី** Twitter៖ តាមរយៈការប្រើប្រាស់សៀវភៅណែនាំពី Africa Check អ្នកអាចស្វែងយល់បន្ថែមអំពីប្រភព ដោយការវិភាគសារតាសង្គមរបស់ពួកគេ និងកំណត់រកមើលថា តើជាការសរសេរសារដោយស្វ័យប្រវត្តិ ឬយ៉ាងណា[27]។

**ការស្រាវជ្រាវរូបភាពត្រឡប់** (Reverse Image Search)៖ តាមរយៈការប្រើប្រាស់មុខងារ Google Reverse Image Search[28] កម្មវិធី TinEye[29] ឬកម្មវិធី RevEye[30] អ្នកអាចពិនិត្យមើលថា តើរូបភាពមួយកំពុងត្រូវគេប្រើប្រាស់ឡើងវិញ ដើម្បីគាំទ្រការអះអាងថ្មី ឬព្រឹត្តិការណ៍ថ្មីមួយ ឬយ៉ាងណា។ ការស្រាវជ្រាវរូបភាពតាមកម្មវិធីនេះ អាចឱ្យអ្នកមើលឃើញថា តើប្រព័ន្ធទិន្នន័យផ្ទុករូបភាពមួយ ឬច្រើន (ដែលមានផ្ទុករូបភាពរាប់ពាន់លានរូប) មានផ្ទុករូបភាពដើមនៃរូបភាពនោះដែរ ឬទេ។ បើការស្រាវជ្រាវបង្ហាញថា មានរូបភាពនោះនៅមុនព្រឹត្តិការណ៍ដែលបានអះអាងមែន នេះជាសញ្ញាព្រមានដ៏ធំមួយ ហើយប្រហែលរូបភាពនេះត្រូវគេប្រើប្រាស់ឡើងវិញ ពីព្រឹត្តិការណ៍មុន។ បើការស្រាវជ្រាវរូបភាពបែបនេះមិនបង្ហាញលទ្ធផលអ្វីទេ ក៏មិនមែនមានន័យថា រូបភាពនោះជារូបភាពដើមដែរ ហើយអ្នកចាំបាច់នៅតែត្រូវផ្ទៀងផ្ទាត់បន្ថែមទៀតដដែល។

24 Artificial intelligence and sophisticated video editing tools make it difficult to discern fake videos, as this footage of Barack Obama shows: https://www.youtube.com/watch?v=AmUC4m6w1wo [accessed 03/04/2018].

25 ចំណាំថាឧបករណ៍ដំណឹងបន្តប្រែប្រួល ហើយអ្នកបង្រៀនជាមួយនិងអ្នករៀនអាចស្វែងរក ហើយនឹងសាកល្បងបច្ចេកទេស និងវិធីសាស្ត្រជាច្រើនផ្សេងគ្នា។

26 Available at: https://inteltechniques.com/osint/facebook.html. [accessed 03/04/2018].

27 Joseph (2018). Op cit

28 How to do a Google Reverse Image Search: https://support.google.com/websearch/answer/1325808?hl=en [accessed 22/04/2018]

29 Go to https://www.tineye.com/[accessed 22/04/2018].].

30 http://squobble.blogspot.co.uk/2009/12/chromeeye-tineye-extension-for-google.html [accessed 22/04/2018].].

**ទិន្នន័យតាម** YouTube (Youtube Data Viewer)៖ កម្មវិធី«ស្រាវជ្រាវវីដេអូរកប្រភពដើម» មិនមានដាក់ឱ្យប្រើប្រាស់ជាសាធារណៈទេ ឧបករណ៍មួយចំនួនដូចជា YouTube Data Viewer[31]របស់អង្គការលើកលែងទោសអន្តរជាតិ កម្មវិធី InVID[32] និងកម្មវិធី NewsCheck[33] អាចស្វែងរកមើលរូបវីដេអូខ្នាតតូចសម្រាប់វីដេអូ YouTube ហើយការស្រាវជ្រាវរកប្រភពដើមលើរូបខ្នាតតូចទាំងនោះ អាចបង្ហាញឱ្យឃើញថា តើរូបភាពទាំងនេះមានគេបង្ហោះពីមុនមកដែរឬទេ (ឧបករណ៍ក៏បង្ហាញម៉ោងពេលដាក់លាក់នៃការបង្ហោះលើអ៊ីនធឺណិតដែរ)។

**EXIF Viewer** ៖ EXIF គឺជាទិន្នន័យមេតា ដែលភ្ជាប់នៅជាមួយមាតិការូបភាពផ្ទុកចំណុចទិន្នន័យជាច្រើន បង្កើតចេញពីកាមេរ៉ាឌីជីថល និងកាមេរ៉ាទូរស័ព្ទដៃនៅចំណុចថត។ ព័ត៌មានទាំងនេះមានដូចជាពេលវេលា និងកាលបរិច្ឆេទជាក់លាក់ ទីតាំង ទិន្នន័យឧបករណ៍ និងព័ត៌មានអំពីការកំណត់ពន្លឺ។ ដូច្នេះហើយកម្មវិធីទិន្នន័យមេតា EXIF មានសារៈប្រយោជន៍ខ្លាំង នៅក្នុងដំណើរការផ្ទៀងផ្ទាត់ ប៉ុន្តែកត្តារឹតត្បិតធំមួយគឺថា ប្រព័ន្ធផ្សព្វផ្សាយសង្គមលុបចោលទិន្នន័យមេតាចេញពីមាតិការូបភាព នៅពេលបង្ហោះចូលប្រព័ន្ធផ្សព្វផ្សាយសង្គម។ ការធ្វើបែបនេះមានន័យថា រូបភាពដែលចែករំលែកនៅលើ Facebook ឬ Twitter នឹងមិនបង្ហាញទិន្នន័យ EXIF ទេ។ ប៉ុន្តែបើអ្នកអាចទាក់ទងទៅអ្នកដែលបង្ហោះ និងសុំរូបភាពដើម អ្នកអាចប្រើប្រាស់ទិន្នន័យ EXIF ដើម្បីផ្ទៀងផ្ទាត់មាតិកានោះបាន។ ការសំខាន់មួយទៀតដែលគួរតែកត់សម្គាល់គឺថា គេអាចកែប្រែទិន្នន័យ EXIF ដូច្នេះចាំបាច់ត្រូវធ្វើការផ្ទៀងផ្ទាត់បន្ថែមទៀត។

សិស្សនឹងទទួលបានការណែនាំឱ្យស្គាល់បច្ចេកទេសទំនើបៗច្រើនទៀតជាមួយនឹងធនធានបន្ថែមសម្រាប់ការអាន និងករណីសិក្សាដែលបានផ្តល់ឱ្យ។ បច្ចេកទេសទាំងនេះរួមមាន ៖

- **ការកំណត់ទីតាំងភូមិសាស្ត្រ៖** ការកំណត់ទីតាំងភូមិសាស្ត្រ គឺជាដំណើរការកំណត់ទីកន្លែងដែលវីដេអូ ឬរូបភាពត្រូវបានថត។ ដំណើរការនេះអាចធ្វើបានដោយត្រង់ៗ បើមានដំណឹងទិន្នន័យគ្រប់គ្រាន់៖ ជាធម្មតាទិន្នន័យ EXIF

31 How to use Amnesty's YouTube Data Viewer: https://firstdraftnews.org/curriculum_resource/youtube-data-viewer/ [accessed 22/04/2018].].

32 InVid video verification tool available at: http://www.invid-project.eu/tools-and-services/invid-verification-plugin/.[accessed 22/04/2018].

33 About NewsCheck: https://firstdraftnews.org/launching-new-chrome-extension-newscheck/ [accessed 22/04/2018].

ពីទូរស័ព្ទដៃបង្ហាញពីចំណុចទីតាំង ហើយមាតិកានៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម (ឧ. នៅលើ Instagram Facebook និង Twitter) មានភ្ជាប់ទីតាំងនៅពេលខ្លះ (ប៉ុន្តែគួរតែចងចាំថាគេអាចកែប្រែទិន្នន័យមេតាទាំងនេះ និងបំភ័ន្តភ្នែកបាន)។ ជារឿយៗ ការកំណត់ទីតាំងភូមិសាស្ត្រទាមទារនូវការពិនិត្យផ្ទៀងផ្ទាត់ ជាមួយនឹងលក្ខណៈពិសេសនៃរូបភាព និងទីសម្គាល់សំខាន់ៗក្នុងមាតិកា រួមជាមួយនឹងរូបភាពផ្កាយរណប រូបភាពសម្គាល់ដងផ្លូវ និងមាតិកាដែលអាចមើលឃើញ និងអាចរកបានពីប្រភពផ្សេងៗទៀត (ដូចជាមាតិកាដែលអាចមើលឃើញផ្សេងទៀត ដែលបង្ហោះនៅលើ Twitter Instagram Facebook និង YouTube)។

- **ការបញ្ជាក់អំពីអាកាសធាតុ៖** ប្រភពនានា ដូចជា WolframeAlpha[34] អាចប្រាប់ឱ្យដឹងពីទិន្នន័យប្រវត្តិធាតុអាកាស ដែលអាចឱ្យយើងពិនិត្យឃើញថាធាតុអាកាស ដែលយើងអាចសង្កេតឃើញនៅក្នុងមាតិកា ដែលអាចមើលឃើញនោះ ត្រូវគ្នានឹងកំណត់ត្រាប្រវត្តិសាស្ត្រនៃធាតុអាកាសដែរឬទេ។ (ឧ. តើវីដេអូនោះបង្ហាញភ្លៀងនៅក្នុងថ្ងៃដែលប្រភពឧតុនិយមព្យាករណ៍បានផ្សាយថាគ្មានភ្លៀងទេ?)
- **ការវិភាគស្រមោល៖** ចំណុចមួយនៃការស៊ើបអង្កេតទៅលើរូបថត ឬវីដេអូ គឺត្រូវពិនិត្យទៅលើភាពស៊ីចង្វាក់គ្នា នៅផ្នែកខាងក្នុងនៃស្រមោលដែលគេអាចមើលឃើញ (ឧ. តើមានស្រមោលនៅកន្លែង ដែលគេរំពឹងថានឹងមានស្រមោលនោះដែរឬទេ ហើយតើស្រមោលដែលគេឃើញស៊ីចង្វាក់គ្នាទៅនឹងប្រភពពន្លឺដែរ ឬទេ?)។
- **កោសល្យវិច័យរូបភាព៖** ឧបករណ៍ខ្លះអាចរកឃើញភាពមិនស៊ីចង្វាក់គ្នានៅក្នុងដំណឹងទិន្នន័យរបស់រូបភាព ដែលបង្ហាញថាមានការក្លែងបន្លំ។ សុពលភាពនៃបច្ចេកទេសទាំងនេះស្ថិតលើ បរិបទ និងការប្រើប្រាស់ ប៉ុន្តែឧបករណ៍ដូចជា Forensically[35] Photo Forensics[36] និង IziTru[37]អាចចាប់បានការចម្លងរូបភាព និងការវិភាគកម្រិតកំហុស ដែលអាចផ្តល់ព័ត៌មានដ៏មានប្រយោជន៍។

---

34 WolframAlpha tools available at https://www.wolframalpha.com/examples/science-and-technology/weather-and-meteorology/ [accessed 22/04/2018].

35 Wagner, J. (2015). Forensically, Photo Forensics for the Web. [Blog]29a.ch. Available at: https://29a.ch/2015/08/16/forensically-photo-forensics-for-the-web [accessed 22/04/2018].

36 Fotoforensics tools available at: http://fotoforensics.com/ [accessed 22/04/2018].

37 Izitru tools available at: https://www.izitru.com/ [accessed 22/04/2018].

## គោលបំណងនៃមេរៀន

- ដើម្បីបង្កើនការយល់ដឹងអំពីតួនាទីនៃមាតិកាបង្កើតឡើងដោយអ្នកប្រើប្រាស់ ដែលចែករំលែកតាមប្រព័ន្ធផ្សព្វផ្សាយសង្គម នៅក្នុងសារព័ត៌មានសហសម័យនេះ រួមជាមួយនឹងហានិភ័យ និងចំណុចខ្វះខាតដែលជាប់ទាក់ទងនឹងការពឹងផ្អែកលើវា
- សម្រេចបាននូវការយល់ដឹងទូលំទូលាយអំពីសារៈសំខាន់នៃការទទួលបានសិទ្ធិប្រើប្រាស់ និងព័ត៌មានពីប្រភពដើមនៅក្នុងរឿង និងដំណើរការរបស់វា
- ដើម្បីពង្រីកការយល់ដឹងអំពីភាពចាំបាច់ ក្នុងការផ្ទៀងផ្ទាត់មាតិកាបង្កើតឡើងដោយអ្នកប្រើប្រាស់ និងដកចេញប្រភេទមាតិកាបំភ័ន្ត និងក្លែងក្លាយ
- បង្កើនការយល់ដឹងអំពីវិធីសាស្ត្រជាមូលដ្ឋាន ដែលប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់រូបភាព និងវីដេអូ និងបកអាក្រាតមាតិការូបភាពដែលក្លែងក្លាយ ឬនាំឱ្យយល់ខុស

## លទ្ធផលសិក្សា

១. ការយល់ដឹងស៊ីជម្រៅអំពីតួនាទីនៃមាតិកា បង្កើតឡើងដោយអ្នកប្រើប្រាស់នៅក្នុងសារព័ត៌មានសហសម័យ

២. ការយល់ដឹងអំពីភាពចាំបាច់សម្រាប់ការផ្ទៀងផ្ទាត់មាតិកាឌីជីថល

៣. ការយល់ដឹង និងយល់ផ្នែកបច្ចេកទេសអំពីរបៀបប្រើប្រាស់ឧបករណ៍ផ្ទៀងផ្ទាត់ប្រភពដើម

៤. លទ្ធភាពក្នុងការអនុវត្តជំហានផ្ទៀងផ្ទាត់ជាមូលដ្ឋាន សម្រាប់មាតិកាជារូបថត និងមាតិកាវីដេអូ

៥. ការយល់ដឹងអំពីបច្ចេកទេសកាន់តែជឿនលឿន និងដំណឹងទិន្នន័យដែលអាចប្រើប្រាស់នៅក្នុងដំណើរការផ្ទៀងផ្ទាត់

៦. ការយល់ដឹងអំពីភាពចាំបាច់ ក្នុងការសុំសិទ្ធិអនុញ្ញាតប្រើប្រាស់មាតិកាបង្កើតឡើងដោយអ្នកប្រើប្រាស់ និងមាតិកាតាមអ៊ីនធឺណិតដទៃទៀត ព្រមទាំងចំណេះដឹងអំពីរបៀបធ្វើកិច្ចការទាំងនេះ

## ទម្រង់នៃមេរៀន

មេរៀននេះបង្រៀនជាបទបង្ហាញទ្រឹស្តីរយៈពេល៦០នាទី និងលំហាត់អនុវត្តន៍បង្ហាញជា៣ផ្នែក សរុប១២០នាទី។ ប៉ុន្តែដោយសារតែលក្ខណៈអនុវត្តន៍ជាក់ស្តែងនៃមុខវិជ្ជានេះ គេអាចបង្រៀនជាសិក្ខាសាលាដែលមានទំនាក់ទំនងគ្នា ក្នុងរយៈពេលវែង រួមនឹងលំហាត់អនុវត្តន៍ ដើម្បីបំពេញបន្ថែមទៅលើការបង្ហាញ។

**ទ្រឹស្តី៖** តាមរយៈការប្រើប្រាស់កំណត់សម្គាល់ខាងលើ សូមតាក់តែងបទបង្ហាញមួយដែលផ្តោតសំខាន់ទៅលើការផ្ទៀងផ្ទាត់ជាផ្នែកស្នូល ប៉ុន្តែជាផ្នែកវិវត្តន៍នៃវិធីសាស្រ្តរបស់សារព័ត៌មានក្នុងសម័យឌីជីថល។

**អនុវត្តន៍៖** វគ្គអនុវត្តន៍១២០នាទីអាចជាការបង្ហាញ និងជាសិក្ខាសាលាដែលបើកឱ្យមានការចូលរួមយ៉ាងសកម្មពីសិស្ស។ មេរៀនអនុវត្តន៍ផ្ទាល់នេះ អាចចែកចេញជា៣ផ្នែក។

អ្នកអប់រំគួរតែប្រើប្រាស់កំណត់សម្គាល់ខាងលើនេះ និងពិនិត្យមើលទៅលើបទបង្ហាញដែលអាចទាញយកពីតំណភ្ជាប់ខាងក្រោម។ សូមកត់សម្គាល់ថានៅមានកំណត់ចំណាំសម្រាប់គ្រូបន្ថែមទៀត ដែលភ្ជាប់ជាមួយនឹងបទបង្ហាញទាំងនេះ៖

១) **ការកំណត់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់ប្រភព៖** ការត្រួតពិនិត្យប្រវត្តិសង្គមរបស់ប្រភព៖ https://en.unesco.org/sites/default/files/unesco_fake_news_curriculum_ verification_digital_sources_one.pdf

២) **ការផ្ទៀងផ្ទាត់រូបភាពជាមូលដ្ឋាន៖** ប្រភេទទូទៅនៃរូបភាពក្លែងបន្លំ និងជំហានជាមូលដ្ឋានសម្រាប់ការផ្ទៀងផ្ទាត់៖ https://en.unesco.org/sites/default/files/unesco_fake_news_ curriculum_verification_digital_sources_two.pdf

៣) **ការផ្ទៀងផ្ទាត់បែបទំនើប៖** វិធីសាស្រ្តនានាសម្រាប់ការវិភាគមាតិកា ក្នុងនោះរួមបញ្ចូលទាំងការវិភាគទិន្នន័យមេតា និងការកំណត់ទីតាំងភូមិសាស្រ្ត៖ https://en.unesco.org/sites/default/files/unesco_fake_news_curriculum_verification_digital_sources_three.pdf

## ភ្ជាប់ផែនការទៅនឹងលទ្ធផលសិក្សា

### ក. ទ្រឹស្តី

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| បទបង្ហាញ ៖ សារតា និងទ្រឹស្តីអំពីការផ្ទៀងផ្ទាត់ និងការវិវត្តនៃវិធីសាស្ត្រ | ១ម៉ោង | ១, ២, ៦ |

### ខ. អនុវត្តន៍

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| ១. ការផ្ទៀងផ្ទាត់ប្រភព - សង្គម (លំហាត់) | ៣០នាទី | ២, ៣ |
| ២. វិធីស្រាវជ្រាវរកប្រភពរូបភាពដើម (ការបង្ហាញ និងលំហាត់) | ១៥នាទី | ២, ៣, ៤ |
| ៣. ការវិភាគវីដេអូ (ការបង្ហាញ) | ៣០នាទី | ២, ៣, ៤ |
| ៤. ការណែនាំអំពីប្រភេទផ្សេងៗនៃទិន្នន័យមេតា(ការបង្ហាញ) | ១៥នាទី | ២, ៥ |
| ៥. ការកំណត់ទីតាំងភូមិសាស្ត្រ (ការបង្ហាញ + លំហាត់) | ២០នាទី | ២, ៤, ៥ |
| ៦. ការវិភាគអាកាសធាតុ, ស្រមោល និងកោសល្យវិច័យរូបភាព | ១០នាទី | ២, ៤, ៥ |

## លំហាត់ស្រាវជ្រាវបន្ថែម

សិស្សគួរតែរៀបចំបង្កើតគំនូសពន្យល់លំហូរការងារ សម្រាប់ការផ្ទៀងផ្ទាត់ប្រភពដោយប្រើប្រាស់គំរូទូទៅមួយ នៅលើសន្លឹកបទបង្ហាញទី៨នៃកម្រងបទបង្ហាញទីមួយ។ សិស្សអាចប្រើប្រាស់តួនាទីពិតប្រាកដ កន្លែងដែលពួកគេធ្វើការ ឬអង្គភាពដំណឹងដែលពួកគេស្គាល់ក៏បាន។

សូមជ្រើសរើសគណនីប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលដំណើរការមួយរបស់មនុស្សល្បីម្នាក់ និងសូមឱ្យសិស្សប្រើប្រាស់ឧបករណ៍នានាដែលបានបង្ហាញដើម្បីកំណត់ថា តើគណនីទាំងនោះជាគណនីពិតដែរឬទេ និងដើម្បីកំណត់អត្តសញ្ញាណគណនីដែលពាក់ព័ន្ធផ្សេងទៀត ប៉ុន្តែជាគណនីក្លែងក្លាយ។

សូមជ្រើសរើស និងចែករំលែករូបភាពមួយក្នុងថ្នាក់រៀន រួចហើយឱ្យពួកគេកំណត់ចំណុចជាក់លាក់នៃព័ត៌មាន ដោយប្រើកម្មវិធី EXIF viewer នៅលើអ៊ីនធឺណិត និងឧបករណ៍ស្រាវជ្រាវរូបភាពប្រភពដើម ដើម្បីប្រាប់អ្នកវិញអំពីប្រភពដើមនៃរូបភាពនោះ។

## ឯកសារបន្ថែម

### បទបង្ហាញ


១. https://en.unesco.org/sites/default/files/unesco_fake_news_curriculum_verification_ digital_sources_one.pdf

២. https://en.unesco.org/sites/default/files/unesco_fake_news_curriculum_verification_ digital_sources_two.pdf

៣. https://en.unesco.org/sites/default/files/unesco_fake_news_curriculum_verification_ digital_sources_three.pdf


## អំណានបន្ថែម

### ការផ្ទៀងផ្ទាត់ប្រភព


AyalaIacucci, A. (2014). Case Study3.1: Monitoring and Verifying During the Ukrainian Parliamentary Election, Verification Handbook. European Journalism Centre. Available at: http://verificationhandbook.com/book/chapter3.1.php. [accessed 04/04/2018].

Bell, F. (2015). Verification: Source vs. Content, First Draft News. Available at: https://medium.com/1st-draft/verification-source-vs-content-b67d6eed3ad0.[accessed 04/04/2018].

Carvin, A. (2013), Distant Witness, CUNY Journalism Press. Available at: http://press. journalism.cuny.edu/book/distant-witness-social-media-the-arab-spring-and-a- journalism-revolution/. [accessed 04/04/2018].

Toler, A. (2017). Advanced guide on verifying video content. Available at: https://www.bellingcat.com/resources/how-tos/2017/06/30/advanced-guide-verifying-video- content/. [accessed 04/04/2018].

Trewinnard, T. (2016). Source verification: Beware the bots, First Draft News. Available at: https://firstdraftnews.com/source-verification-beware-the-bots/. [accessed 04/04/2018].


## វីដេអូ


Real or Fake: How to verify what you see on the internet. (2015). France24. Available at https://www.youtube.com/watch?v= Q8su4chuU3M&feature=yout[accessed 04/04/2018].

Knight, W. (2018). The Defense Department has produced the first tools for catching deepfakes, MIT Technology Review. https://www. technologyreview.com/s/611726/the- defense-department-has-produced-the-first-tools-for-catching-deepfakes/[accessed23/08/2018].


## ប្រព័ន្ធផ្សព្វផ្សាយសាក្សី (Eyewitness Media)


Brown, P. (2015). A global study of eye witness media in online newspaper sites. Eyewitness Media Hub. Available at http://eyewitnessmediahub. com/uploads/browser/files/Final%20Press%20Study%20-%20 eyewitness%20media%20hub.pdf. [accessed 04/04/2018].

Hermida, A. (2013). #JOURNALISM. Digital Journalism, 1(3), pp. 295-313.

Koettl, C. (2016, January 27). Citizen Media Research and Verification: An Analytical Framework for Human Rights Practitioners. Centre of Governance and Human Rights, University of Cambridge. Available at https://www.repository.cam.ac.uk/handle/201810/253508. [accessed 04/04/2018].

Kuczerawy, A. (2016, December 16). Pants on fire: content verification tools and other ways to deal with the fake news problem. Available at https://revealproject.eu/pants-on-fire-content-verification-tools-and-other-ways-to-deal-with-the-fake-news- problem/ [accessed 22/01/2018].

Novak, M. (n.d.). 69 Viral Images From 2016 That Were Totally Fake. Available at https://gizmodo.com/69-viral-images-from-2016-that-were-totally-fake-1789400518. [accessed 12/11/2017].

Online News Association: UGC Ethics Guide https://ethics.journalists.org/topics/user- generated-content/ [accessed 18/4/2018].

Pierre-Louis, K. (2017). You're probably terrible at spotting faked photos. Available at https://www.popsci.com/fake-news-manipulated-photo. [accessed 12/11/2017].

Rohde, D. (2013). Pictures That Change History: Why the World Needs Photojournalists.

The Atlantic. Available at https://www.theatlantic.com/international/archive/2013/12/ pictures-that-change-history-why-the-world-needs-photojournalists/282498/. [accessed 03/04/2018].

Shapiro, I., Brin, C., Bédard-Brûlé, I. & Mychajlowcz, K. (2013) Verification as a Strategic Ritual: How journalists retrospectively describe processes for ensuring accuracy, published in Journalism Practice, 7(6).

Smidt, J. L., Lewis, C. & Schmidt, R. (2017). Here's A Running List Of Misinformation About Hurricane Irma. Available at https://www.buzzfeed.com/janelytvynenko/irma- misinfo/. [accessed 23/10/2017].

Wardle, C. (2015). 7/7: Comparing the use of eyewitness media 10 years on. Available at https://firstdraftnews.com:443/77-comparing-the-use-of-eyewitness-media-10- years-on/. [accessed 12/11/2017].

Wardle, C., Dubberley, S., & Brown, P. (2017). Amateur Footage: A Global Study of User-Generated Content in TV and Online News Output. Available at http://

usergeneratednews.towcenter.org/how-when-and-why-ugc-is-integrated-into-news- output/.[accessed 23/10/2017].

Zdanowicz, C. (2014). "Miracle on the Hudson" Twitpic changed his life. Available at http://www.cnn.com/2014/01/15/tech/hudson-landing-twitpic-krums/index.html. [accessed 12/11/2017]

## ការស្រាវជ្រាវរូបភាពត្រឡប់ **(Reverse Image Search)**

First Draft News. Visual Verification Guide - Photos -. Available at https://firstdraftnews.org/wp-content/uploads/2017/03/FDN_verificationguide_photos.pdf?x47084. [accessed 06/11/2017].

First Draft News. Visual Verification Guide-Video-. Available at https://firstdraftnews.org/wp-content/uploads/2017/03/FDN_verificationguide_videos.pdf?x47084. [accessed 06/11/2017].

Suibhne, E. (2015). Baltimore “looting” tweets show importance of quick and easy image checks. Available at https://medium.com/1st-draft/baltimore-looting-tweets-show- importance-of-quick-and-easy-image-checks-a713bbcc275e.[accessed 06/11/2017].

Seitz, J. (2015). Manual Reverse Image Search With Google and TinEye. Available at https://www.bellingcat.com/resources/how-tos/2015/05/08/manual-reverse-image- search-with-google-and-tineye/. [accessed 06/11/2017].

## ទិន្នន័យតាម **YouTube (YouTube Data Viewer)**

First Draft News. (n.d.). Using YouTube Data Viewer to check the upload time of a video. Available at https://firstdraftnews.com:443/resource/using-youtube-data-viewer-to- check-the-upload-time-of-a-video/. [accessed 13/11/2017].

Toler, A. (2017). Advanced Guide on Verifying Video Content. Available at https://www.bellingcat.com/resources/how-tos/2017/06/30/advanced-guide-verifying-video- content/. [accessed 13/11/2017].

## ការវិភាគទិន្នន័យមេតា **(Metadata)**

Honan, M. (2012). How Trusting in Vice Led to John McAfee’s Downfall. Available at https://www.wired.com/2012/12/how-vice-got-john-mcafee-caught/. [accessed 03/04/2018].

Storyful. (2014). Verifying images: why seeing is not always believing. Available at https://storyful.com/blog/2014/01/23/verifying-images-why-seeing-is-not-always-believing/.[accessed 13/11/2017].

Wen, T. (2017). The hidden signs that can reveal a fake photo. Available at http://www.bbc.com/future/story/20170629-the-hidden-signs-that-can-reveal-if-a-photo-is-fake. [accessed 12/11/2017].

## ការវិភាគមាតិកា


Ess, H. van. (2017). Inside the trenches of an information war..Medium. Available at https://medium.com/@henkvaness/how-to-date-a-mysterious-missile-launcher-78352ca8c3c3. [accessed 03/04/2018].

Farid, H. (2012a). Image Authentication and Forensics | Fourandsix Technologies – Blog-A Pointless Shadow Analysis. Available at http://www.fourandsix.com/blog/2012/9/4/a- pointless-shadow-analysis.html. [accessed 03/04/2018].

Farid, H. (2012b). Image Authentication and Forensics | Fourandsix Technologies - Blog

The JFK Zapruder Film. Available at http://www.fourandsix.com/blog/2012/9/11/the-jfk- zapruder-film.html. [accessed 03/04/2018].

Farid, H. (n.d.-c). Photo Forensics: In the Shadows- Still searching- Fotomuseum Winterthur. Available at http://www.fotomuseum.ch/en/explore/still-searching/articles/26425_photo_forensics_in_the_shadows. [accessed 03/04/2018].

First Draft News. (2016). Watch Eliot Higgins demonstrate advanced verification techniques at #FDLive. Available at https://firstdraftnews.com:443/watch-eliot-higgins- discuss-advanced-verification-and-geolocation-techniques-at-fdlive/. [accessed 03/04/2018].

Higgins, E. (2015, July 24). Searching the Earth: Essential geolocation tools for verification. Available at https://medium.com/1st-draft/searching-the-earth-essential- geolocation-tools-for-verification-89d960bb8fba. [accessed 03/04/2018].


## ប្រទពគាមអ៊ិនធឺណិត


First Draft Interactive: Geolocation Challenge. Available at https://firstdraftnews.com/resource/test-your-verification-skills-with-our-geolocation-challenge/. [accessed 03/04/2018].

First Draft Interactive: Observation Challenge. Available at https://firstdraftnews.com/resource/test-your-verification-skills-with-our-observation-challenge/. [accessed 03/04/2018].

First Draft Online Verification Course. Available at https://firstdraftnews.org/learn/[accessed 03/04/2018].



# ការប្រយុទ្ធប្រឆាំងការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិត៖ នៅពេលដែលអ្នកសារព័ត៌មាន និងប្រភពហ្វានក្លាយជាគោលដៅនៃការរំលោភបំពាន

*Julie Posetti*

# មេរៀនទី៧

## សង្ខេប

បញ្ហាព័ត៌មានមិនពិត និងព័ត៌មានខុស[1]ធ្វើឱ្យខូចដល់សារព័ត៌មាន ដែលគេជឿ និងទុកចិត្តបានរីកដុះដាលយ៉ាងគំហុក ក្នុងសម័យប្រព័ន្ធផ្សព្វផ្សាយសង្គមនេះ។ ជាលទ្ធផល វារួមមានការផ្ដោតគោលដៅក្នុងចេតនាណាមួយ ចំពោះអ្នកសារព័ត៌មាន និងអ្នកផ្សព្វផ្សាយតាមអ៊ីនធឺណិត ក៏ដូចជាប្រភពរបស់ពួកគេ ដែលកំពុងផ្ទៀងផ្ទាត់ព័ត៌មានជាមួយ ឬចែករំលែកព័ត៌មាននិងបទអត្ថាធិប្បាយផ្សេងៗ។ ហានិភ័យដែលពាក់ព័ន្ធ អាចបំផ្លាញដល់ការជឿជាក់លើវិស័យសារព័ត៌មាន ក៏ដូចជាសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងប្រភពព័ត៌មានរបស់គេ។

មានករណីខ្លះ អ្នកសារព័ត៌មានក្លាយជាគោលដៅនៃទង្វើផ្សេងៗដូចជា «ការបញ្ឆោត » (Astroturf )[2] និង «ការបញ្ឆើចបញ្ឆើ» (Troll)[3] ជាដើម ក្នុងចេតនា «បំភ័ន្ត ផ្ដល់ព័ត៌មានខុស ធ្វើឱ្យយល់ច្រឡំ ឬបង្កគ្រោះថ្នាក់ដល់អ្នកសារព័ត៌មាន»[4] ដែលក្នុងនោះ ការចែករំលែកព័ត៌មានបែបនោះ ត្រូវបានរៀបចំឡើងដើម្បីបង្វែរចំណាប់អារម្មណ៍ និងបំបាត់ដានអ្នកសារព័ត៌មាន ឬប្រភពសក្ដានុពលរបស់ពួកគេ។ ក្រៅពីនេះ អ្នកសារព័ត៌មានអាចជាគោលដៅក្នុងការបោកបញ្ឆោតឱ្យចែករំលែកដំណឹងមិនសុក្រឹត ដែលនាំឱ្យមានការបកស្រាយមិនពិតចំពោះរឿងពិតនានា ឬនៅពេលដែលព័តមាននោះបង្ហាញថាជាដំណឹងក្លែងក្លាយ វានឹងធ្វើឱ្យបាត់បង់ភាពជឿទុកចិត្តបានរបស់អ្នកសារព័ត៌មានរូបនោះ (និងស្ថាប័នសារព័ត៌មានទាំងនោះ)។ ក្នុងករណីផ្សេងទៀត ពួកគេប្រឈមនឹងការគម្រាមកំហែងតាមបច្ចេកវិទ្យាដែលបង្កើតឡើងដើម្បីបង្ហាញប្រភពរបស់ពួកគេ បំផ្លាញដល់ភាពឯកជនដែលធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យ ឬលួចចូលទៅមើលទិន្នន័យ ដែលមិនបានផ្សព្វផ្សាយរបស់អ្នកសារព័ត៌មានជាដើម។

---

1 For definitions, see: Wardle, C. & Derakhshan, H. (2017). Information Disorder: Toward an Interdisciplinary Framework for Research and Policymaking (Council of Europe). https://rm.coe.int/information-disorder-toward-an-interdisciplinary-framework-for-researc/168076277c [accessed 30/03/2018].

2 “Astroturfing” គឺជាពាក្យដែលបានមកពីប្រភេទស្មៅក្លែងក្លាយ ដែលត្រូវបានប្រើប្រាស់សម្រាប់ក្រាលនៅខាងក្រៅផ្ទះ ដើម្បីបង្កើតភាពទាក់ទាញ ដែលហាក់បីដូចជាក្រាលស្មៅពិតប្រាកដ។ នៅក្នុងបរិបទព័ត៌មានមិនពិត វាទាក់ទងទៅនឹងការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ដែលកំណត់យកក្រុមគោលដៅ និងអ្នកសារព័ត៌មាន ក្នុងន័យចង់ធ្វើឱ្យពួកគេយល់ខុស ជាពិសេសក្នុងទម្រង់នៃភស្តុតាង នៃការគាំទ្រក្លែងក្លាយសម្រាប់មនុស្សម្នាក់ គំនិត ឬគោលនយោបាយណាមួយ។ សូមមើល Technopedia definition:https://www.techopedia.com/definition/13920/astroturfing [accessed 20/03/2018].

3 Coco, G. (2012). Why Does Nobody Know What Trolling Means? A quick reference guide for the media at Vice.com. https://www.vice.com/ en_au/article/ppqk78/what-trolling-means-definition-UK-newspapers [accessed 30/03/2018].

4 Posetti, J. (2013). The ‘Twitterisation’ of investigative journalism in S. Tanner & N. Richardson (Eds.), Journalism Research and Investigation in a Digital World (pp. 88-100): Oxford University Press, Melbourne. http://ro.uow.edu.au/cgi/viewcontent. cgi?article=2765&context=lhapapers [accessed 30/03/2018].

ទន្ទឹមនឹងនេះ ក៏មានហេតុការណ៍ដែលរដ្ឋាភិបាលដាក់ពង្រាយ «ក្រុមអ្នកបង្កើតពាក្យសម្ដប់តាមអ៊ីនធឺណិត» ដើម្បីគំរាមចំពោះការអធិប្បាយបែបរិះគន់ និងបិទសេរីភាពក្នុងការបញ្ចេញមតិ។[5] បន្ទាប់មក មានបញ្ហាធ្ងន់ធ្ងរទាក់ទងនឹងការបៀតបៀន និងហិង្សាតាមអ៊ីនធឺណិត (ដែលគេហៅថា «ការបញ្ឆើចបញ្ឆើ»[6]) ដែលភាគច្រើនស្ត្រីជាអ្នកជួបប្រទះ ហើយមានចរិតលក្ខណៈជាការរុកគួនថែមទៀតផង។

បញ្ហានេះអាចធ្វើឱ្យអ្នកសារព័ត៌មាន ប្រភពរបស់គេ និងអ្នកអត្ថាធិប្បាយប្រឈមនឹងការបំពានតាមអ៊ីនធឺណិតយ៉ាងខ្លាំង ការចោទប្រកាន់ទាំងខុសមកលើការប្រតិបត្តិរបស់គេ ការក្លែងបន្លំលើអត្តសញ្ញាណ ឬការគំរាមបង្កគ្រោះថ្នាក់ដែលរៀបចំឡើងដើម្បីបង្កភាពអាម៉ាស់ ធ្វើឱ្យបាត់បង់ទំនុកចិត្ត លែងមានជំនឿ បង្វែរចំណាប់អារម្មណ៍ ហើយចុងក្រោយគឺដើម្បីគំរាមដល់ការរាយការណ៍របស់គេ[7]។ ទន្ទឹមនឹងនេះ នៅតាមទីកន្លែងជាច្រើន ការរំលោភបំពានក្នុងពិភពជាក់ស្ដែងត្រូវបានរៀបចំឡើង ដើម្បីកៀបសង្កត់ការរាយការណ៍បែបរិះគន់ នៅតែបន្តកើតមានហើយគ្រោះថ្នាក់នេះ នៅតែបន្តកើតឡើងដោយសារការញុះញង់ និងការបំភ័យតាមអ៊ីនធឺណិត។

អ្នកសារព័ត៌មាន អាចជាជនរងគ្រោះដោយផ្ទាល់ពីយុទ្ធនាការព័ត៌មានមិនពិត ប៉ុន្តែពួកគេក៏ប្រឆាំងតបតដែរ។ ក្រៅពីការពង្រឹងការការពារផ្នែកបច្ចេកវិទ្យា អ្នកសារព័ត៌មានជាច្រើនកំពុងបង្ហាញ និងវែកមុខអ្នកវាយប្រហារ។ ការភ្ជាប់ទំនាក់ទំនងក្នុងចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន ជាមួយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យនេះ និងស្ថាប័នសារព័ត៌មានកំពុងតែដើរតួនាទីយ៉ាងសំខាន់ ក្នុងការអប់រំសាធារណជន ហេតុអ្វីបានជាគួរយកចិត្តទុកដាក់ និងការពារវិស័យសារព័ត៌មាន។

5 Riley M, Etter, L and Pradhan, B (2018) A Global Guide To State-Sponsored Trolling, Bloomberg: https://www.bloomberg.com/features/2018- government-sponsored-cyber-militia-cookbook/ [accessed 21/07/2018].

6 ចំណាំ៖ ការបញ្ឆើចបញ្ឆើ នៅក្នុងកម្មវិធីលើអ៊ីនធឺណិត សំដៅលើសកម្មភាពលលេង បញ្ឆោតនិងចូលទៅបោកបញ្ឆោតដោយចេតនា។ ទោះយ៉ាងណាក៏ដោយ វាត្រូវបានប្រើប្រាស់កាន់តែខ្លាំងឡើងជាពាក្យមួយដើម្បីគ្របដណ្ដប់លើរាល់សកម្មភាពនៃការរំលោភបំពានតាមអ៊ីនធឺណិតទាំងអស់។ នេះគឺជាបញ្ហាដែលមានសក្ដានុពល ដោយសារវារួមបញ្ចូលសកម្មភាពជាច្រើន និងអាចបង្ហាញពីភាពធ្ងន់ធ្ងរនៃការឃាយីតាមអ៊ីនធឺណិត។

7 See for example: https://www.independent.co.uk/news/world/americas/twitter-maggie-haberman-new-york-times-quits-social-media-jack- dorsey-a8459121.html

## គ្រោងនៃមេរៀន

### ការដោះស្រាយបញ្ហា

**១. ការស្គាល់ និងឆ្លើយតបចំពោះ «ការបញ្ឆើចបញ្ឆើ» និង «ការបញ្ឆោត »[8]**

ក្នុងករណីនេះរួមមានការបង្កើតតួអង្គ និងហេតុការណ៍ដែលរៀបចំឡើងដើម្បីបោកបញ្ឆោតអ្នកសារព័ត៌មាន និងក្រុមគោលដៅ និងរៀបចំយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយសង្គម ក្នុងគោលដៅធ្វើឱ្យដូចទៅនឹងប្រតិកម្មសាធារណជន។ វាជារឿងពិបាកក្នុងការញែករវាងដំណឹងទាន់ហេតុការណ៍ និងការរៀបរាប់របស់សាក្សីដែលក្លែងមាតិកា ឬផ្តល់មាតិកាមិនត្រឹមត្រូវក្នុងចេតនាបំភ័ន្ត ឬបង្ខូចដល់ភាពអាចទុកចិត្តបានរបស់អ្នកសារព័ត៌មាន និងអ្នកអត្ថាធិប្បាយលើបណ្តាញអ៊ីនធឺណិត និងបង្ខូចដល់ការងាររបស់ពួកគេ តាមរយៈការបញ្ឆោតឱ្យពួកគេធ្លាក់ចូលទៅក្នុងការចែករំលែកព័ត៌មានមិនពិត។

ឧទាហរណ៍ខ្លះៗបង្ហាញពីការប្រព្រឹត្តបែបនេះរួមមាន៖

- ការបង្កើតឱ្យមានជនរងគ្រោះដោយសារគ្រោះមហន្តរាយ និងមហន្តរាយដោយការវាយប្រហារដោយភេរវកម្ម (សូមមើលឧទាហរណ៍អំពីការបំផ្ទុះគ្រាប់បែក នៅទីក្រុង Manchester[9] ដើម្បីបញ្ឆោតឱ្យមនុស្សចែករំលែកព័ត៌មានដែលមានឥទ្ធិពលដល់ការបំផ្លាញកេរ្តិ៍ឈ្មោះ និងការជឿទុកចិត្តរបស់បុគ្គលនានា រួមទាំងអ្នកសារព័ត៌មានដែលអាចនឹងជាប់ឈ្មោះនៅក្នុងដំណើរការនៃការចែករំលែកព័ត៌មានទាំងនេះ។
- ការចុះផ្សាយមាតិកាដែលមានលក្ខណៈ ដែលគួរឱ្យចាប់អារម្មណ៍ដូចដំណឹងបង្កើតដោយតួអង្គប្រឌិតនានាដូចជា «Gay girl in Damascus»[10]។ ក្នុងឆ្នាំ២០១១ សារព័ត៌មានពិភពលោក បានទាមទារឱ្យមានការរាយការណ៍អំពីការចាប់ខ្លួនរបស់ Blogger ជាស្ត្រីជនជាតិស៊ីរីម្នាក់សង្ស័យថាស្រលាញ់ស្រីដូចគ្នា ប៉ុន្តែម្ចាស់អត្ថបទនោះបែរជានិស្សិតជនជាតិអាមេរិកម្នាក់ ដែលនៅ

---

8 ការពន្យល់ពាក្យ 'astroturfing' សម្រាប់ការបង្រៀនសូមមើល៖ https://youtu.be/Fmh4RdIwswE

9 Manchester bombing example, https://www.theguardian.com/technology/2017/may/26/the-story-behind-the-fake-manchester-attack-victims [accessed 30/03/2018].

10 Young, K. (2017). How to Hoax Yourself: The Case of the Gay Girl in Damascus, November 9th, 2017, in The New Yorker. https://www. newyorker.com/books/page-turner/how-to-hoax-yourself-gay-girl-in-damascus [accessed 30/03/2018].

ក្រៅប្រទេសទៅវិញ។ អ្នកសារព័ត៌មានឈ្មោះថា Jess Hill ត្រូវបានចាត់ឱ្យសរសេររឿងសម្រាប់កម្មវិធី PM របស់ប្រព័ន្ធផ្សព្វផ្សាយអូស្ត្រាលី (Australia Broadcasting Corporation)។ អ្នកសារព័ត៌មានរូបនេះនិយាយថា គុណតម្លៃ និងវិធីសាស្ត្រក្នុងការផ្ទៀងផ្ទាត់ បានហាមមិនឱ្យកម្មវិធីនាងផ្សព្វផ្សាយរឿងក្លែងក្លាយទាំងនេះ។ «យើងមិនបានរាយការណ៍ពីការចាប់ខ្លួននាងនោះទេ ដោយសារតែមិនអាចរកមនុស្សណាម្នាក់ ដែលបានជួបស្ត្រីរូបនោះផ្ទាល់ឱ្យពិតប្រាកដបានឡើយ។ នាងគ្មានសាច់ញាតិ គ្មានមិត្តភក្តិជិតស្និត។ យើងបានចំណាយពេលពីរថ្ងៃស្វែងរកមនុស្សទាំងនោះ ដោយឱ្យអ្នកស៊ើបរបស់យើងនៅប្រទេសស៊ីរី ប្រាប់យើងអំពីមនុស្ស ដែលអាចមានទំនាក់ទំនងនឹងស្ត្រីរូបនោះ ប៉ុន្តែតម្រុយនីមួយៗសុទ្ធតែនាំទៅរកផ្លូវទាល់ច្រក។ ការដែលយើងមិនអាចស្វែងរកនរណាម្នាក់ ដែលបានជួបស្ត្រីរូបនោះ ទើបយើងមិនអាចរាយការណ៍អំពីដំណឹងនោះបាន។ ភ្នាក់ងារដំណឹងដែលរាយការណ៍បន្ទាន់អំពីរឿងនេះ មិនបានធ្វើការងារតាមក្រមមូលដ្ឋាន ដោយការងាកទៅរកប្រភព ដើម្បីផ្ទៀងផ្ទាត់ដំណឹងនោះទេ។ ពួកគេរាយការណ៍ដំណឹង ដោយផ្អែកលើមាតិកានៅលើ Blog»[11]។

ហេតុផលផ្សេងទៀត រួមមានបំណងក្នុងការបង្វែរចំណាប់អារម្មណ៍ ឬបង្វែងដានអ្នកសារព័ត៌មានពីការស៊ើបអង្កេត តាមរយៈការសួរសំណួរឥតប្រយោជន៍ ដែលបង្អាក់ដល់ការខិតខំប្រឹងប្រែងក្នុងការរាយការណ៍ ហើយចុងក្រោយគឺបង្កការភិតភ័យក្នុងការព្យាយាមស្វែងរកការពិត។

ឧទាហរណ៍ស្តីពីវិធីសាស្ត្រក្នុងការបង្វែងដានរួមមាន៖

- ការព្យាយាមកែប្រែអំណះអំណាងអំពីចំនួនមនុស្ស ដែលចូលរួមនៅក្នុងពិធីស្បថឡើងកាន់តំណែងរបស់លោក Donald Trump ក្នុងខែមករា ឆ្នាំ២០១៧ ថាជា «ការពិតមួយផ្សេងទៀត»[12]។
- ការឃោសនាពីពេលសង្គ្រាមនាសហសម័យ ឧទាហរណ៍ ពួកតាលីបាន បានបង្ហោះ(tweeting)សេចក្តីលម្អិតខុស និងនាំឱ្យមានការយល់ច្រឡំស្តីពីការប្រយុទ្ធគ្នាដល់អ្នកសារព័ត៌មាននៅក្នុងប្រទេសអាហ្វហ្គានីស្ថាន[13]។

11 Posetti, J. (2013). op cit

12 NBC News (2017) Video: https://www.nbcnews.com/meet-the-press/video/conway-press-secretary-gave-alternative-facts-860142147643 [accessed 30/03/2018].

13 Cunningham, E (2011). In shift, Taliban embrace new media, GlobalPost. https://www.pri.org/stories/2011-05-21/shift-taliban-embrace-new- media [accessed 30/03/2018].

- សំណុំទិន្នន័យដែលប្រគល់ទៅឱ្យអ្នកសារព័ត៌មាន ហើយដែលអាចផ្តល់ជាការចាប់អារម្មណ៍ដល់សាធារណជន ជាព័ត៌មានដ៏មានតម្លៃ ប៉ុន្តែវាខូចដោយសារតែព័ត៌មានមិនពិត នៅលាយឡំគ្នាក្នុងនោះដែរ។

ថ្មីៗនេះ ការឃោសនាតាមកុំព្យូទ័រ[14] បានបង្កើនហានិភ័យសម្រាប់អ្នកសារព័ត៌មានដែលទប់ទល់នឹង «ការបញ្ឆោត» និង «ការបញ្ឆេះបញ្ឆៀរ»។ ការឃោសនានោះ រួមមានការប្រើប្រាស់មនុស្សយន្ត ដើម្បីផ្សព្វផ្សាយព័ត៌មានខុសចំគោលដៅ និងសារឃោសនាទៅតាមកម្រិតមួយ ដែលដូចទៅនឹងដំណឹងពិត[15]។ ដំណាលគ្នានេះដែរ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត កំពុងត្រូវបានប្រើប្រាស់ដើម្បីបង្កើតវីដេអូ «ក្លែងបន្លំកម្រិតខ្ពស់ (deepfake)»[16] និងទម្រង់ផ្សេងទៀត ដើម្បីបំផ្លាញទំនុកចិត្តរបស់គោលដៅ រួមមានអ្នកសារព័ត៌មាន និងអ្នករាយការណ៍ជាស្ត្រី។

ឧទាហរណ៍ដែលបង្ហាញពីទង្វើបែបនេះរួមមាន៖

- គេហទំព័រសារព័ត៌មានឯករាជ្យមួយឈ្មោះ Rappler.com និងបុគ្គលិកដែលភាគច្រើនជាស្ត្រី បានក្លាយជាគោលដៅក្នុងយុទ្ធនាការបំពានតាមអ៊ីនធឺណិតយ៉ាងផុលផុស។ «ក្នុងប្រទេសហ្វីលីពីន ការបង់លុយលើការបញ្ឆេះបញ្ឆៀរ ការផ្តល់ហេតុផលក្លែងក្លាយ ការងាយសន្និដ្ឋាន ការបំពុលសុទ្ធតែជាបច្ចេកទេសឃោសនា ដែលជួយបង្វែរការយល់ឃើញរបស់សាធារណជនទៅលើបញ្ហាសំខាន់ៗផ្សេងៗ»[17]។ (សូមមើលការពិភាក្សាលម្អិតខាងក្រោមនេះ)
- គ្រួសារអ្នកមានមួយ ដែលបានរងការចោទប្រកាន់ពីបទរឹបអូសយកសហគ្រាសរដ្ឋសំខាន់ៗ ហើយអ្នកនយោបាយនៅអាហ្វ្រិកខាងត្បូងបានជួលក្រុមហ៊ុនទំនាក់ទំនងសាធារណៈរបស់អង់គ្លេសមួយ ឈ្មោះថា Bell Pottinger ដើម្បីប្រឌិតលើការបង្កើតយុទ្ធនាការឃោសនាមួយ។ វាផ្សព្វផ្សាយសារតាម

14 Woolley, S. & Howard, P. (2017). Computational Propaganda Worldwide: Executive Summary, Working Paper No. 2017.11 (Oxford University). http://comprop.oii.ox.ac.uk/wp-content/uploads/sites/89/2017/06/Casestudies-ExecutiveSummary.pdf [accessed 30/03/2018].

15 Note: Shallow reports about bot campaigns during the 2017 UK general election highlight the difficulty of reporting on these issues. C.f. Dias, N. (2017). Reporting on a new age of digital astroturfing, First Draft News. https://firstdraftnews.com/digital-astroturfing/ [accessed 29/03/2018].

16 ពាក្យថា deepfake មកពីពាក្យ deep learning និង fake។ វាពាក់ព័ន្ធនឹងបច្ចេកវិទ្យាAI ក្នុងការបង្កើតមាតិកាបន្លំពេលខ្លះមានលក្ខណៈពិបាកដែលស្ទើរតែមិនអាចរកឃើញ។ វាត្រូវបានប្រើក្នុងការវាយប្រហារតាមអ៊ីនធឺណិត ដើម្បីធ្វើឱ្យមនុស្សមានការស្អប់ខ្ពើមរួមទាំងអ្នកសាព័ត៌មានផងដែរ។ សូមមើល៖ Cuthbertson, A (2018) What is 'deepfake' porn? AI brings face-swapping to disturbing new level in Newsweek http://www.newsweek.com/ what-deepfake-porn-ai-brings-face-swapping-disturbing-new-level-801328 [accessed 17/06/2018].

17 Ressa, M. (2016). Propaganda War: Weaponising the Internet, Rappler. https://www.rappler.com/nation/148007-propaganda-war-weaponizing-internet [accessed 30/03/2018].

រយៈព័ត៌មានមិនពិតមួយ ដែលក្នុងនោះរួមមាន គេហទំព័រប្រព័ន្ធផ្សព្វផ្សាយ និងក្រុមអ្នកប្រើ Twitter ដែលបង់ប្រាក់ បានផ្តោតលើអ្នកសារព័ត៌មាន អ្នកជំនួញ និងអ្នកនយោបាយដោយប្រើសារបែបបំពាន រករឿង និងប្រើរូបភាពកាត់តផ្សេងៗ ដែលបង្កើតឡើងដើម្បីបន្ទុះបង្អាប់ និងប្រឆាំងនឹងការស៊ើបអង្កេត ជុំវិញរឿងរឹបអូសទ្រព្យសម្បត្តិរដ្ឋនេះ។[18] និពន្ធនាយកល្បីឈ្មោះម្នាក់ ឈ្មោះ Ferial Haffajee ជាគោលដៅនៅក្នុងយុទ្ធនាការនៃការបៀតបៀនតាមអ៊ីនធឺណិតក្នុងពេលនេះ ដែលគេឃើញរូបភាពរបស់នាងត្រូវបានកាត់ត ដើម្បីបង្កើតឱ្យមានការយល់ខុសមកលើនាង រួមមានការប្រើប្រាស់#presstitute[19] ថែមទៀត ។

- ករណីអ្នកសារព័ត៌មានឈ្មោះ Rana Ayyub បានទទួលទូរស័ព្ទពីអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិចំនួនប្រាំរូប ដើម្បីសុំឱ្យរដ្ឋាភិបាលឥណ្ឌាផ្តល់ការការពារ ក្រោយពីមានការចែកចាយយ៉ាងគំហុកនូវព័ត៌មានមិនពិតដោយប្រឆាំងតបទៅនឹងរបាយការណ៍រិះគន់របស់នាង។ អ្នកកាសែតឯករាជ្យរូបនេះ ជាអ្នករងគ្រោះពីព័ត៌មានមិនពិត អំពីរូបនាងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម រួមមានទាំងវីដេអូ «ក្លែងបន្លំកម្រិតខ្ពស់» បានបំភ្លៃថា នាងបានថតរឿងអាសអាភាស ការគំរាមរំលោភ និងសម្លាប់ថែមទៀតផង[20]។
- ករណីអ្នកសារព័ត៌មានហ្វាំងឡង់ឈ្មោះ Jessikka Aro ដែលបានលើកយកមកពិភាក្សាក្រោមប្រធានបទ «ការគំរាមកំហែងសុវត្ថិភាពតាមបច្ចេកវិទ្យា និងយុទ្ធសាស្ត្រការពារ» នៅក្នុងផ្នែកទី២នៃមេរៀននេះ។

មេរៀនផ្សេងទៀតនៅក្នុងសៀវភៅនេះ និយាយអំពីវិធីសាស្ត្រផ្ទៀងផ្ទាត់ដោយប្រើបច្ចេកទេស ប៉ុន្តែវាមានសារៈសំខាន់ក្នុងការជំរុញឱ្យសិស្ស អាចកំណត់រកចេតនាមូលបង្កាច់ពីសំណាក់ប្រតិបត្តិករ តាមអ៊ីនធឺណិតមួយចំនួនដែលបង្កើត ចែកចាយព័ត៌មានមិនពិត និងព័ត៌មានខុស និងផ្តោតលើអ្នកសារព័ត៌មាន ដែលជាផ្នែកមួយនៃគំរូរំលោភបំពាន។

---

18 Extensive dossier on the Gupta's 'fake news empire' available at https://www.timeslive.co.za/news/south-africa/2017-09-04-the-guptas-bell- pottinger-and-the-fake-news-propaganda-machine/. [accessed 30/03/2018].

19 Haffajee, F. (2017). Ferial Haffajee: The Gupta fake news factory and me. HuffPost South Africa. [online] Available at: https://www. huffingtonpost.co.za/2017/06/05/ferial-haffajee-the-gupta-fake-news-factory-and-me_a_22126282/ [accessed 06/04/2018].

20 UN experts call on India to protect journalist Rana Ayyub from online hate campaign http://www.ohchr.org/EN/NewsEvents/Pages/ DisplayNews.aspx?NewsID=23126&LangID=E; [accessed 17/08/2018 See also Ayyub, R. (2018). In India, journalists face slut-shaming and rape threats.  https://www.nytimes.com/2018/05/22/opinion/india-journalists-slut-shaming-rape.html [accessed 17/06/2018].

**សំណួរសំខាន់ៗដែលបន្ថែមទៅលើវិធីសាស្រ្តបច្ចេកទេសនៃការផ្ទៀងផ្ទាត់ព័ត៌មាន ៖**

១. តើវាអាចមានចេតនាទុច្ចរិត នៅពីក្រោយការចែករំលែកជាទូទៅ ឬការចែករំលែកដោយចំពោះនេះដែរឬទេ?

២. តើអ្នកដែលបង្ហោះមាតិកា ចំណេញប្រយោជន៍អ្វីពីការចែករំលែកនេះដែរឬទេ?

៣. តើអាចមានផលវិបាកអ្វីខ្លះចំពោះខ្ញុំ/ ភាពជឿជាក់បាននៃវិជ្ជាជីវៈ/ ស្ថាប័នសារព័ត៌មាន ឬនិយោជករបស់ខ្ញុំដែរឬទេ បើខ្ញុំចែករំលែកវា?

៤. តើខ្ញុំបានធ្វើការគ្រប់គ្រាន់ ក្នុងការបញ្ជាក់ភាពពិតនៃអត្តសញ្ញាណ/និន្នាការ/ភាពអាចជឿជាក់បាន/ហេតុផលរបស់បុគ្គលនេះដែរឬទេ (ឧ. តើពួកគេប៉ុនប៉ងសាបព្រួសព័ត៌មានមិនពិត ឬបានចំណេញពីការលក់មាតិកាដែលរកបានមកដោយខុសច្បាប់ ដោយគ្មានហេតុផលប្រយោជន៍សាធារណៈដែរឬទេ)?

៥. តើវាជាមនុស្ស ឬម៉ាស៊ីនស្វ័យប្រវត្តិ[21]?

៦. ប្រសិនបើអ្នកទទួល «ទិន្នន័យដែលគេចោល» ពីអ្នកបង្ហើបព័ត៌មានណាម្នាក់ (Whistleblower) តើអ្នកគួរតែផ្ទៀងផ្ទាត់មាតិកានោះដោយឯករាជ្យ នៅមុនពេលចុះផ្សាយទិន្នន័យនោះទាំងដុលដែរឬទេ? តើវាអាចទេដែលថា ទិន្នន័យនោះបង្កប់ព័ត៌មានមិនពិត ដែលគេធ្វើឡើងដើម្បីធ្វើឱ្យមានការភ័ន្តច្រឡំ ឬបង្ខូចកេរ្តិ៍ដោយចេតនា?

## ២. ការគំរាមកំហែងសុវត្ថិភាពឌីជីថល និងយុទ្ធសាស្រ្តការពារ

អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស អ្នកសរសេរអត្ថបទតាមអ៊ីនធឺណិត (bloggers) និងសកម្មជនប្រព័ន្ធផ្សព្វផ្សាយសង្គម កាន់តែងាយរងគ្រោះខ្លាំងឡើងៗ ដោយសារការវាយប្រហារតាមអ៊ីនធឺណិត ហើយទិន្នន័យ ឬប្រភពរបស់ពួកគេអាចនឹងត្រូវលួចយកដោយតួអង្គទុច្ចរិត ក្នុងនោះរាប់បញ្ចូលទាំងតាមរយៈការបន្លំយកព័ត៌មានសម្ងាត់ ការវាយប្រហារដោយកម្មវិធីកុំព្យូទ័រ និងការបន្លំអត្តសញ្ញាណ[22]។

21 For example, see https://botcheck.me

22 ពី Technopedia Spoofing គឺជាការអនុវត្តក្លែងបន្លំ ឬព្យាបាទដែលការទំនាក់ទំនងត្រូវបានបញ្ជូនចេញពីប្រភពដែលមិនស្គាល់មួយដែលក្លែងបន្លំជាប្រភព។ ការបោកប្រាស់តាមអ៊ីម៉ែលគឺជាទម្រង់ទូទៅបំផុតនៃការអនុវត្តនេះ។ អ៊ីម៉ែលបន្លំអាចមានការគំរាមកំហែងបន្ថែមដូចជា Trojans និងមេរោគផ្សេងទៀត។ កម្មវិធីទាំងនេះអាចបណ្តាលឱ្យខូចខាតកុំព្យូទ័រយ៉ាងធ្ងន់ធ្ងរដោយបង្កឱ្យមានសកម្មភាពមួយចំនួនចូលលុបឯកសារ និងធ្វើរឿងច្រើនទៀត។ សូមមើល៖ https://www.techopedia.com/definition/5398/spoofing [accessed 29/03/2018].

**ឧទាហរណ៍នៃការអនុវត្តបែបនេះ៖**

អ្នកសារព័ត៌មានស៊ើបអង្កេតដែលទទួលបានពានរង្វាន់ Jessika Aro ដែលធ្វើការឱ្យប្រព័ន្ធផ្សព្វផ្សាយសាធារណៈរបស់ប្រទេសហ្វាំងឡង់ ឈ្មោះថា YLE បានក្លាយជាគោលដៅនៃការបង្កើតយុទ្ធនាការ «បញ្ចើចបញ្ចើ» តាំងពីឆ្នាំ២០១៤ មក។ នាងធ្លាប់ទទួលរងការគំរាមកំហែងផ្នែកសុវត្ថិភាពបច្ចេកវិទ្យា ក្នុងនោះរាប់បញ្ចូលទាំងការបន្លំ និងការស្វែងរកព័ត៌មានដោយទុច្ចរិត[23]ដោយមានការបញ្ចើចបញ្ចើលើព័ត៌មានផ្ទាល់ខ្លួនរបស់នាង និងការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីរូបនាង ដែលនាំឱ្យកម្មវិធីសារ និងប្រអប់សាររបស់នាងមានសុទ្ធតែសារកំហឹង។

នាងនិយាយថា «ខ្ញុំបានទទួលទូរស័ព្ទ ហើយឮសំឡេងមនុស្សម្នាក់បាញ់កាំភ្លើង។ ក្រោយមកទៀត មានមនុស្សម្នាក់ផ្ញើសារមកខ្ញុំ អះអាងថា ជាឪពុកខ្ញុំដែលបានស្លាប់ទៅហើយ និងបានប្រាប់ខ្ញុំថា រូបគាត់កំពុង«តាមដានខ្ញុំ»[24]។ Aro បានសរសើរអ្នកបោះពុម្ពផ្សាយ ដែលការពារអ្នកសារព័ត៌មានពីការគំរាមកំហែង និងជំរុញឱ្យស៊ើបអង្កេតនិងបង្ហាញអំពីការឃោសនា។

ដូច្នេះ វាជាការសំខាន់ចំពោះតួអង្គសារព័ត៌មាន ដែលត្រូវប្រយ័ត្នប្រយែងចំពោះការគំរាមកំហែងដូចខាងក្រោមនេះ ៖

**ការគំរាមកំហែងសន្តិសុខឌីជីថលសំខាន់ៗទាំង១២៖**[25]

- ការឃ្លាំមើលតាមមុខសញ្ញាជាក់លាក់ និងការឃ្លាំមើលទូទៅ
- ការជ្រៀតចូល software និង hardware ដោយមុខសញ្ញាមិនបានដឹងខ្លួន
- ការវាយប្រហារដោយការបន្លំយកព័ត៌មានសម្ងាត់[26]

---

23 ពី Technopedia Doxing គឺជាដំណើរការនៃការរកមើល លួចស្ដាប់ និងផ្សព្វផ្សាយព័ត៌មានរបស់អ្នកដទៃដូចជាឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទ និងព័ត៌មានលំអិត កាតឥណទាន។ ការធ្វើអាជីវកម្មអាចត្រូវបានកំណត់គោលដៅឆ្ពោះទៅរកមនុស្សជាក់លាក់ ឬអង្គការ។ មានហេតុផលជាច្រើនសម្រាប់ការ doxing ប៉ុន្តែមួយក្នុងចំណោមការពេញនិយមបំផុតគឺការបង្ខិតបង្ខំ។ Doxing គឺជាពាក្យស្លោកមួយដែលបានមកពីពាក្យ“ .doc” ពីព្រោះឯកសារត្រូវបានយកមកវិញនិងចែកចាយជាញឹកញាប់។ ពួក Hacker បានបង្កើតវិធីផ្សេងៗគ្នាដើម្បីធ្វើ dox ប៉ុន្តែវិធីសាស្ត្រសាមញ្ញបំផុតមួយគឺតាមរយៈការទទួលបានអ៊ីម៉ែលរបស់ជនរងគ្រោះ បន្ទាប់មកបើកលេខសំងាត់ដើម្បីបើកគណនីរបស់ពួកគេ។ សូមមើល៖ https://www.techopedia.com/ definition/29025/doxing [accessed 29/03/2018].

24 Aro, J. 2016. The cyberspace war: propaganda and trolling as warfare tools. European View. Sage Journals, June 2016, Volume 15, Issue 1. http://journals.sagepub.com/doi/full/10.1007/s12290-016-0395-5 [accessed 20/07/2018].

25 Posetti, J. (2015). New Study: Combatting the rising threats to journalists' digital safety (WAN-IFRA). https://blog.wan-ifra.org/2015/03/27/new-study-combatting-the-rising-threats-to-journalists-digital-safety [accessed 30/03/2018].

26 King, G (2014) Spear phishing attacks underscore necessity of digital vigilance, CPJ.https://cpj.org/blog/2014/11/spear-phishing-attacks-underscore-necessity-of-dig.php [accessed 29/03/2018].

- ការវាយប្រហារពីកន្លែងមិនពិត
- ការវាយប្រហារដោយបុគ្គលទីបី (Man-in-the-middle)[27]
- ការវាយប្រហារ រំខានសេវាកម្ម និងការបញ្ជូនទិន្នន័យច្រើនព្រមគ្នា ដើម្បីបង្អាក់ដំណើរការគេហទំព័រ[28]
- ការផ្លាស់ប្តូររូបភាពគេហទំព័រ
- ការបង្ខូចគណនីអ្នកប្រើប្រាស់
- ការបំភ័យ បៀតបៀន និងបង្ហាញបណ្តាញអ៊ីនធឺណិតដោយបង្ខំ
- ព័ត៌មានមិនពិត និងយុទ្ធនាការលាបពណ៌
- ការរឹបអូសផលិតផលការងារសារព័ត៌មាន និង
- ការផ្ទុក និងការរុករកទិន្នន័យ។

សម្រាប់យុទ្ធសាស្ត្រការពារ សូមមើល៖ ការកសាងសុវត្ថិភាពបច្ចេកវិទ្យាសម្រាប់សារព័ត៌មាន[29]។

សម្រាប់ផលប៉ះពាល់ចំពោះប្រភពសម្ងាត់ និងអ្នកបង្ហើបព័ត៌មានដែលទាក់ទងជាមួយអ្នកសារព័ត៌មាន និងផលិតករដំណឹងដទៃទៀត សូមមើល៖ ការការពារប្រភពសារព័ត៌មាននៅក្នុងសម័យបច្ចេកវិទ្យា[30]។

**ការសម្គាល់ និងការគ្រប់គ្រងការបៀតបៀន និងអំពើហិង្សាតាមអ៊ីនធឺណិត**

«គេហៅខ្ញុំថា ស្រីខូច ស្រីស្បែកសចង្រៃ ស្រីជនជាតិជ្វីហ្វ ស្រីចាមដ៏ថោកទាបប៉ាប៉ាស៊ីតរបស់ប្រទេសក្រិក ជនអន្តោប្រវេសន៍ដ៏គួរឱ្យស្អប់ មនុស្សឆ្កួតឡប់ មនុស្សកុហកដ៏គួរឱ្យខ្ពើម មនុស្សដែលស្អប់គេដោយលម្អៀង។ ពួកគេដេញខ្ញុំឱ្យទៅផ្ទះ ឱ្យខ្ញុំសម្លាប់ខ្លួន បើមិនដូច្នោះទេពួកគេនឹងបាញ់សម្លាប់ខ្ញុំ កាត់អណ្តាត

27 និយមន័យរបស់Technopediaនៃ Man in the Middle Attach (MITM)៖ "គឺជាទម្រង់នៃការលួចស្តាប់ នៅពេលដែលទំនាក់ទំនងរវាងអ្នកប្រើប្រាស់ពីរនាក់ ត្រូវបានត្រួតពិនិត្យ និងកែប្រែដោយក្រុមដែលគ្មានការអនុញ្ញាត។ ជាទូទៅអ្នកវាយប្រហារលួចស្តាប់យ៉ាងសកម្ម ដោយរារាំងការផ្លាស់ប្តូរសារសំខាន់ជាសាធារណៈ ហើយបញ្ជូនសារឡើងវិញ ដោយបង្កើតសារជំនួស ដែលធ្វើឡើងដោយខ្លួនឯង។" https://www.techopedia.com/ definition/4018/man- in-the-middle-attack-mitm [accessed 29/03/2018].

28 See definitions at Technopedia. https://www.techopedia.com/definition/24841/denial-of-service-attack-dos b. https://www.techopedia.com/ definition/10261/distributed-denial-of-service-ddos [accessed 29/03/2018].

29 Henrichsen, J. et al. (2015). Building Digital Safety for Journalism (UNESCO) Paris. http://unesdoc.unesco.org/images/0023/002323/232358e.pdf [accessed 30/03/2018].

30 Posetti, J. (2017). Protecting Journalism Sources in the Digital Age (UNESCO). Paris. http://unesdoc.unesco.org/images/0024/002480/248054E.pdf [accessed 30/03/2018].

ខ្ញុំបោះចោល កាច់បំបាក់ម្រាមដៃខ្ញុំម្តងមួយៗ។ ពួកគេបន្តគំរាមរំលោភបូកលើរូបខ្ញុំ និងគំរាមទារុណកម្មផ្លូវភេទ។»[31] ទាំងនេះគឺជាពាក្យសម្តីចេញពីមាត់របស់អ្នកសារព័ត៌មានជនជាតិស៊ុយអែត ឈ្មោះ Alexandra Pascalidou ដែលផ្តល់សក្ខីកម្មកាលពីឆ្នាំ២០១៦ នៅចំពោះមុខការសាកសួររបស់គណៈកម្មការអឺរ៉ុប នៅទីក្រុងប្រ៊ុចសែល អំពីបទពិសោធន៍របស់នាងនៅលើអ៊ីនធឺណិត។

ការសាយភាយជាសកលនូវការរំលោភបំពានតាមអ៊ីនធឺណិតប្រភេទនេះ ដែលសំដៅទៅលើអ្នកសារព័ត៌មាន និងអ្នកអត្ថាធិប្បាយជាស្ត្រីបាននាំឱ្យអង្គការសហប្រជាជាតិ (រួមទាំងអង្គការយូណេស្កូ[32]) និងទីភ្នាក់ងារដទៃទៀតទទួលស្គាល់បញ្ហានេះ និងអំពាវនាវឱ្យមានការចាត់វិធានការ និងដំណោះស្រាយ ។

អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការអឺរ៉ុប (OSCE) បានឧបត្ថម្ភការស្រាវជ្រាវមួយ ដែលបង្ហាញអំពីផលប៉ះពាល់ជាអន្តរជាតិនៃការរំលោភបំពានតាមអ៊ីនធឺណិត ទៅលើអ្នកសារព័ត៌មានជាស្ត្រី ដែលត្រូវគេយកជាគោលដៅវាយប្រហារដោយ «បញ្ឆេះបញ្ឆៅដោយសម្ងំ»[33]។

ការស្រាវជ្រាវនោះ បានធ្វើឡើងតាមក្រោយការសិក្សារបស់ក្រុមគំនិតអង់គ្លេសមួយ ឈ្មោះថា Demos ដែលពិនិត្យទៅលើសារាប់ម៉ឺនរាប់សែន និងបានរកឃើញថា សារព័ត៌មានគឺជាប្រភេទតែមួយគត់ ដែលស្ត្រីទទួលការរំលោភបំពានច្រើនជាងបុរស «ដោយក្នុងនោះ អ្នកសារព័ត៌មានជាស្ត្រី និងពិធីការិនីដំណឹងទូរទស្សន៍ទទួលការរំលោភបំពានច្រើនជាងគេរហូតដល់ពងង[34] បើធៀបនឹងសមភាគីបុរសរបស់ពួកគេ»។ ពាក្យគន្លឹះសំខាន់សម្រាប់ជនល្មើសរំលោភបំពានតាមអ៊ីនធឺណិតគឺ «ស្រីថោកទាប» «រំលោភសេពសន្ថវៈ» និង «ស្រីខូច»។

លក្ខណៈសម្គាល់នៃការរំលោភបំពានតាមអ៊ីនធឺណិត ទៅលើតួអង្គសារព័ត៌មានជាស្ត្រីគឺការប្រើប្រាស់ស្នៀតព័ត៌មានមិនពិត ពាក្យកុហកត្រូវបានផ្សព្វផ្សាយអំពី

31 Posetti, J. (2016). Swedish journalist Alexandra Pascalidou Describes Online Threats of Sexual Torture and Graphic Abuse in The Sydney Morning Herald, 24/11/2016. http://www.smh.com.au/lifestyle/news-and-views/swedish-broadcaster-alexandra-pascalidou-describes-online- threats-of-sexual-torture-and-graphic-abuse-20161124-gswuwv.html [accessed 30/03/2018].

32 Posetti, J. (2017). Fighting Back Against Prolific Online Harassment: Maria Ressa in L. Kilman (Ed) op cit See also: Resolution 39 of UNESCO's 39th General Conference which notes "the specific threats faced by women journalists including sexual harassment and violence, both online and offline." http://unesdoc.unesco.org/images/0026/002608/260889e.pdf [accessed 29/03/2018].

33 OSCE (2016). Countering Online Abuse of Female Journalists. http://www.osce.org/fom/220411?download=true [accessed 30/03/2018].

34 Bartlett, J. et al. (2014) Misogyny on Twitter, Demos. https://www.demos.co.uk/files/MISOGYNY_ON_TWITTER.pdf [accessed 30/03/2018].

ចរិតលក្ខណៈរបស់ពួកគេ ឬការងាររបស់ពួកគេជាវិធីដើម្បីធ្វើឱ្យខូចខាតដល់ភាពអាចជឿជាក់ ធ្វើឱ្យពួកគេអាម៉ាសមុខ ព្យាយាមធ្វើឱ្យខូចការអាធិប្បាយ និងការរាយការណ៍របស់ពួកគេ។

ការបន្ថែមការគំរាមកំហែងប្រើអំពើហិង្សា ក្នុងនោះរាប់ទាំងការរំលោភ និងសម្លាប់ និងផលប៉ះពាល់បន្ថែម (ការវាយប្រហារដោយធម្មជាតិ ដោយមានការរៀបចំ និងដោយមនុស្សយន្តទៅលើមនុស្សម្នាក់នៅលើអ៊ីនធឺណិត) ធ្វើឱ្យមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរឡើងថែមទៀត។

ធម្មជាតិនៃការវាយប្រហារទាំងនេះ ដែលជារឿយៗទទួលបាននៅលើឧបករណ៍ប្រើប្រាស់ផ្ទាល់ខ្លួន មុនគេរៀងរាល់ព្រឹក និងក្រោយគេនៅពេលយប់ ធ្វើឱ្យផលប៉ះពាល់កាន់តែស្រួចស្រាលថែមទៀត។ Pascalidou និយាយថា «មានថ្ងៃដែលខ្ញុំក្រោកពីគេងឡើងត្រូវជួបនឹងអំពើហិង្សាដោយពាក្យសម្តី និងចូលដេកទៅវិញជាមួយនឹងពាក្យជេរទាក់ទងនឹងការរើសអើងភេទ និងប្រកាន់ពូជសាសន៍នៅពេញត្រចៀករបស់ខ្ញុំ។ វាប្រៀបដូចជាសង្គ្រាមរាំរ៉ៃអ៊ីចឹងដែរ»។

នៅហ្វីលីពីន Maria Ressa[35] នាយិកាប្រតិបត្តិ និងជានិពន្ធនាយិកា Rappler គឺជាករណីសិក្សាមួយ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការបៀតបៀនតាមអ៊ីនធឺណិតនៅក្នុងបរិបទជាយុទ្ធនាការផ្សាយព័ត៌មានមិនពិត ដ៏ធំដែលទាក់ទងនឹងរដ្ឋ។

អ្នកនាងគឺជាអតីតអ្នកឆ្លងឆ្លើយដំណឹងសង្គ្រាមរបស់ទូរទស្សន៍ CNN ប៉ុន្តែអ្នកនាងនិយាយថា បទពិសោធន៍ដែលនាងជួបមិនបានជួយនាងឱ្យត្រៀមលក្ខណៈ ក្នុងការប្រយុទ្ធប្រឆាំងនឹងយុទ្ធនាការដ៏ធំ និងការបំផ្លាញនៃការបៀតបៀនយេនឌ័រតាមអ៊ីនធឺណិត ដែលចាប់ផ្តើមតាំងពីឆ្នាំ២០១៦មកម្ល៉េះ។ អ្នកនាងនិយាយថា «គេហៅខ្ញុំថា មនុស្សអាក្រក់ ជាសត្វឆ្កែ សត្វពស់ និងត្រូវគេគំរាមរំលោភ និងសម្លាប់»។ Ressa រាប់លែងចាំនូវចំនួនដង ដែលនាងបានទទួលការគំរាមកំហែងសម្លាប់។ លើសពីនេះ នាងបានក្លាយជាកម្មវត្ថុនៃយុទ្ធនាការ ដែលមានប្រធានបទដូចជាការចាប់ខ្លួន Maria Ressa និងនាំនាងទៅព្រឹទ្ធសភា ដែលគេបង្កើតឡើងដើម្បីញុះញង់មហាជននៅលើអ៊ីនធឺណិត ឱ្យបើកការវាយប្រហារ និងបង្ខូចកេរ្តិ៍ឈ្មោះទាំង Ressa និង Rappler និងធ្វើឱ្យសេចក្តីរាយការណ៍របស់ពួកគេបាត់បង់តម្លៃ និងសុពលភាព ។ Ressa និយាយថា «វាចាប់ផ្តើមដោយការនៅស្ងប់ស្ងៀម។

35 Maria Ressa is chair of the jury of the UNESCO-Guillermo Cano World Press Freedom Prize https://en.unesco.org/prizes/guillermo-cano/jury.

អ្នកណាមួយដែលរិះគន់ ឬសួរសំណួរទាក់ទងនឹងការសម្លាប់មនុស្សក្រៅច្បាប់ត្រូវបានគេវាយប្រហារយ៉ាងសាហាវ។ ស្ត្រីជាអ្នករងគ្រោះខ្លាំងជាងគេបំផុត។ យើងបានឃើញថា ប្រព័ន្ធនេះបង្កើតឡើងដើម្បីបំបិទសំឡេងប្រឆាំង ធ្វើឱ្យអ្នកសារព័ត៌មាននៅស្ងប់ស្ងៀមមិនហ៊ាននិយាយ។ ពួកយើងមិនសង្ឃឹមថា ទទួលបានសំណួរពិបាកៗ និងការរិះគន់នោះទេ។»[36]

យុទ្ធសាស្ត្រប្រយុទ្ធតបតវិញរបស់ Maria Ressa រួមមាន ៖

- ទទួលស្គាល់នូវភាពធ្ងន់ធ្ងរនៃបញ្ហា
- ទទួលស្គាល់ផលប៉ះពាល់ផ្លូវចិត្ត និងសម្រួលឱ្យមានការគាំទ្រផ្នែកចិត្តវិទ្យាដល់បុគ្គលិកដែលរងគ្រោះ
- ប្រើប្រាស់សារព័ត៌មានស៊ើបអង្កេត ជាអាវុធនៅក្នុងការវាយបកវិញ[37]
- សុំជំនួយពីក្រុមគោលដៅដែលមានភក្តីភាព ឱ្យជួយទប់ទល់ និងបដិសេធការវាយប្រហារ
- ពង្រឹងសន្តិសុខទាំងនៅលើ និងក្រៅអ៊ីនធឺណេត ក្នុងការឆ្លើយតបទៅនឹងការបៀតបៀន
- អំពាវនាវជាសាធារណៈឱ្យកម្មវិធីប្រព័ន្ធផ្សព្វផ្សាយសង្គមនានា (ដូចជា Facebook និង Twitter) ឱ្យធ្វើការបន្ថែមទៀតដើម្បីកាត់បន្ថយ និងគ្រប់គ្រងការបៀតបៀនតាមអ៊ីនធឺណិតឱ្យបានគ្រប់គ្រាន់។
- ខណៈដែលដោះស្រាយបញ្ហានៃការគំរាមកំហែង ដែលកើនឡើងពីការបៀតបៀនតាមអ៊ីនធឺណិត អ្វីដែលសំខាន់ដែរនោះគឺគេត្រូវទទួលស្គាល់នូវការបៀតបៀនក្រៅពីអ៊ីនធឺណិត ទៅលើស្ត្រីជាអ្នកសារព័ត៌មាន នៅក្នុងបរិបទនៃយុទ្ធនាការផ្សាយព័ត៌មានមិនពិត។ ឧទាហរណ៍ អ្នកសារព័ត៌មានស៊ើបអង្កេតអូស្ត្រាលី Wendy Carlisle ត្រូវបានបំពាន ឆាឆៅ រុញច្រាន

36 Posetti, J. (2017). Fighting Back Against Prolific Online Harassment: Maria Ressa in Kilman, L. (Ed) An Attack on One is an Attack on All (UNESCO). http://unesdoc.unesco.org/images/0025/002593/259399e.pdf [accessed 30/03/2018].

37 នេះក៏ជាយុទ្ធសាស្ត្រមួយដាក់ពង្រាយដោយ Ferial Haffajee នៅក្នុងករណីសិក្សា “Gupta Leaks” ដែលត្រូវបានយោងមុននេះ។ នាងបានប្រើបច្ចេកទេសស៊ើបអង្កេតនិងសន្តិសុខឌីជីថល“ អ្នកស៊ើបអង្កេត” ដើម្បីលុបចោលនូវវីដេអូខ្លះដែលត្រូវបានគេកំណត់គោលដៅរបស់នាងនៅក្នុងការប៉ុនប៉ង ដើម្បីបំបិទការរាយការណ៍របស់នាងអំពីរឿងអាស្រូវនេះ។ សូមមើល៖ https://www.news24.com/SouthAfrica/News/fake-news-peddlers-can-be-traced-hawks-20170123 [accessed 16/06/2018].

នៅក្នុងអំឡុងពេលបាតុកម្មរបស់ពួកអ្នកបដិសេធបញ្ហាការប្រែប្រួលអាកាសធាតុ នៅអូស្ត្រាលី កាលពីឆ្នាំ២០១១ ខណៈកំពុងផលិតបទយកការណ៍វែងឱ្យវិទ្យុ ABC។ ការបំពាននេះបាននាំឱ្យនាងចាកចេញពីព្រឹត្តិការណ៍នោះ ដើម្បីធានាសុវត្ថិភាពរបស់នាង[38]។

## គោលបំណងនៃមេរៀន

មេរៀននេះ នឹងជួយឱ្យសិស្សយល់ដឹងអំពីហានិភ័យនៃការរំលោភបំពាន នៅលើអ៊ីនធឺណិតនៅក្នុងបរិបទនៃ «ព័ត៌មានច្របូកច្របល់» ជួយសិស្សឱ្យស្គាល់ការគំរាមកំហែង និងផ្តល់ការអភិវឌ្ឍជំនាញ និងឧបករណ៍ដើម្បីជួយប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានតាមអ៊ីនធឺណិត។ គោលបំណងទាំងនោះរួមមាន៖

- បង្កើនការយល់ដឹងរបស់សិស្សអំពីបញ្ហា ដែលតួអង្គអាក្រក់យកអ្នកសារព័ត៌មាន និងប្រភព និងអ្នកប្រាស្រ័យទាក់ទងតាមអ៊ីនធឺណិតដទៃទៀត ជាគោលដៅវាយប្រហារ នៅក្នុងយុទ្ធនាការផ្សាយព័ត៌មានមិនពិត និងព័ត៌មានខុស។
- ផ្តល់លទ្ធភាពឱ្យសិស្សអាចស្គាល់កាន់តែច្បាស់អំពី «ការបញ្ឆោត» «ការបញ្ឆេចបញ្ឆើ» ការគំរាមកំហែងសុវត្ថិភាពបច្ចេកវិទ្យា និងការរំលោភបំពានតាមអ៊ីនធឺណិត។
- បំពាក់បំប៉នសិស្សឱ្យត្រៀមខ្លួនកាន់តែប្រសើរឡើង ដើម្បីប្រយុទ្ធប្រឆាំងនឹង «ការបង្ខូចឈ្មោះ» និង «ការបញ្ឆេចបញ្ឆើ» ការគំរាមកំហែងសុវត្ថិភាពបច្ចេកវិទ្យា និងការរំលោភបំពានតាមអ៊ីនធឺណិត លើបញ្ហាយេនឌ័រ។

## លទ្ធផលសិក្សា

នៅចុងបញ្ចប់នៃមេរៀននេះ សិស្សនឹង៖

១. យល់ដឹងកាន់តែស៊ីជម្រៅអំពីផលប៉ះពាល់នៃការរំលោភបំពានតាមអ៊ីនធឺណិតមកលើតួអង្គសារព័ត៌មាន វិជ្ជាជីវៈសារព័ត៌មាន ការចែករំលែកព័ត៌មាន និងសេរីភាពបញ្ចេញមតិ។

---

38 Carlisle, W. (2011). The Lord Monckton Roadshow, Background Briefing, ABC Radio National. http://www.abc.net.au/radionational/programs/ backgroundbriefing/the-lord-monckton-roadshow/2923400 [accessed 30/03/2018].

២. កាន់តែដឹងច្រើនអំពីបញ្ហា ដែលតួអង្គទុច្ចរិតយកអ្នកសារព័ត៌មាន និងអ្នកទាក់ទងតាមអ៊ីនធឺណិតដទៃទៀត នៅក្នុងយុទ្ធនាការផ្សាយព័ត៌មានមិនពិត។

៣. យល់អំពីការគំរាមកំហែងសុវត្ថិភាពជាពិសេស ដែលប្រឈមមុខចំពោះស្ត្រីដែលកំពុងបំពេញការងារសារព័ត៌មាន នៅលើអ៊ីនធឺណិត។

៤. អាចស្គាល់តួអង្គទុច្ចរិតនៅលើអ៊ីនធឺណិតកាន់តែច្រើន រួមទាំង «ការបង្ខូចឈ្មោះ» «ការបញ្ឆេះបញ្ឆោ» ការគំរាមកំហែងសុវត្ថិភាពបច្ចេកវិទ្យា និងការរំលោភបំពានតាមអ៊ីនធឺណិត។

៥. មានការត្រៀមលក្ខណៈប្រសើរជាងមុន ក្នុងការប្រយុទ្ធប្រឆាំងនឹង «ការបង្ខូចឈ្មោះ» «ការបញ្ឆេះបញ្ឆោ» ការគំរាមកំហែងសុវត្ថិភាពបច្ចេកវិទ្យា និងការរំលោភបំពានតាមអ៊ីនធឺណិតលើបញ្ហាយេនឌ័រ។

## ទម្រង់នៃមេរៀន

មេរៀននេះរៀបចំឡើងសម្រាប់ការបង្រៀនផ្ទាល់រវាងគ្រូ និងសិស្សក៏បាន ឬបង្រៀនតាមអ៊ីនធឺណិតក៏បាន។ មេរៀននេះចែកជាពីរផ្នែក៖ ទ្រឹស្តី និងអនុវត្តន៍។

### ផ្ទាប់ផែនការទៅនឹងលទ្ធផលសិក្សា

ក. ទ្រឹស្តី

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| ជាបទបង្ហាញបែបអន្តរកម្ម និងមានសំណួរចម្លើយ (៩០នាទី) ដែលអាចបង្រៀនបែបប្រពៃណីក្នុងថ្នាក់ក៏បាន ឬតាមអ៊ីនធឺណិតដែលលើកទឹកចិត្តដល់ការចូលរួមបាន។ ខ្លឹមសារបទបង្ហាញអាចដកស្រង់ពីទ្រឹស្តី និងឧទាហរណ៍ដែលផ្តល់ឱ្យខាងលើ។ ប៉ុន្តែ អ្នករៀបចំវគ្គបណ្តុះបណ្តាលត្រូវបានលើកទឹកចិត្តឱ្យដាក់បញ្ចូលករណីសិក្សាដែលស្របនឹងវប្បធម៌/បរិបទក្នុងស្រុក នៅក្នុងមេរៀននេះផងដែរ។ | ៦០-៩០នាទី | ១, ២, ៣, ៤, ៥ |

## ខ. អនុវត្តន៍

| ផែនការមេរៀន | ចំនួនម៉ោង | លទ្ធផលសិក្សា |
|---|---|---|
| សិក្ខាសាលា/ការបង្រៀន (៩០នាទី) ដែលអាចសម្របសម្រួលនៅក្នុងបរិស្ថានថ្នាក់រៀនបែបប្រពៃណី ឬតាមកម្មវិធីរៀនតាមអ៊ីនធឺណិត ដូចជា Moodle, ក្រុម Facebook ឬសេវាផ្សេងទៀតដែលផ្តល់លទ្ធភាពដល់ការចូលរួមពីចម្ងាយតាមអ៊ីនធឺណិត។<br>សិក្ខាសាលា/ការបង្រៀន អាចយកលំនាំតាមទម្រង់ដូចខាងក្រោម៖<br>• បែងចែកការបង្រៀនជាក្រុម ដែលមួយក្រុមៗមានសិស្សពី៣ ទៅ ៥នាក់ ។<br>• ក្រុមការងារនីមួយៗត្រូវផ្តល់ឧទាហរណ៍មួយនៃមាតិកាទុច្ចរិត (ស្រាវជ្រាវរកមើលនៅលើអត្ថបទសរសេរលើអ៊ីនធឺណិត និងប្រព័ន្ធផ្សព្វផ្សាយសង្គមសម្រាប់មាតិកា ដែលបង្កើតឡើងដើម្បីតម្រង់គោលដៅទៅលើ Maria Ressa, Jessikka Aro និង Alexandra Pascalidou ជាឧទាហរណ៍ ដែលករណីរបស់ពួកគេត្រូវបានពិភាក្សានៅក្នុងមេរៀននេះ) ដែលជាប់ទាក់ទងទៅនឹងយុទ្ធនាការព័ត៌មានមិនពិត /ខុស/ការបញ្ឆេចបញ្ឆើ/ការបញ្ឆោត/ការរំលោភបំពានតាមអ៊ីនធឺណិត។<br>• ក្រុមការងារនីមួយៗត្រូវតែ៖ សហការគ្នាវាយតម្លៃទៅលើមាតិកា (ស្រាវជ្រាវរកបុគ្គល/ក្រុមដែលនៅពីក្រោយមាតិកានោះ) កំណត់ហានិភ័យ និងការគំរាមកំហែង (សំដៅលើការស្រាវជ្រាវដែលពាក់ព័ន្ធស្តីពីផលប៉ះពាល់ដែលមាននៅក្នុងបញ្ជីឯកសារអំណាន) លើកផែនការសកម្មភាពដើម្បីឆ្លើយតបនិងមាតិកានោះ (នេះអាចរួមបញ្ចូលការឆ្លើយតបជាលក្ខណ: យុទ្ធសាស្ត្រ ការរាយការណ៍អំពីអ្នកប្រើប្រាស់ទៅកាន់កម្មវិធី ឬប៉ូលិស ចាត់តាំងឱ្យមានការធ្វើរឿងអំពីបញ្ហានេះ) ចូរសរសេរសេចក្តីសង្ខេប២៥០ពាក្យ អំពីផែនការសកម្មភាពរបស់ខ្លួន (ដោយប្រើប្រាស់ឯកសារ Google ឬឧបករណ៍កែសម្រួលអត្ថបទស្រដៀងគ្នានេះផ្សេងទៀត) និងដាក់ជូនទៅឱ្យគ្រូពិនិត្យមើល ។ | ៩០ -១២០នាទី | ១, ២, ៣, ៤, ៥ |

## រចនាសម្ព័ន្ធជំនួស

សម្រាប់ការពិនិត្យទៅលើបញ្ហានេះឱ្យកាន់តែស៊ីជម្រៅ មេរៀននេះអាចពង្រីកបន្ថែមដើម្បីបង្រៀនជា៣មេរៀនដាច់ដោយឡែកពីគ្នា (ដោយមេរៀននីមួយៗបង្រៀនចែកចេញជាពីរផ្នែកដូចដែលបានរៀបរាប់ខាងលើ) ៖

- ➢ ស្គាល់ និងឆ្លើយតបទៅនឹង«ការបញ្ឆេះបញ្ឆៅ» និង «ការបញ្ឆោត»
- ➢ គំរូនៃការគំរាមកំហែងសុវត្ថិភាពតាមឌីជីថល និង យុទ្ធសាស្ត្រការពារ
- ➢ ស្គាល់ និងគ្រប់គ្រងការបៀតបៀន និងអំពើហិង្សាតាមអ៊ីនធឺណិតដែលទាក់ទងនឹងយេនឌ័រ

## លំហាត់ស្រាវជ្រាវបន្ថែម

ចូរសរសេរអត្ថបទពណ៌នា១២០០ពាក្យ ឬផលិតជាសេចក្ដីរាយការណ៍សំឡេង៥នាទី សេចក្ដីរាយការណ៍វីដេអូ៣នាទី ឬក្រាហ្វិកអន្តរកម្មលម្អិតផ្អែកលើកិច្ចសម្ភាសន៍ជាមួយអ្នកសារព័ត៌មានមួយ ឬច្រើននាក់អំពីបទពិសោធន៍នៃការដែលត្រូវគេរំលោភបំពាននៅលើអ៊ីនធឺណិត (ឧ. ត្រូវគេយកជាគោលដៅវាយប្រហារ ដោយព័ត៌មានមិនពិត និង/ឬជួបប្រទះការគំរាមកំហែងផ្នែកសន្តិសុខបច្ចេកវិទ្យា ជាផ្នែកនៃយុទ្ធនាការផ្សាយព័ត៌មានមិនពិត និង/ឬត្រូវគេបៀតបៀន ឬរងនូវអំពើហិង្សាតាមអ៊ីនធឺណិត)។ សិស្សគួរដកស្រង់ការស្រាវជ្រាវដ៏ល្បីណាមួយ និងឱ្យតម្លៃជាឯកសារយោង ជាផ្នែកនៃអត្ថបទពណ៌នារបស់ខ្លួន និងពន្យល់អំពីផលប៉ះពាល់នៃបាតុភាពទាំងនេះ ទៅលើសារព័ត៌មាន/សេរីភាពបញ្ចេញមតិ និងសិទ្ធិដឹងឮរបស់សាធារណជន។

## អំណានបន្ថែម

Aro, J. 2016. The cyberspace war: propaganda and trolling as warfare tools. European View. Sage Journals, June 2016, Volume15, Issue1. http://journals.sagepub.com/doi/full/10.1007/s12290-016-0395-5 [accessed20/07/2018].

Haffajee, F. (2017). The Gupta Fake News Factory and Me in The Huffington Post. http://www.huffingtonpost.co.za/2017/06/05/

ferial-haffajee-the-gupta-fake-news-factory-and- me_a_22126282/ [accessed29/03/2018].

OSCE (2016). Countering Online Abuse of Female Journalists. http://www.osce.org/fom/220411?download=true [accessed 29/03/2018].

Posetti, J. (2017). Fighting Back Against Prolific Online Harassment: Maria Ressa inL. Kilman (Ed) An Attack on One is an Attack on All (UNESCO 2017). http://unesdoc.unesco.org/images/0025/002593/259399e.pdf [accessed 29/03/2018].

Posetti, J. (2016). Swedish journalist Alexandra Pascalidou Describes Online Threats of Sexual Torture and Graphic Abuse in The Sydney Morning Herald, 24/11/2016. http://

www.smh.com.au/lifestyle/news-and-views/swedish-broadcaster-alexandra-pascalidou- describes-online-threats-of-sexual-torture-and-graphic-abuse-20161124-gswuwv.html [accessed 29/03/2018].

Reporters Sans Frontieres (2018) Online Harassment of Journalists: Attack of the trolls Reporters Without Borders: https://rsf.org/sites/default/files/rsf_report_on_online_ harassment.pdf [accessed 20/8/18].

Riley M, Etter, L and Pradhan, B (2018) A Global Guide To State-Sponsored Trolling, Bloomberg: https://www.bloomberg.com/features/2018-government-sponsored-cyber- militia-cookbook/ [accessed 21/07/2018].

Stray, J. (2014). Security for journalists, Part Two: Threat Modelling. https://source.opennews.org/articles/security-journalists-part-two-threat-modeling/ [accessed 02/03/2018].

## ធនធានលើបណ្ដាញអ៊ីនធឺណិត

វីដេអូ: How to Tackle Trolls and Manage Online Harassment – a panel discussion at the International Journalism Festival, Perugia, Italy (April 2017) with Julie Posetti (Fairfax Media), Hannah Storm (International News Safety Institute), Alexandra Pascalidou (Swedish journalist), Mary Hamilton (The Guardian), Blathnaid Healy (CNNi). Available at: http://media.journalismfestival.com/programme/2017/managing-gendered-online-harrassment

# សន្ទានុក្រម

| | |
|---|---|
| Algorithms | ក្បួនដោះស្រាយតាមកុំព្យូទ័រ |
| Audience | ក្រុមគោលដៅ (អ្នកអាន អ្នកស្តាប់ ទស្សនិកជន) |
| Artificial Intelligence (AI) | បញ្ញាសិប្បនិម្មិត |
| Astroturfing | ការបញ្ឆោត |
| Brexit | ដំណើរការដែលប្រទេសអង់គ្លេសចាកចេញពីសហាគមន៍អឺរ៉ុប |
| Bots | កម្មវិធីកុំព្យូទ័រដំណើរការស្វ័យប្រវត្តិ |
| Clickbait | មធ្យោបាយបញ្ឆោតឱ្យចូលអាន ទស្សនា ស្តាប់ |
| Cloning | ការបង្កើតជីវិតសត្វឬរុក្ខជាតិថ្មីមួយ ដោយប្រើប្រាស់កោសិការបស់ «សត្វឬរុក្ខជាតិមួយទៀត ហើយមានលក្ខណៈដូចបេះបិទទៅនឹងសត្វឬរុក្ខជាតិដំបូង |
| Content | ខ្លឹមសារ/ មាតិកា |
| Deepfake | ក្លែងបន្លំកម្រិតខ្ពស់ (សំដៅទៅលើការកែប្រែខ្លឹមសារវីដេអូឱ្យយល់ខុសពីខ្លឹមសារដើម) ឬ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីថតចម្លង និងកែចលនាទឹកមុខ និងសំឡេងរបស់មនុស្សម្នាក់ទៀតនៅក្នុងវីដេអូ |
| Denial of Service (DoS) attacks | ការវាយប្រហារ រំខានសេវាកម្ម |
| Disinformation | ព័ត៌មានមិនពិត |
| Distributed Denial of Service (DDOS) | ការបញ្ជូនទិន្នន័យច្រើនព្រមគ្នាដើម្បបង្អាក់ដំណើរការកុំព្យូទ័រ |
| Doxing | ការស្វែងរកព័ត៌មានដោយទុច្ចរិត |
| Echo Chambers | ទស្សនៈចង្អៀតចង្អល់ |
| Eyewitness Media | ប្រព័ន្ធផ្សព្វផ្សាយសាក្សី |
| Fact-Checking | ការផ្ទៀងផ្ទាត់ការពិត |
| Fake News | ដំណឹងក្លែងក្លាយ |

| | |
|---|---|
| Filter Bubbles | ច្រោះដំណឹងដែលចង់បាន |
| Gatekeeper | ឆ្មាំទ្វារ/ អ្នកបញ្ចេញអត្ថបទព័ត៌មាន |
| Journalist | អ្នកសារព័ត៌មាន/ អ្នកកាសែត |
| Journalism | សារព័ត៌មាន/ វិជ្ជាជីវៈសារព័ត៌មាន |
| Information | ព័ត៌មាន |
| Information Disorder | ព័ត៌មានច្របូកច្របល់ |
| International Fact-Checking Network (IFCN) | បណ្ដាញអ្នកផ្ទៀងផ្ទាត់ការពិតអន្តរជាតិ |
| International Programme for the Development of Communication (IPDC) | កម្មវិធីអន្តរជាតិរបស់អង្គការយូណេស្កូសម្រាប់អភិវឌ្ឍន៍វិស័យសារគមនាគមន៍ |
| Mal-information | ព័ត៌មានបង្កព្យសនកម្ម (បុគ្គល អង្គភាព ប្រទេសជាតិ) |
| Man-in-the-Middle Attack (MitM) | ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតដោយជនទីបី |
| Media and Information Literacy (MIL) | អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន |
| Media Convergence | ការបញ្ចូលគ្នានៃប្រព័ន្ធផ្សព្វផ្សាយច្រើនទម្រង់ |
| Misinformation | ព័ត៌មានខុស |
| Narrative unpacking | ការវិភាគទម្រង់នៃការពិតដើម្បីរកឱ្យឃើញការពិតនិងមិនពិត ដែលត្រូវបានផ្សព្វផ្សាយក្នុងគោលបំណងជាក់លាក់ណាមួយ |
| News | ដំណឹង |
| Newsroom | ការិយាល័យដំណឹង |
| New Media | ប្រព័ន្ធផ្សព្វផ្សាយបែបថ្មី |
| News Insitutions | ស្ថាប័នដំណឹង |
| News Media | ប្រព័ន្ធផ្សព្វផ្សាយដំណឹង |
| Objectivity | សត្យានុម័ត |
| Online/Internet | អ៊ីនធឺណិត |

| | |
|---|---|
| Organization for Security and Co-operation In Europe ( OSCE) | អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការក្នុងតំបន់អឺរ៉ុប |
| Phishing attacks | ការវាយប្រហារដោយការបន្លំយកព័ត៌មានសម្ងាត់ |
| Problem-based Learning (PBL) | ការរៀនដោយផ្អែកលើមូលដ្ឋានដោះស្រាយបញ្ហា |
| Psychological Operations (PSYOP) | សកម្មភាពផ្សព្វផ្សាយព័ត៌មានតែមួយផ្នែកណាមួយក្នុងគោលបំណងទាក់ទាញការចាប់អារម្មណ៍ ឬការគាំទ្រ |
| Satire or Parody | ដៀលត្មិះ ឬ ចំអកឡកឡឺយ |
| Social Media | ប្រព័ន្ធផ្សព្វផ្សាយសង្គម |
| Spoofing | ការបន្លំអត្តសញ្ញាណ |
| Stereotypes | ការមើលឃើញនរណាម្នាក់ ឬអ្វីមួយដោយក្នុងសភាពទូទៅ |
| Thumbnails | ខ្នាតតូច |
| Troll | ចំអកឡកឡឺយ ឬបញ្ឆេចបញ្ឆើ |
| User Generated Content (UGC) | មាតិកាបង្កើតឡើងដោយអ្នកប្រើប្រាស់ |
| Verification | ការផ្ទៀងផ្ទាត់ |
| Virality | ការរាលដាល ឬការសាយភាយ |
| Whistleblower | អ្នកបង្ហើបព័ត៌មាន |

## អ្នកចូលរួមចំណែក

**Magda Abu-Fadil** គឺជានាយកអង្គការ Media Unlimited ដែលមានមូលដ្ឋាននៅប្រទេសលីបង់

**Fergus Bell** គឺជាអ្នកជំនាញផ្នែកការប្រមូលដំណឹងបច្ចេកវិទ្យា និងការផ្ទៀងផ្ទាត់មាតិកាបង្កើតឡើងដោយអ្នកប្រើប្រាស់។ គាត់ក៏ជាស្ថាបនិក Dig Deeper Media ផងដែរ។

**Hossein Derakhshan** គឺជាអ្នកនិពន្ធជនជាតិកាណាដា-អ៊ីរ៉ង់ ជាអ្នកស្រាវជ្រាវ និងនិស្សិតអាហារូបករណ៍នៅមជ្ឈមណ្ឌល Shorenstein នៃសាលា Harvard's Kennedy។

**Cherilyn Ireton** ជាអ្នកសារព័ត៌មានអាហ្វ្រិកខាងត្បូង ដែលដឹកនាំវេទិកាការីនិពន្ធពិភពលោក នៅក្នុងសមាគមកាសែត និងចាងហ្វាងដំណឹងពិភពលោក (WAN-IFRA) ។

**Alexios Mantzarlis** ដឹកនាំបណ្តាញត្រួតពិនិត្យមើលការពិតអន្តរជាតិ នៅវិទ្យាស្ថាន Poynter។

**Alice Matthews** ជាអ្នកសារព័ត៌មានកិច្ចការបរទេស នៅស្ថានីយផ្សព្វផ្សាយអូស្ត្រាលី (ABC) ប្រចាំទីក្រុងស៊ីដនី ។

**Julie Posetti** សហការីស្រាវជ្រាវជាន់ខ្ពស់ នៅវិទ្យាស្ថាន Reuters សម្រាប់ការសិក្សាផ្នែកសារព័ត៌មាននៅសកលវិទ្យាល័យ Oxford ដែលនៅទីនោះនាងដឹកនាំគម្រោងច្នៃប្រឌិតសារព័ត៌មាន ។

**Tom Trewinnard** ជាប្រធានកម្មវិធីកញ្ចប់ឧបករណ៍ផ្ទៀងផ្ទាត់ប្រភពរបស់ Meedan។

**Claire Wardle** គឺជានាយិកាប្រតិបត្តិនៃ First Draft និងជាសហការីស្រាវជ្រាវនៅមជ្ឈមណ្ឌល Shorenstein សម្រាប់ប្រព័ន្ធផ្សព្វផ្សាយនយោបាយ និងគោលនយោបាយសាធារណៈនៃសាលា Harvard's Kennedy។

## សិទ្ធិលើរូបថត

ក្រុមមុខ៖ UNESCO/ Oscar Castellanos

មេរៀនទី១៖ Abhijith S Nair on Unsplash

មេរៀនទី២: Christoph Scholz on Flickr

មេរៀនទី៣៖ Samuel Zeller on Unsplash

មេរៀនទី៤៖ Aaron Burden on Unsplash

មេរៀនទី៥៖ The Climate Reality Project on Unsplash

មេរៀនទី៦៖ Olloweb Solutions on Unsplash

មេរៀនទី៧៖ rawpixel on Unsplash

ក្របខាងក្រោយ៖ rawpixel on Unsplash

## រចនាទំព័រ

Mr. Clinton  www.mrclinton.be

ក្រុមអ្នកត្រួតពិនិត្យមាតិកានៃសៀវភៅ៖ សាស្ត្រាចារ្យ Ylva Rodny-Gumede នៃនាយកដ្ឋានសារព័ត៌មាន ខ្សែភាពយន្ត និងទូរទស្សន៍ នៃសកលវិទ្យាល័យ Johannesburg អាហ្វ្រិកខាងត្បូង; សាស្ត្រាចារ្យ Basyouni Hamada នៃនាយកដ្ឋានសារគមនាគមន៍ដ៏ធំ (Mass Communication) នៃមហាវិទ្យាល័យសិល្បៈ និងវិទ្យាសាស្ត្រ សកលវិទ្យាល័យ Qatar; សាស្ត្រាចារ្យ Jayson Harsin នៃនាយកដ្ឋានសារគមនាគមន៍សកល, សកលវិទ្យាល័យ American នៃទីក្រុងប៉ារីស (American University of Paris)។



សៀវភៅមេរៀននេះ មានបំណងផ្ដល់នូវកម្មវិធីសិក្សាគំរូដែលមានសារៈសំខាន់ជាអន្តរជាតិ បើកចំហសម្រាប់ការកែសម្រួល ឬការយកទៅប្រើទាំងស្រុងដើម្បីឆ្លើយតបទៅនឹងបញ្ហាសកល ដែលកំពុងកើតឡើងនៃព័ត៌មានមិនពិតដែលសង្គមទូទៅ និងជាពិសេសសារព័ត៌មានកំពុងប្រឈម។

ដោយដើរតួនាទីជាកម្មវិធីសិក្សាគំរូ សៀវភៅនេះរៀបចំឡើងដើម្បីផ្ដល់ឱ្យអ្នកអប់រំ និងអ្នកបណ្ដុះបណ្ដាលផ្នែកវិជ្ជាជីវៈសារព័ត៌មាននូវក្របខ័ណ្ឌ និងមេរៀនដើម្បីជួយសិស្ស និងអ្នកប្រកបអាជីពសារព័ត៌មាន ក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹង «ដំណឹងក្លែងក្លាយ»។ យើងក៏សង្ឃឹមថា សៀវភៅនេះនឹងក្លាយជាមគ្គុទេសក៍ដ៏មានប្រយោជន៍សម្រាប់អ្នកសារព័ត៌មានអាជីព។

មាតិកានៅក្នុងសៀវភៅនេះ ប្រមូលផ្ដុំធាតុចូលដែលផ្ដល់ដោយអ្នកអប់រំវិជ្ជាជីវៈសារព័ត៌មានអន្តរជាតិឈានមុខគេ អ្នកស្រាវជ្រាវ និងអ្នកគិតគូរដ៏ចំណានៗ ដែលជួយធ្វើបច្ចុប្បន្នភាពវិធីសាស្ត្រ និងការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន ដើម្បីដោះស្រាយភាពប្រឈម ដែលបង្កដោយការផ្សាយព័ត៌មានមិនពិត។ មេរៀនទាំងអស់ផ្អែកតាមបរិបទទ្រឹស្ដី និងមានប្រយោជន៍ខ្លាំង នៅក្នុងករណីនៃការផ្ទៀងផ្ទាត់តាមអ៊ីនធឺណិត។ មេរៀនទាំងនេះអាចជួយជុសខាត់ឱ្យកាន់តែភ្លឺថែមទៀតនូវមេរៀនដែលមានស្រាប់ ឬបង្កើតការផ្ដល់ជូនថ្មី ដោយប្រើប្រាស់បញ្ចូលគ្នាជាវគ្គមួយ ឬប្រើដាច់ដោយឡែកៗពីគ្នា។

វាជាផ្នែកនៃ «គំនិតផ្ដួចផ្ដើមសកលលោកដើម្បីឧត្ដមភាពនៃការអប់រំវិជ្ជាជីវៈសារព័ត៌មាន» ដែលជាការផ្ដោតរបស់កម្មវិធី អន្តរជាតិរបស់អង្គការយូណេស្កូសម្រាប់អភិវឌ្ឍន៍វិស័យសារគមនាគមន៍ (IPDC)។ គំនិតផ្ដួចផ្ដើមនេះ ប្រឹងប្រែងផ្សារភ្ជាប់ និងការបង្រៀន ការអនុវត្ត និងការស្រាវជ្រាវវិជ្ជាជីវៈសារព័ត៌មានចេញពីទស្សនទានពិភពលោក ក្នុងនោះរាប់ទាំងការចែករំលែកការអនុវត្តគំរូ នៅថ្នាក់អន្តរជាតិ។

UNESCO
United Nations
Educational, Scientific and
Cultural Organization

IPDC THE INTERNATIONAL PROGRAMME
FOR THE DEVELOPMENT OF COMMUNICATION

UNESCO - Communication and Information Sector 7,
place de Fontenoy, F-75352 Paris 07 SP, France
For further information, contact ipdc.secretariat@unesco.org

FOJO:MEDIEINSTITUTET
Linnéuniversitetet

9 789230 000905